# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

## សារត្ថប្បកាសិនី

ភាគ ៣១

## និទានវគ្គ តតិយភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

និទានវគ្គ តតិយភាគ

រួមមាន ១ សំយុត្ត ស្មើនឹង ៧១ អដ្ឋកថា

# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

## សារត្ថប្បកាសិនី

ភាគ ៣១

## និទានវគ្គ តតិយភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

និទានវគ្គ តតិយភាគ

រួមមាន ១ សំយុត្ត ស្មើនឹង ៧១ អដ្ឋកថា

# អភិសមយសំយុត្ត

## រួមមាន ១០ វគ្គ

| | | |
|---|---|---|
| ១-ពុទ្ធវគ្គ | មាន ៥ | អដ្ឋកថា |
| ២-អាហារវគ្គ | មាន ១០ | អដ្ឋកថា |
| ៣-ទសពលវគ្គ | មាន ៩ | អដ្ឋកថា |
| ៤-កឡារខត្តិយវគ្គ | មាន ១០ | អដ្ឋកថា |
| ៥-គហបតិវគ្គ | មាន ១០ | អដ្ឋកថា |
| ៦-ទុក្ខវគ្គ | មាន ១០ | អដ្ឋកថា |
| ៧-មហាវគ្គ | មាន ១០ | អដ្ឋកថា |
| ៨-សមណព្រាហ្មណវគ្គ | មិនមានអដ្ឋកថាកែ | |
| ៩-អន្តរបេយ្យាល | មាន ១ | អដ្ឋកថា |
| ១០-អភិសមយវគ្គ | មាន ៦ | អដ្ឋកថា |

រួមក្នុងអភិសមយសំយុត្ត មាន ១០ វគ្គ ព្រះអដ្ឋកថាចានកែសេចក្តី

ដែលលំចាកចំនួន ៧១ សូត្រ

# ស្រៈនិស្ស័យ

# *Signes et accents:*



# ស្រះពេញតួ
# Voyelles:

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រ៉ូម Romain | a | ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

# Consonnes:

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| [illegible] Romain | k | kh | g | gh | ṅ |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| [illegible]<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ဉ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ဉ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី*

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសការធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

> ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
> ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
> មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
> បណ្ឌិតគប្បីដឹងបាន ។

ព្រោះសការៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ **ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុញ្ញាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាម អាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយ ច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមក ហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះ ខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយ ខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណា ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ភាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម៉្យាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្រ្តទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុថៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្តាប់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់ លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន

ឧបាសក ទុំ ទូន

ឧបាសក ជឹម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក សោម រតនៈ

ឧបាសក ម៉ៅ ផុន

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៉ែន រមណី

ឧបាសក នាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត ទិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ

ឧបាសក ជា ស៊ីបាន

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ប៊ុត សេដាដួង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នួវ ប៊ូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ឆុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក ហាយ ចំរើន |
| ឧបាសក ហុក សឹងហួត | ឧបាសក អ៊ឹម រ៉ៃយ៉ា |
| ឧបាសក ឈួន សំណាង | ឧបាសក ឃឿម សារ៉ែន |

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.000 ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | | ទំព័រ |
|---|---|---|
| **អភិសមយសំយុត្ត** | | |
| **ពុទ្ធវគ្គ** | | |
| អដ្ឋកថា ទេសនាសូត្រ | ទី ១ | ១ |
| អដ្ឋកថា វិភង្គសូត្រ | ទី ២ | ២៧ |
| អដ្ឋកថា បដិបទាសូត្រ | ទី ៣ | ៤៨ |
| អដ្ឋកថា វិបស្សីសូត្រ | ទី ៤ | ៥១ |
| អដ្ឋកថា សិខីសូត្រជាដើម | ទី ៥ | ៥៧ |
| **អាហារវគ្គ** | | |
| អដ្ឋកថា អាហារសូត្រ | ទី ១ | ៥៩ |
| អដ្ឋកថា ផគ្គុនសូត្រ | ទី ២ | ៧៨ |
| អដ្ឋកថា បឋមសមណព្រាហ្មណសូត្រ | ទី ៣ | ៨៤ |
| អដ្ឋកថា ទុតិយសមណព្រាហ្មណសូត្រ | ទី ៤ | ៨៦ |
| អដ្ឋកថា កច្ចានគោត្រសូត្រ | ទី ៥ | ៨៧ |
| អដ្ឋកថា ធម្មកថិកសូត្រ | ទី ៦ | ៩១ |
| អដ្ឋកថា អាចេលកស្សបសូត្រ | ទី ៧ | ៩៣ |
| អដ្ឋកថា តិម្ពរុក្ខសូត្រ | ទី ៨ | ១០១ |
| អដ្ឋកថា ពាលបណ្ឌិតសូត្រ | ទី ៩ | ១០៤ |

| | | |
|---|---|---|
| អដ្ឋកថា បច្ចយសូត្រ | ទី ១០ | ១០៩ |

## ទសពលវគ្គ

| | | |
|---|---|---|
| អដ្ឋកថា ទុតិយទសពលសូត្រ | ទី ២ | ១១៨ |
| អដ្ឋកថា ឧបនិសសូត្រ | ទី ៣ | ១៤១ |
| អដ្ឋកថា អញ្ញតិត្ថិយសូត្រ | ទី ៤ | ១៥១ |
| អដ្ឋកថា ភូមិជសូត្រ | ទី ៥ | ១៥៥ |
| អដ្ឋកថា ឧបវាណសូត្រ | ទី ៦ | ១៥៩ |
| អដ្ឋកថា បច្ចយសូត្រ | ទី ៧ | ១៦០ |
| អដ្ឋកថា ភិក្ខុសូត្រ | ទី ៨ | ១៦២ |
| អដ្ឋកថា បឋមសមណព្រាហ្មណសូត្រ | ទី ៩ | ១៦៣ |
| អដ្ឋកថា ទុតិយសមណព្រាហ្មណសូត្រ | ទី ១០ | ១៦៤ |

## កឡារខត្តិយវគ្គ

| | | |
|---|---|---|
| អដ្ឋកថា ភូតមិទសូត្រ | ទី ១ | ១៨៥ |
| អដ្ឋកថា កឡារខត្តិយសូត្រ | ទី ២ | ១៧០ |
| អដ្ឋកថា បឋមញាណវត្ថុសូត្រ | ទី ៣ | ១៨៥ |
| អដ្ឋកថា ទុតិយញាណវត្ថុសូត្រ | ទី ៤ | ១៨៨ |
| អដ្ឋកថា បឋមអវិជ្ជាបច្ចយសូត្រ | ទី ៥ | ១៩០ |
| អដ្ឋកថា ទុតិយអវិជ្ជាបច្ចយសូត្រ | ទី ៦ | ១៩៤ |
| អដ្ឋកថា នតុម្ហសូត្រ | ទី ៧ | ១៩៥ |

អដ្ឋកថា បឋមចេតនាសូត្រ ទី ៨ ១៩៧
អដ្ឋកថា ទុតិយចេតនាសូត្រ ទី ៩ ២០២
អដ្ឋកថា តតិយចេតនាសូត្រ ទី ១០ ២០៣

## គហបតិវគ្គ

អដ្ឋកថា បឋមបញ្ចភយវេរសូត្រ ទី ១ ២០៥
អដ្ឋកថា ទុតិយបញ្ចភយវេរសូត្រ ទី ២ ២១០
អដ្ឋកថា ទុក្ខនិរោធសូត្រ ទី ៣ ២១១
អដ្ឋកថា លោកនិរោធសូត្រ ទី ៤ ២១៣
អដ្ឋកថា ញាតិកសូត្រ ទី ៥ ២១៤
អដ្ឋកថា អញ្ញត្រសូត្រ ទី ៦ ២១៦
អដ្ឋកថា ជាណុស្សោណិសូត្រ ទី ៧ ២១៧
អដ្ឋកថា លោកយតិកសូត្រ ទី ៨ ២១៨
អដ្ឋកថា បឋមអរិយសាវកសូត្រ ទី ៩ ២២០
អដ្ឋកថា ទុតិយអរិយសាវកសូត្រ ទី ១០ ២២១

## ទុក្ខវគ្គ

អដ្ឋកថា បរិវីមំសនសូត្រ ទី ១ ២២២
អដ្ឋកថា ឧបាទានសូត្រ ទី ២ ២៣៥
អដ្ឋកថា បឋមសំយោជនសូត្រ ទី ៣ ២៤០
អដ្ឋកថា ទុតិយសំយោជនសូត្រ ទី ៤ ២៤១

| | | |
|---|---|---|
| អដ្ឋកថា បឋមមហារុក្ខសូត្រ | ទី ៥ | ២៤២ |
| អដ្ឋកថា ទុតិយមហារុក្ខសូត្រ | ទី ៦ | ២៤៥ |
| អដ្ឋកថា តរុណារុក្ខសូត្រ | ទី ៧ | ២៤៦ |
| អដ្ឋកថា នាមរូបសូត្រ | ទី ៨ | ២៤៧ |
| អដ្ឋកថា វិញ្ញាណសូត្រ | ទី ៩ | ២៤៨ |
| អដ្ឋកថា និទានសូត្រ | ទី ១០ | ២៤៩ |


## មហាវគ្គ


| | | |
|---|---|---|
| អដ្ឋកថា អស្សុតវតាសូត្រ | ទី ១ | ២៧៩ |
| អដ្ឋកថា អស្សុតវតាសូត្រ | ទី ២ | ២៨៩ |
| អដ្ឋកថា បុត្តមំសសូត្រ | ទី ៣ | ២៩១ |
| អដ្ឋកថា អត្ថិរាគសូត្រ | ទី ៤ | ៣២០ |
| អដ្ឋកថា នគរសូត្រ | ទី ៥ | ៣២៣ |
| អដ្ឋកថា សម្មសសូត្រ | ទី ៦ | ៣៣២ |
| អដ្ឋកថា នឡកលាបិយសូត្រ | ទី ៧ | ៣៣៩ |
| អដ្ឋកថា កោសម្ពីសូត្រ | ទី ៨ | ៣៤១ |
| អដ្ឋកថា ឧបយសូត្រ | ទី ៩ | ៣៤៤ |
| អដ្ឋកថា សុសិមសូត្រ | ទី ១០ | ៣៤៥ |


## សមណព្រាហ្មណវគ្គ


| | | |
|---|---|---|
| អដ្ឋកថា សមណព្រាហ្មណវគ្គ | | ៣៥៤ |

**អន្តរបេយ្យាលវគ្គ**

អដ្ឋកថា សត្តុសូត្រជាដើម ៣៥៥

**អភិសមយវគ្គ**

អដ្ឋកថា នខសិខាសូត្រ ទី ១ ៣៥៧

អដ្ឋកថា បោក្ខរណីសូត្រ ទី ២ ៣៥៩

អដ្ឋកថា បឋមសម្ភេជឧទកសូត្រទី ៣ ៣៦០

អដ្ឋកថា ទុតិយសម្ភេជឧទកសូត្រទី ៤ ៣៦១

អដ្ឋកថា បឋវីសូត្រ ទី ៥ ៣៦២

អដ្ឋកថា ទុតិយបឋវីសូត្រ ទី ៦ ជាដើម ៣៦៣

# អដ្ឋកថា ព្រះសុត្តន្តបិដក

# ឈ្មោះ សារត្ថប្បកាសិនី

## អដ្ឋកថា សំយុត្តនិកាយ

### អភិសមយសំយុត្ត និទានវគ្គ

### លេខ ៣១

### ពុទ្ធវគ្គទី ១

### អ ដ្ឋ ក ថា

### បឋមបដិច្ចសមុប្បាទសូត្រ[១]ទី ១

*សូមនមស្ការចំពោះព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

[១] *បដិច្ចសមុប្បាទសូត្រ*[២] *ព្រះសូត្រដំបូងក្នុង និទានវគ្គ* មានពាក្យ*ផ្ដើមថា ឯវំមេ សុតំ ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។*

*ក្នុងបដិច្ចសមុប្បាទសូត្រនោះ ពណ៌នាតាមលំដាប់បទថា តត្រ ខោ*

---

១-២ *បាលីជាទេសនាសូត្រ.*

**ភគវា ភិក្ខូ អាមន្តេសិ** ដូចតទៅនេះ ៖

បណ្ដាបទទាំងនោះ បទថា **តត្រ** ជាពាក្យសម្ដែងដល់ទេសៈ ស្ថានទី និងកាលវេលា ។

ពិតណាស់ ពាក្យថា **តត្រ** នោះ រមែងសម្ដែង (អត្ថន័យ) ថា ក្នុងសម័យដែលព្រះមានព្រះភាគប្រថាប់នៅ និងក្នុងវត្តជេតពនដែលព្រះមានព្រះភាគប្រថាប់នៅ ឬសម្ដែងដល់ទេសៈ និងកាលដែលសមគួរដល់ពាក្យដែលព្រះអង្គគួរត្រាស់ ។ ព្រោះថា ព្រះមានព្រះភាគមិនត្រាស់ធម្មៈក្នុងទេសៈ និងកាលៈដែលមិនគួរ ។ ក៏ក្នុងរឿងនេះ មានពាក្យថា **អកាលោ ខោ តាវ ពាហិយ** ជាប្រការសាធកៈ ។ ស័ព្ទថា **ខោ** ជានិបាត ប្រើក្នុងន័យថា ត្រឹមតែជាធ្វើបទឲ្យពេញ មានន័យថា ហាមសេចក្ដីដទៃ ឬក្នុងន័យសំដៅដល់កាលខាងដើម ។ ពាក្យថា **ភគវា** ជាពាក្យសម្ដែងថា ព្រះមានព្រះភាគទ្រង់ជាគ្រូរបស់មនុស្សលោក ។ ដោយពាក្យថា **ភិក្ខូ** ជាពាក្យសំដៅដល់បុគ្គលដែលគួរដល់ការស្ដាប់ព្រះតម្រាស់ ន័យមួយទៀត ក្នុងពាក្យថា **ភិក្ខូ** នេះ គប្បីជ្រាបន័យពាក្យ ដោយន័យជាដើមថា ដែលឈ្មោះថា ភិក្ខុ ព្រោះអត្ថថា **សូម** (និង) ដែលឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា ចូលដល់ការ

ភិក្ខាចារ ។ បទថា **អាមន្តេសិ** នេះ មានអធិប្បាយដូច្នេះ តែក្នុងទីដទៃ មានន័យថា ឲ្យដឹង ដូចដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតជាស់តឿនអ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រកាសដល់អ្នកទាំងឡាយ ។ មានន័យថា ហៅក៏មាន ដូចដែលត្រាស់ទុកថា មកចុះភិក្ខុ អ្នកចូរហៅព្រះសារីបុត្រមក តាមពាក្យរបស់តថាគត ។ បទថា **ភិក្ខវោ** ជាបទសម្តែងអាការ គឺ ការត្រាស់ហៅ ។ ក៏ពាក្យថា **ភិក្ខវោ** នោះ ព្រះមាន-ព្រះភាគត្រាស់ដល់ពួកភិក្ខុ ព្រោះសម្រេចដោយការប្រកបដោយគុណ មានភាពជាអ្នកសូមជាប្រក្រតីក្តី អ្នកប្រកបដោយគុណមានការសូមជាធម្មតាក្តី អ្នកប្រកបដោយគុណ គឺ ធ្វើសេចក្តីល្អព្រោះការសូមក្តី ឈ្មោះថា **ភិក្ខុ** ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទ្រង់ប្រកាសការប្រព្រឹត្តរបស់ភិក្ខុទាំងនោះ ដែលបុគ្គលអាក្រក់ និងបុគ្គលល្អសេពហើយ ដោយពាក្យដែលសម្រេចដោយការប្រកបដោយគុណ មានការសូមជាប្រក្រតីជាដើម ទើបទ្រង់ធ្វើការគ្របសង្កត់ភាវៈដែលពួកភិក្ខុក្រអឺតក្រទមជាដើម ។

មួយទៀត ដោយពាក្យថា **ភិក្ខវោ** នេះ ដែលមានការទតព្រះនេត្រចុះ ដែលសម្តែងដល់ព្រះហឫទយដ៏ត្រជាក់ ផ្សាយទៅដោយព្រះករុណា ព្រះ

មានព្រះភាគទ្រង់ធ្វើភិក្ខុទាំងនោះឲ្យបែរមកកាន់ផ្លូវព្រះអង្គ ទ្រង់ឲ្យភិក្ខុទាំងនោះកើតសេចក្តីប្រាថ្នានឹងស្តាប់ ដោយព្រះតម្រាស់ដែលសម្តែងភាពជាអ្នកប្រាថ្នានឹងត្រាស់នោះឯង ។ ទ្រង់ប្រកបភិក្ខុទាំងនោះទុកក្នុងមនសិការដោយល្អ ដោយអត្ថ គឺ ការដាស់ឲ្យភ្ញាក់ទុំះឯង ។ ព្រោះការធ្វើពាក្យទូន្មានឲ្យដល់ព្រម ត្រូវប្រកបដោយមនសិការឲ្យល្អ ។

ប្រសិនបើមានពាក្យសួរថា កាលមានពួកទេព និងមនុស្សដទៃៗ ហើយហេតុដូចម្តេច ព្រះមានព្រះភាគទើបត្រាស់ហៅតែភិក្ខុប៉ុណ្ណោះ ។

ឆ្លើយថា ព្រោះភិក្ខុទាំងនោះជាប្រធាន ជាបុគ្គលប្រសើរ នៅជិត និងមានចិត្តតាំងមាំហើយក្នុងគ្រប់កាល ។ ពិតហើយ ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគ ជាសាធារណៈដល់បរិស័ទគ្រប់ជំពូក ។ ភិក្ខុទាំងឡាយឈ្មោះថា ជាប្រធានបរិស័ទ ព្រោះកើតឡើងមុន ឈ្មោះថា ជាបុគ្គលប្រសើរ ព្រោះប្រព្រឹត្តបណ្តោយតាមព្រះចរិយាវត្តព្រះសាស្តា ផ្តើមតាំងពីភាពជាអ្នកមិនមានផ្ទះ និងព្រោះទទួលយកពាក្យទូន្មាន (របស់ព្រះសាស្តា) ទាំងអស់ ឈ្មោះថា ជាអ្នកនៅជិត ព្រោះអង្គុយជិតព្រះសាស្តា (និង) ឈ្មោះថា មានចិត្តតាំងមាំហើយក្នុងគ្រប់កាល ព្រោះត្រាច់ទៅក្នុងសម្នាក់

ព្រះសាស្ដា ។ ម្យ៉ាងទៀត ភិក្ខុទាំងនោះជាភាជនៈសម្រាប់ទទួលព្រះធម្ម-ទេសនា ព្រោះជាអ្នកបដិបត្តិតាមពាក្យទូន្មាន (របស់ព្រះសាស្ដា) និងព្រោះជាបុគ្គលពិសេស ។ សូម្បីព្រះធម៌ទេសនានេះ ទ្រង់សំដៅដល់ភិក្ខុពួកខ្លះប៉ុណ្ណោះ ។ ព្រោះដូច្នោះ ទើបត្រាស់ហៅយ៉ាងនេះ សួរថា ព្រះមានព្រះ-ភាគ កាលទ្រង់សម្ដែងធម៌ ត្រាស់ហៅភិក្ខុមុន រមែងមិនសម្ដែងធម៌ឡើយ ព្រោះអ្វី ។ ឆ្លើយថា ដើម្បីឲ្យ (ពួកភិក្ខុ) កើតសតិ (ព្រោះ) ភិក្ខុទាំងឡាយកាលគិតរឿងដទៃ នឹងអង្គុយរវល់តែមានចិត្តរាយមាយខ្លះ រវល់តែពិចារណាធម៌ខ្លះ រវល់មានចិត្តក្នុងកម្មដ្ឋានខ្លះ ។ កាលព្រះមានព្រះភាគមិនត្រាស់ហៅពួកភិក្ខុ ទ្រង់សម្ដែងធម៌ទៅ ពួកភិក្ខុទាំងនោះមិនអាចកំណត់បានថា ព្រះធម៌ទេសនានេះ មានអ្វីជាខាងដើម មានអ្វីជាបច្ច័យ ទ្រង់សម្ដែងព្រោះអត្ថុប្បត្តិយ៉ាងណា នឹងគប្បីទទួលយកបានមិនល្អ ឬទទួលយកមិនបានឡើយ ព្រោះហេតុនោះ ដើម្បីនឹងឲ្យភិក្ខុទាំងនោះកើតសតិ ព្រះមានព្រះភាគទើបត្រាស់ហៅជាមុន ហើយទើបសម្ដែងធម៌ជាខាងក្រោយ ។

ពាក្យថា ភទន្តេ នោះ ជាពាក្យសម្ដែងសេចក្ដីគោរព ។ ម្យ៉ាងទៀត ពាក្យនោះ ជាការឲ្យឆ្លើយតបដល់ព្រះសាស្ដា ។ ប្រការមួយទៀត ក្នុងពាក្យ

នេះ ព្រះមានព្រះភាគកាលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា រមែងត្រាស់ហៅភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះកាលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឈ្មោះថា ឆ្លើយតបនឹងព្រះមានព្រះភាគ ។ ពិតដូច្នោះ ព្រះមាន-ព្រះភាគទើបត្រាស់ថា ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយរមែងក្រាបទូលថា ព្រះករុណា ព្រះអង្គ ។ ពាក្យថា **ភិក្ខវោ** គឺ ព្រះមានព្រះភាគ ទ្រង់ប្រោសឲ្យពួកភិក្ខុឆ្លើយតប ។

ពាក្យថា **ភទន្តេ** គឺ ពួកភិក្ខុឆ្លើយតប ។

បទថា **តេ ភិក្ខូ** បានដល់ ពួកភិក្ខុដែលព្រះមានព្រះភាគត្រាស់ហៅ ។

បទថា **ភគវតោ បច្ចស្សោសុំ** សេចក្តីថា ទទួលការត្រាស់ហៅរបស់ព្រះមានព្រះភាគ អធិប្បាយថា បែរមុខស្តាប់ បានដល់ ទទួល គឺទទួលបដិបត្តិ ។

ពាក្យថា **ភគវា ឯតទវោច** សេចក្តីថា ព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រទាំងអស់នេះ ដែលគួរត្រាស់ក្នុងកាលឥឡូវនេះ ។

ការពិចារណាខ្លឹមសារនៃពាក្យផ្តើម ដែលប្រដាប់ដោយ**កាលៈ ទេសៈ ទេសកៈ** (អ្នកសម្តែង) **បរិស័ទ** និង **អបទេស** (ការអាង) របស់ព្រះសូត្រ

នេះ ដែលសម្បូរណ៍ដោយអត្ថ និងព្យញ្ជនៈ បំភ្លឺដល់ព្រះសូត្រនេះ ជ្រាលជ្រៅដោយទេសនាញាណរបស់ព្រះសម្ពុទ្ធ ដែលព្រះអានន្ទកាសិតទុក ដើម្បីកំណត់បានងាយស្រួលចប់បរិបូរណ៍ហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ឱកាសនៃការពណ៌នាព្រះសូត្រ ដែលព្រះមានព្រះភាគទ្រង់តាំងទុកដោយន័យថា **បដិច្ចសមុប្បាទំ វោ** ជាដើម មកដល់ដោយលំដាប់ ។ ក៏ព្រោះការពណ៌នាព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់បានពិចារណាហេតុតាំងព្រះសូត្រមុនហើយ ទើបត្រាស់ប្រាកដច្បាស់ ព្រោះដូច្នោះ ខ្ញុំនឹងពិចារណាហេតុតាំងព្រះសូត្រមុន ។

ពិតហើយ ហេតុតាំងព្រះសូត្រមាន ៤ យ៉ាង គឺ អជ្ឈាស្រ័យរបស់ព្រះអង្គ ១ អជ្ឈាស្រ័យរបស់អ្នកដទៃ ១ ប្រព្រឹត្តទៅដោយអំណាចពាក្យសួរ ១ កើតរឿងឡើង ១ ។

បណ្ដាហេតុតាំងព្រះសូត្រ ៤ យ៉ាងនោះ ព្រះមានព្រះភាគដែលជនដទៃមិនបានអារាធនាឡើយ ត្រាស់ព្រះសូត្រពួកណា ព្រោះអជ្ឈាស្រ័យរបស់ព្រះអង្គតែម្យ៉ាងប៉ុណ្ណោះ គឺ វសលសូត្រ ចន្ទោបមសូត្រ វីណោ-បមសូត្រ សម្មប្បធានសូត្រ ឥទ្ធិបាទសូត្រ ឥន្ទ្រិយសូត្រ ពលសូត្រ ពោ-

ជ្ឈន្តសូត្រ មគ្គសូត្រនិង មង្គលសូត្រជាដើម ព្រះសូត្រទាំងនោះ ឈ្មោះថា មានអជ្ឈាស្រ័យរបស់ព្រះអង្គឯង ជាហេតុតាំងព្រះសូត្រ ។ ព្រះមានព្រះភាគទ្រង់ពិចារណាអជ្ឈាស្រ័យ សេចក្តីអត់ធន់ សេចក្តីពេញចិត្ត សេចក្តីដឹងអភិនិហារ និងការត្រាស់ដឹងរបស់បុគ្គលដទៃ យ៉ាងនេះថា ធម៌ទាំងឡាយដែលបន្ទំដល់វិមុត្តិរបស់ព្រះរាហុលចាស់ក្លាហើយ តថាគតគប្បីណែនាំរាហុលក្នុងធម៌ជាទីអស់អាសវៈឲ្យក្រៃលែងៗ ឡើង ដូច្នេះហើយ ត្រាស់ព្រះសូត្រពួកណាទុកដោយអជ្ឈាស្រ័យរបស់បុគ្គលដទៃ គឺ ចូឡរាហុលោវាទសូត្រ មហារាហុលោវាទសូត្រ ធម្មចក្កប្បវត្តនសូត្រ អនត្តលក្ខណសូត្រ អាសីវិសូបមសូត្រ (និង) ធាតុវិភង្គសូត្រជាដើម ព្រះសូត្រទាំងនោះ ឈ្មោះថា មានអជ្ឈាស្រ័យរបស់បុគ្គលដទៃជាហេតុតាំងព្រះសូត្រ ។

មួយទៀត ជនទាំងឡាយមានជាដើមថា បរិស័ទ ៤ វណ្ណៈ ៤ នាគ គ្រុឌ គន្ធព្វ អសុរ យក្ខ ស្តេចចតុមហារាជ ទេវតាជាន់តាវត្តិង្ស ជាដើម (និង) ស្តេចមហាព្រហ្ម ចូលទៅគាល់ព្រះមានព្រះភាគហើយ ទូលសួរបញ្ហាដោយន័យជាដើមថា បពិត្រព្រះអង្គ ធម៌ទាំងនេះ ព្រះអង្គត្រាស់ហៅថា ពោជ្ឈង្គៈ ពោជ្ឈង្គ ឬព្រះអង្គ ធម៌ទាំងនេះ ព្រះអង្គត្រាស់ហៅថា នីវរណៈ

នីវារណៈ ឬព្រះអង្គ ធម៌ទាំងនេះ ព្រះអង្គត្រាស់ហៅថា បញ្ចុបាទានខន្ធ ឬព្រះអង្គ ក្នុងលោកនេះ អ្វីជាទ្រព្យជាគ្រឿងរីករាយចិត្តដ៏ប្រសើរទីបំផុតរបស់បុរស ព្រះមានព្រះភាគដែលជនមានបរិស័ទ ៤ ជាដើមនោះទូលសួរហើយយ៉ាងនេះ បានត្រាស់ព្រះសូត្រពួកណា មានពោជ្ឈង្គសំយុត្ត ជាដើម ឬសូម្បីសូត្រដទៃណា មានទេវតាសំយុត្ត សក្កបញ្ហសូត្រ ចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សាមញ្ញផលសូត្រ អឡវកសូត្រ សូចិលោមសូត្រ និងខរលោមសូត្រជាដើម ព្រះសូត្រទាំងនោះឈ្មោះថា មានហេតុតាំងព្រះសូត្រប្រព្រឹត្តទៅដោយអំណាចនៃពាក្យទូលសួរ ។

ព្រះមានព្រះភាគទ្រង់អាស្រ័យហេតុកើតឡើង ហើយត្រាស់ព្រះសូត្រពួកណា គឺ ធម្មទាយាទសូត្រ មំសូបមសូត្រ ទារុខន្ធូបមសូត្រ អគ្គិខន្ធូ-បមសូត្រ ផេណបិណ្ឌូបមសូត្រ (និង) បារិឆត្តកូបមសូត្រជាដើម ព្រះសូត្រទាំងនោះឈ្មោះថា ហេតុតាំងព្រះសូត្រ គឺ កើតរឿងឡើង ។

បណ្តាហេតុតាំង (ព្រះសូត្រ) ៤ យ៉ាងទាំងនេះ ដូចជា បដិច្ចសមុ-ប្បាទសូត្រនេះ ឈ្មោះថា មានហេតុតាំង (ព្រះសូត្រ) គឺ អជ្ឈាស្រ័យអ្នកដទៃ ។ ពិតហើយ ព្រះមានព្រះភាគទ្រង់តាំងព្រះសូត្រនេះទុក ដោយអំណាច

អធ្យាស្រ័យបុគ្គលដទៃ សួរថា ទ្រង់តាំងទុកដោយអំណាចអធ្យាស្រ័យបុគ្គលប្រភេទណា ។ ឆ្លើយថា ប្រភេទឧគ្ឃដិតញ្ញូ ។

ពិតណាស់ បុគ្គលមាន ៤ ពួក គឺ ឧគ្ឃដិតញ្ញូ វិបចិតញ្ញូ នេយ្យៈ (និង) បទបរមៈ ។ បណ្តាបុគ្គល ៤ ទាំងនោះ បុគ្គលដែលបានត្រាស់ដឹងធម៌ព្រមជាមួយវេលាដែលលោកលើកមាតិកាធម៌ឡើងសម្តែង នេះហៅថា **ឧគ្ឃដិតញ្ញូ** ។ បុគ្គលដែលត្រាស់ដឹងធម៌ក្នុងកាលលោកអធិប្បាយសេចក្តីរបស់ធម៌ដែលលោកពោលទុកដោយសង្ខេបឲ្យពិស្តារ នេះហៅថា **វិបចិតញ្ញូ** ។ បុគ្គលកាលញុំាងយោនិសោមនសិការដោយឧទ្ទេស និងបរិបុច្ឆា អន្តុយជិតកល្យាណមិត្ត ទើបបានត្រាស់ដឹងធម៌ នេះហៅថា **នេយ្យ** ។ បុគ្គលសូម្បីស្តាប់ច្រើនក្តី ពោលច្រើនក្តី ចាំច្រើនក្តី ទន្ទេញច្រើនក្តី ក៏មិនបានត្រាស់ដឹងធម៌ក្នុងជាតិនោះ ហៅថា **បទបរមៈ** ។

ព្រះមានព្រះភាគទ្រង់តាំងព្រះសូត្រនេះ ដោយអំណាចអធ្យាស្រ័យរបស់ពួកបុគ្គលដែលជាឧគ្ឃដិតញ្ញូ ក្នុងបណ្តាបុគ្គលទាំងនេះ ដោយប្រការដូច្នេះ ។

បានឮថា ក្នុងគ្រានោះភិក្ខុអ្នកស្រុកជនបទចំនួន ៥០០ រូប ត្រាច់ទៅ

តែម្នាក់ឯង (ខ្លះ) ត្រាប់ទៅ ២ រូប (ខ្លះ) ត្រាប់ទៅ ៣ រូប(ខ្លះ) ត្រាប់ទៅ ៤ រូប (ខ្លះ) ត្រាប់ទៅ ៥ រូប (ខ្លះ) មានការប្រព្រឹត្តជាសភាគគ្នា សមាទានធុតង្គ ប្រារព្ធសេចក្តីព្យាយាម ប្រកបសេចក្តីព្យាយាម ជាអ្នកជូនក្នុងវិបស្សនា ប្រាថ្នាការសម្តែងបច្ច័យការដែលល្អិត សុខុម សម្តែងភាពសូន្យទទេ វេលាល្ងាច ទើបចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ បំណងដល់ការសម្តែងបច្ចយាការ ទើបនាំគ្នាអង្គុយហែហម (ព្រះអង្គ) ដូចហែហមដោយវាំងននសំពត់កម្ពលពណ៌ក្រហមដូច្នោះ ព្រះមានព្រះភាគទ្រង់ប្រារព្ធព្រះសូត្រនេះ ព្រោះអំណាចអធ្យាស្រ័យរបស់ពួកភិក្ខុទាំងនោះ ។ ប្រៀបដូចចិត្រករដែលឆ្លាត បានជញ្ជាំងផ្ទះដែលមិនទាន់បានបូកលាប មិនទាន់បានសាងរូបភាពតាំងពីដើម តែគេធ្វើការលាបជញ្ជាំងផ្ទះ ដោយការបូកលាបដោយដីស្អិតជាដើមមុនហើយ សាងរូបភាពត្រង់ជញ្ជាំងផ្ទះដែលបូកលាបហើយ តែគ្រាបានជញ្ជាំងផ្ទះដែលបូកលាបហើយ មិនត្រូវធ្វើការខ្វល់ខ្វាយក្នុងជញ្ជាំងផ្ទះឡើយ លាយពណ៌ហើយ យកបន្ទាត់ ឬលាបពណ៌សាងរូបភាពតែម្យ៉ាង យ៉ាងណា ព្រះមានព្រះភាគក៏ដូច្នោះ បានកុលបុត្រអ្នកផ្តើមបំពេញព្យាយាម តែនៅមិនទាន់ធ្វើសេចក្តីជ្រះថ្លានោះ ទើបមិនបាន

ត្រាស់ប្រាប់លក្ខណៈវិបស្សនាកម្មដ្ឋានដែលល្អិត សុខុម សម្តែងភាពសូន្យដែលជាបទដ្ឋានព្រះអរហត្ត ដល់ភិក្ខុទាំងនោះតាំងអំពីដើម តែទ្រង់ប្រកប (ភិក្ខុនោះ) ទុកក្នុងសម្បទា គឺ សីល សមាធិ និងកម្មស្សកតាទិដ្ឋិ សេចក្តីឃើញថា សត្វមានកម្មជារបស់ខ្លួនជាមុន ទើបត្រាស់ប្រាប់បដិបទាដែលជាចំណែកខាងដើម ដែលព្រះអង្គទ្រង់បំណងយក ត្រាស់ថា ម្នាលភិក្ខុព្រោះហេតុនោះឯង អ្នកចូរជម្រះបដិបទាខាងដើមក្នុងកុសលធម៌ ក៏អ្វីជាខាងដើមរបស់កុសលធម៌ (គឺ) សីលដែលបរិសុទ្ធិ និងទិដ្ឋិត្រង់ ម្នាលភិក្ខុកាលអ្នកមានសីលបរិសុទ្ធិ និងទិដ្ឋិត្រង់ក្នុងកាលណា ម្នាលភិក្ខុ ក្នុងកាលនោះ អ្នកអាស្រ័យសីល តាំងនៅក្នុងសីលហើយ ចម្រើនសតិប្បដ្ឋាន ៤ ៣ យ៉ាង ។ សតិប្បដ្ឋាន ៤ ដូចម្តេច ។ ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញខាងក្នុងកាយ មានសេចក្តីព្យាយាម មានសម្បជញ្ញៈ មានសតិ គប្បីកម្ចាត់បង់អភិជ្ឈា ទោមនស្សក្នុងលោក ពិចារណាឃើញកាយខាងក្រៅ ។ល។ ពិចារណាឃើញទាំងខាងក្នុង និងខាងក្រៅ ។ល។ ពិចារណាឃើញធម៌ក្នុងធម៌ មានសេចក្តីព្យាយាម មានសម្បជញ្ញៈ មានសតិ គប្បីកម្ចាត់បង់អភិជ្ឈា និងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុ ក្នុងកាលណាអ្នកអាស្រ័យ

សីល តាំងនៅក្នុងសីល គប្បីចម្រើនសតិប្បដ្ឋាន ៤ ទាំងនេះ យ៉ាងនេះ ម្នាលភិក្ខុ ក្នុងកាលនោះ ពេលយប់ ឬពេលថ្ងៃនឹងមកដល់អ្នក សេចក្តីចម្រើនតែម្យ៉ាងក្នុងកុសលធម៌ អ្នកគប្បីប្រាថ្នាបាន មិនមានសេចក្តីសាបសូន្យឡើយ ។

ព្រះមានព្រះភាគ លុះត្រាស់ការអប់រំដោយសីលកថា ដល់អាទិកម្មិកកុលបុត្រ ដោយប្រការដូច្នេះហើយ ទើបត្រាស់ប្រាប់លក្ខណៈរបស់វិបស្សនាដែលល្អិត សុខុម សម្តែងភាពសូន្យទទេ ដែលជាបទដ្ឋាននៃព្រះអរហត្ត និងលុះបានភិក្ខុដែលជាវិបស្សនា អ្នកមានសីលបរិសុទ្ធិ ប្រារព្ធសេចក្តីព្យាយាម ប្រកបសេចក្តីព្យាយាមហើយ ក៏មិនត្រាស់ប្រាប់បដិបទាដែលជាចំណែកខាងដើមដល់ភិក្ខុទាំងនោះ តែទ្រង់ត្រាស់ប្រាប់លក្ខណៈនៃវិបស្សនាដ៏ល្អិត សុខុម សម្តែងសភាពទទេ ដែលជាបទដ្ឋាននៃព្រះអរហត្តត្រង់ៗ ឡើយ ។ ភិក្ខុចំនួន ៥០០ រូបទាំងនោះ គ្រាជម្រះបដិបទាដែលជាចំណែកខាងដើមហើយ តាំងនៅដូចមាសដ៏បរិសុទ្ធិ ប្រៀបដូចជាដុំកែវមណីដែលខាស់ហើយ ។ លោកុត្តរមគ្គណាមួយមិនបានមកដល់ពួកភិក្ខុឡើយ ។ ព្រះសាស្តាបានពិចារណាអធ្យាស្រ័យរបស់ពួកភិក្ខុទាំងនោះ ដើម្បីនឹងឲ្យ

ដល់លោកុត្តរមគ្គនោះ ទើបទ្រង់នាំព្រះសូត្រនេះមក ។

បណ្តាបទទាំងនោះ បទថា **បដិច្ចសមុប្បាទំ** បានដល់ បច្ចយាការ ។ ពិតហើយ បច្ចយាការអាស្រ័យគ្នាហើយ រមែងឲ្យសហជាតធម៌កើតឡើង ។ ព្រោះដូច្នោះ **បច្ចយាការ** ព្រះមានព្រះភាគទើបត្រាស់ថា បដិច្ចសមុប្បាទ ។ សេចក្តីសង្ខេបក្នុងនិទានវគ្គនេះ ប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារ អ្នកសិក្សាគប្បីស្រាវជ្រាវអំពីគម្ពីរបករណ៍វិសេសវិសុទ្ធិមគ្គ ។

សព្ទថា **វោ** ក្នុងពាក្យថា **វោ** នេះ រមែងប្រើបានទាំងក្នុងបឋមាវិភត្តិ ទុតិយាវិភត្តិ តតិយាវិភត្តិ បតុត្ថីវិភត្តិ ឆដ្ឋីវិភត្តិ និងក្នុងការធ្វើបទឲ្យពេញ ពិតណាស់ **វោ** សព្ទនេះ រមែងប្រាកដក្នុងបឋមាវិភត្តិ ដូចក្នុងប្រយោគជាដើមថា **កច្ចិ បន វោ អនុរុទ្ធា សមគ្គា សម្មោទមានា** ម្នាលអនុរុទ្ធ និងអានន្ទ ពួកអ្នកញ៉ាំងការរីករាយ ការព្រមព្រៀងគ្នាល្អហើយឬ ។ ប្រើក្នុងទុតិយាវិភត្តិ ក្នុងប្រយោគជាដើមថា **គច្ឆថ ភិក្ខវេ បណាមេមិ វោ** ភិក្ខុទាំងឡាយ ពួកអ្នកចូរចេញទៅ តថាគតបណ្តេញពួកអ្នក ។ ប្រើក្នុងតតិយាវិភត្តិ ក្នុងប្រយោគជាដើមថា **ន វោ មម សន្តិកេ វត្ថព្វំ** អ្នកទាំងឡាយ មិនគួរនៅក្នុងសម្នាក់របស់យើង ។ ប្រើក្នុងចតុត្ថីវិភត្តិ ដូចក្នុង

ប្រយោគជាដើមថា **វិនបដ្ឋបរិយាយំ វោ ភិក្ខវេ ទេសេស្សាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងវិនបត្ថបរិយាយសូត្រដល់ពួកអ្នក ។ ប្រើក្នុងឆដ្ឋីវិភត្តិ ក្នុងប្រយោគជាដើមថា **សព្វេសំ វោ សារីបុត្ត សុភាសិតំ** សារីបុត្រពាក្យរបស់ពួកអ្នកទាំងអស់ជាសុភាសិត ។ ប្រើក្នុងបទបូរណៈ (ធ្វើបទឲ្យពេញ) ក្នុងប្រយោគជាដើមថា **យេ ហិ វោ អរិយា បរិសុទ្ធកាយកម្មន្តា** ក៏ព្រះអរិយៈទាំងឡាយពួកណា មានការងារផ្លូវកាយបរិសុទ្ធិ ។ តែក្នុងទីនេះសព្ទថា **វោ** នេះ គប្បីឃើញថា ចុះក្នុងចតុត្ថីវិភត្តិ ។

ពាក្យថា **ភិក្ខវេ** ជាពាក្យហៅពួកភិក្ខុដែលប្រាកដចំពោះព្រះភ័ក្ត្រដោយទទួលព្រះតម្រាស់ ។ ពាក្យថា **ទេសេស្សាមិ** ជាពាក្យប្ដេជ្ញាដែលនឹងសម្ដែង (ធម៌) ។ ពាក្យថា **តំ សុណាថ** សេចក្ដីថា អ្នកទាំងឡាយចូរស្ដាប់បដិច្ចសមុប្បាទនោះ គឺ ទេសនាកណ្ឌនោះ ដែលតថាគតកំពុងពោលហើយ ។

ក៏ពាក្យថា **សាធុកំ** នោះ ក្នុងពាក្យថា **សាធុកំ មនសិករោថ** នេះមានអត្ថដូចគ្នាថា **សាធុ** មួយវិញទៀត **សាធុ** សព្ទនេះ ប្រើក្នុងអត្ថថា ទូលសូមការឆ្លើយទទួល ការធ្វើឲ្យរីករាយ ត្រេកអរ និងការធ្វើឲ្យមុតមាំជាដើម ។

ពិតណាស់ សាធុ ស័ព្ទនេះ ប្រើក្នុងអត្ថថា ទូលសូម ក្នុងប្រយោគជាដើមថា សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាស សូមព្រះមានព្រះភាគ មេត្តាសម្តែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គចុះ ប្រើក្នុងអត្ថថា ឆ្លើយទទួល ក្នុងពាក្យជាដើមថា សាធុ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភិក្ខុនោះឯង ក្រាបទូលថា ព្រះករុណាព្រះអង្គ ដូច្នេះ បានលើកសរសើរ អនុមោទនាភាសិតព្រះមានព្រះភាគ ។ ប្រើក្នុងអត្ថថា ធ្វើចិត្តឲ្យរីករាយ ក្នុងប្រយោគជាដើមថា សាធុ សាធុ សារីបុត្ត ប្រពៃហើយ ប្រពៃហើយ សារីបុត្រ ។ ប្រើក្នុងអត្ថថា ល្អ ដូចក្នុងប្រយោគជាដើមថា

សាធុ ធម្មរុចិរាជា សាធុ បញ្ញាណវា នរោ
សាធុ មិត្តានមទ្ទុព្ភោ បាបស្ស អករណំ សុខំ ។

ព្រះរាជាទ្រង់ពេញព្រះទ័យក្នុងធម៌ល្អ នរជនអ្នកមានបញ្ញាល្អ
ការមិនប្រទូស្តរាយមិត្តល្អ ការមិនធ្វើសេចក្តីអាក្រក់ជាសុខ ។

សាធុក ស័ព្ទនុ៎ះឯង ប្រើក្នុងការធ្វើឲ្យមុតមាំ ដូចក្នុងប្រយោគជាដើមថា តេនហិ ព្រាហ្មណ សាធុកំ សុណាហិ ព្រាហ្មណ៍ ប្រសិនបើដូច្នោះ

អ្នកចូរស្តាប់ឲ្យមុតមាំ ។ **សាធុក** ស័ព្ទនេះ លោកពោលថា ប្រើក្នុងការបង្គាប់ក៏បាន ។ តែក្នុងទីនេះ **សាធុក** ស័ព្ទនេះ ប្រើក្នុងអត្ថថា ការធ្វើឲ្យមុតមាំតែម្យ៉ាង ។ ម្យ៉ាងទៀត អត្ថនៃការបង្គាប់ គប្បីជ្រាបដូចតទៅ ។ សូម្បីក្នុងអត្ថថា **ជាសេចក្តីល្អ** ក៏ប្រើបាន ។ **សាធុក** ស័ព្ទ ក្នុងអត្ថទាំងពីរនោះ លោកសម្តែងទុកដោយអត្ថនៃការធ្វើឲ្យមុតមាំថា **ទឡ្ហំ ឥមំ ធម្មំ សុណាថ សុគហិតំ គណ្ហន្តា** កាលនឹងកាន់យកឲ្យល្អ ពួកអ្នកក៏ចូរស្តាប់ធម៌នេះឲ្យមុតមាំ ដោយអត្ថនៃការបង្គាប់ថា **មម អាណត្តិយា សុណាថ** អ្នកទាំងឡាយចូរស្តាប់តាមពាក្យបង្គាប់របស់យើង ដោយអត្ថថា **ជាសេចក្តីល្អ** ថា **សុន្ទរមិមំ ភទ្ទកំ ធម្មំ សុណាថ** អ្នកចូរស្តាប់ធម៌នេះឲ្យល្អ ឲ្យចម្រើន ។ បទថា **មនសិករោថ** សេចក្តីថា ចូររលឹក គឺ ប្រមូលមក ។ អធិប្បាយថា អ្នកចូរមានចិត្តកុំរវើរវាយ តាំងចិត្តស្តាប់ គឺ ធ្វើទុកក្នុងចិត្ត ។

ឥឡូវនេះ ពាក្យថា **តំ សុណាថ** ក្នុងទីនោះ ជាពាក្យហាមដល់សោតិន្ទ្រិយរវើរវាយ ។ ពាក្យថា **សាធុកំ មនសិករោថ** ជាពាក្យហាមដល់មនិន្ទ្រិយរវើរវាយ ដោយការប្រកបឲ្យមាំក្នុងមនសិការ ក៏ក្នុង ២ ពាក្យនេះ ពាក្យដំបូងជាការប្រកាន់ដោយសេចក្តីឃៀងឃ្លាតនៃព្យញ្ជនៈ ពាក្យ

ក្រោយជាការហាមការប្រកាន់សេចក្ដីឃ្លៀងឃ្លាតនៃអត្ថ ។ ព្រះមានព្រះភាគប្រកបភិក្ខុទុកក្នុងការស្ដាប់ធម៌ដោយពាក្យដំបូង ។ ទ្រង់ប្រកបភិក្ខុទុកក្នុងការទ្រទ្រង់ និងសាកសួរធម៌ដែលភិក្ខុស្ដាប់ហើយ ដោយពាក្យក្រោយ ។ ម្យ៉ាងទៀត ដោយពាក្យដំបូង ទ្រង់រមែងសម្ដែងថា ធម៌នេះប្រព្រឹត្តទៅដោយព្យញ្ជនៈ ព្រោះដូច្នោះ ទើបគប្បីស្ដាប់ ។ ដោយពាក្យក្រោយ ទ្រង់សម្ដែងថា ធម៌នេះប្រព្រឹត្តទៅដោយអត្ថ ព្រោះដូច្នោះ ទើបគប្បីធ្វើទុកក្នុងចិត្ត ។ ម្យ៉ាងទៀត គួរប្រកប **សាធុក** បទ ដោយបទ ២ បទ គប្បីជ្រាបការប្រកបសេចក្ដីយ៉ាងនេះថា ព្រោះធម៌នេះជ្រាលជ្រៅដោយធម៌ និងជ្រាលជ្រៅដោយទេសនា ដូច្នោះ ពួកអ្នកចូរស្ដាប់ឲ្យល្អ ។ ព្រោះហេតុដែលធម៌នេះជ្រាលជ្រៅដោយអត្ថ និងជ្រាលជ្រៅដោយបដិវេធ ដូច្នោះ ពួកអ្នកចូរធ្វើក្នុងចិត្តឲ្យល្អ ។ បទថា **ភាសិស្សាមិ** ប្រែថា នឹងសម្ដែង ។ ក្នុងពាក្យថា **តំ សុណាថ** នេះ លោកអធិប្បាយថា តថាគតនឹងសង្ខេបសេចក្ដីសម្ដែងទេសនាដែលតថាគតប្ដេជ្ញាទុកហើយនោះ ។

ម្យ៉ាងទៀត តថាគតនឹងមិនពោលសូម្បីដោយពិស្ដារ ។ មួយទៀត បទទាំងនេះ ជាបទប្រាប់សេចក្ដីសង្ខេប និងពិស្ដារទុក ដូចដែលព្រះវង្គី-

សត្ថេរពោលទុកថា ៖

សង្ខិត្តេនបិ ទេសេតិ វិត្ថារេនបិ ភាសតិ

សាលិកាយិវ និគ្ឃោសោ បដិភាណំ ឧទិរីយតិ ។

ព្រះមានព្រះភាគទ្រង់សម្តែងធម៌ដោយសង្ខេបខ្លះ ត្រាស់ដោយពិស្តារខ្លះ ទ្រង់មានព្រះសូរសៀងពីរោះដូចសត្វសាលិកា ទ្រង់សម្តែងចេញនូវបដិភាណ ។

កាលព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះ ភិក្ខុទាំងនោះឯងកើតសេចក្តីឧស្សាហ៍ ស្តាប់ព្រះមានព្រះភាគ មានពាក្យអធិប្បាយទទួលហើយ គឺ ទទួលព្រះតម្រាស់របស់ព្រះសាស្តាថា យ៉ាងនោះឯង ព្រះអង្គ ។

បទថា **ភគវា ឯតទវោច** សេចក្តីថា លំដាប់នោះ ព្រះមានព្រះភាគបានត្រាស់ព្រះសូត្រទាំងអស់នេះ ដែលនឹងគប្បីត្រាស់ក្នុងកាលឥឡូវនេះដល់ភិក្ខុទាំងនោះ មានជាអាទិ៍ថា **កតមោ ច ភិក្ខវេ បដិច្ចសមុប្បាទោ** ។ បណ្តាបទទាំងនោះ **កតមោ ច ភិក្ខវេ បដិច្ចសមុប្បាទោ** ជាកថេតុកម្យតាបុច្ឆា ពាក្យសួរដើម្បីនឹងត្រាស់ដោយព្រះអង្គឯង ។

ពិតណាស់ ការសួរមាន ៥ យ៉ាង គឺ ការសួរបំភ្លឺសេចក្តីដែលមិន

ទាន់ឃើញ ការសួរប្រៀបធៀបនូវធម៌ដែលបានឃើញហើយ ការសួរដើម្បីកាត់សេចក្ដីសង្ស័យ ការសួរដែលឃើញតាម (អនុមតិ) ការសួរដើម្បីនឹងត្រាស់ដោយព្រះអង្គឯង ។ ការសួរទាំង ៥ យ៉ាងនេះ មានសេចក្ដីផ្សេងគ្នាដូចតទៅនេះ ៖

ការសួរបំភ្លឺសេចក្ដីដែលមិនទាន់ឃើញដូចជាម្ដេច ។ លក្ខណៈនៃពាក្យសួរតាមប្រក្រតី ដែលជនដទៃមិនដឹង មិនឃើញ មិនត្រិះរិះ មិនពិចារណា មិនជាក់ច្បាស់ មិនថ្លៃឲ្យច្បាស់ ។ បុគ្គលរមែងសួរបញ្ហាដើម្បីដឹងឃើញ ត្រិះរិះ ពិចារណាជាក់ច្បាស់ ថ្លៃបញ្ហានោះឲ្យឃើញច្បាស់ ការសួរនេះ ឈ្មោះថា ការសួរបំភ្លឺសេចក្ដីដែលនៅមិនទាន់ឃើញ ។

ការសួរដើម្បីប្រៀបធៀបសេចក្ដីដែលឃើញហើយ ដូចជាម្ដេច ។ លក្ខណៈ (ពាក្យសួរ) តាមប្រក្រតី ដែលខ្លួនដឹងឃើញ ត្រិះរិះ ពិចារណាជាក់ច្បាស់ ជាក់ច្បាស់ហើយ បុគ្គលនោះរមែងសួរបញ្ហាដើម្បីប្រៀបធៀបជាមួយពួកបណ្ឌិតដទៃ ។ ការសួរនេះ ឈ្មោះថា ការសួរដើម្បីប្រៀបធៀបសេចក្ដីដែលខ្លួនឃើញហើយ ។

ការសួរដើម្បីកាត់សេចក្ដីសង្ស័យ ដូចម្ដេច ។ តាមប្រក្រតីបុគ្គល

ដែលស្ទុះទៅកាន់សេចក្តីសង្ស័យ អ្នកផ្ចោះទៅកាន់សេចក្តីងឿងឆ្ងល់ កើតសេចក្តីគិតបែកជា ២ បែកខ្ញែកថា យ៉ាងនេះមែនឬហ្ន៎ ឬមិនមែន ឬជាយ៉ាងណា គេទើបសួរបញ្ហាដើម្បីកាត់សេចក្តីសង្ស័យ ការសួរយ៉ាងនេះ ឈ្មោះថា ការសួរដើម្បីកាត់សេចក្តីសង្ស័យ ។

ការសួរដែលឃើញតាម (អនុមតិ) ដូចម្តេច ។ ព្រះមានព្រះភាគរមែងត្រាស់សួរបញ្ហាដើម្បីការឃើញតាមរបស់ភិក្ខុថា ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយរមែងសម្គាល់សេចក្តីនោះដូចជាម្តេច រូបទៀងឬ មិនទៀង ភិក្ខុក្រាបទូលថា រូបមិនទៀងទេ ព្រះអង្គ ។ ព្រះមានព្រះភាគ ត្រាស់ថា ក៏រូបណាមិនទៀង រូបនោះជាទុក្ខ ឬជាសុខ ។ ពួកភិក្ខុក្រាបទូលថា ជាទុក្ខព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ក៏រូបណាមិនទៀង ជាទុក្ខ មានការប្រែប្រួលជាធម្មតា គប្បីឃើញរូបនោះថា នោះរបស់យើង នោះជាយើង នោះជាខ្លួនរបស់យើងឬ ។ ពួកភិក្ខុក្រាបទូលថា ការប្រកាន់យ៉ាងនោះមិនគួរទេ ព្រះអង្គ ។ ការសួរយ៉ាងនេះ ឈ្មោះថា ការសួរដោយឃើញតាម ។

ការសួរដើម្បីនឹងត្រាស់ឆ្លើយដោយព្រះអង្គឯង ដូចម្តេច ។ ព្រះមានព្រះភាគរមែងត្រាស់សួរបញ្ហា ដើម្បីត្រាស់ឆ្លើយនឹងភិក្ខុទាំងឡាយថា ភិក្ខុ

ទាំងឡាយ សតិប្បដ្ឋាន ៤ ទាំងនេះឯង សតិប្បដ្ឋាន ៤ ដូចម្តេចជាដើម ការសួរនេះ ឈ្មោះថា ការសួរដើម្បីនឹងទ្រង់វិសជ្ជនាដោយព្រះអង្គឯង ។

បណ្តាការសួរ ៥ យ៉ាងទាំងនេះ ចំពោះព្រះសម្ពុទ្ធ មិនមានការសួរ ៣ យ៉ាងខាងដើមឡើយ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា អ្វីដែលត្រូវបច្ច័យតាក់តែងក្នុងកាលទាំង ៣ ឬផុតចាកកាល មិនត្រូវបច្ច័យតាក់តែង ឈ្មោះថា ទ្រង់មិនឃើញ មិនក្លឺ មិនបានត្រិះរិះ មិនពិចារណា មិនឃើញច្បាស់ មិនច្បាស់លាស់ហើយ មិនមានដល់ព្រះពុទ្ធឡើយ ព្រោះហេតុនោះ ការសួរដើម្បីបំភ្លឺអត្ថ ដែលព្រះពុទ្ធទាំងនោះទ្រង់មិនឃើញ ទើបមិនមាន ក៏វត្ថុណាដែលព្រះមានព្រះភាគ ទ្រង់ចាក់ធ្លុះហើយដោយព្រះញាណរបស់ព្រះអង្គ កិច្ចដោយការប្រៀបធៀបវត្ថុនោះ នឹងសមណ ព្រាហ្មណ៍ ទេវតា មារ ឬព្រហ្មដទៃរបស់ព្រះអង្គ ទើបមិនមាន ព្រោះហេតុនោះ ការសួរប្រៀបធៀបសេចក្តីដែលព្រះអង្គឃើញហើយ ទើបមិនមាន ។ ក៏ព្រោះហេតុដែលព្រះមានព្រះភាគព្រះអង្គនោះទ្រង់មិនសង្ស័យថា យ៉ាងណា ទ្រង់ឆ្លងសេចក្តីសង្ស័យបាន កម្ចាត់សេចក្តីសង្ស័យក្នុងធម៌ទាំងពួងបាន ដូច្នោះ ការសួរកាត់សេចក្តីសង្ស័យរបស់ព្រះអង្គ ទើបមិនមាន ចំណែកការសួរ ២ យ៉ាងដ៏សេស

របស់ព្រះមានព្រះភាគ នៅមាន បណ្ឌិតគប្បីជ្រាបថា ក្នុងពាក្យសួរ ២ យ៉ាង នោះ ការសួរដើម្បីនឹងត្រាស់វិសជ្ជនាដោយព្រះអង្គឯង ដូចតទៅនេះ ៖

ឥឡូវនេះ ព្រះមានព្រះភាគកាលទ្រង់ចែកបច្ចយាការ ដោយការសួរ នោះ ទើបត្រាស់ថា **អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា** ជាដើម ។ ក៏ក្នុងពាក្យ ថា **អវិជ្ជាបច្ចយា ភិក្ខវេ សង្ខារា** ជាដើមនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ នេះ ៖ ប្រៀបដូចបុគ្គលផ្ដើមពោលថា យើងនឹងនិយាយដល់បិតា រមែង និយាយដល់បិតាមុនថា បិតារបស់តិស្សៈ បិតារបស់សោណៈ យ៉ាងណា ព្រះមានព្រះភាគក៏ដូច្នោះដែរ ទ្រង់ផ្ដើមដើម្បីត្រាស់បច្ច័យ កាលត្រាស់ដល់ ធម៌ មានអវិជ្ជាជាដើម ដែលជាបច្ច័យនៃធម៌មានសង្ខារជាដើម ដោយន័យ ជាដើមថា **អវិជ្ជាបច្ចយា សង្ខារា** ដូច្នេះហើយ ទើបត្រាស់ដល់ធម៌ដែល អាស្រ័យបច្ច័យកើតឡើង ។ តែក្នុងទីបំផុតនៃអាហារវគ្គ ព្រះមានព្រះភាគ ទើបត្រាស់ធម៌សូម្បី ២ យ៉ាងថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែង បដិច្ចសមុប្បាទ (ការអាស្រ័យគ្នានិងគ្នាកើតឡើង) និងបដិច្ចសមុប្បន្នធម៌ ដល់អ្នកទាំងឡាយ ។

ក៏ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អវិជ្ជាបច្ចយា សង្ខារា**

ជាដើមដូចតទៅនេះ ៖ អវិជ្ជានោះផង ជាបច្ច័យផង ឈ្មោះថា អវិជ្ជាជាបច្ច័យ ។ ព្រោះហេតុនោះ គប្បីជ្រាបអត្ថដោយន័យនេះថា សង្ខាររមែងកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ ក្នុងពាក្យថា **អវិជ្ជាបច្ចយា សង្ខារា** នេះ មានសេចក្តីសង្ខេបប៉ុណ្ណេះ តែពោលដោយពិស្តារ អនុលោមបដិច្ចសមុប្បាទកថាដែលកើតព្រមគ្នាគ្រប់យ៉ាង លោកពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ព្រោះហេតុនោះ អនុលោមបដិច្ចសមុប្បាទកថានោះ អ្នកសិក្សាគប្បីកាន់យកន័យដែលពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គនោះចុះ ។

ក៏ក្នុងបដិលោមកថា ពាក្យថា **អវិជ្ជាយត្វេវ** កាត់បទជា **អវិជ្ជាយ តុ ឯវ** ។ បទថា **អសេសវិរាគនិរោធា** បានដល់ ព្រោះអវិជ្ជារលត់ដោយមិនមានសល់ដោយមគ្គ ពោលគឺ វិរាគៈ ។ ព្រោះសង្ខាររលត់ដោយមិនការកើតឡើង (ទៀត) ឈ្មោះសង្ខារនិរោធៈ (សង្ខាររលត់) ។ ក៏ដើម្បីសម្តែងថា ព្រោះការរលត់សង្ខារ និងព្រោះការរលត់ខន្ធ ៥ មានវិញ្ញាណជាដើម ដែលរលត់ទៅហើយយ៉ាងនេះ នាមរូប ឈ្មោះថា ជាការរលត់ទៅហើយដូចគ្នា ព្រះមានព្រះភាគទើបត្រាស់ថា **សង្ខារនិរោធា វិញ្ញាណនិរោធោ** ព្រោះសង្ខាររលត់ វិញ្ញាណទើបរលត់ជាដើម ហើយត្រាស់ថា **ឯវ-**

**មេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ** ការរលត់នៃកងទុក្ខទាំងមូលនេះ រមែងមាន ដោយប្រការដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **កេវលស្ស** ប្រែថា ទាំងអស់ គឺ សុទ្ធៗ អធិប្បាយថា វៀរចាកសត្វ ។ បទថា **ទុក្ខក្ខន្ធស្ស** ប្រែថា កងទុក្ខ ។ ពាក្យថា **និរោធោ ហោតិ** គឺ ការមិនកើតឡើង ។

ដូច្នោះ ព្រះមានព្រះភាគ លុះត្រាស់វដ្តកថា (កថាពោលអំពីវដ្ដៈ) ដោយបទ ១២ បទ ដោយអនុលោម ទ្រង់ត្រឡប់បទនោះហើយ ត្រាស់វិវដ្ដ-កថា (និព្វាន) ដោយបទ ១២ ទ្រង់កាន់យកដល់កំពូលព្រះទេសនាដោយអរហត្ត ។

ក្នុងវេលាចប់ទេសនា ភិក្ខុអ្នកវិបស្សនាចំនួនទាំង ៥០០ រូបនោះជាបុគ្គលប្រភេទឧគ្ឃដិតញ្ញូ ចាក់ធ្លុះសច្ចៈ តាំងនៅក្នុងព្រះអរហត្តផលដូចផ្កាបទុមដល់ការចាស់ក្លា ល្មមត្រូវពន្លឺព្រះអាទិត្យក៏រីកហើយ ដូច្នោះ ។

បទថា **ឥទមវោច ភគវា** បានដល់ ព្រះមានព្រះភាគបានត្រាស់ពាក្យនេះ គឺ ព្រះសូត្រទាំងអស់ គឺ វដ្តកថា និងវិវដ្ដកថា ។ បទថា **អត្ត-មនា តេភិក្ខូ** សេចក្ដីថា ភិក្ខុចំនួនទាំង ៥០០ រូបនោះ មានចិត្តត្រេកអរជា

ព្រះទីណាស្រេចហើយ ។ បទថា **ភគវតោ ភាសិតំ អភិនន្ទុំ** សេចក្តីថា (ភិក្ខុទាំងនោះ) នាំគ្នាលើកសរសើរព្រះតម្រាស់ព្រះមានព្រះភាគដែលត្រាស់ដោយព្រះសូរសេងដូចសម្លេងព្រហ្ម ពីរោះដូចសម្លេងសត្វការវេក ស្រស់-ស្រាយដូចជាអម្រឹតាភិសេកស្រោចស្រប់ហឫទយបណ្ឌិតជន អធិប្បាយថា អនុមោទនាទទួលព្រមគ្នាហើយ ។ ព្រោះហេតុនោះ ព្រះបុរាណាចារ្យទើបពោលថា ៖

*សុភាសិតំ សុលបិតំ ឯតំ សាធូតិ តាទិនោ*
*អនុមោទមានា សិរសា សម្បដិច្ឆឹសុ ភិក្ខវោ ។*

ភិក្ខុទាំងឡាយអនុមោទនាចំពោះព្រះមានព្រះភាគថា ព្រះ-តម្រាស់ព្រះមានព្រះភាគ ទ្រង់ភាសិតហើយ ត្រាស់ទុកហើយ ញុំាងប្រយោជន៍ឲ្យសម្រេច ដូច្នេះ ទទួលព្រមគ្នាហើយដោយសិរសា ។

ចប់អដ្ឋកថា បដិច្ចសមុប្បាទសូត្រទី ១

# អ ដ្ឋ ក ថា

# វិភង្គសូត្រទី ២

[៤] សូម្បីក្នុងវិភង្គសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

គប្បីជ្រាបហេតុតាំងព្រះសូត្រ តាមន័យដែលពោលហើយនុ៎ះឯង ។ តែសេចក្តីប្លែកគ្នា មានដូច្នេះ ៖

ព្រះសូត្រដំបូង ព្រះអង្គទ្រង់សម្តែងទុកដោយសង្ខេប ដោយឧគ្ឃដិតញ្ញូបុគ្គល ព្រះសូត្រនេះ ទ្រង់សម្តែងទុកដោយពិស្តារដោយវិបចិតញ្ញូបុគ្គល ។ ក៏ក្នុងព្រះសូត្រនេះ គប្បីពោលឧបមាដោយបុរសនាំវល្លិទៅ ៤ ឧបមា ។ ឧបមានោះលោកពោលទុកហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនុ៎ះឯង ។ ប្រៀបដូចបុរសអ្នកនាំវល្លិ៍ទៅ ជួបខាងចុងវល្លិ៍ហើយ ក៏ស្វែងរកខាងគល់តាមចុងវល្លិ៍នោះ ឃើញគល់ (វល្លិ៍) ហើយ ក៏កាត់ត្រង់គល់វល្លិ៍កាន់យកទៅប្រើក្នុងការងារបាន យ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះ កាលទ្រង់សម្តែងទេសនាយ៉ាងពិស្តារ ទ្រង់នាំទេសនាតាំងពីជរាមរណៈដែលជាខាងចុងនៃបដិច្ចសមុប្បាទ ដរាបដល់អវិជ្ជាបទ ដែលជាឫសគល់ សម្តែងវដ្តកថា

និងវិវដ្តកថា ដដែលទៀតឲ្យចប់ស្រេច ។

ក្នុងពាក្យនោះ គប្បីជ្រាបវិនិច្ឆ័យសេចក្តីនៃជរា និងមរណៈជាដើម ដោយវិត្ថារទេសនា ដូចតទៅនេះ៖

[៦] គប្បីជ្រាបវិនិច្ឆ័យក្នុងជរាមរណនិទ្ទេសមុន ។ ស័ព្ទថា **តេសំ តេសំ** នេះ ដោយសង្ខេប គប្បីជ្រាបថា ជាស័ព្ទ សម្តែងអត្ថន័យទូទៅដល់ពពួកសត្វជាច្រើន ។ ពិតហើយ កាលបុគ្គលពោលហើយសូម្បីរហូតអស់មួយថ្ងៃយ៉ាងនេះថា ជរាមកដល់ព្រះទេវទត្ត ជរាមកដល់ព្រះសោមទត្ត សត្វទាំងឡាយរមែងមិនដល់សភាពចាស់ដោយជុំវិញតែម្យ៉ាង តែដោយ ២ បទនេះ សត្វណាៗ ដែលឈ្មោះថា មិនត្រូវជរាមរណៈគ្របសង្កត់ មិនមាន ព្រោះដូច្នោះ លោកទើបពោលថា ស័ព្ទថា **តេសំ តេសំ** នេះ ពោលដោយសង្ខេប ជាស័ព្ទសម្តែងសេចក្តីទូទៅដល់ពពួកសត្វដ៏ច្រើន ដូច្នេះ ។

ស័ព្ទថា **តម្ហិ តម្ហិ** នេះ ជាស័ព្ទសម្តែងន័យទូរទៅដល់ពពួកសត្វចំនួនច្រើន ដោយចាត់តាមគតិ និងជាតិ ។ ពាក្យថា **សត្តនិកាយេ** ជាពាក្យសម្តែងដោយសរុប ដែលលោកសម្តែងទុកហើយក្នុងសាធារណនិទ្ទេស ។ ក៏ស័ព្ទថា **ជរា** ក្នុងពាក្យថា **ជរា ជីរណតា** ជាដើម ជាស័ព្ទសម្តែងសភាវ-

ធម៌ ។

សព្ទថា **ជីរណតា** ជាសព្ទសម្តែងអាការ ។ សព្ទថា **ខណ្ឌិច្ចំ** ជាដើម ជាសព្ទសម្តែងកិច្ចក្នុងការកន្លងកាល ។ សព្ទ ២ សព្ទ ចុងក្រោយ ជាសព្ទសម្តែងភាពប្រក្រតី ។ ក៏ដោយបទថា **ជរា** នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងជរាដោយជាសភាវធម៌ ។ ព្រោះហេតុនោះ សព្ទថា **ជរា** នេះ ទើបជាសព្ទសម្តែងសភាវធម៌ ។ ព្រោះហេតុនោះ សព្ទថា **ជរា** នេះ ទើបជាសព្ទសម្តែងសភាវធម៌នៃជរានោះ ។ ដោយពាក្យថា **ជីរណតា** នេះ ទ្រង់សម្តែងដោយអាការ ។ ព្រោះហេតុនោះ សព្ទថា **ជរា** នេះ ទើបជាសព្ទសម្តែងអាការរបស់ជរានោះ ។ ដោយបទថា **ខណ្ឌិច្ចំ** នេះ ទ្រង់សម្តែងដោយកិច្ច គឺ ភាវៈនៃធ្មេញ និងក្រចកបាក់ក្នុងវេលាកន្លងទៅ ។ ដោយបទថា **បាលិច្ចំ** នេះ ទ្រង់សម្តែងដោយកិច្ច គឺ ភាវៈនៃសក់ និងរោមស្កូវ ។ ដោយបទថា **វលិតចតា** នេះ ទ្រង់សម្តែងដោយកិច្ច គឺ ភាវៈនៃសាច់ និងស្បែកជ្រីវជ្រួញ ព្រោះហេតុនោះ សព្ទ ៣ សព្ទ មានសព្ទថា **ខណ្ឌិច្ចំ** ជាដើមនេះ ជាសព្ទសម្តែងកិច្ច ព្រោះវេលាកន្លងទៅដល់ជរា ។ ដោយសព្ទទាំង ៣ នោះ លោកសម្តែងជរាដែលប្រាកដ ដោយសម្តែងការប្រែប្រួល

ប្រៀបដូចផ្លូវទៅរបស់ទឹក ខ្យល់ ឬភ្លើង រមែងប្រាកដ ព្រោះស្មៅ និង ដើមឈើជាដើម ត្រូវជុត ឬឆេះ តែផ្លូវទៅរបស់ស្មៅ និងដើមឈើនោះ មិនប្រាកដ ប្រាកដតែទឹកជាដើមប៉ុណ្ណោះ យ៉ាងណា ផ្លូវទៅរបស់ជរាប្រាកដ ត្រង់ធ្មេញបាក់ជាដើម ដូច្នោះដូចគ្នា អវយវៈ មានធ្មេញជាដើម បុគ្គល សូម្បីបើកភ្នែកក៏ចាប់យកបាន តែសភាពធ្មេញបាក់ជាដើម សូម្បីបើកភ្នែក ក៏នឹងដឹងផ្លូវចក្ខុមិនបាន ចាប់យកមិនបាន ជរាក៏មិនបានដូចគ្នា ព្រោះថា ជរាមិនគប្បីដឹងដោយចក្ខុ ។

ក៏ដោយបទថា **អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ** (សេចក្តី វិនាសនៃអាយុ ភាពចាស់ទុំនៃឥន្ទ្រិយ) នេះ ព្រះមានព្រះភាគទ្រង់សម្តែង ទុកតាមប្រក្រតី ព្រោះបុគ្គលនឹងចូលដល់ការអស់ទៅនៃអាយុ និងការចាស់ ទុំនៃឥន្ទ្រិយ មានចក្ខុជាដើម ព្រោះសង្ខារប្រែប្រួលទៅក្នុងកាលកន្លងទៅ នុ៎ះឯង ។ ព្រោះហេតុនោះ បទ ២ បទក្រោយនេះ នៃពាក្យថា ជរានោះ គប្បីជ្រាបថា ជាបទសម្តែងនូវភាពប្រក្រតី ។ ព្រោះក្នុង ២ បទទាំងនោះ បុគ្គលដែលដល់ជរា អាយុរមែងសាបសូន្យទៅ ដូច្នោះ ជរា ព្រះមានព្រះ-ភាគទើបត្រាស់ទុកដោយអាស្រ័យហេតុជិតជាមួយផលថា ការសាបសូន្យ

អាយុ ។ និងព្រោះក្នុងវេលាជាកម្លោះ ឥន្ទ្រិយមានចក្ខុជាដើម ក៏ថ្លាផូរផង់ អាចទទួលអារម្មណ៍របស់ខ្លួនសូម្បីដែលល្អិតបានដោយងាយ កាលបុគ្គលដល់ភាពជរាហើយ រមែងចាស់ទុំ គឺ កករល្អក់ បានដល់ មិនថ្លាផូរផង់ មិនអាចនឹងទទួលអារម្មណ៍របស់ខ្លួនសូម្បីគ្រោតគ្រាតបាន ព្រោះហេតុនោះ ជរានោះ ព្រះមានព្រះភាគទើបត្រាស់ទុក ដោយអាស្រ័យហេតុជិតនឹងផល ថា ភាពចាស់ទុំនៃឥន្ទ្រិយ ។

ក៏ជរាសូម្បីទាំងអស់ដែលព្រះអង្គទ្រង់សម្តែងទុកយ៉ាងនេះ មាន ២ យ៉ាង គឺ **បាកដជរា បដិច្ឆន្នជរា** ។ ក្នុងជរា ២ យ៉ាងនោះ ការចាស់របស់រូបធម៌ ព្រោះសម្តែងដល់ធ្មេញបាក់ជាដើម ឈ្មោះថា **បាកដជរា** ។ ចំណែកការចាស់របស់អរូបធម៌ ព្រោះមិនសម្តែងវិការ (ភាពប្រែប្រួល) ដូច្នោះ ឈ្មោះថា **បដិច្ឆន្នជរា** ។ ជរាន័យមួយទៀតមាន ២ យ៉ាង យ៉ាងនេះគឺ **អវិចិជរា សវិចិជរា** ។ ក្នុងជរា ២ យ៉ាងនោះ ជរា ឈ្មោះថា **អវិចិជរា** ព្រោះធម្មជាតិមានសេចក្តីប្លែកនៃវណ្ណៈជាប់តគ្នាជាដើម ដឹងបានលំបាក ដូចកែវមណី មាស ប្រាក់ កែវប្រវាឡ ព្រះចន្ទ ព្រះអាទិត្យជាដើម ដូចសត្វដែលជាប់ទាក់ទងនឹងខ្យល់ដកដង្ហើមក្នុងសត្វមនុស្សកៈជាដើម និងដូចវត្ថុ

ដែលមិនជាប់ទាក់ទងនឹងខ្យល់ដកដង្ហើម មានផ្កាឈើ ផ្លែឈើ និងស្លឹកជាដើម ដូច្នោះ ។ អធិប្បាយថា ជរាដែលជាប់តគ្នា ជរា គប្បីជ្រាបថា ដែលឈ្មោះថា **សវិចិជរា** ព្រោះធម្មជាតិមានការប្រែប្រួលនៃវណ្ណៈជាប់តគ្នាជាដើម វត្ថុដទៃអំពីនោះតាមដែលពោលហើយ បុគ្គលដឹងបានងាយ ។ ពាក្យថា **តេសំ តេសំ** ជាដើមក្រៅអំពីនេះ គប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។ ក៏ពាក្យថា **ចុតិ** ក្នុងពាក្យថា **ចុតិ ចវនតា** ជាដើម លោកពោលដោយអំណាចការឃ្លាតចាកភព (ដើម) ។ ពាក្យថា **ចុតិ** នោះ ជាឈ្មោះរបស់ខន្ធ ១ ខន្ធ ៤ ខន្ធ ៥ និងអាយតនៈ ។ **ចវនតា** ជាពាក្យសម្តែងលក្ខណៈ ដោយពាក្យសម្តែងភាវៈ ។ ពាក្យថា **ភេទោ** ជាពាក្យសម្តែងការកើតឡើង និងការរលត់ទៅនៃចុតិខន្ធ ។ ពាក្យថា **អន្តរធានំ** ជាពាក្យសម្តែងភាវៈនៃវត្ថុដែលវិភេជិប្បច្ច័យប៉ះខ្ទប់បែកធ្លាយទៅនៃចុតិខន្ធដែលបែកធ្លាយទៅ ដោយបរិយាយណាមួយ ។ បទថា **មច្ចុ មរណំ** បានដល់ មរណៈ គឺ មច្ចុ ។ ព្រះមានព្រះភាគ ទ្រង់បដិសេធសមុច្ឆេទមរណៈជាដើម ដោយបទថា **មច្ចុ-មរណំ** នោះ ។ សភាវៈដែលធ្វើទីបំផុត ឈ្មោះថា **កាលៈ** ។ ការធ្វើនូវកាលៈនោះ ឈ្មោះថា **កាលកិរិយា** ។ ព្រះមានព្រះភាគទ្រង់សម្តែងមរណៈ

ដោយលោកសម្មតិ ដោយបទថា **កាលោ** នោះ ដោយប្រការដូច្នេះ ។

ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងដោយបរមត្ថ ព្រះមានព្រះភាគទើបត្រាស់ថា **ខន្ធានំ ភេទោ** ដូច្នេះជាដើម ។ ពិតណាស់ កាលពោលដោយបរមត្ថ ខន្ធប៉ុណ្ណោះបែកធ្លាយ ។ នរណាៗ ដែលឈ្មោះថា សត្វ រមែងមិនស្លាប់ ។ តែកាលខន្ធបែកធ្លាយ សត្វរមែងស្លាប់ ទើបមានវោហារថា កាលខន្ធបែកធ្លាយ សត្វក៏ឈ្មោះថា ស្លាប់ ។

ក៏ក្នុងទីនេះគប្បីជ្រាបការបែកធ្លាយ នៃខន្ធដោយអំណាចចតុវោការភព (ភពដែលមានខន្ធ ៤ វៀររូបខន្ធ) គប្បីជ្រាបការលះបង់ចោលរាងកាយដោយអំណាចឯកវោការភព (ភពដែលមានខន្ធ ១ គឺ រូបខន្ធ) និងគប្បីជ្រាបការបែកធ្លាយខន្ធ ដោយអំណាចបញ្ចវោការភព ។ គប្បីជ្រាបការលះបង់រាងកាយដោយអំណាចភព ២ ដ៏សេស ។ ព្រោះហេតុអ្វី ។ ព្រោះរាងកាយពោលគឺ រូបកាយ កើតក្នុងភពទាំង ២ ។ ម្យ៉ាងទៀត ក៏ព្រោះខន្ធក្នុងពួកទេវជាន់ចតុមហារាជ រមែងបែកធ្លាយដូចគ្នា មិនលះបង់អ្វីៗ ទុក ដូច្នោះ គប្បីជ្រាបការបែកនៃខន្ធដោយអំណាចទេវទាំងនោះ ។ ក្នុងពួកសត្វ មានមនុស្សជាដើម មានការលះបង់រាងកាយទុក ។ ក៏ក្នុងទីនេះ គប្បីឃើញន័យយ៉ាង

នេះថា សេចក្ដីស្លាប់ ព្រោះលះបង់ចោលរាងកាយទុក លោកពោលទុកថា កឡេវរស្ស និក្ខេបោ ។

ពាក្យថា **ឥតិ អយញ្ច ជរា ឥទញ្ច មរណំ ឥទំ វុច្ចតិ ភិក្ខវេ** នេះ លោកពោលរួមទាំងពីរចូលគ្នាតែមួយថា **ជរាមរណំ** ដូច្នេះ ។

[៧] ក្នុង **ជាតិនិទ្ទេស** មានវិនិច្ឆ័យដូចតទៅនេះ ៖

ដែលឈ្មោះថា **ជាតិ** ក្នុងពាក្យជាដើមថា **ជាតិ សញ្ជាតិ** នេះ ព្រោះអត្ថថា **កើត** ។ ជាតិនោះ ប្រកបដោយអាយតនៈដែលមិនបរិបូណ៌ ។ ដែលឈ្មោះថា **សញ្ជាតិ** ព្រោះអត្ថថា កើតព្រម ។ សញ្ជាតិនោះ ប្រកបដោយអាយតនៈដែលបរិបូណ៌ ។ ដែលឈ្មោះថា **ឱក្កន្តិ** ព្រោះអត្ថថា (កាន់) បដិសន្ធិ ។ បដិសន្ធិនោះ ប្រកបដោយអណ្ឌជកំណើត និងជលាពុជកំណើត ។ ទាំងពីរនោះ ឈានចុះកាន់សំបកពង និងស្បូន ។ កាលឈានចុះ រមែងបដិសន្ធិ ដូចជាចូលទៅ (ខាងក្នុង) ។ ដែលឈ្មោះថា **អភិនិព្វត្តិ** ព្រោះអត្ថថា កើតប្រាកដ ។ **អភិនិព្វត្តិ** នោះ រមែងប្រកបដោយសំសេទជកំណើត និងឱបបាតិកកំណើត ។ ទាំងពីរនោះកើតប្រាកដតែម្ដង ។ នេះជាវោហារទេសនាមុន ។

ឥឡូវនេះ ជាបរមត្ថទេសនា ។ ពិតហើយ កាលពោលដោយបរមត្ថ ខន្ធប៉ុណ្ណោះប្រាកដ សត្វមិនប្រាកដ ។ បណ្ដាបទទាំងនោះ គប្បីជ្រាបស័ព្ទថា **ខន្ធានំ** បានដល់ ខន្ធ ១ ក្នុងឯកវោការភព ខន្ធ ៤ ក្នុងចតុវោការភព ខន្ធ ៥ ក្នុងបញ្ចវោការភព ។ បទថា **បាតុភាវោ** ប្រែថា ការកើត ។ ក្នុងបទថា **អាយតនានំ** នេះ គប្បីជ្រាបការរួបរួមដោយអាយតនៈ ដែលកើតក្នុងភព នោះៗ ។ បទថា **បដិលាភោ** បានដល់ ការប្រាកដដោយសន្តតិនុ៎ះឯង ។ ពិតណាស់ អាយតនៈដែលកំពុងប្រាកដទាំងនោះឯង ដែលឈ្មោះថា បាន ចំពោះហើយ ។ ដោយបទថា **អយំ វុច្ចតិ ភិក្ខវេ ជាតិ** នេះ លោកធ្វើការ ពោលដដែលទៀតដល់ជាតិ ដែលទ្រង់សម្ដែងដោយបញ្ញត្តិ និងដោយបរមត្ថ នោះឯង ។

[៨] ក្នុង **ភវនិទ្ទេស** មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **កាមភវោ** បានដល់ កម្មភព និងឧប្បត្តិភព ។ ក្នុងភពទាំង ពីរនោះ ឈ្មោះថា **កម្មភព** បានដល់ កម្មដែលឲ្យកើតក្នុងកាមភពនុ៎ះឯង ។ ពិតណាស់ កម្មនោះ ព្រោះជាហេតុនៃឧប្បត្តិភព លោកទើបហៅថា ភព ដោយបញ្ញត្តិថា ជាតួផល ដូចពាក្យជាដើមថា **សុខោ ពុទ្ធានំ ឧប្បាទោ**

**ទុក្ខោ បាបស្ស ឧច្ចយោ** ការកើតឡើងនៃព្រះពុទ្ធ ជាហេតុនាំមកនូវសេចក្តីសុខ ការសន្សំបាប ជាហេតុនាំមកនូវទុក្ខ ។ ដែលឈ្មោះថា **ឧប្បត្តិភព** បានដល់ ខន្ធ ៥ ដែលមានចិត្តគ្រប់គ្រង ព្រោះកើតដោយកម្មនោះ ។ ពិតហើយ កម្មនោះ លោកហៅថា **ភព** ព្រោះកើតខន្ធ ៥ នោះ ។ សូម្បីក្នុងទីទាំងពួង ពោលសំដៅយកកម្មភព និងឧប្បត្តិភព ដូច្នេះ និងទាំងពីរនេះលោកពោលថា កាមភពក្នុងទីនេះ ។ ក្នុងរូបភព និងអរូបភពក៏ន័យនេះឯង ។

[៩] ក្នុង **ឧបាទាននិទ្ទេស** មានវិនិច្ឆ័យដូចតទៅនេះ ៖

ឈ្មោះថា **កាមុបាទាន** ក្នុងពាក្យថា **កាមុបាទានំ** ជាដើម ព្រោះជាហេតុប្រកាន់ក្នុងវត្ថុកាម ឬខ្លួនឯងប្រកាន់ក្នុងវត្ថុកាមនោះ កាមនោះផង ជាឧបាទានផង ដូច្នោះ ទើបឈ្មោះ **កាមុបាទាន** ។ ការប្រកាន់មាំ លោកហៅថា **ឧបាទាន** ពិតណាស់ **ឧប** ស័ព្ទ ក្នុងពាក្យថា **ឧបាទានំ** នេះ មានអត្ថថា **មាំ** ដូចក្នុង **ឧបាយាស** ស័ព្ទ និង **ឧបកដ្ឋ** ស័ព្ទជាដើម ។ ពាក្យថា **កាមុបាទាន** នេះ ជាឈ្មោះរបស់តម្រេកដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ។ ក្នុងទីនេះមានសេចក្តីសង្ខេបត្រឹមតែប៉ុណ្ណេះ តែកាលពោលដោយពិស្តារ

ឧបាទាននេះ គប្បីជ្រាបតាមន័យដែលពោលហើយថា ក្នុងឧបាទាន ២ យ៉ាងនោះ **កាមុបាទាន** ដូចជាម្ដេច ។ គឺ សេចក្ដីពេញចិត្ត ដោយអំណាចនៃសេចក្ដីប្រាថ្នាក្នុងកាមទាំងឡាយនុ៎ះឯង ។

ម្យ៉ាងទៀត ទិដ្ឋិនោះផង ជាឧបាទានផង ដូច្នោះទើបឈ្មោះថា **ទិដ្ឋុ-បាទាន** ម្យ៉ាងទៀត ឈ្មោះថា **ទិដ្ឋុបាទាន** ព្រោះប្រកាន់ដោយទិដ្ឋិ ឬជាហេតុប្រកាន់ដោយទិដ្ឋិ ។ ពិតហើយ **ឧត្តរទិដ្ឋិ** រមែងប្រកាន់ **បុរិមទិដ្ឋិ** ចេតសិក-ធម៌ទាំងឡាយ រមែងប្រកាន់ទិដ្ឋិដោយឧត្តរទិដ្ឋិនេះ ដូចដែលពោលថា អត្តានិងលោកទៀង ពាក្យនេះប៉ុណ្ណោះពិត ពាក្យដទៃជាមោឃៈ ។ បទថា **ទិដ្ឋុបាទាន** នេះ ជាឈ្មោះរបស់ **សីលព្វតុបាទាន អត្តវាទុបាទាន** និងទិដ្ឋិទាំងពួងដែលមានទោស ។ សេចក្ដីសង្ខេបក្នុងប្រការនេះ មានប៉ុណ្ណោះ ចំណែកសេចក្ដីពិស្ដារ **ទិដ្ឋុបាទាន** គប្បីជ្រាបដោយន័យដែលពោលហើយថា ក្នុងបណ្ដាឧបាទានទាំងនោះ **ទិដ្ឋុបាទាន** ដូចជាម្ដេច ។ គឺ ទានដែលបុគ្គលឲ្យហើយ រមែងមិនមានផល ដូច្នេះជាដើម ។

ម្យ៉ាងទៀត ដែលឈ្មោះថា **សីលព្វតុបាទាន** ព្រោះប្រកាន់មាំក្នុងសីលវត្តដោយទិដ្ឋិនោះ ឬប្រកាន់ដោយទិដ្ឋិនោះឯង , សីលវត្តនោះផង ជា

ឧបាទានផង ព្រោះដូច្នោះទើបឈ្មោះថា **សីលព្វតុបាទាន** ។ ដែលឈ្មោះថា **ឧបាទាន** ព្រោះប្រកាន់មាំថា សេចក្ដីបរិសុទ្ធិ រមែងមានដោយអាការយ៉ាងនេះ មានសីលគោ និងវត្តគោជាដើម ។ ក្នុងប្រការនោះ មានសេចក្ដីសង្ខេបត្រឹមតែប៉ុណ្ណោះ ចំណែកសេចក្ដីពិស្ដារ **សីលព្វតុបាទាន** នោះ គប្បីជ្រាបដោយន័យដែលពោលហើយថា ក្នុងឧបាទានទាំងនោះ **សីលព្វតុបា-ទាន** ដូចជាម្ដេច ។ គឺ សេចក្ដីបរិសុទ្ធិ ដោយសីលរបស់សមណៈ និងព្រាហ្មណ៍ ខាងក្រៅព្រះពុទ្ធសាសនានេះ ។

ឥឡូវនេះ ឈ្មោះថា **វាទៈ** ព្រោះហេតុពោលរបស់ពួកជន ។ ឈ្មោះថា **ឧបាទាន** ព្រោះជាហេតុប្រកាន់របស់ពួកជន ។ សួរថា ពោល ឬប្រកាន់អ្វី ។ ឆ្លើយថា ពោល ឬប្រកាន់ខ្លួន ។ ការប្រកាន់មាំវាទៈរបស់ខ្លួន ឈ្មោះថា **អត្តវាទុបាទាន** ។ម្យ៉ាងទៀត ត្រឹមតែវាទៈថា ខ្លួនប៉ុណ្ណោះ ឈ្មោះថា **អត្តវាទុបាទាន** ។ **អត្តវាទុបាទាន** នេះ ជាឈ្មោះរបស់ទិដ្ឋិមានវត្ថុ ២០ ។ ក្នុងប្រការនេះ មានសេចក្ដីសង្ខេបត្រឹមតែប៉ុណ្ណោះ ចំណែកកាលពោលដោយពិស្ដារ **អត្តវាទុបាទាន** នេះ គប្បីជ្រាបដោយន័យដែលពោលហើយថា ក្នុងឧបាទានទាំងនោះ **អត្តវាទុបាទាន** ដូចជាម្ដេច ។ គឺ បុថុជ្ជនអ្នកមិនបានស្ដាប់

ក្នុងព្រះសាសនានេះ មិនបានឃើញព្រះអរិយៈទាំងឡាយ ។

[១០] ក្នុង *តណ្ហានិទ្ទេស* មានវិនិច្ឆ័យដូចតទៅនេះ ៖

ពាក្យថា រូបតណ្ហា ។លៗ ធម្មតណ្ហា នេះ ជាឈ្មោះនៃតណ្ហាដែលប្រព្រឹត្តទៅក្នុងជវនវិថីក្នុងចក្ខុទ្វារជាដើម ដោយជាអារម្មណ៍ ដូចជាបិតា ដូចជាឈ្មោះចំណែកបិតា ក្នុងប្រយោគជាដើមយ៉ាងនេះថា បុត្ររបស់សេដ្ឋី បុត្ររបស់ព្រាហ្មណ៍ ។ ក៏ក្នុងទីនេះ តណ្ហាដែលមានរូបជាអារម្មណ៍ ឈ្មោះថា រូបតណ្ហា ព្រោះមានសេចក្តីចង់បានក្នុងរូប , តណ្ហានោះ ពេញចិត្តក្នុងរូប ប្រព្រឹត្តទៅដោយកាមរាគៈ ឈ្មោះថា **កាមតណ្ហា** , ដែលពេញចិត្ត ប្រព្រឹត្តទៅយ៉ាងនេះថា រូបទៀង ស្ថិតស្ថេរ ប្រព្រឹត្តទៅជាប់ត ជារាគៈដែលកើតរួមជាមួយទិដ្ឋិ ឈ្មោះថា **ភវតណ្ហា** , ដែលពេញចិត្ត ប្រព្រឹត្តទៅយ៉ាងនេះថា រូបដាច់សូន្យ វិនាស លះបង់ទៅហើយរមែងមិនកើតទៀត ឈ្មោះថា **វិភវតណ្ហា** រួមសេចក្តីថា រូបតណ្ហា មាន ៣ យ៉ាង ដោយប្រការដូច្នេះ ។ សូម្បីសទ្ទតណ្ហាជាដើម ក៏ដូចរូបតណ្ហា រួមសេចក្តីថា ជាតណ្ហាវិបរិត ១៨ ដោយប្រការដូច្នេះ , តណ្ហាវិបរិតទាំងនោះ ដែលប្រព្រឹត្តទៅក្នុងរូបខាងក្នុងជាដើម មាន ១៨ ដែលប្រព្រឹត្តទៅក្នុងរូបខាងក្រៅ ១៨ រួម ៣៦ , ជា

អតីត ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ , រួមជាតណ្ហាវិចរិត ១០៨ ដោយប្រការដូច្នេះ ។ តណ្ហាវិចរិត ១៨ ដែលអាស្រ័យរូប ប្រព្រឹត្តទៅក្នុងខាងក្នុងជាដើម មានជាអាទិយ៉ាងនេះថា ព្រោះអាស្រ័យអាយតនៈដែលប្រព្រឹត្តទៅខាងក្នុង តណ្ហាវិចរិតបានមានហើយ ឬថានឹងមាន ឬថាកំពុងមាន (មួយយ៉ាង ៦) ជាតណ្ហាវិចរិត ១៨ ដែលអាស្រ័យរូបប្រព្រឹត្តទៅក្នុងខាងក្រៅជាដើមថា ព្រោះអាស្រ័យអាយតនៈខាងក្រៅ ៦ តណ្ហាវិចរិតបានមានហើយ ដោយអាយតនៈខាងក្រៅនេះ ឬថានឹងមាន ឬថាកំពុងមាន ទើបរួមជាតណ្ហាវិចរិត ៣៦ ដូច្នោះ តណ្ហាវិចរិតដែលជាអតីត ៣៦ ដែលជាអនាគត ៣៦ ដែលជាបច្ចុប្បន្ន ៣៦ ទើបរួមជាតណ្ហាវិចរិត ១០៨ ។ កាលរួបរួមទៀត ក្នុងអារម្មណ៍ មានរូបជាដើម រមែងមានពួកនៃតណ្ហា ៦ មានកាមតណ្ហាជាដើម ៣ ទុះឯង កាលនឹងរួមដោយពិស្តារ និងដោយសង្ខេបរបស់និទ្ទេសទៀត បណ្ឌិតគប្បីជ្រាប តណ្ហាដោយអត្ថនៃនិទ្ទេសយ៉ាងនេះដោយប្រការដូច្នេះឯង ។

[១១] ក្នុង *វេទនានិទ្ទេស* មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា *វេទនាកាយា* ប្រែថា ពួកនៃវេទនា ។ ពាក្យថា **ចក្ខុសម្ផស្ស-**

ជាវេទនា ។ល។ មនោសម្ផស្សជាវេទនា នេះ ជាឈ្មោះរបស់វេទនាដែល ជាកុសល អកុសល និងអព្យាកតៈ ដែលប្រព្រឹត្តទៅក្នុងចក្ខុទ្វារជាដើម ព្រោះមកក្នុងវិភង្គយ៉ាងនេះថា ចក្ខុសម្ផស្សជាវេទនា ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន មានឈ្មោះដោយវត្ថុ ដូចមាតា ដូចជាឈ្មោះចំណែកមាតា ដែលមកក្នុងប្រយោគយ៉ាងនេះ មានជាអាទិ៍ថា បុត្ររបស់នាងព្រាហ្មណី ឈ្មោះថា សារី , បុត្ររបស់ព្រាហ្មណី ឈ្មោះថា មន្តានី ។ ក៏ក្នុងទីនេះ មានអត្ថនៃពាក្យដូចតទៅនេះ វេទនាដែលកើតអំពីហេតុ គឺ ចក្ខុសម្ផស្ស ឈ្មោះថា ចក្ខុសម្ផស្សជាវេទនា ។ ក្នុងបទទាំងពួងក៏ន័យនេះដូចគ្នា ក្នុងប្រការនេះមានកថារួបរួមវេទនាទាំងពួង ជាលដាប់ដំបូងតែពោលដោយអំណាចវិបាក គប្បីជ្រាបវេទនាដោយអំណាចសម្បយុត្តជាមួយចិត្តទាំងនេះ គឺ ក្នុងចក្ខុទ្វារ ចក្ខុវិញ្ញាណ ២ មនោធាតុ ២ មនោវិញ្ញាណធាតុ ៣ ។ ក្នុងសោតទ្វារជាដើម ក៏ន័យនេះ ។ និងក្នុងមនោទ្វារប្រកបជាមួយមនោវិញ្ញាណធាតុ ។

[១២] ក្នុង ផស្សនិទ្ទេស មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា ចក្ខុសម្ផស្សោ បានដល់ ផស្សៈក្នុងចក្ខុ ។ ក្នុងបទទាំងពួង

ក៏មានន័យនេះ ។ ដោយលំដាប់ពាក្យត្រឹមតែប៉ុណ្ណេះថា **ចក្ខុសម្ផស្សោ** ។ល។ **កាយសម្ផស្សោ** គឺ លោកពោលផស្សៈ ១០ ដែលមានវត្ថុ ៥ ជាកុសលវិបាក និងអកុសលវិបាក ។ បទថា **មនោសម្ផស្សោ** នេះ លោកពោលផស្សៈដែលសម្បយុត្តដោយវិបាកចិត្តដែលជាលោកិយៈ ២២ ដ៏សេស ។

[១៣] ក្នុង **សឡាយតននិទ្ទេស** មានវិនិច្ឆ័យដូចតទៅនេះ ៖

ក្នុងបទថា **ចក្ខាយតនំ** ជាដើម ពាក្យដែលត្រូវពោល លោកពោលទុកហើយក្នុងខន្ធនិទ្ទេស និងអាយតននិទ្ទេស ក្នុងវិសុទ្ធិមគ្គនុ៎ះឯង ។

[១៤] ក្នុង **នាមរូបនិទ្ទេស** មានវិនិច្ឆ័យដូចតទៅនេះ ៖

**នាម** មានការបង្អោនទៅជាលក្ខណៈ , **រូប** មានការបែកធ្លាយជាលក្ខណៈ ។ ក៏ក្នុងការចែកនាមរូបនោះ បទថា **វេទនា** បានដល់ វេទនាខន្ធ ។ បទថា **សញ្ញា** បានដល់ សញ្ញាខន្ធ ។ បទថា **ចេតនា ផស្សៈ មនសិការ** គប្បីជ្រាបថា ជាសង្ខារក្ខន្ធ ។ ក៏ធម៌ដែលសង្គ្រោះដោយសង្ខារក្ខន្ធ សូម្បីដទៃមានហើយក៏ពិត សូម្បីដូច្នោះ ធម៌ ៣ ប្រការនេះ មាននៅក្នុងចិត្តដែលមានកម្លាំងខ្សោយជាងធម៌ទាំងពួង ព្រោះដូច្នោះ ក្នុងទីនេះលោកសម្តែងសង្ខារក្ខន្ធដោយអំណាចធម៌ទាំងនោះឯង ។ បទថា **ចត្តារោ** ក្នុងបទថា **ចត្តា-**

**ភោ ច មហាភូតា** នេះ ជាការកំណត់ចំនួន ។ បទថា **មហាភូតា** នេះ ជាឈ្មោះរបស់បឋវីធាតុ អាបោធាតុ តេជោធាតុ និងវាយោធាតុ ។ ក៏ន័យវិនិច្ឆ័យម្យ៉ាងក្នុងប្រការជាហេតុឲ្យលោកពោលថា **តានិ មហាភូតានិ** ទាំងអស់លោកពោលទុកហើយក្នុងរូបក្ខន្ធនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ក៏បទថា **ចតុន្នំ** ក្នុងពាក្យថា **ចតុន្នញ្ច មហាភូតានំ ឧបាទាយ** នេះ ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃទុតិយាវិភត្តិ លោកអធិប្បាយថា មហាភូតរូប ៤ ។ បទថា **ឧបាទាយ** ប្រែថា ប្រកាន់មាំ អធិប្បាយថា ប្រកាន់មាំ អាចារ្យពួកខ្លះពោលថា អាស្រ័យក៏មាន ។ ក៏បាឋៈដ៏សេសថា **បវត្តមានំ** នេះ គប្បីនាំមកភ្ជាប់ចូលក្នុងទីនេះ ។ ម្យ៉ាងទៀត ពាក្យនេះជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថថា ប្រជុំ គប្បីជ្រាបខ្លឹមសារដូច្នេះថា រូបអាស្រ័យការប្រជុំនៃមហាភូតរូប ៤ ប្រព្រឹត្តទៅ ។ កាលពោលដោយប្រការទាំងពួង មហាភូតរូប ៤ មានបឋវីជាដើម និងរូប ២៣ ដែលអាស្រ័យមហាភូតរូប ៤ ប្រព្រឹត្តទៅ លោកពោលទុកក្នុងបាលីក្នុងអភិធម្ម ដោយចែកជាចក្ខាយតនៈជាដើម ទាំងអស់នោះ គប្បីជ្រាបថា រូប ។

[១៥] ក្នុង *វិញ្ញាណនិទ្ទេស* មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **ចក្ខុវិញ្ញាណំ** សេចក្ដីថា ដែលឈ្មោះថា ចក្ខុវិញ្ញាណ ព្រោះវិញ្ញាណអាស្រ័យចក្ខុ ឬវិញ្ញាណកើតពីចក្ខុ ។ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណក៏ដូចគ្នា ។ តែវិញ្ញាណមួយទៀត ឈ្មោះថា មនោវិញ្ញាណ ព្រោះអត្ថថា វិញ្ញាណ គឺ ចិត្ត ។ ពាក្យនេះ ជាឈ្មោះរបស់វិបាកចិត្ត ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ វៀរទ្វិបញ្ចវិញ្ញាណ ។

[១៦] ក្នុង **សង្ខារនិទ្ទេស** មានវិនិច្ឆ័យដូចតទៅនេះ ៖

**សង្ខារ** មានការតាក់តែងជាលក្ខណៈ ក៏ក្នុងការបែកសង្ខារនោះ មានអធិប្បាយដូច្នេះ សង្ខារដែលប្រព្រឹត្តទៅផ្សវកាយ ឈ្មោះ **កាយសង្ខារ** ។ ពាក្យថា កាយសង្ខារនេះ ជាឈ្មោះនៃកាយសញ្ចេតនា ២០ គឺ ចំណែកកាមាវចរកុសលចិត្ត ៨ ចំណែកអកុសលចិត្ត ១២ ដែលប្រព្រឹត្តទៅដោយអំណាចកម្រើកកាយទ្វារ ។ ពាក្យថា **វចីសង្ខារ** នេះ ជាឈ្មោះនៃវចីសញ្ចេតនា ២០ ដូចគ្នា ។ ដែលប្រព្រឹត្តទៅដោយអំណាចការថ្លែងវាចា ក្នុងវចីទ្វារ ។ សង្ខារដែលប្រព្រឹត្តទៅផ្សវចិត្ត ឈ្មោះថា ចិត្តសង្ខារ ។ ពាក្យថា **ចិត្តសង្ខារ** នេះ ជាឈ្មោះនៃមនោសញ្ចេតនា ២៩ គឺ កុសលចិត្ត ១៧ អកុសលចិត្ត ១២ ដែលជាចំណែកលោកិយៈ ដែលប្រព្រឹត្តទៅដល់បុគ្គល

មិនធ្វើការកម្រើកក្នុងកាយទ្វារ និងវចីទ្វារ អគ្គិយគិតនៅក្នុងទីកំបាំង ។

[១៧] ក្នុង អវិជ្ជានិទ្ទេស មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា ទុក្ខេ អញ្ញាណំ បានដល់ ការមិនដឹងក្នុងទុក្ខសច្ចៈ ពាក្យនេះជាឈ្មោះរបស់មោហៈ ។ ក្នុងពាក្យថា សមុទយេ អញ្ញាណំ ជាដើម ក៏ន័យនេះដូចគ្នា ។ ក្នុងសច្ចៈ ៤ នោះ គប្បីជ្រាបការមិនដឹងក្នុងទុក្ខសច្ចៈដោយហេតុ ៤ គឺ ដោយការៈដែលធ្លាក់ចុះក្នុងខាងក្នុង ដោយវត្ថុ ដោយអារម្មណ៍ និងដោយការបិទបាំង ។ ពិតយ៉ាងនោះ ការមិនដឹងនោះ ឈ្មោះថា ទុក្ខសច្ចៈ ព្រោះធ្លាក់ចុះក្នុងខាងក្នុងទុក្ខ ព្រោះរាប់បញ្ចូលក្នុងទុក្ខសច្ចៈ ឈ្មោះថា ជាវត្ថុ ព្រោះជានិស្សយប្បច្ច័យនៃទុក្ខសច្ចៈនោះ ឈ្មោះថា ជាអារម្មណ៍ ព្រោះជាអារម្មណប្បច្ច័យ ការមិនដឹងនោះ រមែងបិទបាំងទុក្ខសច្ចៈ ដោយហាមការចាក់ធ្លុះលក្ខណៈតាមសេចក្ដីពិតរបស់ទុក្ខសច្ចៈនោះ និងដោយប្រាសចាកការប្រព្រឹត្តទៅនៃញាណ ក្នុងប្រការនេះ ។

គប្បីជ្រាបការមិនដឹងក្នុងសមុទយសច្ចៈ ដោយហេតុ ៣ គឺ ដោយវត្ថុ ដោយអារម្មណ៍ និងដោយការបិទបាំង ។ គប្បីជ្រាបការមិនដឹងក្នុងនិរោធ-ប្បដិបទា ដោយហេតុតែម្យ៉ាងប៉ុណ្ណោះ គឺ ដោយការបិទបាំង ។ ពិតណាស់

ការមិនដឹង ដែលបិទបាំងនិរោធប្បដិបទានុ៎ះឯង ដោយហាមការចាក់ចុះលក្ខណៈ តាមសេចក្តីពិតរបស់បដិបទាទាំងនោះ និងដោយប្រាសចាកការប្រព្រឹត្តទៅនៃញាណក្នុងបដិបទាទាំងនោះ ការមិនដឹងនុ៎ះ មិនបានធ្លាក់ចុះក្នុងខាងក្នុងក្នុងបដិបទាទាំងនោះ ព្រោះមិនរាប់បញ្ចូលក្នុងសច្ចៈទាំងពីរនោះ សច្ចៈទាំងពីរនោះ មិនបានជាវត្ថុ ព្រោះមិនបានកើតរួមគ្នា មិនបានជាអារម្មណ៍ ព្រោះមិនបានប្រារព្ធវត្ថុនោះប្រព្រឹត្តទៅ ។ ក៏សច្ចៈទាំងពីរខាងចុង ឃើញបានលំបាក ព្រោះជ្រាលជ្រៅ ការមិនដឹងដែលងងឹត រមែងមិនប្រព្រឹត្តទៅក្នុងសច្ចៈទាំងពីរនោះ ។ ក៏សច្ចៈប្រការដំបូង ឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញសភាវៈលក្ខណៈដោយអត្ថដែលគួរពោលបានលំបាក រមែងប្រព្រឹត្តទៅក្នុងការមិនដឹងនោះ ព្រោះប្រកាន់យៀងឃ្លាតពីសេចក្តីពិត ។

មួយទៀត ត្រឹមតែបទថា **ទុក្ខេ** នេះ លោកសម្តែងអវិជ្ជា ដោយរួបរួមដោយវត្ថុ ដោយអារម្មណ៍ និងដោយកិច្ច ។ ត្រឹមតែបទថា **ទុក្ខសមុទយេ** នេះ លោកសម្តែងដោយវត្ថុ ដោយអារម្មណ៍ និងដោយកិច្ច ។ ត្រឹមតែបទថា **ទុក្ខនិរោធគាមិនិយា បដិបទា** នេះ លោកសម្តែងដោយកិច្ច ។ តែដោយមិនពិសេស ដោយបទថា **អញ្ញាណំ** នេះ គប្បីជ្រាបថា លោកសម្តែង

អធិប្បាយអវិជ្ជាដោយសការៈ ។

បទថា **ឥតិ ខោ ភិក្ខវេ** ប្រែថា ម្នាលភិក្ខុទាំងឡាយ ដោយប្រការយ៉ាងនេះឯង ។ បទថា **បិរោធោ ហោតិ** បានដល់ មិនកើតឡើង ។ មួយទៀត ដោយបទថា **និរោធ** ទាំងនោះគ្រប់បទក្នុងទីនេះ លោកសម្តែងដល់ព្រះនិព្វាន ។ សេចក្តីថា ធម៌នោះៗ អាស្រ័យព្រះនិព្វាន រលត់ទៅ ដូច្នោះ ព្រះនិព្វាននោះ លោកទើបពោលថា **តេសំ និរោធោ** ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងវដ្តៈ និងវិវដ្តៈ ដោយ ១២ បទ ក្នុងព្រះសូត្រនេះ ទើបឲ្យទេសនាចប់ស្រេចដល់កំពូលនៃព្រះអរហត្តនុ៎ះឯង ។ ក្នុងវេលាចប់ទេសនា ភិក្ខុ ៥០០ រូប សម្រេចព្រះអរហត្ត ដោយន័យដូចពោលហើយនុ៎ះឯង ។

ចប់អដ្ឋកថា វិភង្គសូត្រទី ២

# អ ដ្ឋ ក ថា

## បដិបទាសូត្រទី ៣

[១៩] ក្នុង បដិបទាសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **មិច្ឆាបដិបទំ** សេចក្ដីថា នេះជាបដិបទាមិននាំសត្វចេញចាកទុក្ខ ជាលំដាប់ដំបូង ។ សួរថា ក៏ព្រោះអវិជ្ជាជាបច្ច័យ ទើបមានបុញ្ញាភិសង្ខារខ្លះ អនេញ្ជាភិសង្ខារខ្លះ មិនមែនឬ ។ អភិសង្ខារទាំងពីរនោះ ជាមិច្ឆាបដិបទា ដូចម្ដេច ។ ឆ្លើយថា ព្រោះរាប់ថា ជាវដ្ដៈ ។ វត្ថុណាមួយដែលបុគ្គលប្រាថ្នាវដ្ដៈ ពោលគឺ ភព ៣ បដិបត្តិដោយទីបំផុតអភិញ្ញា ៥ ឬសមាបត្តិ ៨ វត្ថុទាំងអស់ប្រព្រឹត្តទៅក្នុងចំណែកវដ្ដៈ ចាត់ជាមិច្ឆាបដិបទា ព្រោះជាវដ្ដៈ ។ វត្ថុណាមួយដែលបុគ្គលប្រាថ្នាវិវដ្ដៈ គឺ ព្រះនិព្វាន បដិបត្តិដោយទីបំផុតថ្វាយទានត្រឹមតែបាយយាគូមួយវែកក្ដី ត្រឹមតែថ្វាយស្លឹកឈើមួយក្ដាប់ក្ដី វត្ថុទាំងអស់នោះចាត់ជាសម្មាបដិបទាដោយពិត ព្រោះជាចំណែកវិវដ្ដៈ បុគ្គលមិនសម្រេចព្រះអរហត្ត ហើយទីងដល់ទីបំផុតមិនមាន ដូច្នោះគប្បីជ្រាបថា លោកសម្ដែងមិច្ឆាបដិបទាដោយអំណាចអនុលោម សម្ដែង

សម្មាបដិបទាដោយអំណាចបដិលោម ។

[២០] សួរថា ក៏ក្នុងទីនេះ លោកសួរបដិបទា បែកព្រះនិព្វាន កំណត់បដិបទាសួម្បីក្នុងការឆ្លើយ និងបទថា **បដិបទា** មិនមែនជាឈ្មោះនៃព្រះនិព្វាន តែពាក្យថា **បដិបទា** នេះ ជាឈ្មោះរបស់មគ្គ ៤ ព្រមដោយវិបស្សនា ព្រោះដូច្នោះ បទភាជនៈទើបសមគួរដោយការសួរការឆ្លើយ មិនមែនឬ ។ ឆ្លើយថា មិនមែន ។ ព្រោះហេតុអ្វី ។ ព្រោះលោកសម្តែងបដិបទាដោយផលពិតណាស់ ក្នុងទីនេះលោកសម្តែងបដិបទាដោយផល ។ សេចក្តីក្នុងពាក្យថា ព្រោះអវិជ្ជានុ៎ះឯង រលត់ទៅដោយមិនមានសេសសល់ សង្ខារទើបរលត់ នេះ មានអធិប្បាយដូច្នេះ **និព្វាន** ពោលគឺ ការរលត់ស្និទ្ធនេះ ជាផលរបស់បដិបទាណា ម្នាលភិក្ខុទាំងឡាយ បដិបទានេះតថាគតហៅថា **សម្មាបដិ-បទា** ។ ក៏ក្នុងអត្ថនេះ **វិរាគៈ** ក្នុងពាក្យថា **អសេសវិរាគនិរោធា** នេះ ជាវេវចនៈនៃការរលត់ស្និទ្ធនុ៎ះឯង ។ ក៏ក្នុងពាក្យថា **អសេសវិរាគា អសេ-សនិរោធា** នេះ មានអធិប្បាយដូចតទៅនេះ មា្យ៉ាងទៀត ដើម្បីសម្តែងមគ្គពោលគឺ **វិរាគៈ** ដែលជាហេតុរលត់ស្និទ្ធដោយមិនមានសេសសល់ ព្រះមាន-ព្រះភាគទើបត្រាស់បទភាជនៈនេះថា បើដូច្នេះ បដិបទាដែលប្រព្រឹត្តទៅ

ជាមួយអានុភាព ព្រះអង្គទ្រង់បែកហើយ ។ ដូច្នោះ ព្រះអង្គទើបត្រាស់ចំពោះវដ្តៈ និងវិវដ្តៈ សូម្បីនេះប៉ុណ្ណោះឯង ។

ចប់អដ្ឋកថា បដិបទាសូត្រទី ៣

# អ ដ្ឋ ក ថា

## វិបស្សីសូត្រទី ៤

[២២] ក្នុង *វិបស្សីសូត្រទី ៤* មានវិនិច្ឆ័យដូចតទៅនេះ ៖

*បទថា **វិបស្សិស្ស** សេចក្ដីថា បានឮថា គ្រាប់ភ្នែកទាំងឡាយរបស់លោកិយមនុស្សដែលសម្លឹងមើលអ្វីៗ រមែងត្រឡប់ទៅមក ព្រោះចក្ខុ-បសាទដែលកើតពីកម្ម ដែលបង្កើតពីកម្មតិចតួច មានកម្លាំងខ្សោយ យ៉ាងណា តែគ្រាប់ភ្នែករបស់ព្រះពោធិសត្វនោះមិនដូច្នោះទេ ព្រោះចក្ខុបសាទដែលកើតពីកម្ម បង្កើតពីកម្មមានកម្លាំង មានកម្លាំងច្រើន ព្រះអង្គទើបសម្លឹងមើលដោយកែវភ្នែក ដែលមិនត្រឡប់ចុះឡើង មិនប៉ប្រិចនុ៎ះឯង ដូចទេវតាក្នុងភពតាវត្តិង្សដូច្នោះ ព្រោះហេតុនោះ លោកទើបពោលថា ព្រះកុមារសម្លឹងមើលដោយមិនប៉ប្រិច ព្រោះដូច្នោះ ព្រះវិបស្សីកុមារនោះ ទើបកើតសមញ្ញា (ព្រះនាម) ថា **វិបស្សី វិបស្សី** នុ៎ះឯង ។ ពិតណាស់ ក្នុងសេចក្ដីនេះ មានអធិប្បាយដូច្នេះ ឈ្មោះថា **វិបស្សី** ព្រោះឃើញសេចក្ដីបរិសុទ្ធិម្យ៉ាងទៀត ឈ្មោះថា **វិបស្សី** ព្រោះឃើញដោយព្រះនេត្រដែលបើក ។ ក៏*

ក្នុងទីនេះ ព្រះនេត្ររបស់ព្រះពោធិសត្វទាំងអស់ ដែលកើតក្នុងភពចុងក្រោយ រមែងមិនត្រឡប់ចុះឡើង ព្រោះបសាទដែលកើតពីកម្មមានកម្លាំង មានកម្លាំងខ្លាំង ។ ក៏ព្រះពោធិសត្វនោះ រមែងមានព្រះនាមដោយហេតុនោះឯង ។ ម្យ៉ាងទៀត ឈ្មោះថា **វិបស្សី** ព្រោះពិចារណាឃើញ អធិប្បាយថា ព្រោះពិចារណាទើបឃើញ ។

បានឮថា ថ្ងៃមួយ អាមាត្រទាំងឡាយនាំព្រះមហាបុរសដែលប្រដាប់តាក់តែងព្រះវរកាយហើយ មកដាក់លើភ្លៅរបស់ព្រះរាជាដែលប្រថាប់អង្គុយពិចារណាក្តីនៅក្នុងសាលាក្តី កាលព្រះរាជាទ្រង់ពេញព្រះទ័យ ដែលបានមហាបុរសនោះនៅលើភ្លៅ អាមាត្រទាំងឡាយបានធ្វើម្ចាស់ទ្រព្យ មិនឲ្យជាម្ចាស់ទ្រព្យ ។ ព្រះពោធិសត្វទ្រង់បន្លឺសំឡេង សម្តែងសេចក្តីមិនពេញព្រះទ័យ ។ ព្រះរាជាត្រាស់ថា ពួកលោកពិចារណាឡើងវិញមើល ឬថារឿងនោះដូចម្តេច រឿងនេះដូចម្តេច ។ ពួកអាមាត្រកាលពិចារណាឡើងវិញក៏មិនឃើញករណីជាយ៉ាងដទៃ ទើបគិតថា ប្រហែលជាការធ្វើទៅហើយយ៉ាងនេះ នឹងជាការវិនិច្ឆ័យក្តីដែលមិនត្រូវ ។ ទើបធ្វើអ្នកជាម្ចាស់ទ្រព្យ ឲ្យជាម្ចាស់ទ្រព្យទៀត កាលសាកល្បងថា កុមារនឹងដឹងឬហ្ន៎ ទើបធ្វើយ៉ាងនេះ ។

ទើបធ្វើម្ចាស់ទ្រព្យ មិនឲ្យជាម្ចាស់ទ្រព្យទៀត ។ គ្រានោះ ព្រះរាជាទ្រង់ព្រះរាជតម្រិះថា ព្រះមហាបុរសគង់នឹងដឹង តាំងពីនោះមក ទើបជាអ្នកមិនប្រយ័ត្ន ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ព្រះកុមារពិចារណាហើយ ពិចារណាទៀតទើបដឹងក្តី ព្រោះហេតុនោះឯង ម្នាលភិក្ខុទាំងឡាយ ព្រះកុមារនោះ ទើបកើតព្រះនាមប្រមាណដ៏យ៉ាងក្រៃលែងថា **វិបស្សី** នោះឯង ។

បទថា **ភគវតោ** ប្រែថា អ្នកដល់ព្រមដោយភាគ្យៈ ។ បទថា **អរហតោ** បានដល់ អ្នកមានព្រះនាមដែលកើតឡើងដោយគុណយ៉ាងនេះថា ឈ្មោះថា **អរហា** ព្រោះកម្ចាត់កិលេសដូចជាសឹកសត្រូវ មានរាគៈជាដើមចេញបាន ព្រោះទ្រង់កាច់បំបាក់កាំនៃសង្សារចក្រ ឬព្រោះជាអ្នកគួរដល់បច្ច័យទាំងឡាយ ។ បទថា **សម្មាសម្ពុទ្ធស្ស** បានដល់ អ្នកត្រាស់ដឹងសច្ចៈ ៤ ដោយសេចក្តីព្យាយាមរបស់បុរស ដោយព្រះអង្គឯង ចំពោះព្រះអង្គដោយប្រពៃ ដោយន័យ ដោយហេតុ ។ បទថា **បុព្វេវ សម្ពោធា** សេចក្តីថា ញាណក្នុងមគ្គ ៤ លោកហៅថា **សម្ពោធៈ** ត្រាស់ដឹងព្រម , មុនការត្រាស់ដឹងនោះឯង ។ បទថា **ពោធិ** ក្នុងពាក្យថា **ពោធិសត្តស្សេវ**

**សត្តោ** នេះ បានដល់ **ញាណ** , សត្វអ្នកត្រាស់ដឹង ឈ្មោះថា **ពោធិសត្វ** អធិប្បាយថា អ្នកមានញាណ គឺ អ្នកមានបញ្ញា ឈ្មោះថា **បណ្ឌិត** ។ ពិតណាស់ សត្វនោះជាបណ្ឌិត ចាប់ផ្ដើមតាំងពីទ្រង់មានអភិនិហារទៀបបាទមូលនៃព្រះពុទ្ធទាំងឡាយ មិនមែនអន្ធពាល ព្រោះដូច្នោះ ទើបឈ្មោះថា **ព្រះ-ពោធិសត្វ** ម្យ៉ាងទៀត ឈ្មោះថា ពោធិសត្វ ព្រោះជាសត្វអ្នករីករាយ ដោយអត្ថវិគ្រោះថា បំពេញព្រះបារមីហើយនឹងរីករាយ ដោយរកអន្តរាយមិនបានយ៉ាងពិត ព្រោះបានពាក្យព្យាករណ៍ក្នុងសម្នាក់នៃព្រះពុទ្ធទាំងឡាយ ប្រៀបដូចផ្កាបទុមដែលផុសឡើងពីទឹកតាំងនៅ បានដល់ នឹងរីកហើយដោយសម្ផស្សព្រះអាទិត្យយ៉ាងពិត ព្រោះដូច្នោះ លោកទើបហៅថា ផ្កាបទុមរីក ។ មួយទៀត សត្វប្រាថ្នាពោធិ ពោលគឺ ញាណក្នុងមគ្គ ៤ បដិបត្តិហើយ ហេតុនោះ អ្នកដែលនៅជាប់នៅក្នុងពោធិ ទើបឈ្មោះថា **ពោធិសត្វ** ដូច្នេះក៏មាន ។ កាលព្រះពោធិសត្វមានហើយ ដោយព្រះនាមដែលកើតឡើងដោយប្រការដូច្នេះ ។ បទថា **កិច្ឆំ** ប្រែថា លំបាក ។ បទថា **អាបន្នោ** ប្រែថា ដល់ហើយរឿយៗ ។ លោកពោលអធិប្បាយទុកថា គួរអនាថៈ សត្វលោកនេះដល់នូវសេចក្ដីលំបាករឿយៗ ។ បទថា **ចវតិ ច ឧប្បជ្ជតិ ច** នេះ លោក

ពោលដោយអំណាចចុតិ និងបដិសន្ធិទៅមករឿយៗ ។ បទថា **និស្សរណំ** បានដល់ ព្រះនិព្វាន ។ ពិតហើយ ព្រះនិព្វាននោះ លោកហៅថា និស្សរណៈ ព្រោះរលាស់ចេញចាកទុក្ខ គឺ ជរា និងមរណៈ ។ បទថា **កុទាស្សុ នាម** បានដល់ ក្នុងកាលណាៗ នោះឯង ។

[២៣] បទថា **យោនិសោមនសិការា**[១] បានដល់ ព្រោះការធ្វើទុកក្នុងចិត្តដោយឧបាយ គឺ ការធ្វើទុកក្នុងចិត្តគ្រាដំបូង ។ បទថា **អហុ បញ្ញាយ អភិសមយោ** សេចក្ដីថា បានដល់ ការត្រាស់ដឹង គឺ ការប្រកបត្រូវនូវហេតុនៃជរា និងមរណៈដោយបញ្ញា អធិប្បាយថា ព្រះអង្គឃើញដូច្នេះថា ព្រោះជាតិជាបច្ច័យ ទើបមានជរា និងមរណៈ ។ម្យ៉ាងទៀត បទថា **យោនិសោមនសិការា អហុ បញ្ញាយ** បានដល់ បានត្រាស់ដឹង ដោយយោនិសោមនសិការ និងដោយបញ្ញា ។ អធិប្បាយថា បានចាក់ធ្លុះហេតុនៃជរា និងមរណៈយ៉ាងនេះថា កាលការកើតមានហើយ ជរា និងមរណៈក៏មាន ។ ក្នុងបទទាំងពួង ក៏ន័យនេះ ។

បទថា **ឥតិ ហិទំ** ស្មើនឹង **ឯវមិទំ** វត្ថុនេះមានដោយប្រការដូច្នេះ ។ ដោយបទថា **សមុទយោ** នេះ លោកប្រមូលការកើតឡើងនៃសង្ខារជាដើម

សម្ដែងក្នុងឋានៈ ១១ ។ បទថា **បុព្វេ អននុស្សុតេសុ** សេចក្ដីថា ក្នុងធម៌ដែលមិនធ្លាប់បានស្ដាប់មកអំពីមុន យ៉ាងនេះថា ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ការកើតឡើងរបស់សង្ខាររមែងមាន ព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះ ឬក្នុងអរិយសច្ចធម៌ ៤ ។ បទថា **ចក្ខុំ** ជាដើម ជាវេវចនៈរបស់ញាណនុ៎ះឯង ។ ពិតណាស់ ក្នុងទីនេះ ញាណនុ៎ះឯង លោកពោលថា **ចក្ខុ** ព្រោះអត្ថថា ឃើញ , ពោលថា **ញាណ** ព្រោះអត្ថថា ដឹង , ពោលថា **បញ្ញា** ព្រោះអត្ថថា ដឹងច្បាស់ , ពោលថា **វិជ្ជា** ព្រោះអត្ថថា ចាក់ធ្លុះ , ពោលថា **អាលោកៈ** ព្រោះអត្ថថា ភ្លឺស្វាង ។ ក៏ញាណនេះ គប្បីជ្រាបថា លោកបង្ហាញថា មានទាំងលោកិយៈ និងលោកុត្តរៈក្នុងសច្ចៈ ៤ ។ សូម្បីក្នុងនិរោធវារៈ គប្បីជ្រាបសេចក្ដីដោយន័យនេះឯង ។

ចប់អដ្ឋកថា វិបស្សីសូត្រទី ៤

# អ ដ្ឋ ក ថា

## សិខីសូត្រជាដើម (៥-១០)

[២៥] ក្នុង *សិខីសូត្រទី ៥ ជាដើម* មានវិនិច្ឆ័យដូចតទៅនេះ ៖

*អត្ថនៃបទថា **សិខិស្ស ភិក្ខវេ** ជាដើម គប្បីពោលសេចក្តីប្រកប យ៉ាងនេះថា **សិខិស្សបិ ភិក្ខវេ** ។ ព្រោះហេតុអ្វី ព្រោះមិនសម្តែងក្នុងអាសនៈ តែមួយ ។ ពិតណាស់ ព្រះសូត្រទាំងនេះ ទ្រង់សម្តែងទុកក្នុងឋានៈផ្សេងៗ តែខ្លឹមសារដូចគ្នាគ្រប់កន្លែង សេចក្តីពិត កាលព្រះពោធិសត្វគ្រប់ៗ ព្រះអង្គ ប្រថាប់អង្គុយត្រង់ពោធិបល្ល័ង្ក បុគ្គលដទៃមិនថាជាសមណៈក្តី ព្រាហ្មណ៍ ក្តី ទេវតាក្តី ព្រហ្មក្តី មិនបានប្រាប់ថា ព្រះពោធិសត្វក្នុងអតីត ពិចារណា បច្ចយាការហើយជាព្រះពុទ្ធ ។ ដូចជាព្រះពុទ្ធព្រះអង្គក្រោយៗ រមែងដំណើរ ទៅតាមផ្លូវដែលព្រះពុទ្ធមុនៗ ទាំងនោះដំណើរទៅហើយ ដូចកាលភ្លៀង ធ្លាក់ក្នុងគ្រាបឋមកប្ប សូម្បីទឹកភ្លៀង ក៏រមែងហូរទៅតាមផ្លូវដែលទឹកហូរ ទៅហើយនោះឯង ។ ពិតហើយ ព្រះពោធិសត្វគ្រប់ព្រះអង្គ ចេញចាកចតុ-ត្ថជ្ឈានដែលមានខ្យល់ដកដង្ហើមចេញចូលជាអារម្មណ៍ ធ្វើញាណឲ្យចុះកាន់*

ក្នុងបច្ចយាការ ពិចារណាបច្ចយាការនោះ ដោយអនុលោម និងបដិលោម រមែងត្រាស់ព្រះពុទ្ធ ដូច្នោះ លោកទើបពោលឲ្យឈ្មោះថា **ពុទ្ធវិបស្សនា** ក្នុង ៧ សូត្រ តាមលំដាប់នុ៎ះឯង ។

ចប់អដ្ឋកថា សិវិសូត្រទី ៥ ជាដើម

## ចប់ពុទ្ធវគ្គ ទី ១

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថាទេសនាសូត្រ
២-អដ្ឋកថាវិភង្គសូត្រ
៣-អដ្ឋកថាបដិបទាសូត្រ
៤-អដ្ឋកថាវិបស្សីសូត្រ
៥-អដ្ឋកថាសិវិសូត្រជាដើម

# អាហារវគ្គទី ២

## អ ដ្ឋ ក ថា

### អាហារសូត្រទី ១

[២៨] អាហារសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **អាហារា** បានដល់ បច្ច័យ ។ ពិតហើយ បច្ច័យលោកហៅថា អាហារ ព្រោះនាំផលឲ្យដល់ខ្លួន ។ ក្នុងបទថា **ភូតានំ វា សត្តានំ** ជាដើម គប្បីជ្រាបខ្លឹមសារដូចតទៅនេះ ។ បទថា **ភូតា** បានដល់ កើតហើយ គឺ បង្កើតហើយ ។ បទថា **សម្ភវេសិនោ** បានដល់ ពួកសត្វអ្នកស្វែងរក ស្វែងរកសម្ភពទីកើត ។ បណ្តាកំណើតទាំង ៤ នោះ អណ្ឌជសត្វ ជលាពុជសត្វ នៅទម្លាយសំបកពង និងពងមិនបាននៅដរាបណា ឈ្មោះថា **សម្ភវេសី** (អ្នកស្វែងរកកពទីកើត) ដរាបនោះ ។ ពួកសត្វដែលទម្លាយសំបកពង និងពងចេញមកខាងក្រៅ ឈ្មោះថា **ភូត** ។ ពួកសំសេទជសត្វ និងឱបបាតិកសត្វ (សត្វដែលកើតក្នុងញើសក្អែល និងដែលផុសឡើងឯង) ឈ្មោះថា **សម្ភវេសី** ក្នុងខណៈនៃចិត្តដួងដំបូង ។ តាំងពីខណៈចិត្តដួងទី ២

ទៅ ឈ្មោះថា **ភូត** ។ ម្យ៉ាងទៀត ពួកសត្វដែលនៅមិនទាន់ដល់ឥរិយាបថ ដទៃអំពីឥរិយាបថដែលខ្លួនកើតដរាបណា ក៏ចាត់ថា ជាសម្ភវេសីដរាបនោះ ។ បន្ទាប់អំពីនោះ ឈ្មោះថា **ភូត** ។ ម្យ៉ាងទៀត បទថា **ភូតា** បានដល់ កើតហើយ គឺ បង្កើតហើយ ភូតពួកណា គឺ ភូតដែលដល់ការរាប់ (ដែលចាត់ចូលក្នុងប្រភេទ) ថា នឹងមិនមាន (ការកើត) ទៀត ពាក្យនោះ ជាឈ្មោះរបស់ព្រះខីណាស្រពទាំងនោះ ។ ឈ្មោះថា **សម្ភវេសី** ព្រោះស្វែងរកកពទីកើត ។ ពាក្យនោះ ជាឈ្មោះរបស់ព្រះសេក្ខៈ និងបុថុជ្ជនអ្នកស្វែងរកកពតទៅ ព្រោះលះភវសញ្ញោជនៈមិនបាន ដោយអាការយ៉ាងនេះ កិលេសភវសញ្ញោជនៈនោះ ទើបប្រកបសព្វសត្វទុកដោយបទទាំង ២ នេះ ដោយប្រការទាំងពួង ។ ម្យ៉ាងទៀត **វា** ស័ព្ទ ក្នុងពាក្យថា **ភូតានំ វា សត្តានំ** នេះ មានអត្ថថា ប្រមូលចូលគ្នា ព្រោះហេតុនោះ គប្បីជ្រាបសេចក្តីដូច្នេះថា **ភូតានំ ច សម្ភវេសីនំ ច** សត្វអ្នកកើតហើយ និងសត្វអ្នកស្វែងរកកព ។

បទថា **ឋិតិយា** បានដល់ ដើម្បីការតាំងនៅ ។ បទថា **អនុគ្គហាយ** បានដល់ ដើម្បីសេចក្តីអនុគ្រោះ ។ នេះជាត្រឹមតែជាការផ្សេងនៃពាក្យប៉ុណ្ណោះ ចំណែកខ្លឹមសារ (អត្ថន័យ) របស់បទសូម្បីទាំង ២ នោះ ក៏តែមួយ៉ាងនុ៎ះឯង ។

ម្យ៉ាងទៀត បទថា **ឋិតិយា** បានដល់ មិនដាច់ខ្សែព្រោះធម៌ដែលកើតឡើងដល់សត្វនោះៗ នៅតាមបង ។ បទថា **អនុគ្គហាយ** បានដល់ ដើម្បីការកើតឡើងនៃធម៌ដែលមិនទាន់កើត ។ បទទាំង ២ នេះ គប្បីឃើញក្នុងទីទាំង ២ យ៉ាងនេះថា **ភូតានំ វា ឋិតិយា ចេវ អនុគ្គហាយ ច សម្ភវេសីនំ ឋិតិយា ចេវ អនុគ្គហាយ ច** (ដើម្បីការតាំងនៅ និងដើម្បីអនុគ្រោះភូតទាំងឡាយ ឬដើម្បីការតាំងនៅ និងដើម្បីអនុគ្រោះសម្ភវេសីទាំងឡាយ) ។

អាហារដែលធ្វើជាដុំពំនូតបរិភោគចូលទៅ ឈ្មោះថា **កវឡីការាហារ** ។ ពាក្យថា **កវឡីការាហារ** នោះ ជាឈ្មោះរបស់ឱជា មានបាយ និងនំកុម្មាសជាដើមជាទីតាំង ។

បទថា **ឱឡារិកោ វា សុខុមោ វា** បានដល់ ឈ្មោះថា គ្រោតគ្រាតព្រោះមានវត្ថុគ្រោតគ្រាត ។ ឈ្មោះថា ល្អិត ព្រោះមានវត្ថុល្អិត ។ **កវឡី-ការាហារ** ឈ្មោះថា ល្អិត ព្រោះរាប់បញ្ចូលក្នុងសុខុមរូប រូបល្អិតតាមសភាវៈ ។ គប្បីជ្រាបថា អាហារនោះគ្រោតគ្រាត និងល្អិតដោយវត្ថុ ព្រោះប្រៀបធៀបជាមួយអាហាររបស់ក្រពើ ។ បានឮថា ក្រពើស៊ីដុំថ្ម ។ ក៏ដុំថ្មទាំងនោះពេលចូលទៅក្នុងពោះរបស់វា ក៏រលួយល្អិត ។ សត្វក្ងោកស៊ីសត្វ

ផ្សេងៗ មានពស់ និងខ្ទួយជាដើម ។ តែបើប្រៀបជាមួយអាហាររបស់សត្វក្ងោក អាហាររបស់សត្វក្អែក្អួតជាង ។ បានឮថា សត្វក្អែទាំងនោះ ស៊ីស្នែងសត្វ និងឆ្អឹងដែលគេបោះចោលដល់ ៣ ឆ្នាំ ។ ក៏ឆ្អឹងទាំងនោះពេលសើមព្រោះទឹកមាត់របស់ពួកវា ក៏ផុយដូចមើមដំឡូង ។ កាលបើប្រៀបនឹងអាហាររបស់សត្វក្អែ អាហាររបស់ដំរីល្អិតជាង ។ ព្រោះដំរីទាំងនោះ ស៊ីស្លឹកឈើផ្សេងៗ ជាដើម ។ អាហាររបស់គោព្រៃ ប្រើស និងម្រឹគជាដើម ល្អិតជាងអាហាររបស់ដំរី ។ បានឮថា គោព្រៃ ប្រើស និងម្រឹគជាដើម ស៊ីស្លឹកឈើផ្សេងៗ ជាដើមដែលមិនមានខ្លឹម ។ អាហាររបស់គោល្អិតជាងអាហាររបស់គោព្រៃ ប្រើស និងម្រឹគទាំងនោះ ។ គោទាំងនោះស៊ីស្មៅស្រស់ និងស្មៅស្ងួត ។ អាហាររបស់ទន្សាយល្អិតជាងអាហាររបស់គោទាំងនោះ ។ អាហាររបស់សត្វបក្សីល្អិតជាងអាហាររបស់ទន្សាយ ។ អាហាររបស់មនុស្សនៅជាយដែនល្អិតជាងអាហាររបស់ពួកសត្វបក្សី ។ អាហាររបស់មេស្រុកល្អិតជាងអាហាររបស់មនុស្សនៅជាយដែន ។ អាហាររបស់មហាមាត្ររបស់ព្រះរាជាល្អិតជាងអាហាររបស់មេស្រុក ។ ព្រះក្រយាហាររបស់ស្ដេចចក្រពត្តិល្អិតជាងអាហាររបស់មហាមាត្រ សូម្បីទាំងនោះ ។ អាហាររបស់ពួកភុម្មទេវតា

ល្អិតជាងព្រះក្រយាហាររបស់ស្ដេចចក្រពត្តិ ។ អាហាររបស់ទេវតាជាន់ចាតុម្មហារាជិកាល្អិតជាងអាហាររបស់ភុម្មទេវតា ។ គប្បីឲ្យអាហាររបស់ទេវតាទាំងឡាយរហូតដល់ទេវតាជាន់បរនិម្មិតវសវត្តី ពិស្ដារដូចពណ៌នាមកដូច្នេះ ។ គប្បីជ្រាបថា អាហាររបស់ទេវតាទាំងនោះល្អិត ដូច្នោះ ។

ក៏ក្នុងពាក្យថា **ឱឡារិកោ វា សុខុមោ វា** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

កាលវត្ថុគ្រោតគ្រាត ឱជាក៏តិច និងមានកម្លាំងខ្សោយ ។ កាលវត្ថុល្អិត ឱជាច្រើន និងមានកម្លាំងខ្លាំង ។ ពិតណាស់ បុគ្គលដែលបរិភោគបបរស្ងួតប្បីពេញមួយបាត្រ ត្រឹមតែមួយភ្លែតប៉ុណ្ណោះក៏អស់កម្លាំង ប្រាថ្នានឹងបរិភោគអ្វីៗ ទៀតទុះឯង ។ ចំណែកបុគ្គលបានផឹកទឹកដោះថ្លាត្រឹមតែមួយទូកដៃ ក៏មិនចង់បរិភោគរហូតអស់មួយថ្ងៃ ។ វត្ថុក្នុងបណ្ដាបាយយាគូ និងទឹកដោះថ្លានោះ រមែងបន្ទោបង់អន្តរាយ ពោលគឺ ភ្លើងដែលកើតពីកម្មបាន តែមិនអាចនឹងចិញ្ចឹមជីវិតបាន ។ ស្ងួប្បីឱជាទាំងនោះ ចិញ្ចឹមជីវិតបាន តែមិនអាចបន្ទោបង់អន្តរាយបាន ។ តែបាយយាគូ ទឹកដោះថ្លា និងឱជា ទាំង ២ យ៉ាងរួមគ្នាចូលហើយ រមែងបន្ទោបង់អន្តរាយ និងចិញ្ចឹមជីវិតបាន ដូច

ពណ៌នាមក ដូច្នេះ ។

បទថា **ផស្សោ ទុតិយោ** សេចក្តីថា ផស្សៈទាំង ៦ យ៉ាង មានចក្ខុសម្ផស្សជាដើម គប្បីជ្រាបថា ឈ្មោះថា អាហារទី ២ ក្នុងអាហារ ៤ យ៉ាងនោះ ។ នេះក៏ជាទេសនាន័យប៉ុណ្ណោះ ។ ព្រោះហេតុនោះ ដោយហេតុឈ្មោះនេះ ទើបមិនចាំត្រូវស្វែងរកក្នុងពាក្យថា **ទុតិយោ តតិយោ** ច នេះ ក្នុងទីនេះ ។ ចេតនាទុះឯងលោកហៅថា **មនោសញ្ចេតនា** ។ បទថា **វិញ្ញាណំ** បានដល់ ចិត្ត ។ ព្រះមានព្រះភាគទ្រង់សម្តែងអាហារ ៤ ឲ្យជាពួកតែមួយទុកក្នុងទីនេះ ដោយអំណាចអាហារដែលជាឧបាទិន្នកៈ និងអនុបាទិន្នកៈដោយប្រការដូច្នេះ ។ ពិតណាស់ កវឡីការាហារដែលជាឧបាទិន្នកៈក៏មាន ដែលជាអនុបាទិន្នកៈក៏មាន ឯផស្សៈជាដើម ក៏ដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះ (ពាក្យថា **ឧបាទិន្នកោបិ អត្ថិ អនុបាទិន្នកោបិ**) ដូចតទៅនេះ ៖ គប្បីជ្រាប កវឡីការាហារដែលជាឧបាទិន្នកៈដោយអំណាចសត្វកន្ទើបជាដើម ដែលត្រូវពស់លេប ។ សត្វកន្ទើបជាដើមត្រូវពស់លេប សូម្បីនឹងនៅក្នុងពោះក៏នៅមានជីវិត ក្នុងវេលាតិចតួចប៉ុណ្ណោះ ។ កន្ទើបនោះ ដរាបណាដែលនៅក្នុងចំណែកឧបាទិន្នកៈ ក៏មិនសម្រេចប្រយោជន៍

ជាអាហារដែកបនោះ តែកាលទម្លាយទៅក្នុងចំណែកអនុបាទិន្នកៈ ទើបឲ្យសម្រេចជាអាហារបាន ។ លោកពោលថា ឧបាទិន្នកាហារក៏ពិត តែពាក្យដែលពោលនេះ លោកបន្ថែមចូលក្នុងអដ្ឋកថាថា អាចារ្យទាំងឡាយមិនបានពោលទុក ហើយពោលទុកដូច្នេះថា អាហារដែលកើតរួមនឹងបដិសន្ធិចិត្តរបស់សត្វទាំងនេះ ដែលស៊ីក្តី មិនស៊ីក្តី បរិភោគក្តី មិនបរិភោគក្តី ឈ្មោះថា កម្មជរូប (រូបកើតពីកម្ម) មានហើយ អាហារនោះ រមែងចិញ្ចឹមជីវិតបានរហូតដល់ថ្ងៃទី ៧ ។ អាហារនេះឯងគប្បីជ្រាបថា **កវឡីការាហារ** ដែលជាឧបាទិន្នកៈ ។ ផស្សៈជាដើម ដែលជាឧបាទិន្នកៈ គប្បីជ្រាបដោយអំណាចវិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ដែលជាអនុបាទិន្នកៈ គប្បីជ្រាបដោយអំណាចកុសលចិត្ត អកុសលចិត្ត និងកិរិយាចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ចំណែកលោកុត្តរៈ លោកពោលទុកដោយដែលស៊ីសេចក្តីដល់ផង ។

ក្នុងសេចក្តីនេះ លោកអ្នកជាស់តឿនបានរំលឹកថា ប្រសិនបើអាហារមានអត្ថថា បច្ច័យ បច្ច័យមានអត្ថថា អាហារសោត ដូច្នោះ ព្រោះហេតុអ្វីកាលបច្ច័យសូម្បីពួកដទៃរបស់សត្វទាំងឡាយមាន ព្រះមានព្រះភាគទើបត្រាស់អាហារទាំង ៤ នេះទុកដែរ ។ នឹងឆ្លើយតទៅ ៖

ដែលព្រះអង្គត្រាស់ទុកថា ព្រោះអាហារជាបច្ច័យពិសេសនៃការបន្ត (សន្តតិ) ក្នុងខាងក្នុង ។ ពិតហើយ **កវឡីការាហារ** នោះ ជាបច្ច័យពិសេសនៃរូបកាយរបស់សត្វទាំងឡាយ ដែលមានកវឡីការាហារជាកក្សា ។ **ផស្សាហារ** ជាបច្ច័យពិសេសនៃវេទនាក្នុងនាមកាយ ។ **មនោសញ្ចេតនាហារ** ជាបច្ច័យពិសេសនៃវិញ្ញាណ ។ **វិញ្ញាណាហារ** ជាបច្ច័យពិសេសនៃនាមរូប ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ កាយនេះតាំងនៅបានព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារក៏តាំងនៅមិនបាន យ៉ាងណា ព្រោះមានផស្សៈជាបច្ច័យ ទើបមានវេទនា ព្រោះមានសង្ខារជាបច្ច័យ ទើបមានវិញ្ញាណ ព្រោះមានវិញ្ញាណជាបច្ច័យ ទើបមាននាមរូប ក៏ដូច្នោះ ។

សួរថា ក៏ក្នុងសេចក្តីនេះ អាហារអ្វី នាំអ្វីមកឲ្យ ។

ឆ្លើយថា កវឡីការាហារនាំរូបដែលមានឱជៈជាទី ៨ មក ផស្សាហារនាំវេទនា ៣ មក មនោសញ្ចេតនាហារនាំភពទាំង ៣ មក វិញ្ញាណាហារនាំបដិសន្ធិ និងនាមរូបមក ។

សួរថា នាំមកយ៉ាងណា ។

ធ្វើយថា ជាដំបូង **កវឡីការាហារ** ពេលដាក់ត្រង់មាត់ប៉ុណ្ណោះ ក៏ឲ្យរូប ៨ តាំងឡើង ។ សូម្បីគ្រាប់បាយតែមួយគ្រាប់ដែលធ្មេញទំពារល្អិតលេបចូលទៅ ក៏ឲ្យរូប ៨ តាំងឡើងភ្លាម ។ កវឡីការាហារ នាំរូបដែលមានឱជៈជាទី ៨ មកដោយអាការយ៉ាងនេះ ។ មួយទៀត ក្នុង **ផស្សាហារ** ផស្សៈដែលជាទីតាំងនៃសុខវេទនា កាលកើតឡើងទុះឯង រមែងនាំសុខ-វេទនាមក ។ ដែលជាទីតាំងនៃទុក្ខវេទនា រមែងនាំទុក្ខមក ។ ដែលជាទីតាំងនៃអទុក្ខមសុខវេទនា រមែងនាំអទុក្ខមសុខវេទនាមក ។ រួមសេចក្តីថា ផស្សា-ហារ រមែងនាំវេទនាទាំង ៣ មកឲ្យ សូម្បីដោយប្រការទាំងពួង ដោយអាការយ៉ាងនេះ ។

**មនោសញ្ចេតនាហារ** រមែងនាំកាមភពមកឲ្យ ដល់អ្នកចូលដល់កាម-ភព ។ រមែងនាំភពនោះៗ មកឲ្យ ដល់អ្នកចូលដល់រូបភព និងអរូបភព ។ មនោសញ្ចេតនាហារ រមែងនាំភពទាំង ៣ មកឲ្យ សូម្បីដោយប្រការទាំងពួង ដោយអាការយ៉ាងនេះ ។ ចំណែក **វិញ្ញាណាហារ** លោកពោលថា រមែងនាំមកនូវខន្ធទាំង ៣ ដែលសម្បយុត្តដោយបដិសន្ធិវិញ្ញាណនោះ ក្នុងខណៈបដិសន្ធិ និងរូប ៣០ ដែលកើតឡើងដោយអំណាចគតិសន្តតិ ដោយន័យ

នៃបច្ច័យ មានសហជាតប្បច្ច័យជាដើម ។ ព្រោះហេតុនោះ វិញ្ញាណាហារ រមែងនាំនាមរូបក្នុងបដិសន្ធិមក យ៉ាងនេះ ។ ក៏ក្នុងសេចក្ដីនេះ លោកពោល កុសលចេតនាដែលមានអាសវៈប៉ុណ្ណោះថា មនោសញ្ចេតនានាំភពទាំង ៣ មកឲ្យ ។ ពោលបដិសន្ធិវិញ្ញាណប៉ុណ្ណោះថា វិញ្ញាណនាំនាមរូបក្នុងខណៈ បដិសន្ធិមកឲ្យ ។ តែកាលពោលដោយមិនប្លែកគ្នា បច្ច័យទាំងនោះ គប្បី ជ្រាបថា **អាហារ** ព្រោះនាំធម៌ដែលសម្បយុត្តដោយបច្ច័យនោះៗ មានបច្ច័យ នោះៗ ជាសមុដ្ឋានមកឲ្យ ។

បណ្ដាអាហារ ៤ យ៉ាងនោះ កវឡីការាហារ កាលទីងឧបត្ថម្ភ រមែង ឲ្យអាហារកិច្ចសម្រេចបាន ។ ផស្សៈកាលបើពាល់ត្រូវ ក៏ញ៉ាំងអាហារកិច្ច ឲ្យសម្រេចបាន ។ មនោសញ្ចេតនា កាលប្រមូលមក ក៏ញ៉ាំងអាហារកិច្ច សម្រេចបាន ។ វិញ្ញាណកាលដឹងច្បាស់ ក៏ឲ្យអាហារកិច្ចសម្រេចដូចគ្នា ។

សួរថា ឲ្យសម្រេចដូចម្ដេច ។

ឆ្លើយថា ពិតហើយ កវឡីការាហារ កាលឧបត្ថម្ភ រមែងមានការ តាំងនៅនៃសត្វទាំងឡាយ ព្រោះការតាំងនៅកាយ ។ ក៏កាយនេះ សូម្បីកម្ម ឲ្យកើត តែកវឡីការាហាររមែងឧបត្ថម្ភឲ្យតាំងនៅ រហូតអស់ប្រមាណអាយុ

១០ ឆ្នាំខ្លះ១០០ ឆ្នាំខ្លះ ។

សួរថា ប្រៀបដូចអ្វី ។

ឆ្លើយថា ប្រៀបដូចកុមារតូច សូម្បីមាតាឲ្យកើតមក ក៏ត្រូវមេដោះឲ្យបៅដោះជាដើម ចិញ្ចឹមរក្សា រមែងតាំងនៅបានយូរ និងប្រៀបដូចផ្ទះដែលត្រូវសសរផ្ទះទ្រទុក ។

សមដូចព្រះមានព្រះភាគត្រាស់ទុកថា មហាបពិត្រ ផ្ទះកាលត្រូវដួលរលំ ត្រូវឈើជាគ្រឿងផ្ទះដទៃទ្រទុក ផ្ទះនោះក៏មិនដួល យ៉ាងណា មហាបពិត្រ កាយរបស់យើងនេះក៏ដូចគ្នា តាំងនៅបានព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន ។ កវឡីការាហារ កាលឧបត្ថម្ភ រមែងញ៉ាំងអាហារកិច្ចឲ្យសម្រេចដោយអាការយ៉ាងនេះ ។

មួយទៀត កវឡីការាហារ សូម្បីនឹងឲ្យអាហារកិច្ចសម្រេចដោយអាការយ៉ាងនេះ រមែងជាបច្ច័យដល់សន្តតិរូបទាំងពីរ គឺ ទាំងដែលមានអាហារជាសមុដ្ឋាន និងទាំងដែលជាឧបាទិន្នក: ។ កវឡីការាហារ ជាអនុ-បាលបច្ច័យ (បច្ច័យដែលតាមរក្សា) ដល់រូបដែលកើតពីកម្ម ជាជនកបច្ច័យ (បច្ច័យឲ្យកើត) ដល់រូបដែលមានអាហារជាសមុដ្ឋាន ដោយប្រការដូច្នេះ ។

ចំណែកផស្សៈ កាលពាល់ត្រូវអារម្មណ៍ដែលជាទីតាំងនៃសុខជាដើម រមែង ប្រព្រឹត្តទៅដើម្បីការតាំងនៅនៃសត្វទាំងឡាយ ព្រោះការប្រព្រឹត្តទៅនៃសុខ-វេទនាជាដើម ។ មនោសញ្ចេតនា កាលនឹងប្រមូលមកដោយអំណាចកុសល-កម្ម និងអកុសលកម្ម រមែងប្រព្រឹត្តទៅដើម្បីការតាំងនៅនៃសត្វទាំងឡាយ ព្រោះញុំាំងមូលនៃភពឲ្យសម្រេច ។ វិញ្ញាណកាលដឹងច្បាស់ រមែងប្រព្រឹត្ត ទៅដើម្បីការតាំងនៅនៃសត្វទាំងឡាយ ព្រោះឲ្យនាមរូបប្រព្រឹត្តទៅ ដោយ អាការយ៉ាងនេះ ។

ក្នុងអាហារទាំងនេះ ដែលញុំាំងអាហារកិច្ចឲ្យសម្រេចដោយអំណាច ការឧបត្ថម្ភនេះ ក៏គប្បីឃើញភ័យ ៤ យ៉ាង គឺ ភ័យដែលកើតពីការពេញ ចិត្តក្នុងកវឡីការាហារ ភ័យ គឺ ការចូលទៅរកផស្សៈ ភ័យ គឺ ការប្រមូល នៃមនោសញ្ចេតនា ភ័យ គឺ ការធ្លាក់ទៅក្នុងវិញ្ញាណ ។ ព្រោះហេតុអ្វី ។ ព្រោះសត្វទាំងឡាយពេញចិត្តក្នុងកវឡីការាហារហើយ ប្រាថ្នាភាពត្រជាក់ ជាដើម ខាងមុខកាលនឹងធ្វើការងារ មានមុទ្ទាគណនា (វិជ្ជាគណនា) ជាដើម ដើម្បីត្រូវការអាហារ រមែងជួបប្រសព្វទុក្ខដ៏ច្រើន ។ ក៏បុគ្គលពួកខ្លះសូម្បី នឹងបួសក្នុងសាសនានេះហើយ ក៏ស្វែងរកអាហារដោយអនេសនកម្ម មាន

វេជ្ជកម្មជាដើម រមែងត្រូវគេតិះដៀលក្នុងបច្ចុប្បន្ន សូម្បីក្នុងភពមុខក៏រមែងជាសមណប្រេត តាមន័យដែលពោលទុកក្នុងលក្ខណសំយុត្ត មានជាដើមថា សូម្បីសង្ឃាដិរបស់គេ ក៏ត្រូវភ្លើងឆេះសន្ធោសន្ធៅហើយ ។ ព្រោះហេតុនេះ ជាដំបូង ការពេញចិត្តក្នុងកវឡីការាហារ គប្បីជ្រាបថា ជាភ័យ ។

អ្នកដែលត្រេកអរក្នុងផស្សៈ សូម្បីចូលទៅជិតផស្សៈ ក៏រមែងខុសក្នុងភណ្ឌៈ មានប្រពន្ធគេជាដើម ដែលបុគ្គលដទៃគេរក្សាឃុំគ្រងទុក ។ ម្ចាស់របស់ភណ្ឌៈ (ម្ចាស់គេ) ចាប់យកបុគ្គលទាំងនោះមកព្រមទាំងភណ្ឌៈ (ប្រពន្ធ) ហើយកាត់ជាចំណែកតូចធំ ចោលទៅក្នុងគំនរសម្រាម ឬប្រគល់ថ្វាយចំពោះព្រះរាជា ។ តពីនោះ ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យដាក់អាជ្ញាកម្មផ្សេងៗ ។ បុគ្គលទាំងនោះ កាលស្លាប់ ក៏មានទុគតិជាទីសង្ឃឹម ។ ភ័យក្នុងបច្ចុប្បន្នក្តី ក្នុងភពខាងមុខក្តី ដែលមានសេចក្តីត្រេកអរក្នុងផស្សៈជាមូលហេតុ រមែងមកព្រមគ្នាបានទាំងអស់ ដោយប្រការដូច្នេះ ។ ព្រោះហេតុនេះ ការចូលទៅរកផស្សាហារនុ៎ះឯង គប្បីជ្រាបថា ជាភ័យ ។

ក៏ព្រោះប្រមូលកុសលកម្ម និងអកុសលកម្ម ភ័យក្នុងភពទាំង ៣ ដែលមានកុសលកម្ម និងអកុសលកម្មជាហេតុ ទើបមកព្រមគ្នាទាំងអស់ ។

ដោយហេតុនេះ ការប្រមូលមកក្នុងមនោសញ្ចេតនាហារនុ៎ះឯង គប្បីជ្រាប

ថា ជាភ័យ ។

ចំណែកបដិសន្ធិវិញ្ញាណ ធ្លាក់ទៅក្នុងទីណាៗ ក៏រមែងកាន់យកបដិ-

សន្ធិនាមរូបទៅកើតក្នុងទីនោះៗ ។ កាលបដិសន្ធិនាមរូបកើតហើយ ភ័យ

គ្រប់យ៉ាង ក៏រមែងកើតតាមមកជាមួយ ព្រោះមានបដិសន្ធិនាមរូបនោះជា

មូល ដោយប្រការដូច្នេះ ។ ព្រោះហេតុនេះ ការធ្លាក់ទៅក្នុងវិញ្ញាណាហារ

នុ៎ះឯង គប្បីជ្រាបថា ជាភ័យ ដូចពណ៌នាមកដូច្នេះ ។

[២៩] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **កឹ និទានា** ដូចតទៅនេះ ៖

និទានៈ (ហេតុកើត) ទាំងពួង ជាវេវចនៈរបស់ការណៈ (ហេតុ)

រមែងប្រគល់ផលឲ្យ ហាក់ដូចជានឹងប្រគល់ឲ្យថា អញ្ជើញទទួលវត្ថុនោះចុះ

ព្រោះហេតុនោះ លោកទើបហៅថា **និទានៈ** ។ ព្រោះហេតុដែលផលផុស

ឡើង គឺ កើត បានដល់ កើតពីហេតុនោះ ព្រោះដូច្នោះ លោកទើបហៅថា

**សមុទយោ ជាតិបភវោ** ដូច្នេះ ។

ក៏ក្នុងប្រការនេះ មានខ្លឹមសារចំពោះបទដូចតទៅនេះ ៖

អ្វីជាដែនប្រគល់ឲ្យនៃហេតុទាំងនោះ ហេតុនោះ ទើបឈ្មោះថា **កឹ**

**និទានា** ។ អ្វីជាដែនកឲ្យកើតនៃហេតុទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **ក៏ សមុទយា** ។ អ្វីជាដែនកើតនៃហេតុទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **ក៏ ជាតិយា** ។ អ្វីជាដែនកើតមុននៃហេតុទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **ក៏ បភវា** ។ ក៏ព្រោះតណ្ហារបស់បុគ្គលទាំងនោះ ជាដែនប្រគល់ឲ្យ ជាហេតុបន្តឲ្យកើត ជាការកើត និងជាដែនកើតមុន ដោយន័យ គឺដោយអត្ថតាមដែលពោលមក ព្រោះហេតុនោះ លោកទើបពោលពាក្យថា **តណ្ហានិទានា** ។ សេចក្តីគ្រប់ៗ បទ គប្បីជ្រាបដោយអាការយ៉ាងនេះ ។

ក៏ក្នុងពាក្យថា **ឥមេ ចត្តារោ អាហារា តណ្ហានិទានា** នេះ គប្បីជ្រាបហេតុនៃអាហារ ពោលគឺ អត្តភាព ចាប់តាំងពីបដិសន្ធិដោយអំណាចតណ្ហាក្នុងមុន ។

សួរថា គប្បីជ្រាបយ៉ាងណា ។

ឆ្លើយថា ជាដំបូងក្នុងខណៈបដិសន្ធិ សត្វដែលមានអាយតនៈគ្រប់បរិបូណ៌ មានឱជាដែលកើតក្នុងខាងក្នុងរូប កើតឡើងដោយអំណាចសន្តតិ ៧ សត្វដ៏សេស មានឱជាដែលកើតក្នុងខាងក្នុងរូប កើតឡើងដោយអំណាចសន្តតិដែលតិចជាងនោះ នេះឈ្មោះថា កវឡីការាហារដែលជាឧបាទិន្នកៈ

មានតណ្ហាជាហេតុ ។ ចំណែកអាហារទាំងនេះ គឺ ផស្សៈ និងចេតនាដែលសម្បយុត្តដោយបដិសន្ធិចិត្ត និងចិត្ត គឺ វិញ្ញាណនុ៎ះឯង ឈ្មោះថា ផស្សាហារ មនោសញ្ចេតនាហារ និងវិញ្ញាណាហារ ដែលជាឧបាទិន្នកៈ មានតណ្ហាជាហេតុ ហេតុនោះ អាហារដែលសម្បយុត្តនឹងបដិសន្ធិចិត្ត មានតណ្ហាក្នុងកាលមុនជាហេតុ ទើបមានដោយអាការយ៉ាងនេះ ។ គប្បីជ្រាបអាហារដែលសម្បយុត្តជាមួយបដិសន្ធិចិត្ត យ៉ាងណា តពីនោះ ក៏គប្បីជ្រាបអាហារសូម្បីដែលកើតក្នុងខណៈនៃភវង្គចិត្តដួងដំបូងជាដើម ដូច្នោះ ។

ព្រះមានព្រះភាគ ទ្រង់មិនបានជ្រាបចំពោះហេតុនៃអាហារតែម៉្យាងក៏ទេ ទ្រង់ជ្រាបទាំងហេតុនៃតណ្ហាដែលជាហេតុនៃអាហារ ទាំងហេតុនៃវេទនាសូម្បីដែលជានៃហេតុតណ្ហាផង ព្រោះហេតុនោះ ព្រះអង្គទ្រង់សម្តែងវដ្តៈហើយ សម្តែងវិវដ្តៈ ដោយន័យមានជាដើមថា **តណ្ហា ចាយំ ភិក្ខវេ កឹនិទានា** ដូច្នេះ ។ តែក្នុងទីនេះ ព្រះមានព្រះភាគទ្រង់ធ្វើទេសនាចំពោះអតីតហើយសម្តែងវដ្តៈ ដោយន័យដែលជាអតីត ។

សួរថា ទ្រង់សម្តែងយ៉ាងណា ។

ឆ្លើយថា ទ្រង់កាន់យកអត្តភាពនេះដោយអំណាចអាហារ ។

តណ្ហា នោះ បានដល់ កម្មដែលញ៉ាំងអត្តភាពនេះឲ្យកើត ។ ព្រះអង្គត្រាស់ វេទនា ផស្សៈ សឡាយតនៈ នាមរូប និងវិញ្ញាណទុក ដើម្បីនឹងសម្ដែងដល់អត្តភាពដែលកម្មប្រមូលទុក ។ ព្រោះមានអវិជ្ជា និងសង្ខារកម្មទើបឲ្យអត្តភាពនោះកើត ។ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងធម៌សូម្បីទាំង ២ ប្រការ គឺ កម្ម និងវិបាករបស់កម្ម ដោយសង្ខេបថា អត្តភាពក្នុងឋានៈទាំង ២ កម្មដែលញ៉ាំងអត្តភាពនោះឲ្យកើតក្នុងឋានៈទាំង ២ ទ្រង់ធ្វើទេសនាចំពោះអតីត សម្ដែងវដ្ដៈដោយន័យដែលជាអតីត ដោយប្រការដូច្នេះ ។ ក្នុងសេចក្ដីនោះ មិនគប្បីឃើញថា ទេសនាមិនបរិបូណ៌ ព្រោះទ្រង់មិនសម្ដែងអនាគតទុក តែគប្បីឃើញថា បរិបូណ៌ដោយន័យ ។ ប្រៀបដូចបុរសដែលមានចក្ខុ ឃើញក្រពើដេកនៅលើទឹក កាលសម្លឹងមើលចំណែកខាងមុខរបស់វា ក៏នឹងឃើញតែ.ក តែចូលទៅផ្នែកខាងក្រោយពីគល់កន្ទុយកាលសម្លឹងមើលក្រោមពោះ ក៏មិនឃើញចុងកន្ទុយដែលនៅក្នុងទឹក និងជើងទាំង ៤ ត្រឹមតែប៉ុណ្ណោះ បុរសនោះក៏យល់ថា ក្រពើមិនបរិបូណ៌ (មានអវយវៈមិនគ្រប់) មិនបានទេ តែកាលពោលអំពីន័យក៏រាប់បានថា ក្រពើមានអវយវៈគ្រប់បរិបូណ៌ យ៉ាងណា ការឧបមេយ្យនេះ ក៏គប្បីជ្រាបដូច្នោះ ។

ក៏វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ប្រៀបដូចក្រពើដែលដេកនៅលើទឹក ។ ព្រះយោគាវចរ ប្រៀបដូចបុរសដែលមានចក្ខុ ឈរត្រង់មាត់ច្រាំងទឹក ។ វេលាដែលព្រះយោគីឃើញអត្តភាពនេះ ដោយអំណាចអាហារ ក៏ដូចវេលាដែលបុរសនោះឃើញក្រពើដេកលើទឹក ។ វេលាដែលតណ្ហាដែលឲ្យអត្តភាពនេះកើត ដូចវេលាដែលបុរសនោះឃើញ.កខាងមុខ ។ វេលាដែលឃើញអត្តភាព ដែលបុគ្គលធ្វើកម្មប្រកបដោយតណ្ហា ដោយអំណាចវេទនាជាដើម ដូចវេលាដែលបុរសនោះឃើញខ្នង ។ វេលាដែលអវិជ្ជា និងសង្ខារញ៉ាំងអត្តភាពនោះឲ្យកើត ក៏ដូចវេលាដែលឃើញគល់កន្ទុយ ។ ក៏បច្ច័យវដ្តៈមិនមកក្នុងបាលីក្នុងទីណាៗ ក្នុងទីនោះៗ កុំយល់ថា ទេសនាមិនបរិបូណ៌ គប្បីកាន់យកដោយន័យថា បរិបូណ៌តែម្យ៉ាង ប្រៀបដូចបុរសនោះ កាលសម្លឹងមើលពីក្រោមពោះក្រពើ សូម្បីនឹងមិនឃើញចុងកន្ទុយ និងជើងទាំង ៤ ក៏មិនរាប់ថា ក្រពើមានអវយវៈមិនបរិបូណ៌ តែត្រូវយល់ដោយន័យថា បរិបូណ៌ ដូច្នោះ ។ ក៏ក្នុងប្រការនោះ ទ្រង់សម្តែងវដ្តៈ មានសន្ធិ ដោយសង្ខេប ៣ ប្រការ គឺ រវាងអាហារ និងតណ្ហា ចាត់ជាសន្ធិមួយ , រវាងតណ្ហា និងចេតនា ចាត់ជាសន្ធិមួយ , រវាងវិញ្ញាណ និងសង្ខារ ចាត់ជាសន្ធិ

មួយ ដូចពណ៌នាមកដូច្នេះ ។

ចប់អដ្ឋកថា អាហារសូត្រទី ១

# អ ដ្ឋ ក ថា

## ផគ្គុនសូត្រទី ២

[៣១] ក្នុង ផគ្គុនសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **សម្មាវេសីនំ វា អនុគ្គហាយ** បានដល់ ព្រះមានព្រះភាគទ្រង់ឲ្យទេសនាចប់ស្រេចក្នុងទីនេះនុ៎ះឯង ។ ព្រោះហេតុអ្វី ។ ព្រោះអ្នកមានទិដ្ឋិ អគ្គុយហើយ ។ ពិតហើយ ព្រះមោលិយផគ្គុនភិក្ខុដែលមានទិដ្ឋិអគ្គុយនៅក្នុងបរិស័ទនោះ តពីនោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា មោលិយផគ្គុនភិក្ខុនេះ នឹងក្រោកឡើងសួរបញ្ហាដល់តថាគត បើដូច្នោះ តថាគតនឹងដោះស្រាយបញ្ហាឲ្យគេ ហើយឲ្យទេសនាចប់ស្រេច ដើម្បីឲ្យឱកាសលោកបានសួរ ។ ផ្នួងសក់ លោកហៅថា **មោលី** ក្នុងពាក្យថា **មោលិយផគ្គុនោ** នេះ ។ សមដូចដែលព្រះអគ្គត្រាស់ទុកថា ៖

ព្រះសក្យមុនី ទ្រង់កាត់ព្រះមោលី ដែលអប់ដោយទឹក
ក្រអូបយ៉ាងល្អ ហើយទ្រង់បោះទៅក្នុងអាកាស ស្តេចវាសវៈ
ជាសហស្សនេត្រក៏យកប្រអប់មាសដ៏ប្រសើរ ទទួលទុក

ដោយសិរសា ។

ក្នុងសម័យដែលលោកជាគ្រហស្ថ **មោលី** (ផ្នួងសក់) របស់លោកធំ ។ ព្រោះហេតុនោះ លោកទើបមានឈ្មោះហៅថា **មោលិយផគ្គុនៈ** ។ សូម្បីលោកបួសហើយ គេក៏នៅស្គាល់តាមឈ្មោះនោះឯង ។

[៣២] បទថា **ឯតទវោច** បានដល់ លោកកាលនឹងបន្តទេសនានុសន្ធិ ក៏បានក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកណាហ្ន៎នាំវិញ្ញាណាហារមក ។ គប្បីជ្រាបសេចក្តីនៃពាក្យនោះដូចតទៅនេះ ៖

បពិត្រព្រះអង្គដ៏ចម្រើន អ្នកដែលទំពារស៊ី ឬបរិភោគវិញ្ញាណាហារនោះ គឺ នរណា ។

សួរថា ក៏ព្រោះហេតុអ្វី ។ ព្រះមោលិយៈនេះ ទើបមិនសួរដល់អាហារ ៣ ក្រៅអំពីនេះ សួរត្រឹមតែវិញ្ញាណាហារនេះតែម្យ៉ាង ។

ឆ្លើយថា ព្រោះលោកមានលទ្ធិ ការឃើញថា ខ្លួនឯងដឹង ។ ពិតហើយ លោកឃើញដល់អ្នកដែលធ្វើពំនូតបាយដុំធំៗ ហើយបរិភោគអាហារជាដុំៗ ព្រោះហេតុនោះ លោកទើបមានលទ្ធិ គឺ ការឃើញថា ខ្លួនឯងដឹង ។ ក៏លោកឃើញសត្វសត្វទទា សត្វក្អែក និងមាន់ជាដើម ចិញ្ចឹមជីវិតដោយ

មាតុសម្ពស្ស ទើបមានការឃើញថា សត្វទាំងនោះ ចិញ្ចឹមជីវិតដោយមាតុ-សម្ពស្ស ។ ចំណែកអណ្តើកឡើងអំពីសមុទ្រក្នុងឧតុសម័យរបស់ខ្លួនហើយ ដាក់ពងក្នុងរណ្តៅខ្សាច់នាច្រាំងសមុទ្រហើយ យកខ្សាច់លុប ទើបចុះទៅកាន់សមុទ្រដូចដើម ។ ពងទាំងនោះមិនវិនាស (មិនស្អុយ) ដោយអំណាចរលឹកដល់មេ ។ លោកមានលទ្ធិឃើញថា ពងទាំងនោះមានជីវិតនៅបានដោយមនោសញ្ចេតនាហារ ។ សូម្បីព្រះថេរៈមានសេចក្តីឃើញយ៉ាងនោះក៏ពិត សូម្បីយ៉ាងនោះ លោកសួរបញ្ហានេះតាមការឃើញនោះក៏ទេ ។ ព្រោះលោកមានទិដ្ឋិដូចជាមនុស្សឆ្កួត ។ មនុស្សឆ្កួត កាន់កញ្ច្រែងចូងចន្ទោះថ្នល់ ក៏កាន់យកអាចម៍គោខ្លះ ដុំថ្មខ្លះ ឈាមកខ្លះ ខ្សែខ្លះ វត្ថុនោះៗ ពេញចិត្តខ្លះ មិនពេញចិត្តខ្លះ ក៏ដាក់ចុះក្នុងកញ្ច្រែង យ៉ាងណា ព្រះថេរៈដែលមានទិដ្ឋិនេះ ក៏ដូច្នោះដែរ សួរបញ្ហាដែលគួរខ្លះ មិនគួរខ្លះ ។ លោកក៏មិនត្រូវគ្រប់សង្កត់ថា ហេតុដូចម្តេចសួរបញ្ហាយ៉ាងនេះ តែទ្រង់ក្រោកឲ្យដឹងដល់ការប្រកាន់ក្នុងពាក្យសួរហើយសួរទៀត ។ ដោយហេតុនោះឯង ព្រះមានព្រះ-ភាគទើបមិនត្រាស់ ព្រោះហេតុអ្វី លោកទើបសួរយ៉ាងនេះ ទ្រង់ត្រឡប់ជាត្រាស់ថា នោ កល្លោបញ្ហោ (បញ្ហាមិនសមគួរ) ដើម្បីនឹងដោះលោកឲ្យផុត

ពីការប្រកាន់ដែលលោកប្រកាន់អំពីមុន ។

បណ្តាបទទាំងនោះ បទថា **នោ កល្លោ** បានដល់ មិនសមគួរ ។ បទថា **អាហារេតីតិ អហំ ន វទាមិ** បានដល់ តថាគតមិនពោលថា សត្វ ឬបុគ្គលណាៗ នាំអាហារមក ។ បទថា **អាហារេតីតិ ចាហំ វទេយ្យំ** អធិប្បាយបានថា **យទិ អហំ អាហារេតីតិ វទេយ្យំ** ប្រសិនបើ តថាគតនឹងគប្បីពោលថា នាំមកសោត ។

បទថា **តត្រស្ស កល្លោ បញ្ហោ** បានដល់ កាលតថាគតពោលយ៉ាងនេះ បញ្ហានេះក៏នឹងសមគួរ ។ បទថា **កិស្ស នុ ខោ ភន្តេ វិញ្ញាណាហារោ** បានដល់ បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណាហារនេះ ជាបច្ច័យនៃធម៌ណា ។ បទថា **តត្ថ កល្លំ វេយ្យាករណំ** បានដល់ កាលបញ្ហាត្រូវសួរយ៉ាងនេះ វេយ្យាករណ៍នេះក៏រមែងសមគួរ វិញ្ញាណាហារ រមែងជាបច្ច័យដល់ការកើតក្នុងភពថ្មីតទៅ ។ ពាក្យថា **វិញ្ញាណាហារោ** បានដល់ បដិសន្ធិចិត្ត ។ បទថា **អាយតឹបុនព្ភវាភិនិព្វត្តិ** បានដល់ នាមរូបដែលកើតឡើងព្រមជាមួយវិញ្ញាណនោះឯង ។ បទថា **តស្មឹ ភូតេ សតិ សឡាយតនំ** បានដល់ កាលនាមរូប ពោលគឺ ការកើតឡើងក្នុងភពថ្មីតទៅនេះ កើតមានហើយ

សឡាយតនៈ ក៏រមែងមាន ។

ព្រះមានព្រះភាគ កាលនឹងទ្រង់ឲ្យឱកាសលោកបានសួរបញ្ហាខ្ពស់ឡើងបន្តទៀត ទើបបញ្ចប់ទេសនា សូម្បីក្នុងពាក្យនេះថា **សឡាយតនប្បច្ចយា ផស្សោ** ។ ព្រោះលោកមានទិដ្ឋិ ទើបមិនអាចនឹងឲ្យបញ្ហាថ្មីៗ កើតឡើង តែកាន់យកប្រការដែលព្រមព្រៀងគ្នាបានប៉ុណ្ណោះសួរ ដោយហេតុនោះ ព្រះមានព្រះភាគទើបបានប្រទានឱកាសដល់លោក តែសេចក្តីក្នុងគ្រប់ៗបទ ក៏គប្បីកាន់យកតាមន័យដែលពោលមកនុ៎ះឯង ។ ព្រោះហេតុអ្វី លោកទើបមិនទូលសួរថា នរណាហ្ន៎មានហើយ ព្រះអង្គ ។ ព្រោះលោកមានទិដ្ឋិ ទើបមានការឃើញថា ដែលឈ្មោះថា សត្វកើតហើយ គឺ បង្កើតហើយ ព្រោះហេតុនោះ លោកទើបបានទូលសួរថា នេះខុសអំពីការឃើញរបស់ខ្លួន ។ ម្យ៉ាងទៀត លោកឈ្មោះថា ចូលដល់សញ្ញត្តិ ព្រោះពោលទុកក្នុងទីច្រើនកន្លែងថា **ឥទប្បច្ចយា ឥទំ ឥទប្បច្ចយា ឥទំ** ព្រោះវត្ថុនេះជាបច្ច័យ វត្ថុនេះទើបមាន សូម្បីព្រោះហេតុនោះ លោកទើបមិនទូលសួរ ។ សូម្បីព្រះសាស្តាក៏ទ្រង់ត្រិះរិះថា ភិក្ខុនេះ សូម្បីនឹងសួរច្រើនក៏មិនឆ្អែត ក៏នៅសួរបញ្ហាដែលគ្មានសារៈនុ៎ះឯង តពីនោះ ក៏ទ្រង់សម្តែងទេសនាឲ្យតជាប់គ្នាទៅ ។

[៣៧] បទថា ឆន្នំ តេ្វ បានដល់ ព្រះមានព្រះភាគទ្រង់កាន់យកវេលាដែលទេសនាត្រូវលើកឡើងសម្តែង ក៏ទ្រង់បើកបង្ហាញទេសនាត្រាស់យ៉ាងនោះ ។ ក៏ក្នុងព្រះសូត្រនេះ មានសន្ធិ ៣ យ៉ាង ដោយសង្ខេបដូច្នេះគឺ រវាងវិញ្ញាណ និងនាមរូបចាត់ជាសន្ធិមួយ , រវាងវេទនា និងតណ្ហាជាសន្ធិមួយ , រវាងភព និងជាតិជាសន្ធិមួយ ។

ចប់អដ្ឋកថា ឆក្កុសសូត្រទី ២

# អដ្ឋកថា

## បឋមសមណព្រាហ្មណសូត្រទី ៣

*បឋមសមណព្រាហ្មណសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៨] បទថា **សមណា វា ព្រាហ្មណា វា** បានដល់ សមណៈ និងព្រាហ្មណ៍អ្នកកាន់លទ្ធិខាងក្រៅ មិនអាចនឹងចាក់ធ្លុះសច្ចៈទាំងឡាយបាន ។ ក្នុងបទថា **ជរាមរណំ នប្បជានន្តិ** ជាដើម លោកប្រកបសេចក្តីទុកដូច្នេះ សមណព្រាហ្មណ៍ មិនដឹងជរា និងមរណៈដោយអំណាចទុក្ខសច្ច មិនដឹងហេតុកើតនៃជរា និងមរណៈដោយអំណាចសមុទយសច្ចថា ជាតិ និងតណ្ហាជាហេតុកើតនៃជរា និងមរណៈ មិនដឹងការរលត់នៃជរា និងមរណៈដោយអំណាចនិរោធសច្ច មិនដឹងបដិបទាដោយអំណាចមគ្គសច្ច មិនដឹងជាតិដោយអំណាចទុក្ខសច្ច មិនដឹងជាតិសមុទ័យដោយអំណាចសមុទ័យសច្ច ដែលថា ភព និងតណ្ហាជាហេតុឲ្យកើតជាតិ ។ គប្បីប្រកបសមុទ័យ និងតណ្ហាដោយអាការយ៉ាងនេះ គប្បីជ្រាបសេចក្តីដោយអំណាចចតុសច្ចៈក្នុងគ្រប់ៗបទ ។ សាមញ្ញៈ និងព្រហ្មញ្ញៈ ក្នុងពាក្យថា **សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ** នេះ*

បានដល់ អរិយមគ្គ ។ អត្ថ (ផល) របស់សាមញ្ញៈ និងព្រហ្មញ្ញៈទាំងពីរ គប្បីជ្រាបថា អរិយផល ។

ព្រះមានព្រះភាគត្រាស់សច្ចៈទាំង ៤ ក្នុងឋានៈ ១១ យ៉ាង ទុកក្នុងព្រះសូត្រនេះ ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា បឋមសមណព្រាហ្មណសូត្រទី ៣

# អ ដ្ឋ ក ថា

## ទុតិយសមណព្រាហ្មណសូត្រទី ៤

*ក្នុង ទុតិយសមណព្រាហ្មណសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[៤០] *ព្រះអង្គត្រាស់ថា* ***ឥមេ ធម្មេ*** *នប្បជានន្តិ ជាដើម តាមអធ្យាស្រ័យរបស់បុគ្គលដែលអាចចាក់ធ្លុះទេសនា ដែលត្រាស់ឲ្យយូរមានប្រមាណប៉ុណ្ណោះ ដោយពាក្យថា* ***ឥមេ កតមេ ធម្មេ*** *ដូច្នេះ ។ ពាក្យដ៏សេសក៏មានន័យដូចមុននុ៎ះឯង ។*

ចប់អដ្ឋកថា ទុតិយសមណព្រាហ្មណសូត្រទី ៤

# អ ដ្ឋ ក ថា

## កច្ចានគោត្តសូត្រទី ៥

*កច្ចានគោត្តសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[៤២] *បទថា **សម្មាទិដ្ឋិ សម្មាទិដ្ឋិ** សេចក្តីថា ទេវតា និងមនុស្ស ដែលជាបណ្ឌិត ពោលការឃើញត្រូវណាៗ ព្រះកច្ចានៈទូលសួរសេចក្តីបៗ ដល់ការឃើញត្រូវនោះទាំងអស់ចូលដោយបទទាំងពីរ ។*

[៤៣] *បទថា **ទ្វយនិស្សិតោ** បានដល់ អាស្រ័យចំណែកទាំងពីរ ។ ទ្រង់សម្តែងដល់មហាជនដ៏សេស វៀរលែងតែព្រះអរិយបុគ្គល ដោយបទថា **យេភុយ្យេន** នេះ ។ បទថា **អត្ថិតំ** បានដល់ ទៀង ។ បទថា **នត្ថិតញ្ច** បានដល់ ដាច់សូន្យ ។ សង្ខារលោក ឈ្មោះថា **លោក** ការកើតឡើងនៃ សង្ខារលោកនោះ ឈ្មោះថា **លោកសមុទយ** ។ បទថា **សម្មប្បញ្ញាយ បស្សតោ** សេចក្តីថា មគ្គបញ្ញាព្រមទាំងវិបស្សនា ឈ្មោះថា **សម្មប្បញ្ញា** ការដឹងត្រូវ អ្នកពិចារណាឃើញដោយសម្មប្បញ្ញានោះ ។ បទថា **យា លោកេ នត្ថិតា** បានដល់ កាលគេពិចារណាឃើញដោយបញ្ញានូវធម៌ដែលកើតឡើង*

ក្នុងសង្ខារលោក ឧច្ឆេទទិដ្ឋិដែលថា **មិនមាន** ក៏រមែងមិនកើតឡើង ។ បទថា **លោកនិរោធំ** បានដល់ ការបែកធ្លាយនៃសង្ខារទាំងឡាយ ។ បទថា **យា លោកេ អត្ថិតា** បានដល់ កាលគេពិចារណាឃើញដោយបញ្ញានូវធម៌ដែលកំពុងបែកធ្លាយក្នុងសង្ខារលោក សស្សតទិដ្ឋិដែលថា **មាន** ក៏រមែងមិនកើតឡើង ។

ម្យ៉ាងទៀត បទថា **លោកសមុទយំ** បានដល់ បច្ចយាការដោយអនុលោម ។ បទថា **លោកនិរោធំ** បានដល់ បច្ចយាការផ្នែកបដិលោម ។ ក៏កាលបុគ្គលសូម្បីនឹងពិចារណាឃើញ គឺ ពិចារណាឃើញការមិនសូន្យនៃធម៌ដែលអាស្រ័យបច្ច័យកើតឡើង ព្រោះការមិនសូន្យនៃបច្ច័យទាំងឡាយ ឧច្ឆេទទិដ្ឋិដែលថា មិនមាន រមែងមិនកើតឡើង ។ កាលបុគ្គលពិចារណាឃើញការរលត់នៃបច្ច័យ គឺ ពិចារណាឃើញការរលត់នៃធម៌ដែលអាស្រ័យបច្ច័យកើតឡើង ព្រោះបច្ច័យរលត់ សស្សតទិដ្ឋិដែលថា មាន ក៏រមែងមិនកើតឡើង សេចក្តីក្នុងប្រការនេះមានដូចពោលមកនេះ ។

ចំណងដោយឧបាយ ឧបាទាន និងអភិនិវេស ឈ្មោះថា **ឧបាយុ-បាទានាភិនិវេសវិនិពន្ធោ** ។ ក្នុងបទទាំងនោះ បទថា **ឧបាទាយ** បានដល់

ឧបាយមាន ២ យ៉ាង គឺ តណ្ហាឧបាយ និងទិដ្ឋិឧបាយ ។ ន័យសូម្បីក្នុងឧបាទានជាដើម ក៏ដូចគ្នានេះ ។ ក៏តណ្ហា និងទិដ្ឋិ លោកហៅថា ឧបាយ ព្រោះចូលដល់ គឺ ចូលទៅដល់ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយអាការជាដើមថាយើង ថារបស់យើង ។ មួយទៀត លោកថា ឧបាទាន និងអភិនិវេស ព្រោះប្រកាន់មាំ និងប្រកាន់ស្អិតធម៌ទាំងនោះ ។ ក៏លោកនេះ ត្រូវតណ្ហា និងទិដ្ឋិទាំងនោះចងទុក ។ ព្រោះហេតុនោះ លោកទើបពោលថា **ឧបាយុបាទានាភិនិវេសវិនិពន្ធោ** ។

បទថា **តញ្ចាយំ** បានដល់ ក៏ព្រះអរិយសាវកនេះចូលទៅដល់ឧបាយ និងឧបាទាននោះ ។ បទថា **ចេតសោ អធិដ្ឋានំ** បានដល់ ជាទីតាំងមាំនៃចិត្ត ។ បទថា **អភិនិវេសានុសយំ** បានដល់ ដែលជាអភិនិវេស និងអនុស័យ ។ ព្រោះអកុសលចិត្ត រមែងតាំងនៅក្នុងតណ្ហា និងទិដ្ឋិ ឯតណ្ហា និងទិដ្ឋិក៏តាំងមាំ និងដេកសម្ងំក្នុងអកុសលចិត្តនោះ ព្រោះហេតុនោះ លោកទើបពោលធម៌ទាំងពីរប្រការនោះថា ជាទីតាំងមាំ និងជាទីប្រកាន់មាំ និងដេកសម្ងំក្នុងចិត្ត ។ បទថា **ន ឧបេតិ** បានដល់ មិនចូលដល់ ។ បទថា **ន ឧបាទិយតិ** បានដល់ មិនប្រកាន់មាំ ។ បទថា **នាធិដ្ឋាតិ** បានដល់ មិនតាំងមាំថា អ្វីជាតួខ្លួនរបស់យើង ។ បទថា **ទុក្ខមេវ** បានដល់ ត្រឹមតែឧបាទាន-

ក្ខន្ធ ៥ ប៉ុណ្ណោះ ។ បទថា **ន កង្ខតិ** បានដល់ មិនធ្វើសេចក្ដីសង្ស័យថា សេចក្ដីទុក្ខនុ៎ះឯងរមែងកើតឡើង សេចក្ដីទុក្ខរមែងរលត់ទៅ ។ ដែលឈ្មោះថា សត្វដទៃក្នុងលោកនេះមិនមាន ។ បទថា **ន វិចិកិច្ឆតិ** បានដល់ មិនឲ្យសេចក្ដីងឿងឆ្ងល់កើតឡើង ។

បទថា **អបរប្បច្ចយា** បានដល់ ព្រោះអ្នកដទៃមិនធ្វើឲ្យសម្រេចការដឹងច្បាស់ចំពោះខ្លួនប៉ុណ្ណោះរបស់បុគ្គលនេះ មាននៅក្នុងប្រការនេះ ។ ដោយបទថា **ឯត្តាវតាខោ កច្ចាន សម្មាទិដ្ឋិ ហោតិ** ព្រះមានព្រះភាគត្រាស់ដល់សម្មាទិដ្ឋិដែលលាយគ្នាថា ការឃើញត្រូវត្រឹមតែប៉ុណ្ណោះ ព្រោះលះបង់សត្តសញ្ញាបាន ដោយអាការយ៉ាងនេះ ។

[៤៤] បទថា **អយមេកោ អន្តោ** បានដល់ ទីបំផុតទី ១ នេះ ចាត់ជាសស្សតទិដ្ឋិ ការឃើញថា ទៀង ។ បទថា **អយំ ទុតិយោ** បានដល់ ទីបំផុតទី ២ ពោលគឺ ទិដ្ឋិដែលកើតឡើងថា វត្ថុគ្រប់យ៉ាងមិនមាន នេះចាត់ជាឧច្ឆេទទិដ្ឋិ ការឃើញថា ដាច់សូន្យ ។ ពាក្យដ៏សេសក្នុងសេចក្ដីនេះងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ទុតិយសមណព្រាហ្មណសូត្រទី ៤

# អដ្ឋកថា

## ធម្មកថិកសូត្រទី ៦

ធម្មកថិកសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖

[៤៦] បទថា **និព្វិទាយ** បានដល់ ដើម្បីសេចក្តីនឿយណាយ ។ បទថា **វិរាគាយ** បានដល់ ដើម្បីប្រាសចាកតម្រេក ។ បទថា **និរោធាយ** បានដល់ ដើម្បីរលត់ ។ សេចក្តីក្នុងពាក្យថា **បដិបន្នោ ហោតិ** នេះ គប្បីជ្រាបថា បដិបត្តិផ្តើមតាំងពីសីលដរាបដល់អរហត្តមគ្គ ។ បទថា **ធម្មានុធម្មបដិបន្នោ** បានដល់ បដិបត្តិបដិបទាដែលសមគួរដល់និព្វានធម៌ដែលជាលោកុត្តរៈ ។ បទថា **អនុធម្មភូតំ** បានដល់ ដែលមានសភាវៈដ៏សមគួរ ។ បទថា **និព្វិទា វិរាគា និរោធា** បានដល់ ព្រោះនឿយណាយប្រាសចាកតម្រេក និងព្រោះរលត់ទៅ ។ បទថា **អនុបាទា វិមុត្តោ** បានដល់ រួចផុតព្រោះមិនប្រកាន់ធម៌អ្វីៗ ដោយឧបាទាន ៤ ។ បទថា **ទិដ្ឋធម្មនិព្វានប្បត្តោ** គឺ សម្រេចព្រះនិព្វានក្នុងបច្ចុប្បន្នជាតិ ។ បទថា **អលំ វចនាយ** សេចក្តីថា រមែងសមគួរដែលនឹងនិយាយយ៉ាងនេះ គឺ គួរ បានដល់ សមគួរ ។ ក្នុង

សេចក្ដីនេះ ព្រោះធម្មកថិកពោលបុច្ឆាទុកដោយន័យតែមួយ ចង្អុលបង្ហាញសេក្ខភូមិ និងអសេក្ខភូមិ ឲ្យបុច្ឆាប្លែកទៅដោយន័យទាំងពីរ ដូចពណ៌នាមកដូច្នេះ ។

អដ្ឋកថា ធម្មកថិកសូត្រទី ៦

# អ ដ្ឋ ក ថា

## អចេលកស្សបសូត្រទី ៧

ក្នុងអចេលកស្សបសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[៤៧] បទថា **អចេលោ កស្សបោ** បានដល់ អ្នកបួសអចេលៈ គឺ មិនមានសំពត់ដោយកេទ ឈ្មោះកស្សបៈដោយឈ្មោះ ។ បទថា **ទូរតោវ** សេចក្តីថា បានឃើញព្រះមានព្រះភាគ មានភិក្ខុសង្ឃពួកជំហែហាមស្តេចមកពីចម្ងាយ ។

[៤៨] បទថា **កិញ្ចិទេវ ទេសំ** បានដល់ ហេតុការណ៍ណាមួយ ។ បទថា **ឱកាសំ** បានដល់ ខណៈ គឺ កាលនៃការព្យាករណ៍បញ្ហា ។ បទថា **អន្តរឃរំ** បានដល់ ខាងក្នុងស្រុក ឈ្មោះថា លង្វែកស្រុក ។ ក្នុងពាក្យថា **ន បល្លត្ថិកាយ អន្តរឃរេ និសីទិស្សាមិ** (មិនអង្គុយលុតជង្គង់ក្នុងលង្វែកស្រុក) ។ ឈ្មោះថា ខាងក្នុងស្រុកតាំងពីសសរគោលជាដើមទៅ ក្នុងពាក្យថា **ឱក្ខិត្តចក្ខុ អន្តរឃរេ គមិស្សាមិ** (តថាគតតនឹងទតទៅក្នុងលង្វែកស្រុក) ។ ខាងក្នុងស្រុកនេះឯង លោកបំណងយកក្នុងទីនេះ ។

[៤៩] បទថា **យទាកង្ខសិ** បានដល់ ប្រាថ្នាវត្ថុណា ។

សួរថា ក៏ព្រោះហេតុអ្វី ។ ព្រះមានព្រះភាគប្រាថ្នានឹងត្រាស់ ទើបទ្រង់ហាមដល់លើកទី ៣ ។ ឆ្លើយថា ដើម្បីឲ្យកើតសេចក្តីគោរព ។ ព្រោះបុគ្គលប្រកបដោយទិដ្ឋិ កាលបើគេពោលរហ័ស ក៏មិនធ្វើគារវៈ មិនជឿសូម្បីដោយពាក្យ ដោយយល់ថា ការចូលគាល់ព្រះសមណគោតមក្តី ការទូលសួរក្តី ងាយ ត្រឹមតែសួរប៉ុណ្ណោះ ក៏ត្រាស់ឆ្លើយភ្លាម ។ តែកាលហាមដល់ ២-៣ ដង គេក៏ធ្វើសេចក្តីគោរព ក៏ជឿ ដោយយល់ថា ការគាល់ព្រះសមណគោតមក្តី ការទូលសួរបញ្ហាក្តី លំបាក កាលទូលសូមដល់លើកទី ៣ គេក៏នឹងតាំងចិត្តស្តាប់ ជឿពាក្យដែលត្រាស់ ។ ដូច្នោះ ព្រះមានព្រះភាគទើបឲ្យគេទូលសូមដល់លើកទី ៣ ទើបត្រាស់ ដោយបំណងថា បុគ្គលនេះនឹងតាំងចិត្តស្តាប់ និងជឿ ដូចជា ពេទ្យជំនាញដែលស្ងួប្រេង ឬរម្ងាស់ទឹកអំពៅ កាលនឹងស្ងួប្រេង ឬរម្ងាស់ទឹកអំពៅ ក៏រង់ចាំវេលាឲ្យប្រេងនោះត្រជាក់ និងទឹកអំពៅរឹងបាន ដោយមិនបណ្តោយឲ្យឆេះ ហើយលើកចុះយ៉ាងណា ព្រះមានព្រះភាគក៏ដូច្នោះ ទ្រង់រង់ចាំឲ្យញាណរបស់សត្វចាស់ក្លាសិន សូម្បីនឹងជ្រាបថា ញាណរបស់បុគ្គលនេះនឹងចាស់ក្លាដោយវេលា

ត្រឹមប៉ុណ្ណោះ ទើបទ្រង់ឲ្យសូមឱកាសជាបដល់លើកទី ៣ ។

បទថា **មា ហេវំ កស្សប** បានដល់ កស្សបអ្នកកុំពោលដូច្នោះ ។ ទ្រង់សម្តែងថា ការពោលថា វត្ថុដែលខ្លួនឯងធ្វើហើយ ជាត់ជាទុក្ខ ដូច្នេះ មិនគួរ នរណាៗ ដែលឈ្មោះថា ខ្លួនបង្កើតទុក្ខមិនមាន ។ សូម្បីខាងមុខ ក៏មានន័យដូច្នេះដូចគ្នា ។ បទថា **អធិច្ចសមុប្បន្នំ** បានដល់ កើតឡើងដោយមិនមានហេតុ តាមដែលត្រូវការ ។ បទថា **ឥតិ បុដ្ឋោ សមានោ** បានដល់ ព្រោះហេតុអ្វី ទើបពោលយ៉ាងនោះ ។ ន័យថា អចេលកស្សបនោះ មានសេចក្តីគិតយ៉ាងនេះថា ព្រះមានព្រះភាគកាលទ្រង់ត្រូវសួរដោយន័យមានជាដើមថា វត្ថុដែលខ្លួនឯងធ្វើ ជាទុក្ខឬ ក៏ត្រាស់ថាកុំពោលយ៉ាងនោះ ទ្រង់ត្រូវសួរថា មិនមានឬ ក៏ត្រាស់ថា មាន ទ្រង់ត្រូវសួរថា ព្រះគោតមទ្រង់មិនជ្រាប ទ្រង់មិនឃើញទុក្ខឬ ក៏ត្រាស់ថា តថាគតដឹង ពាក្យអ្វីហ្ន៎ ដែលយើងសួរខុស ដូច្នេះ កាលនឹងជម្រះពាក្យសួររបស់ខ្លួនតាំងពីដើម ទើបពោលយ៉ាងនេះ ។

ក្នុងបទថា **អាចិក្ខតុ ច មេ ភន្តេ ភគវា** នេះ គប្បីជ្រាបសេចក្តីដូចតទៅនេះ ៖ បុគ្គលដែលមានសេចក្តីគោរពក្នុងព្រះសាស្តានឹងមិនពោលថា

**ភវំ** តែទីងពោលថា **ភគវា** ។

[៥០] ពាក្យថា **សោ ករោតិ** ជាដើម ព្រះអង្គត្រាស់ដើម្បីទ្រង់បដិសេធលទ្ធិដែលថា វត្ថុដែលខ្លួនឯងធ្វើជាទុក្ខ ។ ក៏បទថា **សតោ** ក្នុងពាក្យថា **អាទិតោ សតោ** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ ព្រោះដូច្នោះគប្បីជ្រាបខ្លឹមសារដូចតទៅនេះថា **កស្សប** ក្នុងពាក្យថា **សោ ករោតិ សោ បដិសំវេទយតិ** ជាដើម អធិប្បាយសេចក្ដីថា បើដូច្នេះ ក៏គប្បីមានការឃើញក្នុងខាងក្រោយថា វត្ថុដែលខ្លួនឯងធ្វើជាទុក្ខ ។ ក៏ទុក្ខ ក្នុងពាក្យថា **សយំកតំ ទុក្ខំ** នេះ លោកបំណងយកវដ្ដទុក្ខ ។ បទថា **ឥតិ វទំ** នេះ រមែងសម្ពន្ធគ្នាដោយ **អាទិ** សព្ទដំបូង និង **សស្សតំ** សព្ទលំដាប់តមក ។ ក៏សព្ទថា **ទីបេតិ គណ្ហាតិ** នេះ ជាព្រះបាលីដ៏សេសក្នុងទីនេះ ។ ពិតណាស់ លោកអធិប្បាយទុកដូច្នេះថា កាលពោលដូច្នេះ គឺ យ៉ាងនេះ រមែងសម្ដែងដល់សស្សតៈ គឺ ប្រកាន់ដោយសស្សតៈតាំងពីដើម ។ ព្រោះហេតុអ្វី ។ ព្រោះប្រការនោះជាការឃើញរបស់គេ ។ បទថា **ឯតំ បរេ** បានដល់ ប្រកាន់បុគ្គលអ្នកធ្វើ និងវេទកៈ អ្នកសោយថា តែមួយដូចគ្នា អធិប្បាយថា ចូលដល់បុគ្គលអ្នកធ្វើ និងអ្នកសោយនោះថា មានសភាពទៀង ។

ព្រះមានព្រះភាគត្រាស់ពាក្យថា **អញ្ញោ ករោតិ** ជាដើមទុក ក៏ដើម្បីបដិសេធលទ្ធិដែលថា ទុក្ខបុគ្គលដទៃធ្វើ ។ ចំណែកពាក្យថា **អាទិតោ សតោ** នេះ គប្បីប្រមូលមកទុកសួម្បីក្នុងទីនេះ ។ គប្បីជ្រាបសេចក្តីក្នុងប្រការនេះដូចតទៅនេះ ៖ **កស្សប:** ក្នុងពាក្យថា **អញ្ញោ ករោតិ អញ្ញោ បដិសំវេទយតិ** ជាដើម អធិប្បាយសេចក្តីបានថា កាលត្រូវវេទនាដែលសម្បយុត្តដោយឧច្ឆេទទិដ្ឋិ ដែលកើតឡើងក្នុងខាងក្រោយយ៉ាងនេះថា បុគ្គលអ្នកធ្វើដាច់សូន្យក្នុងទីនេះឯង បុគ្គលដទៃរមែងសោយវត្ថុ ដែលបុគ្គលនោះធ្វើហើយដូច្នេះ គ្របសង្កត់ គឺ ចាក់ដោត ក៏នឹងមានលទ្ធិយ៉ាងនេះថា វត្ថុដែលបុគ្គលដទៃធ្វើជាទុក្ខ ។ ពាក្យថា **ឥតិ វទំ** ជាដើម គប្បីប្រកបចូលតាមន័យដែលពោលមក ។

ក្នុងសេចក្តីនេះ មានយោជនា (ការប្រកបសេចក្តី) ដូចតទៅនេះ ៖ ក៏កាលពោលយ៉ាងនេះ រមែងសម្តែងដល់សេចក្តីដាច់សូន្យ គឺ ប្រកាន់ការដាច់សូន្យពីដំបូង ។ ព្រោះហេតុអ្វី ។ ព្រោះប្រការនោះ ជាការឃើញរបស់គេ ។ បទថា **ឯតំ បរេ** សេចក្តីថា ចូលដល់ភាពដាច់សូន្យនោះ ។

បទថា **ឯតេ តេ** បានដល់ កស្សប តថាគតមិនអាស្រ័យទីបំផុត ២

យ៉ាងណា គឺ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ហើយសម្តែងធម៌ តថាគតមិនអាស្រ័យ គឺ លះបង់ បានដល់ មិនជាប់ក្នុងទីបំផុត ២ យ៉ាងនោះ សម្តែងធម៌ដោយផ្លូវកណ្តាល អធិប្បាយថា តាំងនៅក្នុងមជ្ឈិមាបដិបទា សម្តែងធម៌ ។ ប្រសិនបើនឹងមានពាក្យសួរថា ធម៌ប្រការណា ។ ក៏ឆ្លើយថា ព្រោះមានអវិជ្ជាជាបច្ច័យទើបមានសង្ខារ ក៏ក្នុងសេចក្តីនេះសម្តែងផលថា មកពីហេតុ និងសម្តែងការរលត់របស់ផលនោះទុក ព្រោះហេតុរលត់ មិនសម្តែងអ្នកធ្វើ ឬអ្នកសោយណាៗ ទុំះទេ ។ ដោយពាក្យត្រឹមតែប៉ុណ្ណោះ ក៏ជាការបដិសេធបញ្ហាដ៏សេស ។ ក៏លោកហាមបញ្ហាទី ៣ ដោយពាក្យថា **ឧភោ អន្តេ អនុបគម្ម** នេះ ។ ដោយពាក្យថា **អវិជ្ជាបច្ចយា សង្ខារា** នេះ គប្បីជ្រាបថា ទ្រង់បដិសេធការកើតឡើងរឿយៗ និងការមិនដឹង ។

[៥១] លោកប្រាថ្នាកិច្ចការៈក្នុងសម្នាក់របស់ព្រះមានព្រះភាគ ទើបពោលពាក្យថា **លភេយ្យំ** នេះ ពេលនោះ ព្រះមានព្រះភាគទ្រង់សំដៅយកតិត្ថិយបរិវាសដែលព្រះអង្គទ្រង់បញ្ញត្តិទុកក្នុងខន្ធកៈ គឺ បរិវាសដែលអ្នកធ្លាប់ជាអន្យតិត្ថិយតាំងនៅក្នុងសាមណេរភូមិហើយសមាទាន ដោយន័យមានជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកមានឈ្មោះនេះ ធ្លាប់ជា

អន្យតិរ្ថិយ បំណងនឹងបានឧបសម្បទក្នុងព្រះសាសនានេះ ខ្ញុំព្រះអង្គនោះនឹងសូមបរិវាសជាមួយព្រះសង្ឃរហូតអស់ ៤ ខែ ដូច្នេះ ទើបត្រាស់ថា **យោ ខោ កស្សប អញ្ញតិត្ថិយបុព្វោ** ។ ពាក្យថា **បព្វជ្ជំ** ក្នុងបទថា **បព្វជ្ជំ លភេយ្យំ** នោះ ព្រះអង្គត្រាស់ទុកដោយអំណាចនៃពាក្យដែលរៀបរយល្អ ។ ព្រោះមិនត្រូវនៅបរិវាសក៏បានបព្វជ្ជា ។ ចំណែកបុគ្គលដែលត្រូវការនឹងឧបសម្បទ គប្បីបំពេញវត្តបដិបទា ៨ ប្រការ មានការចូលស្រុកជាដើមឲ្យបរិបូណ៌ នៅបរិវាសដោយមិនឲ្យកន្លងវេលា ។ បទថា **អារទ្ធចិត្តា** បានដល់ អ្នកមានចិត្តត្រេកអរ ព្រោះបំពេញវត្ត ៨ ប្រការ ។ ក្នុងប្រការនេះ មានសេចក្ដីសង្ខេបប៉ុណ្ណេះ ។ ចំណែកតិត្ថិយបរិវាសនេះ គប្បីជ្រាបដោយពិស្ដារតាមន័យដែលពោលទុកហើយក្នុងអដ្ឋកថានៃបព្វជ្ជាខន្ធកៈ អដ្ឋកថាវិន័យ ឈ្មោះ **សមន្តបាសាទិកា** ។

ព្រះបាលីក្នុងទីនេះថា **អបិច មយា** ចំណែកក្នុងទីដទៃ ប្រាកដថា **អបិចមេត្ថ** ។ បទថា **បុគ្គលវេមត្តតា វិទិតា** បានដល់ ដឹងសេចក្ដីផ្សេងនៃបុគ្គល ។ លោកសម្ដែងថា ពាក្យនេះថា បុគ្គលនេះ គួរដល់បរិវាស បុគ្គលនេះ មិនគួរដល់បរិវាស ដូច្នេះ ប្រាកដដល់យើង ។ តអំពីនោះព្រះ

កស្សបគិតថា គួរអស្ចារ្យណាស់ ព្រះពុទ្ធសាសនាដែលបុគ្គលជ្រើសរើស កាន់យកវត្ថុដែលគួរប៉ុណ្ណោះ លះបង់វត្ថុដែលមិនគួរ ។ បន្ទាប់មក លោកក៏កើតសេចក្ដីឧស្សាហ៍ឡើងក្នុងការបព្វជ្ជាយ៉ាងក្រៃលែង ទើបក្រាបទូលថា **សចេ ភន្តេ** ។ លំដាប់តមក ព្រះមានព្រះភាគទ្រង់ជ្រាបថា លោកមានសេចក្ដីពេញចិត្តយ៉ាងខ្លាំងក្លា ទើបទ្រង់ព្រះតម្រិះថា កស្សបៈ គួរដល់បរិវាស ដូច្នេះ ទើបត្រាស់ហៅភិក្ខុមួយរូបមក ត្រាស់បង្គាប់ថា ទៅចុះភិក្ខុ ឲ្យកស្សបៈងូតទឹក ឲ្យបព្វជ្ជាហើយនាំមក ។ ភិក្ខុនោះធ្វើតាមព្រះតម្រាស់ហើយ ឲ្យកស្សបៈបួសហើយ ទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ប្រថាប់កណ្ដាលពួកព្រះសង្ឃ ហើយឲ្យកស្សបៈឧបសម្បទ ។

[៥២] ដោយហេតុនោះ លោកទើបពោលថា **អលត្ថ ខោ អចេលោ កស្សបោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ** (អចេលកស្សបៈបានបព្វជ្ជា បានឧបសម្បទាក្នុងសម្នាក់របស់ព្រះមានព្រះភាគហើយ) ។ ពាក្យដ៏សេសមានជាដើមថា **អចិរូបសម្បន្នោ** លោកពោលទុកហើយក្នុងព្រាហ្មណសំយុត្តនោះឯង ។

ចប់អដ្ឋកថា អចេលកស្សបសូត្រទី ៧

# អ ដ្ឋ ក ថា

## តិម្ពរុក្ខសូត្រទី ៨

ក្នុងតិម្ពរុក្ខសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖

[៥៥] ពាក្យថា *សា វេទនា* ជាដើម ត្រាស់ដើម្បីនឹងបដិសេធលទ្ធិដែលថា វត្ថុដែលខ្លួនឯងធ្វើ ជាសុខ និងទុក្ខ ។ ពាក្យថា *សតោ* សូម្បីក្នុងបទថា *អាទិតោ សតោ* នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ ។ ក្នុងសេចក្ដីនេះ មានការសម្ដែងសេចក្ដីដូចតទៅនេះ ៖

តិម្ពរុក្ខ: កាលពាក្យជាដើមថា *សា វេទនា សោ វេទយតិ* មានហើយយ៉ាងនេះ ខាងក្រោយមករមែងមានលទ្ធិដូច្នេះថា វត្ថុដែលខ្លួនឯងធ្វើជាសុខ ជាទុក្ខ និងកាលពោលយ៉ាងនេះ រមែងសម្គាល់ថា វេទនានេះមានសូម្បីក្នុងកាលមុន គឺ សម្ដែងដោយសស្សតទិដ្ឋិ ប្រកាន់ដោយសស្សតទិដ្ឋិ ។ ព្រោះហេតុអ្វី ។ ព្រោះប្រការនោះជាការឃើញរបស់គេ ។ បទថា **ឯតំ បរេ** សេចក្ដីថា ចូលដល់សស្សតទិដ្ឋិនោះ ។ ព្រោះទ្រង់សំដៅយកសេចក្ដីមុន ទើបត្រាស់យ៉ាងនោះ ព្រោះហេតុនោះ ក្នុងអដ្ឋកថា លោកទើប

ប្រកបពាក្យនោះ ហើយសម្តែងសេចក្តីនៃពាក្យនោះ ។ បទថា **ឯវញ្ចាហំ ន វទាមិ** សេចក្តីថា យើងនឹងមិននិយាយយ៉ាងនេះថា **សា វេទនា សោ វេទយតិ** ។ ពាក្យថា **អញ្ញា វេទនា** ជាដើម ត្រាស់ដើម្បីនឹងបដិសេធលទ្ធិដែលថា សុខ និងទុក្ខដែលអ្នកដទៃធ្វើ ។ សូម្បីក្នុងបទនេះ មានការប្រកបសេចក្តីដូចតទៅនេះ ៖ តិម្ពរុក្ខ: កាលពាក្យជាដើមថា **អញ្ញា វេទនា អញ្ញោ វេទយតិ** មានហើយយ៉ាងនេះ ក្រោយមក កាលត្រូវវេទនាដែលសម្បយុត្តជាមួយឧច្ឆេទទិដ្ឋិ ដែលកើតឡើងយ៉ាងនេះថា បុគ្គលអ្នកធ្វើវេទនាក្នុងចំណែកដំបូងដាច់សូន្យ តែវត្ថុដែលខ្លួនឯងធ្វើ អ្នកដទៃសោយ ដូច្នេះ រមែងមានលទ្ធិដូច្នេះថា វត្ថុដែលអ្នកដទៃធ្វើជាសុខ ជាទុក្ខ ដូច្នេះ និងកាលពោលយ៉ាងនេះ រមែងសម្តែងឧច្ឆេទទិដ្ឋិ រមែងប្រកាន់ដោយឧច្ឆេទទិដ្ឋិថា បុគ្គលអ្នកធ្វើមិនមាន វត្ថុដទៃកាន់យកបដិសន្ធិ ។ ព្រោះហេតុអ្វី ។ ព្រោះប្រការនោះ ជាការឃើញរបស់គេ ។ បទថា **ឯតំ បរេ** បានដល់ ចូលដល់ឧច្ឆេទទិដ្ឋិនោះ ។ ក៏ក្នុងទីនេះ លោកនាំបទទាំងនេះមកប្រកបទុកក្នុងអដ្ឋកថាហើយ ។ ព្រះអង្គត្រាស់សុខវេទនា និងទុក្ខវេទនាទុកក្នុងព្រះសូត្រនេះ ដោយប្រការដូច្នេះ និងសុខទុក្ខ ដែលជាវិបាកនោះឯង ក៏ត្រាស់ថា **សមគ្គរ** (ដែល

*ពោលទុកក្នុងព្រះសូត្រនេះដូចគ្នា)* ។

ចប់អដ្ឋកថា តិម្ពរុក្ខសូត្រទី ៨

# អ ដ្ឋ ក ថា

## ពាលបណ្ឌិតសូត្រទី ៩

ក្នុងពាលបណ្ឌិតសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[៥៧] បទថា *អវិជ្ជានីវរណស្ស* បានដល់ ត្រូវអវិជ្ជាពាំង ។ បទថា **ឯវមយំ កាយោ សមុទាគតោ** សេចក្តីថា កាយនេះ ឈ្មោះថា កើតឡើងហើយ ព្រោះត្រូវអវិជ្ជាពាំង និងព្រោះប្រកបដោយតណ្ហាទុំះឯង ដោយអាការយ៉ាងនេះ ។ បទថា **អយញ្ចេវ កាយោ** បានដល់ កាយដែលមានវិញ្ញាណរបស់ខ្លួន របស់បុគ្គលពាលនោះ ។ បទថា **ពហិទ្ធា ច នាមរូបំ** បានដល់ និងកាយដែលមានវិញ្ញាណរបស់បុគ្គលពួកដទៃខាងក្រៅ ។ សេចក្តីនេះគប្បីសម្តែងដោយខន្ធ ៥ និងអាយតនៈ ៦ ទាំងរបស់ខ្លួន និងរបស់អ្នកដទៃ ។ បទថា **ឥត្ថេតំ ទ្វយំ** បានដល់ ពួកពីរនេះ ។ ដោយអាការយ៉ាងនេះ ។ ដោយបទថា **ទ្វយំ បដិច្ច ផស្សោ** នេះ លោកពោលចក្ខុសម្ផស្សជាដើម ព្រោះអាស្រ័យអាយតនៈទាំងពីរចំណែក មានចក្ខុ និងរូបជាដើមទុកក្នុងទីដទៃ តែក្នុងទីនេះលោកសំដៅអាយតនៈខាងក្នុង និងអាយ-

តនៈខាងក្រៅ ន័យថា អាយតនៈទាំងពីរចំណែក ឈ្មោះថា ធំទាំងពីរ ។ បទថា **សឡាយតនានិ** បានដល់ ផស្សាយតនៈ គឺ ហេតុនៃផស្សៈ ៦ ។ បទថា **យេហិ ផុដ្ឋោ** បានដល់ ត្រូវផស្សៈដែលកើតឡើង ព្រោះអាយតនៈដែលជាតួហេតុពួកណាពាល់ត្រូវ ។ ក្នុងបទថា **អញ្ញតរេន** នេះ គប្បីជ្រាបអាយតនៈដទៃៗ ដែលបរិបូណ៌ និងមិនបរិបូណ៌ ។

[៥៨] បទថា **តត្រ** បានដល់ ព្រោះការកើតឡើងត្រង់កាយជាដើមរបស់បុគ្គលពាល និងបណ្ឌិតនោះ ។ បទថា **កោ អធិប្បាយសោ** បានដល់ គឺ អ្វីជាសេចក្ដីព្យាយាមយ៉ាងក្រៃលែង ។

បទថា **ភគវំមូលកា** បានដល់ ព្រះមានព្រះភាគជាមូលនៃធម៌ទាំងនោះ ហេតុនោះ ធម៌ទាំងនោះ ឈ្មោះថា **ភគវំមូលកា** ។ លោកពោលអធិប្បាយទុកដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌របស់ពួកខ្ញុំព្រះអង្គនេះដែលព្រះកស្សបសម្មាសម្ពុទ្ធក្នុងកាលមុនទ្រង់ឲ្យកើតឡើង កាលព្រះអង្គស្ដេចបរិនិព្វានហើយ កន្លងទៅមួយពុទ្ធន្តរ បុគ្គលដទៃសូម្បីជាសមណៈក្ដី ព្រាហ្មណ៍ក្ដី ឈ្មោះថា អាចនឹងឲ្យធម៌ទាំងនេះកើតឡើងមិនបានឡើយ តែធម៌ទាំងនេះ ដែលព្រះមានព្រះភាគទ្រង់ឲ្យកើតឡើងដល់ខ្ញុំព្រះអង្គទាំងឡាយ ។

ព្រោះអាស្រ័យព្រះមានព្រះភាគ ពួកខ្ញុំព្រះអង្គទើបមកដឹង គឺ ចាក់ធ្លុះធម៌ទាំងនេះ ព្រោះហេតុនោះ ធម៌របស់ពួកខ្ញុំព្រះអង្គ ទើបឈ្មោះថា មានព្រះមានព្រះភាគជាមូល ដោយប្រការដូច្នេះ ។ បទថា **ភគវំនេត្តិកា** សេចក្តីថា ក៏ព្រះមានព្រះភាគទ្រង់ណែនាំ បានដល់ ណែនាំធម៌ទាំងឡាយ គឺ ឈ្មោះធម្មៈដោយចំពោះ សម្តែងតាមសេចក្តីពិត ព្រោះហេតុនោះ ធម៌ទាំងឡាយទើបឈ្មោះថា មានព្រះមានព្រះភាគជាអ្នកណែនាំ ។ បទថា **ភគវំបដិស-រណា** សេចក្តីថា ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ កាលមកប្រាកដដល់ព្រះសព្វញ្ញុតញ្ញាណ ឈ្មោះថា រមែងរួមចុះក្នុងព្រះមានព្រះភាគ ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា មានព្រះមានព្រះភាគជាទីរួមចុះ ។ បទថា **បដិសរន្តិ** បានដល់ រមែងប្រជុំ ។ មយ៉ាងទៀត ផស្សៈមក ដោយអំណាចការចាក់ធ្លុះនៃព្រះមានព្រះភាគ ដែលប្រថាប់ត្រង់ពោធិមណ្ឌលស្ថាន ទូលសួរថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះអ្វី ។ ព្រះមានព្រះភាគត្រាស់ថា អ្នកឈ្មោះផស្សៈ ព្រោះអត្ថថា ពាល់ត្រូវ ។ វេទនា... សញ្ញា... សង្ខារ... វិញ្ញាណ... ក៏មកទូលសួរថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះអ្វី ព្រះមានព្រះភាគត្រាស់ថា អ្នកឈ្មោះវិញ្ញាណ ព្រោះអត្ថថា ដឹង

ច្បាស់ ព្រះមានព្រះភាគត្រាស់ឈ្មោះធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដោយចំពោះ តាមសេចក្តីពិត រួមធម៌ទាំងឡាយទុកដោយអាការយ៉ាងនេះ ហេតុនោះ ធម៌ទាំងនោះឈ្មោះថា **ភគវំបដិសរណា** ។ បទថា **ភគវន្តំយេវ បដិភាតុ** សេចក្តីថា សេចក្តីនៃភាសិតនោះចូរប្រាកដ (ជាក់ច្បាស់) ដល់ព្រះមានព្រះភាគតែម្តង អធិប្បាយថា សូមព្រះអង្គមេត្តាត្រាស់សម្តែងធម៌ដល់ពួកខ្ញុំព្រះអង្គចុះ ។

[៥៩] ក្នុងពាក្យថា **សា ចេវ អវិជ្ជា** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

អវិជ្ជា និងតណ្ហានោះ សូម្បីញ៉ាំងកម្មឲ្យប្រព្រឹត្តទៅ នាំបដិសន្ធិមក ហើយរលត់ទៅក៏ពិត សូម្បីយ៉ាងនោះ លោកក៏ពោលពាក្យនេះថា **សា ចេវ អវិជ្ជា សា ចេវ តណ្ហា** ទុកសូម្បីក្នុងទីនេះ ព្រោះអត្ថថា ឃើញសមគួរ ដូចកេសជ្ជៈដែលផឹកថ្ងៃម្សិលមិញ សូម្បីថ្ងៃនេះបរិភោគភោជនចូលទៅ កេសជ្ជៈនោះក៏នៅតែហៅថា កេសជ្ជៈនុ៎ះឯង ដូច្នោះ ។ បទថា **ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ។ បទថា **ទុក្ខក្ខយាយ** បានដល់ ដើម្បីការអស់ទៅនៃវដ្តទុក្ខ ។ បទថា **កាយូបយោគ ហោតិ** បានដល់ ជា

អ្នកចូលដល់បដិសន្ធិកាយដទៃ ។ ដោយបទថា យទិទំ ព្រហ្មចរិយវាសោ នេះ លោកសម្ដែងថា មគ្គព្រហ្មចរិយវាសនេះណា ។ នេះគឺសេចក្ដីប្លែកគ្នារបស់បណ្ឌិត និងជនពាល ។ ដូច្នោះក្នុងព្រះសូត្រនេះ លោកទើបហៅថា បុថុជ្ជនអ្នកនៅមានបដិសន្ធិទាំងអស់ថា ជាបុគ្គលពាល ព្រះខីណាស្រពដែលមិនមានបដិសន្ធិ ហៅថា ជាបណ្ឌិត ។ ចំណែកព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី នរណាៗ មិនគួរហៅថា បណ្ឌិត ឬជនពាល ។ តែបើសេពគប់ ក៏សេពគប់ចំពោះតែបណ្ឌិត ។

ចប់អដ្ឋកថា ពាលបណ្ឌិតសូត្រទី៩

# អ ដ្ឋ ក ថា

## បច្ច័យសូត្រទី ១០

*ក្នុងបច្ច័យសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖*

[៦០] *បទថា* **បដិច្ចសមុប្បាទញ្ច វោ ភិក្ខវេ ទេសេស្សាមិ បដិច្ចសមុប្បន្នេ ច ធម្មេ** *សេចក្តីថា ព្រះសាស្តាទ្រង់ផ្តើមពាក្យទាំងពីរ ក្នុងព្រះសូត្រនេះថា តថាគតនឹងសម្តែងបច្ច័យ និងសភាវធម៌ដែលអាស្រ័យបច្ច័យកើតឡើង ។*

[៦១] *បទថា* **ឧប្បាទា វា តថាគតានំ** *សេចក្តីថា សូម្បីក្នុងខណៈឧប្បត្តិឡើងនៃព្រះតថាគត គឺ កាលព្រះពុទ្ធឧប្បត្តិឡើងក្តី ឈ្មោះថា មានជរា និងមរណៈ ព្រោះមានជាតិជាបច្ច័យ បានដល់ ជាតិនុ៎ះឯងជាបច្ច័យដល់ជរា និងមរណៈ ។ បទថា* **ឋិតាវ សា ធាតុ** *បានដល់ សភាវៈនៃបច្ច័យនោះតាំងនៅហើយ គឺ ក្នុងគ្រាខ្លះ ជាតិនឹងមិនជាបច្ច័យដល់ជរាមរណៈមិនមាន ។ ព្រះអង្គត្រាស់បច្ច័យនោះឯង ដោយបទទាំងពីរនេះ គឺ* **ធម្មដ្ឋិតតា ធម្មនិយាមតា** *ព្រោះធម៌ដែលអាស្រ័យបច្ច័យកើតឡើង រមែងតាំងនៅ*

ព្រោះបច្ច័យ ព្រោះហេតុនោះ បច្ច័យនោះឯង លោកហៅថា **ធម្មដ្ឋិតា** ។ បច្ច័យរមែងកំណត់ធម៌ ព្រោះហេតុនោះ ទើបហៅថា **ធម្មនិយាមតា** ។ បទថា **ឥទប្បច្ចយតា** បានដល់ បច្ច័យនៃជរា និងមរណៈជាដើមទាំងនេះ ឈ្មោះថា ឥទប្បច្ច័យ ។ ឥទប្បច្ច័យនោះឯង ឈ្មោះថា **ឥទប្បច្ចយតា** ។ បទថា **តំ** បានដល់ បច្ច័យនោះ ។ បទថា **អភិសម្ពុជ្ឈតិ** បានដល់ ដឹងដោយញាណ ។ បទថា **អភិសមេតិ** បានដល់ មករួមគ្នាដោយញាណ ។ បទថា **អាចិក្ខតិ** គឺ ប្រាប់ ។ បទថា **ទេសេតិ** បានដល់ សម្តែង ។ បទថា **បញ្ញបេតិ** ប្រែថា ឲ្យដឹង ។ បទថា **បដ្ឋបេតិ** បានដល់ ផ្តើមតាំងក្នុងចំណែកជាប្រធាននៃញាណ ។ បទថា **វិវរតិ** បានដល់ បើកបង្ហាញ ។ បទថា **វិភជតិ** បានដល់ សម្តែងដោយការចែក ។ បទថា **ឧត្តានីករោតិ** គឺ ធ្វើឲ្យប្រាកដ ។ បទថា **បស្សថាតិ ចាហ** បានដល់ ត្រាស់ថា ពួកអ្នកចូរមើល ។ សួរថា គឺអ្វី គឺពាក្យថា **ជាតិបច្ចយា ភិក្ខវេ ជរាមរណំ** ជាដើម ។ បទថា **ឥតិ ខោ ភិក្ខវេ** ជា **ឯវំ ខោ ភិក្ខវេ** ។ បទថា **យា តត្រ** បានដល់ ក្នុងពាក្យថា **ជាតិបច្ចយា ជរាមរណំ** ជាដើមនោះណា ។ បទថា **តថតា** ជាដើម ជាវេវចនៈរបស់បច្ចយាការនុ៎ះឯង ។ បច្ចយាការនោះ លោកពោល

ថា **តថតា** (សេចក្តីពិតយ៉ាងនោះ) ព្រោះធម៌នោះៗ កើតឡើងដោយបច្ច័យ ទាំងនោះមិនលើសមិនខ្វះ ហៅថា **អវិតថតា** ព្រោះកាលបច្ច័យចូលដល់ការសោមគ្គី ធម៌ទាំងឡាយដែលកើតអំពីបច្ច័យនោះ ត្រឹមតែមួយគ្រា ក៏មិនកើតឡើង ។ ហៅថា **អនញ្ញថតា** ព្រោះធម៌ដទៃមិនកើតអំពីបច្ច័យធម៌ដទៃ ហៅថា **ឥទប្បច្ចយតា** ព្រោះជាបច្ច័យ ឬជាទីប្រជុំបច្ច័យនៃជរានិងមរណៈជាដើម ក្នុងប្រការនេះ មានវិមសារចំពោះពាក្យដូចតទៅនេះ ៖ បច្ច័យនៃធម៌ទាំងនេះ ឈ្មោះថា **ឥទប្បច្ចយា** **ឥទប្បច្ចយា** នុ៎ះឯង ឈ្មោះថា **ឥទប្បច្ចយតា** ម្យ៉ាងទៀត ទីរួមនៃ **ឥទប្បច្ចយា** ឈ្មោះថា **ឥទប្បច្ចយតា** ។ ក៏លក្ខណៈក្នុងពាក្យថា **ឥទប្បច្ចយតា** នេះ គប្បីជ្រាបអំពីគម្ពីរសព្ទសាស្ត្រ ។

[៦២] បទថា **អនិច្ចំ** ប្រែថា មិនទៀង ព្រោះអត្ថថា មានហើយត្រឡប់មិនមាន ។ ក៏ពាក្យថា **អនិច្ចំ** ក្នុងទីនេះ សំដៅយកធម្មៈមិនទៀងតែដែលឈ្មោះថា មិនទៀង ព្រោះខន្ធដែលមានសភាពមិនទៀង មានជរាមរណៈ ។ សូម្បីក្នុងសង្ខតធម៌ជាដើម ក៏ន័យនេះដូចគ្នា ។ ចំណែកបទថា **សង្ខតំ** ក្នុងទីនេះ បានដល់ ធ្វើរួមគ្នាជាមួយបច្ច័យទាំងឡាយ ។ បទថា

បដិច្ចសមុប្បន្នំ បានដល់ ដែលអាស្រ័យបច្ច័យកើតឡើង ។ បទថា **ខយ-ធម្មំ** បានដល់ មានការអស់ទៅជាសភាវៈ ។ បទថា **វយធម្មំ** បានដល់ មានការបែកធ្លាយទៅជាសភាវៈ ។ បទថា **វិរាគធម្មំ** បានដល់ មានការប្រាសចាកត្រេកអរជាសភាវៈ ។ បទថា **និរោធធម្មំ** បានដល់ មានការរលត់ស្និទ្ធជាសភាវៈ ។ សូម្បីជាតិមិនទៀង ក៏គប្បីជ្រាបតាមន័យដែលពោលមកហើយនុ៎ះឯង ។ ក៏ម្យ៉ាងទៀត បទថា **អនិច្ចំ** ក្នុងសេចក្តីនេះរមែងត្រូវដូចគ្នា ដោយបរិយាយមួយ ព្រោះលោកឃើញជនកប្បច្ច័យ ក្នុងលក្ខណៈដែលមានសភាវៈប្រព្រឹត្តទៅតាមកិច្ច ។ ភពជាដើម ក៏មានការមិនទៀងជាដើម ជាសភាវៈ ។

[៦៣] បទថា **សម្មប្បញ្ញាយ** បានដល់ មគ្គប្បញ្ញាព្រមដោយវិប-ស្សនា ។ បទថា **បុព្វន្តំ** បានដល់ កន្លងទៅមុន ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អហោសិ នុខោ** ជាដើម ដូចតទៅនេះ ៖

តថាគតអាស្រ័យអាការដែលទៀងថា យើងមានហើយហ្ន៎ និងអាការដែលអាស្រ័យគ្នាកើតឡើង ទើបសង្ស័យក្នុងអតីតថា ខ្ញុំមាន ឬមិនមាន មិនគប្បីពោលថា អ្វីជាហេតុ បុគ្គលពាលបុថុជ្ជន រមែងប្រព្រឹត្តតាមតែនឹង

ប្រព្រឹត្តទៅដូចមនុស្សឆ្កួត ។ បទថា **កី នុ ខោ អហោសឹ** បានដល់ អាស្រ័យការកើតឡើងនៃជាតិ និងភេទ ទើបសង្ស័យថា យើងជាក្សត្រិយ៍ ឬព្រាហ្មណ៍ វេស្សៈ សូទ្រៈ គ្រហស្ថ បព្វជិត ទេវតា ឬមនុស្សបុគ្គលណាមួយ ។ បទថា **កថំ នុ ខោ** បានដល់ អាស្រ័យអាការនៃសណ្ឋាន ហើយរមែងសង្ស័យថា យើងជាមនុស្សខ្ពស់ ឬជាមនុស្សទាប ស ខ្មៅ ឬកណ្តាលជាដើម បុគ្គលណាមួយ ។ តែអាចារ្យពួកខ្លះពោលថា អាស្រ័យទិដ្ឋិដែលថា ព្រះឥស្សរបណ្តាលជាដើមទើបសង្ស័យ ដោយហេតុថា ព្រោះហេតុអ្វីហ្ន៎ យើងទើបបានជា (យ៉ាងនោះ) ។ បទថា **កឹ ហុត្វា កឹ អហោសឹ** សេចក្តីថា អាស្រ័យជាតិជាដើម យើងបានជាក្សត្រិយ៍ឬ ហើយទើបសង្ស័យថា ខ្លួនជាបុគ្គលដទៃរឿយៗ ទៅថា យើងជាក្សត្រិយ៍ហើយ ជាព្រាហ្មណ៍ឬ ។ល។ ជាទេវតាហើយ ជាមនុស្ស ។ តែពាក្យថា **អទ្ធានំ** ក្នុងទីគ្រប់កន្លែង ជាឈ្មោះរបស់កាល ។ បទថា **អបរន្តំ** បានដល់ ទីបំផុត ដែលមិនទាន់មកដល់ ។ បទថា **ភវិស្សាមិ នុ ខោ ននុ ខោ** សេចក្តីថា អាស្រ័យអាការទៀង និងអាការដាច់សូន្យ ទើបសង្ស័យថា ខ្លួនមាន និងមិនមាន ក្នុងអនាគត ។ ចំណែកដ៏សេសក្នុងសេចក្តីនេះ ក៏មានន័យដូចពោលមកហើយ ។

បទថា **ឯតរហិ វា បច្ចុប្បន្នំ អទ្ធានំ** សេចក្ដីថា ឬកាន់យកបច្ចុប្បន្ន-កាលសូម្បីទាំងអស់ ផ្ដើមតាំងពីការបដិសន្ធិក្នុងកាលឥឡូវនេះ ដរាបដល់ចុតិ ។ បទថា **អជ្ឈត្តំ កថំកថី ភវិស្សតិ** បានដល់ ជាអ្នកសង្ស័យក្នុងខន្ធរបស់ខ្លួន ។ ដោយបទថា **អហំ នុខោស្មិ** សេចក្ដីថា សង្ស័យថា ខ្លួនមានឬ ។ សួរថា ប្រការនោះគួរឬ ។ នឹងចាំបាច់គិតអ្វីក្នុងប្រការដែលថា គួរមិនគួរនេះ ។ម្យ៉ាងទៀត ក្នុងសេចក្ដីនេះលោកនាំរឿងនេះមកជាឧទាហរណ៍ដូចតទៅនេះ ៖

បានឮមកថា ចូឡមាតាមានបុត្រក្បាលត្រងោល ។ មហាមាតាមានបុត្រក្បាលមិនត្រងោល ។ មាតាទាំងពីរក៏តុបតែងឲ្យបុត្រនោះរឿងៗ ខ្លួន ។ បុត្រម្នាក់ក្រោកឡើង គិតថា យើងជាកូនរបស់ចូឡមាតាឬ ។ បើដូច្នេះរមែងសង្ស័យថា យើងជានរណាហ្ន៎ ។ ដោយបទថា **នោ នុខោស្មិ** សេចក្ដីថា សង្ស័យថា ខ្លួនមិនមាន ។ សូម្បីក្នុងសេចក្ដីនេះ ក៏មានរឿងនេះជាឧទាហរណ៍ ។

បានឮមកថា មានបុរសម្នាក់ កាលនឹងចាប់ត្រី ទើបកាប់ជើងរបស់ខ្លួន ដែលត្រជាក់ព្រោះឈរក្នុងទឹកយូរ ដោយគិតថា ជាត្រី ។ បុគ្គលម្នាក់

ទៀតនៅមើលស្រែក្បែរព្រៃជាទីចោលសាកសព ខ្មាចខ្មោច ទើបដេកបញ្ឈរ ជន្គង់ ពេលគេភ្ញាក់ឡើង គិតថា ជន្គង់ទាំង ២ របស់ខ្លួនជាយក្ខ ២ នាក់ ទើបកាប់យ៉ាងប្រញាប់ ។ ដោយប្រការដូចពោលមកនេះ ទើបកើតមាន សេចក្ដីសង្ស័យថា យើងឬមិនមែនហ្ន៎ ។

បទថា កឹ នុខោស្មិ សេចក្ដីថា ជាក្សត្រិយ៍ហើយ ក៏សង្ស័យថាខ្លួន ឯងជាក្សត្រិយ៍ឬ ។ ក្នុងពាក្យដ៏សេសក៏មានន័យដូច្នេះ ។ ក៏បុគ្គលដែល ជាទេវតា ឈ្មោះថា នឹងមិនដឹងថា ខ្លួនឯងជាទេវតាមិនមាន តែទេវតា នោះ ក៏រមែងសង្ស័យដោយន័យមានជាដើមថា យើងមានរូប ឬមិនមាន រូប ។ ប្រសិនបើមានពាក្យសួរថា ព្រោះហេតុអ្វី ក្សត្រិយ៍ជាដើម ទើបមិន ដឹងហ្ន៎ ។ ឆ្លើយថា ព្រោះក្សត្រិយ៍ជាដើមនោះ កើតក្នុងត្រកូលនោះៗ មិនបានប្រចក្សច្បាស់ ។ មា្យ៉ាងទៀត ពួកគ្រហស្ថសម្គាល់ខ្លួនថាជាបព្វជិត ដែលកាន់លទ្ធិនិកាយបោតលកៈជាដើម សូម្បីបព្វជិតក៏សម្គាល់ខ្លួនឯងថា ជាគ្រហស្ថ ដោយន័យមានជាដើមថា កម្មរបស់យើងកម្រើកឬទេហ្ន៎ ។ មា្យ៉ាងទៀត ពួកមនុស្ស ក៏សម្គាល់ថា ខ្លួនជាទេវតាដូចព្រះរាជាដូច្នោះ ។ បទថា កថំ នុ ខោស្មិ ក៏មានន័យតាមដែលពោលហើយនុ៎ះឯង ។ គប្បី

ជ្រាបសេចក្តីក្នុងប្រការនេះតែម្យ៉ាងថា បុគ្គលប្រកាន់ថា ដែលឈ្មោះថា ជីវៈ មានទៅក្នុងខាងក្នុងដូច្នេះហើយ អាស្រ័យអាការនៃសណ្ឋានរបស់ជីវៈនោះ កាលនឹងសង្ស័យថា យើងជាអ្នកខ្ពស់ ឬថា មានអាការជាអ្នកតឿ ៤ ហត្ថ ៦ ហត្ថ ៨ ហត្ថ ១៦ ហត្ថជាដើមអ្នកណាមួយ ទើបសង្ស័យថា **កថំ នុ ខោស្មិ** ។ តែដែលឈ្មោះថា អ្នកមិនដឹងសរីរៈសណ្ឋានដែលជាបច្ចុប្បន្ន គង់មិនមាន ។ បទថា **កុតោអាគតោ សោ កុហឹ គាមី ភវិស្សតិ** សេចក្តីថា កាលសង្ស័យឋានៈដែលមក ដែលទៅនៃអត្តភាព ទើបសង្ស័យយ៉ាងនេះ ។ ព្រះសោតាបន្ន លោកបំណងយកក្នុងទីនេះថា **អរិយសាវកស្ស** ចំណែកព្រះអរិយបុគ្គល ៣ ពួកក្រៅអំពីនេះ មិនបានហាមទុកឡើយ ។

ចប់អដ្ឋកថា បច្ចយសូត្រទី ១០

## ចប់អាហារវគ្គ ទី ២

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា


១-អដ្ឋកថាអាហារសូត្រ ២-អដ្ឋកថាផគ្គុនសូត្រ
៣-អដ្ឋកថាបឋមសមណព្រាហ្មណសូត្រ ៤-អដ្ឋកថាទុតិយសមណព្រាហ្មណសូត្រ
៥-អដ្ឋកថាកច្ចានគោត្រសូត្រ ៦-អដ្ឋកថាធម្មកថិកសូត្រ
៧-អដ្ឋកថាអចេលកស្សបសូត្រ ៨-អដ្ឋកថាតិម្ពរុក្ខសូត្រ
៩-អដ្ឋកថាពាលបណ្ឌិតសូត្រ ១០-អដ្ឋកថាបច្ច័យសូត្រ

# ទសពលវគ្គ ទី ៣

## អ ដ្ឋ ក ថា

### បឋមទសពលសូត្រទី ១

[៦៤] *ទសពលសូត្រទី ១ មិនមានអដ្ឋកថាអធិប្បាយ ។*

# អ ដ្ឋ ក ថា

## ទុតិយទសពលសូត្រទី ២

[៦៥] គប្បីជ្រាបសេចក្ដីសង្ខេបនៃទសពលសូត្រទី ២ ប៉ុណ្ណោះដូច្នេះ ។ សូត្រទី ២ ព្រះមានព្រះភាគត្រាស់ដោយអំណាចព្រះអធ្យាស្រ័យរបស់ព្រះអង្គ ។ បណ្ដាបទទាំងនោះ បទថា **ទសពលសមន្នាគតោ** ប្រែថា ទ្រង់ប្រកបដោយកម្លាំង ១០ ធម្មតាពលៈនេះមាន ២ គឺ កាយពលៈ កម្លាំងព្រះកាយ ១ ញាណពលៈ កម្លាំងព្រះញាណ ១ ក្នុងពលៈទាំង ២ នោះ កាយពលៈរបស់ព្រះតថាគត គប្បីជ្រាបតាមត្រកូលដំរី ១០ ត្រកូល ដែលព្រះបុរាណាចារ្យទាំងឡាយពោលទុកថា ៖

កាឡាវកញ្ច គង្គេយ្យំ បណ្ឌរំ តម្ពបិង្គលំ គន្ធំ
មង្គលហេមញ្ច ឧបោសថំ ឆទ្ទន្តិមេ ទស ។

ដំរីទាំង ១០ ត្រកូលនេះ គឺ កាឡាវកៈ ១ គង្គេយ្យៈ ១ បណ្ឌរៈ ១ តម្ពៈ ១ បិង្គលៈ ១ គន្ធៈ ១ មង្គលៈ ១ ហេមៈ(១) ១ ឧបោសថៈ ១ ឆទ្ទន្តៈ ១ ។

បណ្ដាដំរីទាំង ១០ ត្រកូលនោះ គប្បីឃើញថា ត្រកូលដំរីដោយប្រក្រតីឈ្មោះថា កាឡាវក: ។

កម្លាំងកាយរបស់បុរស ១០ នាក់ ស្មើកម្លាំងដំរីត្រកូលកាឡាវក: ១ ។

កម្លាំងរបស់ដំរីត្រកូលកាឡាវក: ១០ ស្មើកម្លាំងដំរីត្រកូលគង្គេយ្យ: ១ ។

កម្លាំងដំរីត្រកូលគង្គេយ្យ: ១០ ស្មើកម្លាំងដំរីត្រកូលបណ្ឌរ: ១ ។

កម្លាំងដំរីត្រកូលបណ្ឌរ: ១០ ស្មើកម្លាំងដំរីត្រកូលតម្ព: ១ ។

កម្លាំងដំរីត្រកូលតម្ព: ១០ ស្មើកម្លាំងដំរីត្រកូលបិង្គល: ១ ។

កម្លាំងដំរីត្រកូលបិង្គល: ១០ ស្មើកម្លាំងដំរីត្រកូលគន្ធ: ១ ។

កម្លាំងដំរីត្រកូលគន្ធ: ១០ ស្មើកម្លាំងដំរីត្រកូលមង្គល: ១ ។

កម្លាំងដំរីត្រកូលមង្គល: ១០ ស្មើកម្លាំងដំរីត្រកូលហេមវត:[១] ១ ។

កម្លាំងដំរីត្រកូលហេមវត: ១០ ស្មើកម្លាំងដំរីត្រកូលឧបោសថ: ១ ។

កម្លាំងដំរីត្រកូលឧបោសថ: ១០ ស្មើកម្លាំងដំរីត្រកូលឆទ្ទន្ត: ១ ។

កម្លាំងដំរីត្រកូលឆទ្ទន្ត: ១០ ស្មើនឹងកម្លាំងរបស់ព្រះតថាគតតែមួយ

---

១- គាថា ជាហេម: តែអត្ថជា ហេមវត:.

ព្រះអង្គ ។

កម្លាំងព្រះតថាគតនេះឯង លោកហៅថា កម្លាំងដែលរាប់បានថា ព្រះនារាយណ៍ ដូច្នេះក៏មាន ។ កម្លាំងព្រះនារាយណ៍នេះ គណនាដោយកម្លាំងដំរីតាមប្រក្រតី ក៏ស្មើនឹងកម្លាំងដំរីមួយពាន់កោដិ តែគណនាដោយបុរស ក៏ស្មើនឹងកម្លាំងបុរសដប់ពាន់កោដិ ។ នេះគប្បីជ្រាបថា ជាកម្លាំងព្រះកាយរបស់ព្រះតថាគត ។ តែកម្លាំងព្រះកាយដែលមិនបានចាត់សង្គ្រោះទុក ក្នុងបទថា ***ទសពលសមន្នាគតោ*** នេះ ។ ពិតហើយ ការកំណត់ដឹងទុក្ខក្តី ការលះសមុទ័យក្តី ការចម្រើនមគ្គក្តី ការធ្វើឲ្យច្បាស់ផលក្តី អាស្រ័យកម្លាំងព្រះកាយនេះមិនមាន តែមានកម្លាំងមួយ៉ាងទៀត ឈ្មោះញាណពលៈ កម្លាំងព្រះញាណ ១០ ប្រការ ដោយអត្ថថា មិនញាប់ញ័រ និងដោយអត្ថថា ឧបត្ថម្ភក្នុងឋានៈ ១០ ប្រការ ។ ទ្រង់សំដៅដល់ទសពលញ្ញាណនេះ ទើបត្រាស់ថា ***ទសពលសមន្នាគតោ*** ដូច្នេះ ។

សួរថា ក៏ទសពលញ្ញាណនោះ តើដូចម្តេច ។

ឆ្លើយថា ទ្រង់ដឹងឋានៈ និងអឋានៈជាដើម តាមសេចក្តីពិត ។ គឺទ្រង់ដឹងឋានៈថាជាឋានៈ និងអឋានៈថាជាអឋានៈ ១ ទ្រង់ដឹងវិបាករបស់កម្ម

សមាទាន ទាំងអតីតអនាគត និងបច្ចុប្បន្ន ដោយឋានៈ ដោយហេតុ តាមសេចក្តីពិត ១ ទ្រង់ដឹងវត្តបដិបត្តិដែលប្រព្រឹត្តទៅក្នុងឋានៈទាំងពួង ១ ទ្រង់ដឹងលោកដោយអនេកធាតុ និងនានាធាតុ ១ ។ល។ ទ្រង់ដឹងអធិមុត្តិអធ្យាស្រ័យរបស់សត្វទាំងឡាយ ១ ទ្រង់ដឹងឥន្ទ្រិយរបស់សត្វទាំងនោះថា ចាស់ក្លា និងទន់ខ្សោយ ១ ទ្រង់ដឹងសេចក្តីសៅហ្មងផូរផង់ និងការចេញរបស់ឈានវិមោក្ខ សមាធិ និងសមាបត្តិ ១ ទ្រង់ដឹងខន្ធដែលធ្លាប់អាស្រ័យក្នុងកាលមុនរបស់សត្វទាំងនោះ ១ ទ្រង់ដឹងចុតិ និងឧប្បត្តិរបស់សត្វទាំងឡាយ ១ ទ្រង់ដឹងធម៌ជាទីអស់អាសវៈ ១ ។

ចំណែកក្នុងអភិធម្ម មកដោយពិស្តារដោយន័យថា ក្នុងលោកនេះ ព្រះតថាគតទ្រង់ជ្រាបច្បាស់តាមសេចក្តីពិត នូវឋានៈថាជាឋានៈ និងអឋានៈថាជាអឋានៈ ក៏ចាត់ជាតថាគតពលៈរបស់ព្រះតថាគត ។ ព្រះតថាគតទ្រង់អាស្រ័យអឋានៈ ក៏ចាត់ជាតថាគតពលៈរបស់ព្រះតថាគត ។ ព្រះតថាគតទ្រង់អាស្រ័យពលៈណា រមែងប្តេជ្ញានូវឋានៈដ៏ប្រសើរបំផុត ទ្រង់បន្លឺសីហនាទប្រកាសព្រហ្មចក្កក្នុងបរិស័ទទាំងឡាយ ដូច្នេះជាដើម ។ សូម្បីកថាពណ៌នាសេចក្តី លោកពោលហើយដោយអាការគ្រប់យ៉ាងរបស់ពលៈទាំងនោះទុក

ក្នុងអដ្ឋកថាវិភង្គ និងបបញ្ចសូទនីអដ្ឋកថាមជ្ឈិមនិកាយ ។ កថាពណ៌នាសេចក្ដីនោះ ក៏គប្បីកាន់យកតាមន័យដែលលោកពោលទុកហើយក្នុងអដ្ឋកថាទាំងនោះ ។ ញាណដែលជាបដិបក្ខចំពោះសេចក្ដីញាប់ញ័រ ឈ្មោះថា **វេសារជញ្ញាណ** ក្នុងពាក្យថា **ចតូហិ ច វេសារជ្ជេហិ** ពាក្យនេះជាឈ្មោះរបស់ព្រះញាណដែលសម្រេចដោយសោមនស្ស ដែលកើតឡើងដល់ព្រះតថាគតអ្នកទ្រង់ពិចារណាឃើញភាពជាអ្នកអង់អាចក្នុងឋានៈទាំង ៤ ។ ក្នុងឋានៈទាំង ៤ ដូចម្ដេច ។ គឺ ក្នុងរឿងដែលជំទាស់ថា កាលទ្រង់ប្ដេជ្ញាថាជាព្រះសម្មាសម្ពុទ្ធ ធម៌ទាំងនេះទ្រង់ក៏មិនបានត្រាស់ដឹងដ៏ក្រៃលែងដោយព្រះអង្គឯង ដូច្នេះជាដើម ។ ក្នុងសេចក្ដីនោះ មានបាលីដូច្នេះថា ម្នាលភិក្ខុទាំងឡាយ វេសារជ្ជញ្ញាណ ៤ ទាំងនេះ ៤ ទាំងនេះ ដូចម្ដេច ។ ៤ ទាំងនេះ គឺ នរណាៗ ក្នុងលោក មិនថា សមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម នឹងជំទាស់តថាគតដោយសហធម៌ ក្នុងប្រការថា កាលតថាគតប្ដេជ្ញាថាជាព្រះសម្មាសម្ពុទ្ធ ធម៌ទាំងនេះ តថាគតក៏មិនបានត្រាស់ដឹងដ៏ក្រៃលែងដោយខ្លួនឯងហើយ ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនិមិត្តសូម្បីប្រការនេះឡើយ តថាគតកាលមិនឃើញនិមិត្តនោះ ទើបជាអ្នកដល់សេចក្ដីក្សេម

ដល់សេចក្តីមិនខ្វាច ដល់នូវភាពជាអ្នកអង់អាច នរណាៗ ក្នុងលោកនេះ ។បេ។ ជំទាស់នឹងតថាគតក្នុងប្រការដែលថា កាលតថាគតប្តេជ្ញាថា ជាខីណាស្រព អាសវៈទាំងនេះរបស់តថាគតក៏នៅមិនទាន់អស់ ។បេ។ ធម៌ដែលតថាគតពោលថា ធ្វើអន្តរាយ ក៏មិនអាចធ្វើអន្តរាយដល់អ្នកសេពបានពិត ។បេ។ ធម៌ដែលតថាគតសម្តែងដើម្បីប្រយោជន៍ដល់បុគ្គលណា ក៏មិននាំបុគ្គលនោះ ដែលបដិបត្តិតាមធម៌នោះ ឲ្យអស់ទុក្ខដោយប្រពៃបានពិត ។បេ។ តថាគតកាលមិនឃើញនិមិត្តនោះ ទើបជាអ្នកដល់នូវសេចក្តីក្សេម ដល់នូវសេចក្តីមិនខ្វាច ដល់នូវភាពជាអ្នកអង់អាច ដូច្នេះ ។ បទថា **អាសភណ្ឋានំ** បានដល់ ឋានៈដ៏ប្រសើរបំផុត ឋានៈដែលខ្ពស់បំផុត ឬឋានៈរបស់ព្រះពុទ្ធទាំងឡាយអង្គមុនៗ ដ៏ប្រសើរ អធិប្បាយថា ឋានៈរបស់ព្រះពុទ្ធទាំងនោះ ។ ន័យមួយទៀត មេគោហ្វូង ១០០ ឈ្មោះថា ឧសភៈ មេគោហ្វូង ១,០០០ ឈ្មោះថា វសភៈ ។ ឬថា មេហ្វូងគោ ១០០ ក្រោល ឈ្មោះថា ឧសភៈ ។ មេហ្វូងគោ ១,០០០ ក្រោល ឈ្មោះថា វសភៈ ។ គោដែលប្រសើរបំផុតជាងគោទាំងនោះ អត់ទ្រាំនឹងអន្តរាយបានគ្រប់យ៉ាង ពណ៌ស គួរជ្រះថ្លា នាំការៈជារបស់ធ្ងន់បានច្រើន មិនតក់ស្លុត ញាប់ញ័រ សូម្បីព្រោះសំឡេង

វន្ទះ ១០០ ជង ឈ្មោះថា និសភៈ ។ គោនិសភៈនោះ លោកសំដៅយកថា ឧសភៈ ។ ពិតហើយ ពាក្យនេះ ជាពាក្យហៅគោឧសុភៈនោះដោយបរិយាយ ឋានៈនេះជារបស់គោឧសុភៈ ហេតុនោះ ទើបឈ្មោះថា អាសភៈ ។ បទថា **ឋានំ** បានដល់ កំណត់ទន្រ្ទំផែនដីដោយជើងទាំង ៤ តែក្នុងទីនេះ ប្រៀបបីដូចគោអាសភៈ ហេតុនោះទើបឈ្មោះថា អាសភៈ ដូចជា គោឧសុភៈ ពោលគឺ គោនិសភៈ ប្រកបដោយឧសភពលៈ កម្លាំងគោឧសុភៈ ទន្រ្ទំផែនដីដោយជើងទាំង ៤ ឈរដោយឋានៈដែលមិនញាប់ញ័រ យ៉ាងណា សូម្បីព្រះតថាគត ទ្រង់ប្រកបដោយតថាគតពលៈ កម្លាំងព្រះតថាគត ទ្រង់ទន្រ្ទំផែនដី គឺ បរិស័ទ ៨ ដោយព្រះបាទ គឺ វេសារជ្ជញ្ញាណ ៤ ទ្រង់មិនញាប់ញ័រដោយសត្រូវ ពួកអមិត្តណាៗ ក្នុងលោក ទាំងទេវលោក ទ្រង់ប្រថាប់ឈរដោយឋានៈដែលមិនញាប់ញ័រ ក៏ដូច្នោះ ក៏ព្រះតថាគតកាលទ្រង់ប្រថាប់ឈរយ៉ាងនោះ ក៏ទ្រង់ប្តេជ្ញាចូលដល់មិនពោលលានូវអាសភៈឋានៈ ឋានៈដ៏ប្រសើរបំផុត ទ្រង់ដាក់អាសភឋានៈទុកក្នុងព្រះអង្គ ។ ដោយហេតុនោះ ទើបត្រាស់ថា **អាសភណ្ឋានំ បដិជានាតិ** ដូច្នេះ ។ បទថា **បរិសាសុ** បានដល់ បរិស័ទ ៨ ទាំងនេះ មហាសីហនាទសូត្រថា ម្នាល

សារីបុត្រ បរិស័ទ ៨ ទាំងនេះ គឺ ខត្តិយបរិស័ទ ព្រាហ្មណបរិស័ទ គហ-បតីបរិស័ទ សមណបរិស័ទ ចាតុម្មហារាជិកាបរិស័ទ តាវតឹង្សបរិស័ទ មារបរិស័ទ ព្រហ្មបរិស័ទ ។ បទថា **សីហនាទំ នទតិ** បានដល់ ទ្រង់បន្លឺសំឡេងប្រសើរបំផុត សំឡេងដែលមិនគួរខ្លាច សំឡេងដែលមិនអ្នកណាដូច ឬបន្លឺសំឡេងដូចសំឡេងរាជសីហ៍ ។ គប្បីសម្តែងសេចក្តីនេះ ដោយមហាសីហនាទសូត្រ ។ ប្រៀបដូចរាជសីហ៍ បានឮថា សីហៈ ព្រោះអត់ទ្រាំនិងការប្រមាញ់សត្វ យ៉ាងណា ព្រះតថាគត លោកហៅថា សីហៈ ក៏ព្រោះទ្រង់អត់ធន់ចំពោះលោកធម៌ទាំងឡាយ និងទ្រង់កម្ចាត់បរប្បវាទ ការពោលប្រទូស្តរបស់អ្នកដទៃ ក៏ដូច្នោះ ។ សំឡេងរាជសីហ៍ដែលពោលយ៉ាងនេះឈ្មោះថា **សីហនាទ** ។ ក្នុងសេចក្តីនោះ ព្រះតថាគតទ្រង់ប្រកបដោយកម្លាំងដូចរាជសីហ៍ ទ្រង់អង់អាចក្នុងទីទាំងពួង ប្រាសចាកការព្រឺរោមព្រឺស្បែក ទ្រង់បន្លឺសីហនាទដូចរាជសីហ៍ ។ រាជសីហ៍ គឺ ព្រះតថាគត ទ្រង់ប្រកបដោយកម្លាំងរបស់ព្រះតថាគត ទ្រង់អង់អាចក្នុងបរិស័ទទាំង ៨ ទ្រង់បន្លឺព្រះធម៌ទេសនាដ៏ប្រសើរ មានវិធីផ្សេងៗ ដោយន័យថា ដូច្នេះរូបជាដើម គឺ សីហនាទ ដែលព្រមដោយកាពល្អស្អាត ។ ដោយហេតុនោះ ទើបត្រាស់

ថា **បរិសាសុ សីហនាទំ នទតិ** ។ ក្នុងបទថា **ព្រហ្មចក្កំ បវត្តេតិ** នេះ បទថា **ព្រហ្មំ** បានដល់ ប្រសើរបំផុត ខ្ពស់បំផុត បរិសុទ្ធិ ។ ពាក្យនេះ ជាឈ្មោះរបស់ព្រះធម្មចក្រ ។ ព្រះធម្មចក្រនោះ មាន ២ គឺ **បដិវេធ-ញ្ញាណ ១ ទេសនាញាណ ១** ។ ក្នុងញាណ ២ យ៉ាងនោះ ញាណដែល បញ្ញាអប់រំនាំអរិយផលមកឲ្យព្រះអង្គ ឈ្មោះថា **បដិវេធញ្ញាណ** ។ ញាណ ដែលករុណាអប់រំនាំអរិយផលមកឲ្យពួកសាវក ឈ្មោះថា **ទេសនាញាណ** ។ ក្នុងញាណ ២ យ៉ាងនោះ **បដិវេធញ្ញាណ** មាន ២ គឺ ដែលកំពុងកើតឡើង ១ ដែលកើតឡើងហើយ ១ ពិតណាស់ បដិវេធញ្ញាណនោះ រាប់តាំងពី ស្តេចទ្រង់ចេញព្រះផ្នួសរហូតដល់ព្រះអរហត្តមគ្គ ឈ្មោះថា **កំពុងកើតឡើង** ។ ដែលកើតឡើងក្នុងខណៈអរហត្តផល ឈ្មោះថា **កើតឡើងហើយ** ។ រាប់ តាំងពីកពតុសិតរហូតដល់អរហត្តមគ្គត្រង់មហាពោធិបល្ល័ង្ក ឈ្មោះថា **កំពុង កើតឡើង** ។ ដែលកើតឡើងក្នុងខណៈអរហត្តផល ឈ្មោះថា **កើតឡើង ហើយ** ។ រាប់តាំងពីព្រះពុទ្ធព្រះនាមថា ទីបង្ករ រហូតដល់អរហត្តមគ្គ ឈ្មោះ ថា **កំពុងកើតឡើង** ។ ដែលកើតឡើងក្នុងខណៈអរហត្តផល ឈ្មោះថា **កើតឡើងហើយ** ។ ទេសនាញាណមាន ២ គឺ កំពុងប្រកាស ១ ប្រកាស

ហើយ ១ ។ ពិតណាស់ ទេសនាញាណនោះ ដែលប្រកាសរហូតដល់សោតាបត្តិមគ្គរបស់ព្រះអញ្ញាកោណ្ឌញ្ញៈ ឈ្មោះថា **កំពុងប្រកាស** ។ ដែលប្រកាសក្នុងខណៈសោតាបត្តិផល ឈ្មោះថា **ប្រកាសហើយ** ។ ក្នុងញាណទាំង ២ នោះ បដិវេធញ្ញាណជាលោកុត្តរៈ ។ ទេសនាញាណជាលោកិយៈ តែញាណសូម្បីទាំង ២ នោះ ក៏មិនទូទៅដល់បុគ្គលពួកដទៃ ។ ជាឱរសញ្ញាណរបស់ពួកព្រះមានព្រះភាគប៉ុណ្ណោះ ។

ឥឡូវនេះ កាលទ្រង់សម្តែងសីហនាទដែលទ្រង់ជាអ្នកប្រកបដោយព្រះញាណ ដែលបន្ទឺ ទើបត្រាស់ថា **ឥតិ រូបំ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ឥតិ រូបំ** ប្រែថា នេះរូប ប៉ុណ្ណេះរូប ។ ត្រាស់ការកំណត់រូបមិនមានសល់ ដោយអំណាចលក្ខណៈ រស បច្ចុប្បដ្ឋាន និងបទដ្ឋាន ធ្វើវត្ថុដែលមានការបែកធ្លាយជាសភាវៈ និងសេចក្តីផ្សេងគ្នានៃភូតរូប និងឧបាទាយរូបជាដើមថា ហួសអំពីនេះទៅ រូបមិនមាន ។ ត្រាស់ការកើតឡើងនៃរូប ដែលកំណត់ទុកដោយពាក្យនេះថា នេះជាការកើតឡើងនៃរូប ។ បណ្តាបទទាំងនោះ បទថា **ឥតិ** សេចក្តីថា យ៉ាងនេះជាការកើតឡើង ។ សេចក្តីពិស្តារនៃរូបសមុទ័យនោះ គប្បីជ្រាបយ៉ាងនេះថា ព្រោះ

អវិជ្ជាកើត រូបក៏កើត ព្រោះតណ្ហាកើត រូបក៏កើត ព្រោះកម្មកើត រូបក៏កើត ព្រោះអាហារកើត រូបក៏កើត ។ អរិយសាវកកាលឃើញនិព្វត្តិលក្ខណៈ (លក្ខណៈកើត) រមែងឃើញការកើតនៃរូប ។ សូម្បីក្នុងចំណែកការរលត់ សេចក្តីពិស្តារក៏មានយ៉ាងនេះថា ព្រោះអវិជ្ជារលត់ រូបក៏រលត់ ។ អរិយ-សាវក កាលឃើញវិបរិណាមលក្ខណៈ (លក្ខណៈប្រែប្រួល) រមែងឃើញការរលត់នៃរូបក្ខន្ធ ។ សូម្បីក្នុងបទថា **ឥតិ វេទនា** ជាដើម ក៏ត្រាស់ការកំណត់វេទនា សញ្ញា សង្ខារ និងវិញ្ញាណដ៏សេសទុក ដោយអំណាចលក្ខណៈ រស បច្ចុប្បដ្ឋាន និងបទដ្ឋាន ធ្វើការសោយអារម្មណ៍ ការចាំបាន ការតាក់តែង និងសេចក្តីដឹងជាសភាវៈ និងសេចក្តីផ្សេងគ្នានៃសុខវេទនាជាដើម រូបសញ្ញាជាដើម ប្រសាទ និងចក្ខុវិញ្ញាណជាដើមថា នេះវេទនា ប៉ុណ្ណេះវេទនា ។ ហួសអំពីនេះ វេទនាមិនមាន ។ នេះសញ្ញា ពួកនេះសង្ខារ នេះវិញ្ញាណ ប៉ុណ្ណេះវិញ្ញាណ ។ ហួសអំពីនេះ វិញ្ញាណមិនមាន ដូច្នេះ ។ តែត្រាស់ការកើតនៃវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលកំណត់យ៉ាងនេះ ដោយបទទាំងឡាយថា ដូច្នេះ ជាការកើតឡើងនៃវេទនាជាដើម ។ សូម្បីក្នុងបទទាំងនោះ បទថា **ឥតិ** សេចក្តីថា យ៉ាងនេះជាការកើត ។ សេចក្តី

ពិស្តាររបស់ខន្ធទាំងនោះ ក៏គប្បីជ្រាបតាមន័យដែលពោលទុកហើយ ក្នុងរូបថា ព្រោះអវិជ្ជាកើត វេទនាក៏កើត ដូច្នេះជាដើម ។

ចំណែកសេចក្តីផ្សេងគ្នាមានដូច្នេះ ក្នុងខន្ធ ៣ មិនពោលថា ព្រោះអាហារកើត គួរពោលថា ព្រោះផស្សៈកើត ។ ក្នុងវិញ្ញាណក្ខន្ធ គួរពោលថា ព្រោះនាមរូបកើត ។ សូម្បីបទចំណែកខាងរលត់ ក៏គួរប្រកបដោយអំណាចបញ្ចក្ខន្ធទាំងនោះឯង ។ នេះជាសេចក្តីសង្ខេបក្នុងប្រការនេះ ។ តែកាលពោលដោយពិស្តារ ការវិនិច្ឆ័យការកើត និងការរលត់ ដែលបរិបូណ៌ដោយអាហារគ្រប់យ៉ាង ក៏ពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ សូម្បីសំឡេងយ៉ាងនេះថា កាលវត្ថុនេះមាន វត្ថុនេះក៏មាន ដូច្នេះ ក៏ជាសីហនាទប្រការមួយទៀត ។ ខ្លឹមសារនៃសីហនាទនោះថា កាលបច្ច័យ មានអវិជ្ជាជាដើមនេះនៅមាន ផល មានសង្ខារជាដើមនេះក៏មាន ។ បទថា **ឥទំ ន ហោតិ** សេចក្តីថា កាលបច្ច័យ មានអវិជ្ជាជាដើមមិនមាន ផល មានសង្ខារជាដើមនេះ ក៏មិនមាន ។

បទថា **ឥមស្ស ឧប្បាទា ឥទំ ឧប្បជ្ជតិ** សេចក្តីថា ព្រោះបច្ច័យ មានអវិជ្ជាជាដើមនេះកើត ផលមានសង្ខារជាដើមនេះក៏កើត ។ បទថា **ឥមស្មឹ**

**អសតិ ឥទំ ន ហោតិ** សេចក្តីថា កាលបច្ច័យមានអវិជ្ជាជាដើមនេះមិនមាន ផលមានសង្ខារជាដើមនេះក៏មិនមាន ។ បទថា **ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** សេចក្តីថា ព្រោះបច្ច័យមានអវិជ្ជាជាដើមនេះរលត់ ផលមានសង្ខារជាដើមនេះក៏រលត់ ។

ឥឡូវនេះ កាលទ្រង់សម្តែងអាការដែលវត្តនោះ មាន (កើត) និងរលត់ដោយពិស្តារ ទើបត្រាស់ថា **យទិទំ អវិជ្ជាបច្ចយា សង្ខារា** ជាដើម ។

[៦៦] បទថា **ឯវំ ស្វាក្ខាតោ** បានដល់ ដែលទ្រង់ពោលទុកដោយល្អ គឺ ត្រាស់ទុកល្អហើយ ដោយការចែកបញ្ចក្ខន្ធជាដើម យ៉ាងនេះ ។ បទថា **ធម្មោ** បានដល់ ធម៌ គឺ បញ្ចក្ខន្ធ និងបច្ចយាការ ។ បទថា **ឧត្តានោ** បានដល់ មិនផ្កាប់ ។ បទថា **វិវដោ** បានដល់ បើកបង្ហាញ ។ បទថា **បកាសិតោ** បានដល់ ប្រកាសហើយ បំភ្លឺឲ្យភ្លឺហើយ ។ សំពត់ចាស់ដែលធុះ រហែក មានដេរទុកក្នុងទីនោះៗ ហៅថា **បិលោតិកា** ក្នុងពាក្យថា **ឆិន្នបិលោតិកោ** បុគ្គលណាមិនមានសំពត់ចាស់នោះ ស្លៀកដណ្តប់តែសំពត់ថ្មីខ្នាត ៨ ហត្ថ ឬ ៩ ហត្ថ បុគ្គលនោះ ឈ្មោះថា **ឆិន្នបិលោតិក** ខ្ទះសំពត់ចាស់ ធម៌សូម្បីនេះ ក៏ជាដូច្នោះ ។ ក្នុងធម៌នេះមិនមែនមានការៈ គឺ

សមណៈ ដូចសំពត់ចុះ រហែក និងមានការដេរប៉ះទុក ដោយអំណាចការ បោកបញ្ឆោតគេជាដើម ។ ន័យមួយទៀត សូម្បីសំពត់តូចៗ ក៏ហៅ **បិលោតិកា** [សំពត់ចាស់ សំពត់ដូតដូលី] បុគ្គលណាមិនមាន **បិលោតិកា** នោះ តែមានសំពត់ផ្ទាំងធំខ្នាត ៨-៩ ហត្ថ បុគ្គលនោះ ក៏ឈ្មោះថា **ឆិន្ន-បិលោតិក** ខ្វះសំពត់ចាស់ សំពត់ដូតដូលី អធិប្បាយថា ប្រាសចាកសំពត់ចាស់ ។ ធម៌នេះ ក៏ជាដូច្នោះ [ប្រាសចាកសមណៈ ដូចសំពត់ចាស់ ឬ សំពត់ដូតដូលី] ។ ដូចជា បុរសបានសំពត់ ៤ ហត្ថមក ធ្វើការកំណត់ប៉ាន់ស្មាន ការនាំទៅផ្លូវឯណោះផ្លូវនេះរមែងលំបាក យ៉ាងណា ពួកអ្នកបួសក្នុងលទ្ធិខាងក្រៅ (ព្រះពុទ្ធសាសនា) ក៏ដូច្នោះ នឹងកំណត់ធម៌ដែលតិចតួចៗ របស់ខ្លួនទុកថា កាលវត្ថុនេះជាយ៉ាងនេះ វត្ថុនេះក៏នឹងជាយ៉ាងនេះ កាលនឹងពង្រីក ឬបន្ថែមរមែងលំបាក ។ មួយវិញទៀត បុរសប៉ាន់ស្មាន កំណត់ដោយសំពត់ខ្នាត ៨ ហត្ថ ៩ ហត្ថ រមែងស្លៀកដណ្តប់បានតាមពេញចិត្ត មិនលំបាកឡើយ មិនមានកិច្ចដែលបុរសនឹងត្រូវនាំសំពត់មកពង្រីក ឬបន្ថែមក្នុងសំពត់នោះ យ៉ាងណា មិនមានកិច្ចដែលកុលបុត្រអ្នកបួសដោយសទ្ធានឹងត្រូវស្មាន កំណត់ចំណែកធម៌ទាំងឡាយ សូម្បីក្នុងធម៌នេះ ក៏ដូច្នោះ ។

ព្រះមានព្រះភាគ ទ្រង់សំដៅដល់ប្រការសូម្បីនេះថា ធម៌នេះ តថាគតចែកទុកល្អហើយ បើកបង្ហាញល្អហើយ ដោយហេតុនោះៗ ទើបត្រាស់ថា **ធិន្ន-បិលោតិកោ** ធម៌ដែលប្រាសចាកសមណៈ ដូចសំពត់ជូតជូលី ដូច្នេះ ។ មួយទៀត សូម្បីសម្រាម លោកក៏ហៅថា **បិលោតិកៈ** ។ ដែលឈ្មោះថាសមណៈសម្រាម រមែងតាំងនៅក្នុងព្រះសាសនានេះមិនបាន ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ៖

ការណ្ឌវំ និទ្ធមថ កសម្ពុំ អបកស្សថ
តតោ បលាបេ វាហេថ អសមណេ សមណមានិនេ
និទ្ធមិត្វាន បាបិច្ឆេ បាបអាចារគោចរេ
សុទ្ធាសុទ្ធេហិ សំវាសំ កប្បយវ្ហោ បតិស្សតា
តតោ សមគ្គា និបកា ទុក្ខស្សន្តំ ករិស្សថ ។

ពួកអ្នកចូរកម្ចាត់សមណៈសម្រាម បណ្តេញសមណៈសម្រាម បណ្តេតសមណៈតែសំបក អ្នកមិនមែនជាសមណៈ តែសម្គាល់ខ្លួនថា ជាសមណៈ លុះកម្ចាត់សមណៈអ្នកមានការប្រាថ្នាលាមក អ្នកមានអាចារៈ និងគោចរៈលាមក ទើបឈ្មោះថា នៅរួមនឹង

សមណៈអ្នកបរិសុទ្ធិ និងអ្នកមិនបរិសុទ្ធិ មានសតិតាំងមាំ
តពីនោះពួកអ្នកមានសេចក្តីព្រមព្រៀងគ្នា មានបញ្ញារក្សា
ខ្លួន ក៏នឹងធ្វើទីបំផុតទុក្ខបាន ។

ធម៌នេះ ឈ្មោះថា ប្រាសចាកសមណៈដូចសំពត់ជូតជូលី សូម្បី ព្រោះសមណៈសម្រាម ត្រូវកាត់ផាច់ហើយដោយប្រការដូច្នេះ ។ បទថា **អលមេវ** ប្រែថា សមគួរពិត ។ បទថា **សទ្ធាបព្វជិតេន** ប្រែថា អ្នកបួសដោយសទ្ធា ។ ក្នុងបទថា **កុលបុត្តេន** កុលបុត្រមាន ២ គឺ អាចារកុលបុត្រ និងជាតិកុលបុត្រ ។ បណ្តាកុលបុត្រទាំងពីរនោះ កុលបុត្រណាចេញបួសអំពីត្រកូលណាមួយ បំពេញធម្មក្ខន្ធ ៥ មានសីលខន្ធជាដើម កុលបុត្រនេះ ឈ្មោះថា **អាចារកុលបុត្រ** ចំណែកកុលបុត្រណា ចេញបួសពីត្រកូលដែលសម្បូរណ៍ដោយជាតិ ដូចព្រះយសកុលបុត្រជាដើម កុលបុត្រនេះឈ្មោះថា **ជាតិកុលបុត្រ** ក្នុងកុលបុត្រទាំងពីរនោះ ក្នុងទីនេះ លោកបំណងយកអាចារកុលបុត្រ ។ ប្រសិនបើជាតិកុលបុត្រ មានអាចារៈ ជាតិកុលបុត្រនេះ ក៏បាត់ថាខ្ពង់ខ្ពស់បំផុត ។ ចំពោះកុលបុត្រែបបនោះ ។ បទថា **វីរិយំ អារព្ភិតុំ** បានដល់ ដើម្បីសេចក្តីព្យាយាមប្រកបដោយអង្គ ៤ ។

ឥឡូវនេះ កាលនឹងទ្រង់សម្តែងសេចក្តីព្យាយាមមានអង្គ ៤ ទើបត្រាស់ថា **កាមំ តចោ** ជាដើម ។ ក្នុងអង្គទាំង ៤ នោះ **តចោ** ជាអង្គ ១ **ន្ហារុ** ជាអង្គ ១ **អដ្ឋិ** ជាអង្គ ១ ។ **មំសលោហិតំ** ជាអង្គ ១ ។ ក៏កុលបុត្រដែលអធិដ្ឋានសេចក្តីព្យាយាមប្រកបដោយអង្គ ៤ នេះ គប្បីប្រើក្នុងឋានៈទាំង ៩ គឺ មុនអាហារ ក្រោយអាហារ យាមដើម យាមកណ្តាល យាមចុងក្រោយ វេលាដើរ វេលាឈរ វេលាអង្គុយ វេលាដេក ។ បទថា **ទុក្ខំ ភិក្ខវេ កុសីតោ វិហរតិ** សេចក្តីថា ក្នុងព្រះសាសនានេះ បុគ្គលណាខ្ជិលច្រអូស បុគ្គលនោះរមែងនៅជាទុក្ខ តែក្នុងលទ្ធិក្រៅព្រះពុទ្ធសាសនា បុគ្គលណាខ្ជិលច្រអូស បុគ្គលនោះរមែងនៅជាសុខ ។ បទថា **វោកិណ្ណោ** ប្រែថា ច្របូកច្របល់ ។ បទថា **សទត្ថំ** ប្រែថា ប្រយោជន៍ដែលល្អ ឬប្រយោជន៍របស់ខ្លួន ។ សូម្បីដោយបទទាំងពីរ លោកក៏បំណងយកចំពោះព្រះអរហត្តតែម្យ៉ាង ។ បទថា **បរិហាបេតិ** ប្រែថា ឲ្យវិនាសទៅ មិនសម្រេច ។ ពិតហើយ កុលបុត្រអ្នកខ្ជិលច្រអូស រមែងមិនឃុំគ្រងទ្វារទាំង ៦ ។ កម្ម ៣ ក៏មិនបរិសុទ្ធិ ។ សីលមានអាជីវៈជាទី ៨ (អាជីវមដ្ឋកសីល) ក៏មិនផូរផង់ ។ ភិក្ខុដែលមានអាជីវៈដែលទម្លាយចេញហើយ រមែងជាអ្នកចូលទៅ

ជាព្រះប្រចាំត្រកូល ។ ភិក្ខុនោះជាអ្នកទម្លាយមិត្តសព្រហ្មចារីទាំងឡាយ ដូចផង់ធូលីដែលធ្លាក់ចុះក្នុងគ្រាប់ភ្នែក រមែងនៅជាទុក្ខ ទាំងបានឈ្មោះថា ជាបុគ្គលស្រវឹង និងបរិភោគលាមកដ៏រី ។ មិនអាចនឹងកាន់យកព្រះអជ្ឈា- ស្រ័យរបស់ព្រះសាស្តាទុកបាន ឈ្មោះថា ធ្វើខណៈវេលាដែលរកបានលំបាក ឲ្យកន្លងទៅ ។ សូម្បីអាហាររបស់អ្នកស្រុក ដែលភិក្ខុនោះបរិភោគហើយ រមែងមិនមានផលច្រើន ។ បទថា **អារទ្ធវីរិយោ ច ខោ ភិក្ខវេ** សេចក្តីថា បុគ្គលដែលប្រារព្ធសេចក្តីព្យាយាម រមែងនៅជាសុខក្នុងព្រះសាសនានេះ ដោយពិត ។ ចំណែកអ្នកដែលប្រកបសេចក្តីព្យាយាមក្នុងលទ្ធិក្រៅព្រះពុទ្ធ- សាសនា រមែងនៅជាទុក្ខ ។ បទថា **បវិវិត្តោ** បានដល់ អ្នកប្រាសចាក ហើយ ។ បទថា **សទត្ថំ បរិបូរេតិ** បានដល់ សម្រេចព្រះអរហត្ត ។ ពិត ណាស់ ភិក្ខុដែលប្រារព្ធសេចក្តីព្យាយាម រមែងមានការឃុំគ្រងទ្វារទាំង ៦ ល្អហើយ ។ កម្មទាំង ៣ ក៏បរិសុទ្ធិ ។ សីលមានអាជីវៈជាទី ៨ ក៏ផូរផង់ ។ ម្យ៉ាងវិញទៀត ភិក្ខុនោះជាទីពេញចិត្តនៃមិត្តសព្រហ្មចារីទាំងឡាយ ដូចថ្នាំ បន្តក់ភ្នែកដែលត្រជាក់ក្នុងគ្រាប់ភ្នែក និងដូចព្រះចន្ទតាមធម្មជាតិ រមែងនៅ ជាសុខ រមែងអាចកាន់យកព្រះអជ្ឈាស្រ័យរបស់ព្រះសាស្តាទុកបាន ។ ពិត

ណាស់ ព្រះសាស្តាត្រូវព្រះនាងគោតមីថ្វាយបង្គំដោយក្រាបទូលយ៉ាងនេះ

ថា ៖

ចិរំ ជីវ មហាវីរ  កប្បំ តិដ្ឋ មហាមុនី

បពិត្រព្រះមហាមុនី មេត្តាតាំងព្រះជន្មាយុរហូតអស់នៃកប្បចុះ ។

ក៏ទ្រង់ហាមថា ម្នាលគោតមី នាងមិនគប្បីថ្វាយបង្គំតថាគតដោយ

អាការយ៉ាងនេះឡើយ ត្រូវនាងគោតមីនោះទូលអង្វរ កាលនឹងទ្រង់ប្រាប់អាការ

ដែលគួរថ្វាយបង្គំ ទើបត្រាស់យ៉ាងនេះថា ៖

អារទ្ធវិរិយេ បហិតត្តេ  និច្ចំ ទឡ្ហបរក្កមេ

សមគ្គេ សាវកេ បស្ស  ឯសា ពុទ្ធាន វន្ទនា ។

អ្នកចូរមើលពួកព្រះសាវក ដែលប្រារព្ធសេចក្តីព្យាយាម

អ្នកមានចិត្តតែមួយ តស៊ូពុះពាររឹងមាំជានិច្ច ជាអ្នកព្រម

ព្រៀងគ្នា នេះជាការថ្វាយបង្គំចំពោះព្រះពុទ្ធទាំងឡាយ ។

ភិក្ខុដែលប្រារព្ធសេចក្តីព្យាយាមយ៉ាងនេះ រមែងអាចកាន់យកព្រះ

អធ្យាស្រ័យរបស់ព្រះសាស្តាទុកបាន រមែងធ្វើវេលាដែលរកបានលំបាក មិន

ឲ្យកន្លងទៅ ។ ពិតណាស់ ពុទ្ធុប្បាទកាល សម័យកើតឡើងនៃព្រះពុទ្ធជា

ម្ចាស់ ធម្មទេសនា ការសម្ដែងធម៌ និងសង្ឃសុប្បដិបត្តិ ការបដិបត្តិល្អរបស់សង្ឃ រមែងមានផល មានកម្រៃសម្រាប់ភិក្ខុនោះ ។ សូម្បីអាហាររបស់អ្នកស្រុកដែលភិក្ខុនោះបរិភោគហើយ រមែងមានផលច្រើន ។ បទថា **ហីនេន អគ្គស្ស** សេចក្ដីថា មិនឈ្មោះថាសម្រេចព្រះអរហត្ត ដែលរាប់ថាប្រសើរដោយសទ្ធាយ៉ាងថោកទាប វីរិយៈថោកទាប សតិថោកទាប សមាធិថោកទាប បញ្ញាថោកទាប ។ បទថា **អគ្គេន ច ខោ** សេចក្ដីថា ឈ្មោះថាសម្រេចព្រះអរហត្តដ៏ប្រសើរ ដោយគុណមានសទ្ធាជាដើមយ៉ាងក្រៃលែង ។ ក្នុងបទថា **មណ្ឌបេយ្យំ** ឈ្មោះថា **មណ្ឌៈ** ព្រោះអត្ថថា ផូរផង់ ឈ្មោះថា **បេយ្យៈ** ព្រោះអត្ថថា គួរផឹក ។ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងថាពិតហើយ បុគ្គលផឹកទឹកណាហើយដួលចុះត្រង់រវាងផ្លូវ មិនដឹងខ្លួន មិនជាម្ចាស់របស់ សូម្បីតែសំពត់ជាដើមរបស់ខ្លួន ទឹកផឹកនោះសូម្បីថ្លាល្អ ក៏មិនគួរផឹក ។ ចំណែកសាសនារបស់តថាគត ទាំងថ្លាផូរផង់ ទាំងគួរផឹកយ៉ាងនេះ ទើបត្រាស់ថា **មណ្ឌបេយ្យំ** ដូច្នេះ ។ ក្នុងពាក្យថា **មណ្ឌបេយ្យំ** នោះ ផូរផង់មាន ៣ យ៉ាង គឺ **ទេសនាមណ្ឌៈ** (ទេសនាផូរផង់) ១ **បដិគ្គហមណ្ឌៈ** (អ្នកទទួលផូរផង់) ១ **ព្រហ្មចរិយមណ្ឌៈ** (ព្រហ្មចរិយផូរផង់) ១ ។

ទេសនាថាផ្លូវផង់ ដូចម្តេច ។

គឺ ការប្រាប់ (បង្រៀន) សម្តែង បញ្ញត្តិ បើកបង្ហាញ ចែក ធ្វើឲ្យរាក់នូវអរិយសច្ច ៤ ។ ការប្រាប់ ។បេ។ ធ្វើឲ្យរាក់នូវអរិយមគ្គមានអង្គ ៨ នេះឈ្មោះ **ទេសនាមណ្ឌៈ** ទេសនាផ្លូវផង់ ។

អ្នកទទួលថាផ្លូវផង់ ដូចម្តេច ។

គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស ឬជនសូម្បីពួកដទៃណាមួយដែលជាអ្នកដឹងសេចក្តី ។ នេះឈ្មោះ **បដិគ្គហមណ្ឌៈ** អ្នកទទួលផ្លូវផង់ ។

ព្រហ្មចរិយថាផ្លូវផង់ ដូចម្តេច ។

គឺ អរិយមគ្គមានអង្គ ៨ នេះឯង គឺ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ នេះឈ្មោះ **ព្រហ្មចរិយមណ្ឌៈ** ព្រហ្មចរិយផ្លូវផង់ ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងប្រការនេះ ដោយន័យជាដើមថា សទ្ធិន្ទ្រិយផ្លូវផង់ដោយអធិមោក្ខ ការបង្អោនចិត្តជឿ , អស្សទ្ធិយៈ ការមិនជឿជាកាក ។ លះអស្សទ្ធិយៈដែលជាកាកចេញ ផឹកតែអធិមោក្ខ ដែលជាសេចក្តីថ្លានៃសទ្ធិន្ទ្រិយ ព្រោះហេតុនោះ សទ្ធិន្ទ្រិយទើបឈ្មោះថា **មណ្ឌៈ**

ថ្វា **បេយ្យ:** គួរផឹក ។ ពាក្យថា **សត្ថា សម្មុខីភូតោ** នេះ ជាពាក្យពោល ហេតុក្នុងប្រការនេះ ។ ព្រោះហេតុ ដែលព្រះសាស្តាប្រថាប់នៅចំពោះមុខ ។ ដូច្នោះ ព្រហ្មចរិយ:នោះ ទើបជារបស់ផូរផង់ ក្នុងអត្ថថា ធ្វើប្រយោគ សេចក្តីព្យាយាមហើយផឹកបាន ។ ពិតណាស់ របស់ខាងក្រៅ សូម្បីតែ ភេសជ្ជ:ថ្នាំដែលថ្វានៅកំបាំងមុខ អ្នកផឹកក៏មានសេចក្តីសង្ស័យថា យើងមិន ដឹងខ្នាតឬ ឬថាការបន្ថែមបន្ថយ ។ តែកាលនៅចំពោះមុខ អ្នកផឹកក៏អស់ សង្ស័យក្នុងការផឹក ដោយគិតថា ពេទ្យនឹងដឹង ។ ព្រះសាស្តាទ្រង់ជាម្ចាស់ នៃធម៌ ក៏ដូច្នោះដែរ ទ្រង់ប្រកបសត្វទុកក្នុងព្រហ្មចរិយ:ដែលថ្វា និងគួរផឹក ដោយត្រាស់ថា ពួកអ្នកចូរព្យាយាមផឹក ព្រោះដូច្នោះ ទើបត្រាស់ថា **តិហ ភិក្ខវេ** ។

[៦៧] បណ្តាទាំងនោះ បទថា **សផលា** បានដល់ មានអានិសង្ស ។ បទថា **សឧទ្រិយា** បានដល់ មានផលបន្ថែម គឺ កម្រៃ ។ បទថា **អត្តត្ថំ** បានដល់ ព្រះអរហត្តដែលជាប្រយោជន៍ដល់ខ្លួន ។ បទថា **អប្បមាទេន សម្បាទេតុំ** បានដល់ ដើម្បីធ្វើកិច្ចគ្រប់យ៉ាងដោយសេចក្តីមិនប្រមាទ ។ បទថា **បរត្ថំ** បានដល់ ផលដ៏ច្រើនរបស់អ្នកថ្វាយបច្ច័យ ។ ពាក្យដ៏សេស

ក្នុងទីគ្រប់កន្លែង ឆាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ឧសភលសូត្រទី ២

# អ ដ្ឋ ក ថា

## ឧបនិសសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ឧបនិសសូត្រទី ៣** ដូចតទៅនេះ ៖*

*[៦៨] ក្នុងបទទាំងឡាយមានថា **ជានតោ អហំ** ជាដើម បទថា **ជានតោ** ប្រែថា ដឹងហើយ ។ បទថា **បស្សតោ** ប្រែថា ឃើញហើយ ។ សូម្បីទាំង ២ បទ ក៏មានសេចក្តីដូចគ្នា ផ្សេងតែព្យញ្ជនៈប៉ុណ្ណោះ ។ សូម្បីដូច្នោះ បទថា **ជានតោ** ទើបចង្អុលដល់បុគ្គលអាស្រ័យលក្ខណៈនៃញាណ ។ ព្រោះថា ញាណ មានការដឹងទូទៅ ជាលក្ខណៈ ។ បទថា **បស្សតោ** ចង្អុលដល់បុគ្គលអាស្រ័យអានុភាពនៃញាណ ។ ព្រោះថា ញាណ មានការឃើញជាអានុភាព ។ បុគ្គលដែលប្រកបដោយញាណ រមែងឃើញធម៌ទាំងឡាយដែលបើកបង្ហាញហើយដោយញាណ ដូចអ្នកមានចក្ខុ ឃើញរូបទាំងឡាយដោយចក្ខុ ។*

*ក្នុងពាក្យថា **អាសវានំ ខយោ** នេះ ការលះ ការមិនកើតឡើង អាការដែលអស់ទៅ ការមិនមានអាសវៈទាំងឡាយ ក៏ហៅថា **អាសវក្ខយ** ។*

ក្ខ័ៈក្តី មគ្គ ផល និព្វានក្តី លោកហៅថា **អាសវក្ខយ** ។ ពិតណាស់ អាការដែលអស់ទៅ លោកហៅថា អាសវក្ខយៈ មកក្នុងបាលីជាដើមថា **អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ** ចេតោវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអាសវៈអស់ទៅ ។ ក្ខ័ៈ ក៏ហៅថា អាសវក្ខយៈ មកក្នុងបាលីនេះថា **យោ អាសវានំ ខយោ វយោ ភេទោ បរិភេទោ អនិច្ចតា អន្តរធានំ** អាការដែលអាសវៈអស់ទៅ វិនាសទៅ រលត់ទៅ បែកធ្លាយទៅ មិនទៀង សាបសូន្យទៅ ។ មគ្គ ក៏ហៅថា អាសវក្ខយៈ មកក្នុងបាលីនេះថា

**សេក្ខស្ស សេក្ខមានស្ស ឧជុមគ្គានុសារិនោ**
**ខយស្មឹ បឋមំ ញាណំ តតោ អញ្ញា អនន្តរា ។**

ញាណសេចក្តីដឹងជាដំបូងក្នុងការអស់ទៅ មានដល់ព្រះ-សេក្ខៈអ្នកកំពុងសិក្សា អ្នកប្រព្រឹត្តទៅត្រង់តាមមគ្គ លំដាប់តទៅ ក៏មានបញ្ញាសេចក្តីដឹងទូទៅ ។

ពិតណាស់ មគ្គនោះ រមែងកើតឡើងធ្វើអាសវៈឲ្យអស់ទៅ ស្ងប់ទៅ ។ ព្រោះដូច្នោះ មគ្គ លោកទើបហៅថា ជាទីអស់អាសវៈ ។ ផល ក៏ហៅថា អាសវក្ខយៈ មកក្នុងបាលីនេះថា **អាសវានំ ខយា សមណោ ហោតិ** ឈ្មោះ

ថា ជាសមណៈ ព្រោះអស់អាសវៈ ។ ពិតណាស់ ផលនោះ កើតឡើង ក្នុងទីបំផុតនៃអាសវៈទាំងឡាយអស់ទៅ ព្រោះដូច្នោះ ផល លោកទើប ហៅថា អាសវក្ខយៈ ។ ព្រះនិព្វាន ក៏ហៅថា អាសវក្ខយៈ មកក្នុងបាលី នេះថា

**អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។**

អាសវៈទាំងឡាយរបស់បុគ្គលនោះចម្រើនហើយ បុគ្គល នោះ នៅឆ្ងាយចាកធម៌ជាទីអស់អាសវៈ ។

ពិតណាស់ អាស្រ័យព្រះនិព្វាននោះ អាសវៈទាំងឡាយរមែងអស់ ទៅ ។ ព្រោះដូច្នោះ ព្រះនិព្វាននោះ លោកហៅថា **អាសវក្ខយ** ។ តែក្នុង ទីនេះលោកបំណងដល់មគ្គ និងផល ។ បទថា **នោ អបស្សតោ** សេចក្តី ថា បុគ្គលណាមិនដឹង មិនឃើញ តថាគតមិនពោលការអស់អាសវៈរបស់ បុគ្គលនោះ ។ ដោយបទនោះ ក៏ព្រះមានព្រះភាគទ្រង់ជំទាស់ដល់ពួកអ្នក មានលទ្ធិ ដែលពោលដល់សេចក្តីបរិសុទ្ធិដោយសង្សារវដ្តជាដើម របស់ បុគ្គលសូម្បីមិនដឹង មិនឃើញ ត្រាស់ផ្លូវដែលជាឧបាយដោយពីរបទដើម ត្រាស់ជំទាស់ផ្លូវដែលមិនមែនឧបាយ ដោយបទនេះ ។

ឥឡូវនេះ មានទ្រង់មានព្រះបំណងសម្ដែងប្រការដែលភិក្ខុដឹងហើយ អាសវៈអស់ទៅ ទើបទ្រង់ផ្ដើមសួរថា **កិញ្ច ភិក្ខវេ ជានតោ** ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុដឹងអ្វីហ្ន៎ ។ ក្នុងពាក្យនោះ សេចក្ដីដឹងមានច្រើនយ៉ាង ។ ពិតណាស់ ភិក្ខុអង្គខ្លះជាអ្នកដឹងយ៉ាងធម្មតា ចេះធ្វើឆ័ត្របាន ។ អង្គខ្លះចេះធ្វើចីវរជាដើមយ៉ាងណាមួយ ។ កាលភិក្ខុនោះ តាំងនៅក្នុងគោលវត្ត-បដិបត្តិ ធ្វើតែការងារដូច្នេះ សេចក្ដីដឹងនោះ ក៏មិនគួរពោលថា មិនជាបទដ្ឋាននៃសួគ៌ និងមគ្គផល ។ ប៉ុន្ដែថា បុគ្គលណាបួសក្នុងព្រះសាសនាហើយ ចេះតែធ្វើអនេសនា មានវេជ្ជកម្មជាដើម ។ អាសវៈទាំងឡាយរមែងចម្រើនដល់បុគ្គលនោះ ដែលដឹងហើយ ។ ព្រោះដូច្នោះ កាលភិក្ខុដឹង និងឃើញវត្ថុណា អាសវៈទាំងឡាយអស់ទៅបាន ព្រះអង្គកាលទ្រង់សម្ដែងវត្ថុនោះ ទើបត្រាស់ថា **ឥតិ រូបំ** ដូច្នេះជាដើម ។ បទថា **ឯវំ ខោ ភិក្ខវេ ជានតោ** សេចក្ដីថា អ្នកឃើញការកើត និងការរលត់ទៅនៃបញ្ចក្ខន្ធយ៉ាងនេះ ។ បទថា **អាសវានំ ខយោ ហោតិ** សេចក្ដីថា ព្រះអរហត្តដែលបានឈ្មោះថា **អាសវក្ខយ** ក៏មាន ព្រោះកើតក្នុងទីបំផុតនៃការអស់ទៅនៃអាសវៈទាំងឡាយ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាឲ្យដល់កំពូល គឺ ព្រះ-

អរហត្តយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងបដិបទាជាចំណែកខាងដើម ដែលព្រះវិញ្ញូគប្បីសម្រេច ទើបត្រាស់ថា **យម្បិ តំ ភិក្ខវេ** ជាដើម ។

[៦៩] បណ្តាបទទាំងនោះ បទថា **ខយស្មឹ ខយេ ញាណំ** សេចក្តីថា កាលព្រះអរហត្តផល ពោលគឺ **អាសវក្ខយ** ដែលលោកបានហើយ បដិវេធញ្ញាណក៏មាន ។ ព្រោះថា បដិវេធញ្ញាណនោះ លោកហៅថា **ខយេ ញាណំ** ដឹងក្នុងការអស់ទៅ ព្រោះកាលធម៌ជាទីអស់អាសវៈ ពោលគឺ អរហត្តផលកើតឡើងមុន បដិវេធញ្ញាណកើតជាខាងក្រោយ ។ បទថា **ស-ឧបនិសំ** ប្រែថា មានហេតុមានបច្ច័យ ។ បទថា **វិមុត្តិ** បានដល់ វិមុត្តិ ដែលសម្បយុត្តដោយអរហត្តផល ។ ពិតណាស់ វិមុត្តិនោះ រមែងជាបច្ច័យដោយជាឧបនិស្សយប្បច្ច័យនៃព្រះអរហត្តនោះ សូម្បីក្នុងបច្ច័យយ៉ាងដទៃអំពីនេះ ក៏គប្បីជ្រាបនូវភាពជាបច្ច័យដោយអំណាចបច្ច័យដែលកំពុងតាំងនៅ ដោយអាការយ៉ាងនេះ ។ បទថា **វិរាគោ** បានដល់ មគ្គ ។ ពិតណាស់ មគ្គនោះកើតឡើង ធ្វើឲ្យកិលេសវិនាសទៅ អស់ទៅ ព្រោះដូច្នោះ លោកទើបហៅថា **វិរាគ** ។ បទថា **និព្វិទា** បានដល់ និព្វិទាញាណ ។ ទ្រង់សម្តែង

វិបស្សនាដែលមានកម្លាំងដោយនិព្វិទាញាណនោះ ។ ពាក្យថា វិបស្សនាមានកម្លាំង ជាឈ្មោះរបស់ញាណ ៤ គឺ **ភយតូបដ្ឋានញាណ អាទីនវានុបស្សនាញាណ មុញ្ចិតុកម្យតាញាណ សង្ខារុបេក្ខាញាណ** ។ បទថា **យថាភូតញាណទស្សនំ** ប្រែថា ការឃើញ ពោលគឺ ការដឹងតាមសភាវៈដែលពិត ។ ទ្រង់សម្ដែងវិបស្សនាទន់ខ្ចី ដោយយថាភូតញាណទស្សនៈនោះ ពិតណាស់ វិបស្សនាទន់ខ្ចី រមែងជាបច្ច័យដល់វិបស្សនាដែលមានកម្លាំង ។ ពាក្យថា វិបស្សនាទន់ខ្សោយជាឈ្មោះរបស់ញាណ ៤ គឺ **សង្ខារបរិច្ឆេទញ្ញាណ កង្ខាវិតរណញ្ញាណ សម្មសនញ្ញាណ មគ្គាមគ្គញ្ញាណ** ។ បទថា **សមាធិ** បានដល់ សមាធិដែលមានឈានជាបាទ ។ ពិតហើយ សមាធិនោះរមែងជាបច្ច័យដល់វិបស្សនាទន់ខ្ចី ។ បទថា **សុខំ** បានដល់ សុខខាងដើមនៃអប្បនាសមាធិ ។ ពិតណាស់ សុខនោះ រមែងជាបច្ច័យដល់សមាធិដែលមានឈានជាបាទ ។ បទថា **បស្សទ្ធិ** បានដល់ ការស្ងប់រម្ងាប់សេចក្ដីក្រវល់ក្រវាយ ។ ពិតណាស់ បស្សទ្ធិនោះ រមែងជាបច្ច័យដល់សុខ ដែលជាខាងដើមនៃអប្បនាសមាធិ ។ បទថា **បីតិ** បានដល់ បីតិដែលមានកម្លាំង ។ ពិតហើយ បីតិនោះ រមែងជាបច្ច័យដល់ការស្ងប់រម្ងាប់សេចក្ដីខ្វល់ខ្វាយ ។

បទថា **បាមោជ្ជំ** បានដល់ បីតិដែលកម្លាំងខ្សោយ ។ ពិតហើយ បីតិដែលមានកម្លាំងខ្សោយ រមែងជាបច្ច័យដល់បីតិដែលមានកម្លាំង ។

បទថា **សទ្ធា** បានដល់ សេចក្តីជឿដែលកើតក្នុងកពតៗ ទៅ ។ ពិតណាស់ សេចក្តីជឿដែលកើតក្នុងកពតៗ ទៅនោះ រមែងជាបច្ច័យដល់បីតិដែលមានកម្លាំងខ្សោយ ។ បទថា **ទុក្ខំ** បានដល់ ទុក្ខក្នុងវដ្តៈ ។ ពិតណាស់ ទុក្ខក្នុងវដ្តៈនោះ រមែងជាបច្ច័យដល់សទ្ធាក្នុងកពតៗ ទៅ ។ បទថា **ជាតិ** បានដល់ ការកើតនៃខន្ធដែលមានអាការផ្សេងៗ គ្នា ។ ពិតណាស់ ជាតិនោះ រមែងជាបច្ច័យដល់ទុក្ខក្នុងវដ្តៈ ។ បទថា **ភវោ** បានដល់ កាមភព ។ សូម្បីបទដ៏សេស ក៏គប្បីជ្រាបដោយឧបាយយ៉ាងនេះ ។

[៧០] បទថា **ថុល្លផុសិតកេ** ប្រែថា មានគ្រាប់ធំ ។ ក្នុងបទថា **បព្វតកន្ទរបទរសាខា** នេះ មានវិនិច្ឆ័យដូច្នេះ ។ ប្រទេសនៃភ្នំដែលត្រូវទឹកដែលបានឈ្មោះថា **កំ** ព្រោះឲ្យបែកចេញព្រោះទឹក ឈ្មោះថា **កន្ទរៈ** គេហៅថា **និតម្ពៈ** ក៏មាន **និកុញ្ជៈ** ក៏មាន ។ ភូមិប្រទេស ទីបែកក្រហែងកាលភ្លៀងមិនធ្លាក់កន្ទះខែ ឈ្មោះថា **បទរៈ** ប្រឡាយតូចដែលនាំទៅកាន់ **កុសុព្ភៈ** ឈ្មោះថា **សាខា** ។ ត្រពាំងតូច ឈ្មោះថា **កុសុព្ភៈ** ។ បឹងធំ

ឈ្មោះថា **មហាកុសុព្ភៈ** ។ ស៊ឹង ឈ្មោះថា **កុន្ននទី** ។ ទន្លេ មានគង្គា យមុនាជាដើម ឈ្មោះថា **មហានទី** ។ ក្នុងបទថា **ឯវមេវ ខោ ភិក្ខវេ អវិជ្ជូបនិសា សង្ខារា** ជាដើម មានវិនិច្ឆ័យដូច្នេះ ។ គប្បីឃើញអវិជ្ជាថា ដូចភ្នំ អភិសង្ខារទាំងឡាយថា ដូចទឹកភ្លៀង វដ្ដៈមានវិញ្ញាណជាដើមថា ដូចប្រឡាយទឹក វិមុត្តិថា ដូចសាគរ ។ ភ្លៀងធ្លាក់លើកំពូលភ្នំ ក៏ធ្វើប្រឡាយឲ្យពេញ ធ្វើសាគរ គឺ មហាសមុទ្រឲ្យពេញតាមលំដាប់ យ៉ាងណា ជាដំបូង គប្បីជ្រាបដល់ការធ្លាក់នៃទឹកភ្លៀង គឺ អភិសង្ខារលើកំពូលភ្នំ គឺ អវិជ្ជាក៏ដូច្នោះ ។ ពិតណាស់ បុថុជ្ជនល្ងង់ខ្លៅ មិនបានស្ដាប់ ជាអ្នកមិនដឹង ព្រោះអវិជ្ជា ធ្វើសេចក្ដីប្រាថ្នាព្រោះតណ្ហា រមែងសាងកម្មដែលជាកុសល និងអកុសល ។ កម្មដែលជាកុសល និងអកុសលនោះ ក៏ជាបច្ច័យដល់បដិសន្ធិវិញ្ញាណ ។ បដិសន្ធិវិញ្ញាណជាដើម ក៏ជាបច្ច័យដល់នាមរូបជាដើម ។ វេលាដែលទឹកភ្លៀង គឺ អភិសង្ខារធ្លាក់ចុះលើកំពូលភ្នំ គឺ អវិជ្ជា ធ្វើវដ្ដៈមានវិញ្ញាណជាដើម ឲ្យពេញតាមលំដាប់តាំងនៅ ព្រោះជាបច្ច័យបន្តគ្នាទៅ ក៏ដូចវេលាដែលភ្លៀងធ្លាក់លើកំពូលភ្នំ ធ្វើប្រឡាយឲ្យពេញហើយក៏ហូរទៅដល់មហាសមុទ្រ ។ តែព្រះពុទ្ធវចនៈ សុម្បីលោកមិនកាន់

យកក្នុងព្រះបាលី ក៏គប្បីជ្រាបថា លោកកាន់យកទុកហើយដូចគ្នា ដោយអំណាចព្រះបាលីនេះថា **ឥធ តថាគតោ លោកេ ឧប្បជ្ជតិ អគារស្មា អនាគារិយំ បព្វជតិ** ព្រះតថាគតកើតឡើងក្នុងលោកនេះ ស្ដេចចេញព្រះផ្នួសចាកផ្ទះ មិនមានផ្ទះ ដូច្នេះ ។ ក៏ការកើតក្នុងផ្ទះនៃត្រកូលរបស់ព្រះ-តថាគតនោះ ឈ្មោះថា **ជាតិ** ដែលមានការធ្វើផ្សេងៗ រួមគ្នា ព្រោះមានកម្មភពជាបច្ច័យ ។ បុគ្គលអាស្រ័យសេចក្ដីយល់ព្រមចំពោះព្រះភ័ក្ត្ររបស់ព្រះពុទ្ធព្រះអង្គមុនៗ ឬព្រះពុទ្ធសាវក ស្ដាប់ធម្មកថា ដែលនាំមកដោយលក្ខណៈដែលសម្ដែងដល់ទោសរបស់វដ្ដៈ រមែងឃើញការត្រូវបៀតបៀនដោយអំណាចវដ្ដៈ ។ ជាតិ រមែងជាបច្ច័យដល់វដ្ដទុក្ខ ។ ខន្ធទាំងឡាយដែលមានការធ្វើផ្សេងៗ រមែងមានដល់បុគ្គលនោះដោយអាការយ៉ាងនេះ ។ ជាតិជាបច្ច័យដល់វដ្ដទុក្ខ បុគ្គលនោះត្រូវវដ្ដទុក្ខបៀតបៀន ធ្វើសទ្ធាឲ្យកើតក្នុងភពតៗ ទៅ ក៏ចេញចាកផ្ទះបួស មិនមានផ្ទះ ។ វដ្ដទុក្ខជាបច្ច័យដល់សទ្ធាក្នុងភពតៗ ទៅ របស់បុគ្គលនោះ ដោយប្រការដូច្នេះ ។ បុគ្គលនោះមិនសន្ដោសដោយហេតុត្រឹមតែបព្វជ្ជាប៉ុណ្ណោះ នៅកាន់យកនិស្ស័យក្នុងវេលាវស្សាមិនគ្រប់ ៥ បំពេញវត្តបដិបត្តិ ធ្វើមាតិកាទាំងពីរឲ្យស្ទាត់ជំនាញហើយរៀនកម្ម និងមិនមែនកម្ម ជម្រះឲ្យអស់ឫសកែវជរាបដល់ព្រះអរហត្ត

កាន់យកកម្មដ្ឋានទៅនៅព្រៃ ផ្ដើមការងារក្នុងបបរិកសិណជាដើម ។ បុគ្គល នោះអាស្រ័យកម្មដ្ឋាន ក៏កើតបីតិដែលមានកម្លាំងខ្សោយ គេអាស្រ័យបីតិ នោះ ក៏កើតបាមោជ្ជៈ បាមោជ្ជៈនោះ ក៏ជាបច្ច័យដល់បីតិដែលមានកម្លាំង ។ បីតិដែលមានកម្លាំង ក៏ជាបច្ច័យដល់បស្សទ្ធិ រម្ងាប់សេចក្ដីក្រវល់ក្រវាយ ។ បស្សទ្ធិនោះ ក៏ជាបច្ច័យដល់សុខចំណែកខាងដើមនៃអប្បនាសមាធិ សុខ នោះ ក៏ជាបច្ច័យដល់សមាធិដែលមានឈានជាបាទ ។ បុគ្គលនោះធ្វើសុខ នោះ ដែលព្រមព្រៀងឲ្យកើតដោយសមាធិ ក៏ធ្វើការងារដោយវិបស្សនា ទន់ខ្លី ។ សមាធិដែលមានឈានជាបាទរបស់គេ ក៏ជាបច្ច័យដល់វិបស្សនា ទន់ខ្លី ។ វិបស្សនាដែលមានកម្លាំងទន់ខ្លី ក៏ជាបច្ច័យដល់វិបស្សនាមាន កម្លាំង វិបស្សនាដែលមានកម្លាំង ក៏ជាបច្ច័យដល់មគ្គ ។ មគ្គ ក៏ជាបច្ច័យ ដល់ផលវិមុត្តិ ។ ផលវិមុត្តិ ក៏ជាបច្ច័យដល់បច្ចវេក្ខណញ្ញាណ ។ គប្បី ជ្រាបថា វេលាដែលព្រះវិណាស្រេចធ្វើសាគរ គឺ វិមុត្តិ ឲ្យពេញហើយ តាំងនៅ ក៏ដូចវេលាដែលភ្លៀងធ្វើសាគរឲ្យពេញដោយលំដាប់ហើយតាំងនៅ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា ឧបនិស្សសូត្រទី ៣

# អ ដ្ឋ ក ថា

## អញ្ញតិត្ថិយសុត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង **អញ្ញតិត្ថិយសូត្រទី ៤** ដូចតទៅនេះ ៖

[៧១] បទថា **បាវិសិ** ប្រែថា ចូលទៅហើយ ។ ក៏ព្រះសារីបុត្រនោះចូលទៅមុនហើយ ។ តែលោកពោលយ៉ាងនេះ ក៏ព្រោះព្រះសារីបុត្រចេញទៅហើយ ដោយគិតថា នឹងចូលទៅ ។ សួរថា ដូចអ្វី ។ ដូចបុរសអ្នកចេញទៅហើយ ដោយគិតថា នឹងទៅផ្ទះ សូម្បីមិនទាន់ដល់ផ្ទះ កាលគេសួរថា អ្នកមានឈ្មោះនេះទៅណា ក៏ឆ្លើយថា ទៅផ្ទះ យ៉ាងណា ប្រការនេះក៏ដូច្នោះ ។ បទថា **អតិប្បគោ** សេចក្តីថា បានព្ញថា ក្នុងគ្រានោះថ្ងៃទីចេញទៅនៅព្រឹកពេកសម្រាប់ព្រះថេរៈ ។ ពួកភិក្ខុដែលចេញទៅវេលាព្រឹកព្រលឹម រមែងបង្អែបង្អង់នៅដរាបដល់វេលាភិក្ខាចារ ក្នុងទីទាំងនេះ គឺទីលានព្រះពោធិព្រឹក្ស ទីលានព្រះចេតិយ ទីគ្រងសំពត់ជាប្រចាំ ។ តែព្រះថេរៈគិតថា យើងនឹងធ្វើការនិយាយចរចាជាមួយពួកបរិព្វាជក ដរាបដល់វេលាភិក្ខាចារ ទើបបានត្រិះរិះថា **យន្នូនាហំ** បើយ៉ាងណាយើងជាដើម ។

បទថា **បរិព្វាជការាំ អារាមោ** សេចក្ដីថា បានឮថា អារាមនោះ នៅរវាង ទ្វារផ្នែកខាងត្បូងនៃវត្តវេឡុវ័ន ។

[៧២] បទថា **ឥធ** បានដល់ ក្នុងឋានៈទាំង ៤ នេះ ។ បទថា **កឹវាទី កិមក្ខាយី** បានដល់ (ព្រះសមណគោតម) ហាមអ្វី ប្រាប់អ្វី ។ ព្រះថេរៈសួរថា ពួកបរិព្វាជកនឹងឲ្យអ្វីក្នុងប្រការនេះ ដល់ព្រះសមណគោតម ។ បទថា **ធម្មស្ស ចានុធម្មំ ព្យាករេយ្យាម** សេចក្ដីថា ព្រះគោតមត្រាស់ហេតុយ៉ាងណា ពួកយើងគប្បីពោលហេតុតាមសមគួរដល់ហេតុយ៉ាងនោះ ។ បទថា **សហធម្មិកោ វាទានុបាតោ** សេចក្ដីថា សហធម្មិកៈអ្នករួមប្រព្រឹត្តធម៌ណាៗ សូម្បីមានចំនួនតិច ជាអ្នកប្រព្រឹត្តទៅជាមួយហេតុ ដោយហេតុនៃពាក្យដែលជនពួកដទៃពោលហើយ ឈ្មោះថា ធ្លាក់ទៅតាមវាទៈ ចូលដល់វាទៈរបស់ព្រះសមណគោតម មិនគប្បីមកដល់ហេតុ ដែលបណ្ឌិតគួរតិះ-ដៀលយ៉ាងណា ។ លោកអធិប្បាយទុកយ៉ាងនេះថា ហេតុដែលគួរតិះដៀលក្នុងវាទៈរបស់ព្រះសមណគោតម ដោយអាការដែលពិត នឹងមិនគប្បីមានបានយ៉ាងណា ។

[៧៣] បទថា **ឥតិ វទំ** សេចក្ដីថា បុគ្គលកាលពោលយ៉ាងនេះថា

ទុក្ខមាន ព្រោះផស្សៈជាបច្ច័យ ។ បទថា **តត្រ** បានដល់ ក្នុងវាទៈទាំង ៤ នោះ ។ ពាក្យថា **តេ វត អញ្ញត្រ ផស្សា** នេះ ជាពាក្យសាធកហេតុថាថា សូម្បីប្រការនោះមាន ព្រោះផស្សៈជាបច្ច័យ ។ អធិប្បាយក្នុងសេចក្តីនោះ មានដូច្នេះថា ក៏ព្រោះហេតុដែលវៀរផស្សៈចេញ ការសោយទុក្ខក៏មិនមាន ដូច្នោះ ប្រការនោះ ក៏គប្បីជ្រាបដូចពាក្យថា សូម្បីប្រការនោះមាន ព្រោះផស្សៈជាបច្ច័យ ។

[៧៥] សាធុការនេះថា **សាធុ សាធុ អានន្ទ** ព្រះមានព្រះភាគ ក៏ប្រទានដល់ព្រះសារីបុត្តត្ថេរ តពីនោះ ព្រះមានព្រះភាគទ្រង់ប្រឹក្សានឹង ព្រះអានន្ទត្ថេរ ។

[៧៦] ពាក្យថា **ឥទ** ក្នុងពាក្យថា **ឯកមិទាហំ** នេះ ត្រឹមតែនិបាត ។ សេចក្តីថា សម័យមួយ ។ ពាក្យនេះលោកពោលដើម្បីសម្តែងថា មិនមែន ព្រះសារីបុត្រប៉ុណ្ណោះ ចូលទៅក្រុងរាជគ្រឹះតែម្យ៉ាង សូម្បីតថាគតក៏ចូល ទៅ ។ មិនមែនវិតក្កៈនេះកើតដល់ព្រះសារីបុត្រតែម្យ៉ាងប៉ុណ្ណោះ ក៏កើត ឡើងសូម្បីដល់តថាគត ។ ការពោលនឹងពួកតិរ្ថិយនេះ មិនមែនកើតដល់ សារីបុត្រនោះតែម្យ៉ាងប៉ុណ្ណោះ ការពោលនោះក៏ធ្លាប់កើតសូម្បីដល់តថាគត ។

[៧៧] ពាក្យ ២ ពាក្យនេះថា **អច្ឆរិយំ អព្ភុតំ** ជាពាក្យសម្តែងការអស្ចារ្យតែម្យ៉ាង ។ ក៏សេចក្តីរបស់ពាក្យក្នុងពាក្យទាំង ២ នោះថា ដែលឈ្មោះថា អច្ឆរិយៈ ព្រោះគួរដល់ការផ្ទាត់ម្រាមដៃ ។ ឈ្មោះថា **អព្ភុតៈ** ព្រោះមិនធ្លាប់មាន ក៏មានឡើង ។ បទថា **ឯកេន បទេន** បានដល់ ដោយបទតែមួយនេះថា ទុក្ខមាន ព្រោះផស្សៈជាបច្ច័យ ។ ត្រាស់សេចក្តីជំទាស់បទទាំងឡាយគ្រប់កន្លែង ដោយបទទាំងនោះ ។ បទថា **ឯសេវត្ថោ** សេចក្តីថា នុ៎ះឯង ជាសេចក្តីនៃបដិច្ចសមុប្បាទដែលថា ទុក្ខមាន ព្រោះផស្សៈជាបច្ច័យ ។ បទថា **តញ្ញេវេត្ថ បដិភាតុ** ប្រែថា ក្នុងប្រការនោះ ញាណចូរប្រាកដក្នុងព្រះមានព្រះភាគនោះ ។

[៧៨] ឥឡូវនេះ ព្រះថេរៈកាលនឹងធ្វើសេចក្តីនោះឲ្យជ្រាលជ្រៅ និងមានឱកាសជ្រាលជ្រៅដោយបដិច្ចសមុប្បាទកថា មានជរាមរណៈជាដើម ទើបពោលថា **សចេ មំ ភន្តេ** ជាដើម ពាក្យមានបទណាជាមូលកើតឡើង ក៏កាន់យកបទនោះហើយសម្តែងវិវដ្តៈ ទើបពោលថា **ឆន្នំ ត្វេវ** ជាដើម ។ ពាក្យដ៏សេសងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា អញ្ញតិត្ថិយសូត្រទី ៤

# អ ដ្ឋ ក ថា

## ភូមិជសូត្រទី ៥

*ក្នុង ភូមិជសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ៖*

*[៧៩] ពាក្យថា ភូមិជ ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ពាក្យដ៏សេស សូម្បីក្នុងសូត្រនេះ ក៏គប្បីជ្រាបដោយន័យដែលពោលទុកហើយក្នុងសូត្រដើមៗ ។ ចំណែកសេចក្ដីប្លែកគ្នាមានដូច្នេះ ។ ក៏ព្រោះហេតុដែលសុខទុក្ខនេះ មិនមែនកើតឡើងព្រោះផស្សៈជាបច្ច័យតែម្យ៉ាងប៉ុណ្ណោះ កម្មកាលបុគ្គលធ្វើ រមែងធ្វើដោយកាយខ្លះ ដោយវាចាខ្លះ ដោយចិត្តខ្លះ ធ្វើដោយខ្លួនឯងខ្លះ បុគ្គលដទៃធ្វើខ្លះ ធ្វើដោយមានសម្បជញ្ញៈខ្លះ ធ្វើដោយមិនមានសម្បជញ្ញៈខ្លះ ដូច្នោះ ដើម្បីនឹងទ្រង់សម្ដែងបច្ច័យដែលប្លែកគ្នាសូម្បីយ៉ាងដទៃៗ របស់កម្មនោះ ទើបត្រាស់ថា* ***ហានន្ទ សតិ*** *ជាដើម ។ បទថា* ***កាយសញ្ចេតនាហេតុ*** *ប្រែថា ព្រោះហេតុនៃចេតនាដែលកើតឡើងក្នុងកាយ-ទ្វារ ។ សូម្បីក្នុងវចីសញ្ចេតនា និងមនោសញ្ចេតនាក៏ន័យនេះដូចគ្នា ។ បណ្ដាទ្វារទាំងនោះ ក្នុងកាយទ្វារបានចេតនា ២០ ដោយអំណាចកុសល*

និងអកុសលចំណែកកាមាវចរ ។ ក្នុងវចីទ្វារក៏ដូចគ្នា ។ ក្នុងមនោទ្វារ ចេតនា ២០ នឹងរូបចេតនា និងអរូបចេតនា ៩ បានចេតនា ២៩ ។ ក្នុងទ្វារទាំង ៣ ទើបមនាចេតនា ៦៩ ។ ទ្រង់សម្តែងសុខទុក្ខចំណែកវិបាក ដែលមានចេតនានោះជាបច្ច័យ ។

[៨៣] ពាក្យថា *អវិជ្ជាបច្ចយា វ* នេះ ត្រាស់ទុកដើម្បីទ្រង់សម្តែងថា ចេតនាសូម្បីទាំងនោះ ក៏រមែងមានអវិជ្ជាជាបច្ច័យ ។ តែព្រោះហេតុដែលបុគ្គលដទៃមិនបានដឹកនាំ រមែងធ្វើកម្មនោះ ដែលជាកាយសង្ខារ វចី-សង្ខារ និងមនោសង្ខារ ត្រូវដោយចេតនាតាមដែលពោលហើយ ទាំងចិត្តដែលជាអសង្ខារិកៈក៏មាន ។ ត្រូវអ្នកដទៃប្រើឲ្យធ្វើ ក៏ធ្វើដោយចិត្តដែលជាសសង្ខារិកៈក៏មាន ។ រមែងធ្វើកម្មឈ្មោះនេះ វិបាករបស់កម្មនោះ នឹងមានឈ្មោះបែបនេះ បុគ្គលដឹងកម្ម និងវិបាក ដូចដែលពោលមកនេះ ទើបធ្វើក៏មាន ។ ដឹងកម្មតែម៉្យាងប៉ុណ្ណោះ ដូចទារក កាលបិតាមាតាធ្វើការថ្វាយបង្គំព្រះចេតិយជាដើម ក៏ធ្វើតាម តែគេមិនដឹងវិបាកថា នេះជាវិបាករបស់កម្មនេះ ហើយធ្វើក៏មាន ដូច្នោះ ដើម្បីទ្រង់សម្តែងកម្មនោះ ទើបត្រាស់ថា *សាមំ វា តំ អានន្ទ កាយសង្ខារំ អភិសង្ខរោតិ* ជាដើម ។ បទ

ថា **ឥមេសុ អានន្ទ ធម្មេសុ** សេចក្តីថា ម្នាលអានន្ទ ចេតនាធម៌ ២៧៦ ដែលតថាគតពោលក្នុងឋានៈ ៤ មាន **សាមំ វា តំ អានន្ទ កាយសង្ខារំ** ជាដើម បណ្តាធម៌ទាំងនេះ អវិជ្ជាធ្លាក់ទៅតាមកោដិឧបនិស្ស័យ ក៏ធម៌ទាំងអស់នោះ រមែងសង្គ្រោះចូលក្នុងសេចក្តីនេះថា **អវិជ្ជាបច្ចយា សង្ខារា** ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ដូច្នេះ ។

[៨៤] ឥឡូវនេះ កាលនឹងទ្រង់សម្តែងវិវដ្តៈ ទើបត្រាស់ថា **អវិជ្ជាយ ត្វេវ** ដូច្នេះជាដើម ។ បទថា **សោ កាយោ ន ហោតិ** សេចក្តីថា កាលកាយណាមាន សុខទុក្ខខាងក្នុង ដែលមានកាយសញ្ចេតនាជាបច្ច័យ ក៏កើតឡើង ។ កាយនោះមិនមាន ។ សូម្បីក្នុងវាចា និងមនៈ ក៏ន័យនេះឯង ។ មួយទៀត ចេតនាកាយ ឈ្មោះថា **កាយ** ចេតនាវាចា ក៏ឈ្មោះថា **វាចា** ។ កម្មមនោទ្វារនុ៎ះឯង ក៏ឈ្មោះថា **មនៈ** ។ ន័យមួយទៀត ទ្វារកាយ ឈ្មោះថា **កាយ** ។ សូម្បីក្នុងវាចា និងមនៈ ក៏ន័យនេះដូចគ្នា ។ ព្រះខីណាស្រព រមែងថ្វាយបង្គំព្រះចេតិយ សម្តែងធម៌ ធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន ។ សួរថា កាយកម្មជាដើម របស់ព្រះខីណាស្រព មិនមានទេឬ ។ ឆ្លើយថា ព្រោះកម្មនោះមិនមានវិបាក ។ ពិតណាស់ កម្មដែលព្រះខីណាស្រពធ្វើ មិនជា

កុសល មិនជាអកុសល មិនមានវិបាក តាំងនៅត្រឹមតែជាកិរិយា ។ ដោយហេតុនោះ ទើបពោលថា កាយកម្មជាដើមទាំងនោះ របស់ព្រះខីណាស្រពនោះមិនមាន ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ខេត្តំ ន ហោតិ** ជាដើមដូច្នេះ ។ កម្មនោះ មិនមែនជាខេត្ត ព្រោះអត្ថថា បញ្ចេញផល ។ មិនមែនជាវត្ថុ ព្រោះអត្ថថា ជាទីតាំង ។ មិនមែនជាអាយតនៈ ព្រោះអត្ថថា ជាបច្ច័យ ។ មិនមែនជាអធិករណ៍ ព្រោះអត្ថថា ជាហេតុ ។ សេចក្តីពិតសុខទុក្ខខាងក្នុង ដែលមានចេតនាណាជាមូល គប្បីកើតឡើង ។ សញ្ចេតនានោះ មិនមែនជាខេត្ត មិនមែនជាវត្ថុ មិនមែនជាអាយតនៈ មិនមែនជាអធិករណ៍ នៃសុខទុក្ខនោះ ព្រោះមិនមានផលប្រយោជន៍ មានការបញ្ចេញផលជាដើមនោះឯង ។ ក្នុងព្រះសូត្រនេះ ត្រាស់សុខទុក្ខប៉ុណ្ណោះ ក្នុងវេទនាជាដើម ។ ក៏សុខទុក្ខនោះឯង ជាវិបាកតែម្យ៉ាង ។

ចប់អដ្ឋកថា ភូមិជសូត្រទី ៩

# អ ដ្ឋ ក ថា

## ឧបវាណសូត្រទី ៦

[៨៥] *ឧបវាណសូត្រទី ៦ មានសេចក្ដីងាយទាំងអស់នោះឯង ។ តែក្នុងព្រះសូត្រនេះ ត្រាស់ចំពោះវដ្ដទុក្ខតែម្យ៉ាង ។*

ចប់អដ្ឋកថា ឧបវាណសូត្រទី ៦

# អ ដ្ឋ ក ថា

## បដិច្ចសមុប្បាទសូត្រទី ៧[1]

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបដិច្ចសមុប្បាទសូត្រទី ៧ ដូចតទៅនេះ ៖

[៨៩] កាលត្រាស់បដិច្ចសមុប្បាទតាមលំដាប់ ព្រះមានព្រះភាគទ្រង់កាន់យកបទចុងក្រោយ ត្រាស់ថា **កតមញ្ច ភិក្ខវេ ជរាមរណំ** ជាដើម ។

[៩០] បទថា **ឯវំ បច្ចយំ បជានាតិ** សេចក្តីថា អរិយសាវកដឹងច្បាស់ដល់បច្ច័យ ដោយអំណាចទុក្ខសច្ចៈយ៉ាងនេះ ។ សូម្បីបច្ចយសមុទ័យ ជាដើម ក៏គប្បីជ្រាបដោយអំណាចសមុទយសច្ចៈជាដើមដូចគ្នា ។ បទថា **ទិដ្ឋិសម្បន្នោ** បានដល់ បរិបូណ៌ដោយបញ្ញាក្នុងមគ្គ ។ បទថា **ទស្សនសម្បន្នោ** ជាវេវចនៈរបស់បទថា **ទិដ្ឋិសម្បន្នោ** នោះឯង ។ បទថា **ឥមំ សទ្ធម្មំ** បានដល់ មកដល់ព្រះសទ្ធម្ម គឺ មគ្គ ។ បទថា **បស្សតិ** បានដល់ ឃើញព្រះសទ្ធម្ម គឺ មគ្គនុ៎ះឯង ។ បទថា **សេក្ខេន ញាណេន** បានដល់ ដោយញាណក្នុងមគ្គ ។ បទថា **សេក្ខាយ វិជ្ជាយ** បានដល់ ដោយសេចក្តី

---

១ ព្រះសូត្រ គឺ បច្ចយសូត្រ ។

ដឹងច្បាស់ក្នុងមគ្គ ។ បទថា **ធម្មសោតំ សមាបន្នោ** បានដល់ ចូលដល់ក្រសែធម៌ ពោលគឺ មគ្គនុ៎ះឯង ។ បទថា **អរិយោ** បានដល់ កន្លងភូមិរបស់បុថុជ្ជន ។ បទថា **និព្វេធិកបញ្ញោ** បានដល់ បុគ្គលប្រកបដោយបញ្ញាជាគ្រឿងចាក់ធ្លុះ ។ **ព្រះនិព្វាន** ឈ្មោះថា អមតៈ ក្នុងពាក្យថា **អមតទ្វារំ អាហច្ច តិដ្ឋតិ** ។ តាំងនៅទល់អរិយមគ្គដែលជាទ្វាររបស់ព្រះនិព្វាននោះឯង ។

ចប់អដ្ឋកថា បដិច្ចសមុប្បាទសូត្រទី ៧

# អ ដ្ឋ ក ថា

## ភិក្ខុសូត្រទី ៨

[៩០] *ភិក្ខុសូត្រទី ៨ ក៏ងាយទាំងអស់ដូចគ្នា ។*

ចប់អដ្ឋកថា ភិក្ខុសូត្រទី ៨

# អ ដ្ឋ ក ថា

## បឋមសមណព្រាហ្មណសុត្រទី ៩

[៩៤] *សមណព្រាហ្មណសូត្រទី ៩ ព្រះមានព្រះភាគត្រាស់ដោយអធ្យាស្រ័យរបស់ពួកភិក្ខុ អ្នកពោលអំពីអក្ខរៈ ។ ភិក្ខុពួកនោះ កាលត្រូវគេដាក់ឧបសគ្គថា បរិ ហើយពោល ទើបអាចគិតចេញ ។*

ចប់អដ្ឋកថា បឋមសមណព្រាហ្មណសូត្រទី៩

# អ ដ្ឋ ក ថា

## ទុតិយសមណព្រាហ្មណសូត្រទី ១០

[៩៦] *សមណព្រាហ្មណសូត្រទី ១០ គ្រប់ពាក្យក៏ងាយទាំងអស់នោះឯង ។ ក្នុងសូត្រទាំងពីរនេះ ព្រះមានព្រះភាគត្រាស់ការបោកប្ចុះសច្ចៈ ៤ ។*

ចប់អដ្ឋកថា ទុតិយសមណព្រាហ្មណសូត្រទី ១០

## ចប់ទសពលវគ្គ ទី ៣

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថាបឋមទសពលសូត្រ ២-អដ្ឋកថាទុតិយទសពលសូត្រ
៣-អដ្ឋកថាឧបនិស្សសូត្រ ៤-អដ្ឋកថាអញ្ញតិត្ថិយសូត្រ
៥-អដ្ឋកថាភូមិជសូត្រ ៦-អដ្ឋកថាឧបវាណសូត្រ
៧-អដ្ឋកថាបច្ចយសូត្រ ៨-អដ្ឋកថាភិក្ខុសូត្រ
៩-អដ្ឋកថាបឋមសមណព្រាហ្មណសូត្រ ១០-អដ្ឋកថាទុតិយសមណព្រាហ្មណសូត្រ

# កឡារខត្តិយវគ្គទី ៤

## អ ដ្ឋ ក ថា

### ភូតមិទសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង ភូតមិទសូត្រទី ១ នៃកឡារខត្តិយវគ្គតទៅ ។

[៩៨] បទថា **អជិតបញ្ហេ** បានដល់ ក្នុងបញ្ហាដែលអជិតមាណព ទូលសួរហើយ ។ បទថា **សង្ខាតធម្មាសេ** បានដល់ អ្នកមានធម៌ដែលដឹងហើយ គឺ មានធម៌ដែលត្រាស់ដឹងហើយ មានធម៌ដែលបានថ្លឹងហើយ មានធម៌ដែលបានពិចារណាស្រេចហើយ ។ បទថា **សេក្ខា** បានដល់ ព្រះសេក្ខៈទាំង ៧ ។ បទថា **បុថូ** ចំនួនច្រើន គឺ ព្រះមានព្រះភាគទ្រង់សំដៅយកជន (ព្រះសេក្ខៈ) ៧ ពួកនុ៎ះឯង ទើបត្រាស់ថា **បុថូ** ។ បទថា **ឥធ** គឺ ក្នុងព្រះសាសនានេះ ។ ក្នុងបទថា **និបកោ** បញ្ញា លោកហៅថា នេបក្កៈ អ្នកប្រកបដោយបញ្ញានោះ ឈ្មោះថា និបកៈ អជិតមាណពទូលអង្វរថា ក៏ព្រះអង្គជាអ្នកឆ្លាត សូមមេត្តាត្រាស់ប្រាប់ ។ បទថា **ឥរិយំ** ដល់នូវការប្រព្រឹត្ត បានដល់ ការប្រព្រឹត្ត គឺ ការបដិបត្តិដែលមានអាចារៈ ការ

ប្រព្រឹត្តល្អដែលជាផ្លូវ ។ អជិតមាណពក្រាបទូលហៅព្រះមានព្រះភាគថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ក្នុងអជិតបញ្ហានេះ មានសេចក្តីសង្ខេបដូច្នេះ ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ អ្នកមានបញ្ញា បុគ្គលអ្នកប្រាថ្នាការបដិបត្តិរបស់ព្រះសេក្ខបុគ្គល និងព្រះខីណាស្រពអ្នកត្រាស់ដឹងធម៌ហើយ ដែលខ្ញុំព្រះអង្គសួរហើយ សូមទ្រង់មេត្តាសម្តែងឲ្យទាន ។

[៩៩] ពាក្យថា **តុណ្ហី អហោសិ** នៅស្ងៀម បានដល់ ព្រះសារីបុត្តត្ថេរ ត្រូវព្រះមានព្រះភាគត្រាស់សួរដល់ ៣ ដង ព្រោះហេតុអ្វី ទើបបានស្ងៀម ។

សួរថា លោកសង្ស័យក្នុងបញ្ហា ឬក៏សង្ស័យក្នុងព្រះអធ្យាស្រ័យរបស់ព្រះមានព្រះភាគ ។

ឆ្លើយថា មិនបានសង្ស័យក្នុងបញ្ហា ។

បានឮមកថា ព្រះសារីបុត្តត្ថេរ មានការគិតយ៉ាងនេះថា ព្រះសាស្តាទ្រង់មានព្រះបំណងនឹងឲ្យយើងពោលអំពីបដិបទា (វត្តបដិបត្តិ) ដែលគួរសម្រេចចំពោះព្រះសេក្ខបុគ្គល និងព្រះអសេក្ខៈ ឯបដិបទានោះ មិនអាចពោលដោយហេតុច្រើនយ៉ាង គឺ ដោយអំណាចខន្ធ ដោយអំណាចធាតុ

ដោយអំណាចអាយតនៈ និងដោយអំណាចនៃបច្ចយាការ ។ កាលបើយើង ហើយ នឹងអាចកំណត់ព្រះអធ្យាស្រ័យរបស់ព្រះសាស្តា ឬទេហ្ន៎ ។ គ្រានោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា វៀរតថាគតចេញហើយ ឈ្មោះថាសាវកដទៃ អ្នកកាន់បាត្រត្រាច់ទៅ នឹងមានបញ្ញាស្មើព្រះសារីបុត្រ រមែងមិនមាន សូម្បី សារីបុត្តត្រូវតថាគតសួរបញ្ហា ក៏នៅស្ងៀមរហូតដល់ ៣ ដង គេសង្ស័យ ក្នុងបញ្ហា ឬក៏សង្ស័យក្នុងអធ្យាស្រ័យ (បំណងរបស់តថាគត) ។

[១០០] ទ្រង់ជ្រាបថា សង្ស័យក្នុងអធ្យាស្រ័យ កាលនឹងទ្រង់ប្រទាន ន័យដើម្បីពោលដោះស្រាយបញ្ហា ទើបត្រាស់ថា **ភូតមិទន្តិ សារីបុត្ត បស្សសិ** ម្នាលសារីបុត្រ អ្នកឃើញទេថា នេះគឺ ខន្ធបញ្ចកៈ (ខន្ធ ៥) ដែលកើតហើយ ក្នុងព្រះបាលីនោះ ពាក្យថា **ភូតំ** ប្រែថា កើត បានដល់ កើតហើយ ។ និងពាក្យថា **ភូតំ** នេះ ជាឈ្មោះរបស់ខន្ធបញ្ចកៈ ។ ព្រោះហេតុនោះ ព្រះ សាស្តាទើបប្រទានន័យដល់ព្រះសារីបុត្តត្ថេរថា **ម្នាលសារីបុត្រ អ្នកចូរពោល ដោះស្រាយបញ្ហានេះដោយអំណាចនៃខន្ធ ៥ ដូច្នេះ** ។ ព្រមជាមួយការ ប្រទានន័យ ការព្យាករណ៍បញ្ហាទើបប្រាកដដល់ព្រះសារីបុត្តត្ថេរ ដោយន័យ រាប់រយរាប់ពាន់ ដូចមហាសមុទ្រដែលល្ហល្ហេវជាផ្ទាំងតែមួយ ប្រាកដដល់

បុរសអ្នកឈរត្រង់មាត់ប្រាំងដូច្នោះ គ្រានោះ ព្រះសារីបុត្តត្ថេរ កាលនឹង ព្យាករណ៍បញ្ហានោះ បានពោលថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលឃើញ ដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតថា នេះគឺ ខន្ធបញ្ចកៈដែលកើតហើយ ។ ពាក្យថា **ភូតមិទំ** ក្នុងប្រការនោះ ប្រែថា នេះគឺ ខន្ធបញ្ចកៈដែលកើតហើយ ។ ពាក្យថា **រមែងឃើញដោយបញ្ញាដ៏ប្រពៃ** បានដល់ រមែងឃើញដោយប្រពៃ ដោយមគ្គប្បញ្ញា (ដឹងផ្លូវទៅកាន់សេចក្តីរលត់ទុក្ខ) ព្រមដោយវិបស្សនា ។ ប្រការថា **បដិបន្នោ ហោតិ** បានដល់ រមែងបដិបត្តិដើម្បីប្រយោជន៍ដល់ និព្វិទាជាដើម ផ្តើមពីសីល រហូតដល់ព្រះអរហត្តមគ្គ ។ ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបទ្រង់ប្រារព្ធសេចក្តីនេះថា **ខន្ធបញ្ចកៈនេះកើតព្រោះ អាហារនោះ** ។ ព្រោះខន្ធបញ្ចកៈនេះ អាស្រ័យអាហារទើបតាំងនៅបាន ដូច្នោះ ព្រះពុទ្ធអង្គទើបទ្រង់ប្រារព្ធសេចក្តីនេះ ដើម្បីទ្រង់សម្តែងអាហារ នោះ ធ្វើឲ្យជាសភាវនាម ។ បដិបទា គឺ វត្តបដិបត្តិរបស់ព្រះសេក្ខបុគ្គល ព្រះមានព្រះភាគត្រាស់ហើយដោយបរិយាយនេះឯង ។ បទថា **តទាហារ- និរោធា** ព្រោះអាហារនោះរលត់ គឺ ព្រោះសេចក្តីរលត់នៃអាហារទាំងនោះ ។ ព្រោះហេតុអ្វីព្រះមានព្រះភាគ ទ្រង់ប្រារព្ធសេចក្តីនេះ ។ ព្រោះខន្ធបញ្ចកៈ

នោះរមែងរលត់ ព្រោះអាហាររលត់ ដូច្នោះ ព្រះពុទ្ធអង្គទើបទ្រង់ប្រារព្ធសេចក្តីនេះ ដើម្បីទ្រង់សម្តែងសេចក្តីរលត់នៃអាហារនោះ ធ្វើឲ្យជាសការនាម ។ បដិបទារបស់ព្រះសេក្ខបុគ្គល ទើបជាការដែលព្រះមានព្រះភាគត្រាស់ហើយដោយបរិយាយនេះឯង ។

[១០១] ពាក្យថា **និព្វិទា** ជាដើម គប្បីជ្រាបថា ជាការពោលប្រាប់ហេតុគ្រប់យ៉ាង ។ បទថា **អនុបាទា** ព្រោះការមិនប្រកាន់មាំ បានដល់ផុតចាកឧបាទាន គឺ ការប្រកាន់មាំ ៤ ប្រការ មិនកាន់យកធម៌ណាៗ ។

[១០២] ដោយពាក្យថា **សាធុ សាធុ** ត្រូវហើយ ត្រូវហើយ នេះ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើការព្យាករណ៍បញ្ហារបស់ព្រះសារីបុត្តត្ថេរឲ្យរីករាយ កាលទ្រង់ព្យាករណ៍ដូច្នោះ ដោយព្រះអង្គឯង ទើបត្រាស់ដដែលថា នេះគឺ ខន្ធបញ្ចកៈដែលកើតហើយ ដូច្នេះជាដើម ។

ចប់អដ្ឋកថា ភូតមិទសូត្រទី ១

# អ ដ្ឋ ក ថា

## កង្ខារេវតិយសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង **កង្ខារេវតិយសូត្រទី ២** តទៅ ។*

[១០៤] *ពាក្យថា **កង្ខារេវតោ** ជាឈ្មោះរបស់ព្រះថេរៈ ។ កំហែងរបស់ព្រះថេរៈនោះស្រគាំ តាំង (ឡើង) មិនស្មើគ្នា ដូច្នោះ ទើបហៅថា **កង្ខារ** ។ ពាក្យថា **ហីនាយាវត្តោ** វិលមកដើម្បីភាពជាបុគ្គលអាក្រក់ គឺ វិលមកដើម្បីប្រយោជន៍ដល់ភាពជាគ្រហស្ថដែលជាបុគ្គលថោកទាប ។ ពាក្យថា **អសម្បាសមលត្ថ** មិនបានសេចក្តីពេញចិត្ត បានដល់ ព្រះមោលិយផគ្គុនៈ មិនបាននូវការពេញចិត្ត គឺ ទីអាស្រ័យ ទីពឹងដោយពិត ។ ព្រះសារីបុត្តត្ថេរសម្តែងថា មិនបានមគ្គ ៣ និងផល ៣ ។ ពាក្យអធិប្បាយរបស់ព្រះថេរៈមានដូច្នេះថា ប្រសិនបើព្រះមោលិយផគ្គុនៈ គប្បីបានមគ្គនិងផលទាំងនោះ លោកមិនគប្បីលាសិក្ខា វិលមកផ្លូវថោកថយ ។ បទថា **ន ខ្វាហំ អាវុសោ** លោកដ៏មានអាយុ ខ្ញុំមិនសង្ស័យឡើយ សេចក្តីថា ម្នាលលោកដ៏មានអាយុ ខ្ញុំមានសេចក្តីពេញចិត្ត ព្រោះហេតុនោះ ខ្ញុំទើប*

មិនសង្ស័យ ព្រោះថា សាវកបារមីញាណរបស់ព្រះសារីបុត្តត្ថេរ ជាទីពឹង (របស់ខ្លួន) បាន ដូច្នោះ លោកទើបមិនសង្ស័យ ។ ដោយពាក្យថា **អាយតឹ បនាវុសោ** លោកដ៏មានអាយុ អំណឹះតទៅ នេះ ព្រះកឡារខត្តិយៈសួរ ដល់ការសម្រេចព្រះអរហត្តរបស់ព្រះសារីបុត្តត្ថេរថា ការបដិសន្ធិតទៅ លោក ដកឡើងហើយ ឬមិនទាន់ដកឡើង ។ ដោយពាក្យថា **ន ខ្វាហំ អាវុសោ វិចិកិច្ឆាមិ** អ្នកមានអាយុ ខ្ញុំមិនសង្ស័យឡើយ នេះ ព្រះសារីបុត្តត្ថេរសម្ដែង សេចក្ដីមិនសង្ស័យក្នុងការសម្រេចព្រះអរហត្តនោះ ។

[១០៥] បទថា **យេន ភគវា តេនុបសង្កមិ** បានចូលទៅគាល់ ព្រះមានព្រះភាគដល់ទីប្រថាប់ សេចក្ដីថា បានចូលទៅគាល់ដោយគិតថា យើងនឹងក្រាបទូលចំពោះព្រះមានព្រះភាគសូម្បីហេតុល្អនេះ ។ ពាក្យថា **អញ្ញា ព្យាកតា** ប្រែថា ព្យាករណ៍ព្រះអរហត្តហើយ ។ ព្រះអរហត្តផល ឈ្មោះថា ព្រះសារីបុត្តត្ថេរព្យាករណ៍ហើយយ៉ាងនេះថា **ជាតិអស់ហើយ** ។ ក៏ព្រះថេរៈនេះ ត្រេកអរហើយ ជ្រះថ្លាហើយ ទើបលើកបទ និងព្យញ្ជនៈ ឡើងពោលយ៉ាងនេះ ។ បទថា **អញ្ញតរំ ភិក្ខុំ អាមន្តេសិ** ទ្រង់ត្រាស់ បង្គាប់ភិក្ខុមួយរូប សេចក្ដីថា ព្រះសាស្ដាទ្រង់ស្ដាប់ពាក្យក្រាបទូលនោះ

ហើយ ទ្រង់ព្រះតម្រិះថា ព្រះសារីបុត្រជាបណ្ឌិតល្អិតល្អន់ អ្នកនឹងមិនព្យាករណ៍យ៉ាងនេះដោយហេតុណាៗ ព្រោះបញ្ហាដែលអ្នកកព្យាករណ៍ហើយដោយសង្ខេប តថាគតនឹងឲ្យហៅគេមកហើយ ឲ្យព្យាករណ៍បញ្ហានោះ ដូច្នេះ ទើបទ្រង់ត្រាស់រកភិក្ខុមួយរូប ។

ព្រះមានព្រះភាគត្រាស់សួរថា **សចេ តំ សារីបុត្ត** យ៉ាងនេះ ដើម្បីឲ្យព្រះសារីបុត្តត្ថេរព្យាករណ៍អរហត្តផល ដោយមានព្រះតម្រិះថា សារីបុត្រនេះនឹងមិនព្យាករណ៍អរហត្តផលតាមធម្មតារបស់ខ្លួន តថាគតនឹងសួរបញ្ហានេះ និងកាលគេពោលដោះស្រាយបញ្ហានេះ នឹងព្យាករណ៍អរហត្តផល ។ បទថា **យំ និទានាវុសោ ជាតិ** លោកដ៏មានអាយុ ជាតិ គឺការកើត មានអ្វីជាហេតុ សេចក្តីថា លោកដ៏មានអាយុ ឈ្មោះថា ជាតិ គឺការកើតនេះ មានវត្ថុណាជាហេតុ ។ ខ្ញុំដឹងហើយថា កាលបច្ច័យនៃជាតិអស់ហើយ ព្រោះបច្ច័យដែលជាដើមហេតុនោះអស់ទៅ ផល គឺ ជាតិ ទើបអស់ទៅ ដូច្នេះ ។

ម្យ៉ាងទៀត ព្រះសារីបុត្តត្ថេរមិនសង្ស័យក្នុងបញ្ហានេះ តែសង្ស័យក្នុងព្រះអធ្យាស្រ័យ (ព្រះបំណង) របស់ព្រះមានព្រះភាគ ។ បានឮមកថា

ព្រះសារីបុត្តត្ថេរនោះ មានសេចក្តីគិតយ៉ាងនេះថា យើងមិនអាចព្យាករណ៍ព្រះអរហត្តផលដោយហេតុច្រើនយ៉ាង មានជាអាទិ៍ដូចជា តណ្ហាអស់ហើយ ឧបាទានអស់ហើយ ភពអស់ហើយ បច្ច័យអស់ហើយ កិលេសអស់ហើយ តែកាលទឹងពោលដោះស្រាយបញ្ហា យើងក៏នឹងអាចកំណត់ព្រះបំណងរបស់ព្រះសាស្តាបាន ដូច្នេះ ។ ព្រះសារីបុត្តត្ថេរសង្ស័យក្នុងព្រះបំណង (របស់ព្រះមានព្រះភាគ) យ៉ាងនេះក៏ពិត ។ សូម្បីយ៉ាងនោះ ក៏មិនបានវៀវបញ្ហាឡើយ បានព្យាករណ៍ដោយអំណាចបច្ចយាការ ។ សូម្បីព្រះសាស្តា ក៏ទ្រង់មានព្រះបំណងនឹងឲ្យព្យាករណ៍ដោយអំណាចបច្ចយាការនុ៎ះឯង ។ ដូច្នោះ ព្រះសារីបុត្តត្ថេរនេះ កាលទឹងព្យាករណ៍បញ្ហា ទើបបានកំណត់ព្រះបំណងរបស់ព្រះសាស្តា និងបានដឹងមុនហើយដូចគ្នាថា យើងកំណត់ព្រះបំណងព្រះមានព្រះភាគបានហើយ ។ ក៏ព្រោះហេតុដែលព្រះមានព្រះភាគទ្រង់សួរបញ្ហាដែលខ្ពស់ឡើងទៅ ដូច្នោះ ទើបគួរជ្រាបថា ការព្យាករណ៍បញ្ហានោះព្រះមានព្រះភាគទ្រង់អនុមោទនាហើយ ។ សួរថា ព្រោះហេតុអ្វី ព្រះមាន-ព្រះភាគទ្រង់ទើបប្រារព្ធសេចក្តីនេះថា ក៏អ្នកដឹងដូចម្តេច ដូច្នេះ ។ ឆ្លើយថា ដើម្បីឲ្យព្រះសារីបុត្តត្ថេរបន្លឺសីហនាទ ក្នុងសេចក្តីដែលមិនមែនវិស័យ

*(របស់ខ្លួន) ។*

*បានឮមកថា កាលព្រះសាស្តាសម្តែងវេទនាបរិគ្គហសូត្រ ដល់ទីឃនខបរិព្វាជក ត្រង់ទ្វារល្អាងសូករខាតា ព្រះសារីបុត្តត្ថេរកាន់ផ្លិតស្លឹកត្នោតឈរបក់ថ្វាយព្រះសាស្តា កំណត់វេទនា ៣ ហើយបានសម្រេចសាវកបារមីញាណ ។ វេទនានេះ មិនមែនធម៌ដែលជាវិស័យរបស់ព្រះសារីបុត្តត្ថេរនោះ ។ ព្រះសាស្តាទ្រង់សំដៅយកថា ព្រះសារីបុត្រ អ្នកតាំងនៅក្នុងធម៌ដែលជាវិស័យរបស់ខ្លួននេះ នឹងបន្លឺសីហនាទ ដូច្នេះ ទើបទ្រង់សួរបញ្ហានេះក៏ទេ ។*

[១១២] *បទថា* ***អនិច្ចា*** *បានដល់ ឈ្មោះថា មិនទៀង ព្រោះអត្ថថា មានហើយត្រឡប់ជាមិនមាននោះឯង ។ ក្នុងពាក្យថា* ***វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ*** *នេះ បានដល់* ***សុខវេទនា*** *ជាសុខព្រោះតាំងនៅ ជាទុក្ខព្រោះប្រែប្រួល ,* ***ទុក្ខវេទនា*** *ជាទុក្ខព្រោះតាំងនៅ ជាសុខព្រោះប្រែប្រួល ។* ***អទុក្ខមសុខវេទនា*** *ជាសុខព្រោះដឹង ជាទុក្ខព្រោះមិនដឹងក៏ពិត សូម្បីយ៉ាងនោះ ដោយទីបំផុតនៃសេចក្តីប្រែប្រួល វេទនាគ្រប់យ៉ាង ឈ្មោះថា ជាទុក្ខទាំងអស់ ។ បទថា* ***វិទិតំ*** *ដឹងហើយ បានដល់ ព្រោះយើងដឹងហើយថា*

វេទនា ៣ ជាទុក្ខយ៉ាងនេះ ដូច្នោះ ការប្រាថ្នាក្នុងវេទនាទាំងនោះ ទើបព្រះសារីបុត្តត្ថេរនោះកម្ចាត់ចេញហើយ ព្រះមានព្រះភាគ ទ្រង់សម្តែងថា តណ្ហានោះមិនប្រាកដ ។

[១១៣] ពាក្យថា សាធុ សាធុ ប្រពៃហើយៗ ជាការរីករាយក្នុងការកំណត់វេទនារបស់ព្រះសារីបុត្តត្ថេរ ។ ក៏កាលមិនពោលថា វេទនាមានតែម្យ៉ាងខ្លះ មាន ២ មាន ៣ មាន ៤ ខ្លះ ដូច្នេះឡើយ ។ ព្រះសារី-បុត្តត្ថេរ បានកំណត់ដឹងវេទនាទាំងនោះថា មាន ៣ ។ ដោយហេតុនោះព្រះមានព្រះភាគ កាលនឹងទ្រង់ឲ្យព្រះសារីបុត្តត្ថេររីករាយ ទើបត្រាស់យ៉ាងនេះ ។ ព្រះមានព្រះភាគត្រាស់ពាក្យថា ទុក្ខស្មឹ នេះ ដោយព្រះបំណងដូច្នេះថា ម្នាលសារីបុត្រ សេចក្តីដែលអ្នកព្យាករណ៍ថា សេចក្តីប្រាថ្នាក្នុងវេទនាទាំងឡាយមិនប្រាកដដល់យើង ព្រោះហេតុនេះ ដូច្នេះនោះ ជាការព្យាករណ៍ដែលល្អហើយ តែកាលអ្នកចែកថា វេទនាមាន ៣ ទើបធ្វើឲ្យយឺតយូរក្រៃលែង ព្រោះថា កាលអ្នកព្យាករណ៍ វេទនានោះថា ជាទុក្ខ ដូច្នេះជាការព្យាករណ៍ល្អហើយទុំឯង និងកាលត្រឹមតែមានសេចក្តីដឹងថា វេទនាយ៉ាងណាមួយ សុទ្ធតែជាទុក្ខនោះ ដូច្នេះ សេចក្តីប្រាថ្នាក្នុងវេទនាទាំងឡាយ

ក៏តាំងនៅមិនបាន ។

បទថា **កថំ វិមោក្ខា** ព្រោះសេចក្ដីរួចផុត ដូចម្ដេច បានដល់ ព្រោះសេចក្ដីរួចផុតណា អធិប្បាយថា អ្នកបានព្យាករណ៍ព្រះអរហត្តផល ព្រោះវិមោក្ខប្រការណា ។ បទថា **អជ្ឈត្តវិមោក្ខា** ព្រោះសេចក្ដីរួចផុតខាងក្នុងបានដល់ ព្រោះព្រះអរហត្តដែលខ្លួនកំណត់សង្ខារក្នុងខាងក្នុងបានសម្រេចហើយ ។

ក្នុងពាក្យថា **ព្រោះសេចក្ដីរួចផុតខាងក្នុងនោះ** គប្បីជ្រាបពួក ៤ ដូច្នេះ សេចក្ដីតាំងមាំក្នុងខាងក្នុង ដែលឈ្មោះថា ការចេញក្នុងខាងក្នុង ១ សេចក្ដីតាំងមាំក្នុងខាងក្នុងទីឈ្មោះថា ការចេញខាងក្រៅ ១ សេចក្ដីតាំងមាំក្នុងខាងក្រៅ ដែលឈ្មោះថា ការចេញខាងក្រៅ ១ សេចក្ដីតាំងមាំក្នុងខាងក្រៅ ដែលឈ្មោះថា ការចេញខាងក្នុង ១ ក៏សូម្បីធម៌តាំងមាំហើយក្នុងខាងក្នុង គប្បីជ្រាបថា មានក្នុងខាងក្រៅនុ៎ះឯង ដែលតាំងមាំក្នុងខាងក្រៅ ក៏គប្បីជ្រាបថា ជាធម៌ខាងក្នុងនុ៎ះឯង ព្រោះដូច្នោះ ភិក្ខុរូបខ្លះញុំាងញាណចុះក្នុងសង្ខារដែលជាខាងក្នុង កំណត់សង្ខារទាំងនោះហើយ ចុះកាន់ខាងក្រៅ គ្រាកំណត់ (សង្ខារ) សូម្បីក្នុងចំណែកខាងក្រៅបានហើយ រមែង

ឈានចុះកាន់ខាងក្នុងទៀត ។ ក្នុងវេលាដែលភិក្ខុនោះពិចារណាសង្ខារដែលជាខាងក្នុង រមែងមានការចេញចាកមគ្គ ។ សេចក្តីតាំងមាំក្នុងខាងក្នុង ឈ្មោះថា ជាការចេញចំណែកខាងក្នុងយ៉ាងនេះ ។ ភិក្ខុរូបខ្លះ ញ៉ាំងញាណចុះក្នុងសង្ខារដែលជាខាងក្នុង កំណត់សង្ខារទាំងនោះហើយ ឲ្យធ្លាក់ចុះខាងក្រៅទៀត ។ ក្នុងវេលាដែលភិក្ខុនោះពិចារណាសង្ខារក្នុងខាងក្រៅ ឈ្មោះថា ជាការចេញចាកមគ្គ ។ សេចក្តីតាំងមាំក្នុងខាងក្នុង ឈ្មោះថា ជាការចេញខាងក្រៅយ៉ាងនេះ ។ ភិក្ខុរូបខ្លះញ៉ាំងញាណឲ្យធ្លាក់ចុះក្នុងសង្ខារក្នុងខាងក្រៅ កំណត់សង្ខារទាំងនោះហើយ ឲ្យធ្លាក់ចុះក្នុងខាងក្នុង លុះកំណត់សង្ខារសូម្បីជាខាងក្នុងបានហើយ ក៏ធ្លាក់ចុះខាងក្រៅទៀត កាលដែលភិក្ខុនោះពិចារណាសង្ខារក្នុងខាងក្រៅបាន ឈ្មោះថា ចេញចាកមគ្គ ។ សេចក្តីតាំងមាំក្នុងខាងក្រៅ ឈ្មោះថា ជាការចេញក្នុងខាងក្រៅយ៉ាងនេះ ។ ភិក្ខុរូបខ្លះញ៉ាំងឲ្យធ្លាក់ចុះក្នុងសង្ខារខាងក្រៅ កំណត់សង្ខារទាំងនោះហើយ ឲ្យធ្លាក់ចុះខាងក្នុងទៀត ក្នុងវេលាដែលភិក្ខុនោះពិចារណាសង្ខារដែលជាខាងក្នុង ឈ្មោះថា ជាការចេញចាកមគ្គ ។ សេចក្តីតាំងមាំក្នុងខាងក្រៅ ឈ្មោះថា ជាការចេញក្នុងខាងក្នុងយ៉ាងនេះ ។ ក្នុងសេចក្តីនោះ ព្រះសារីបុត្តត្ថេរ

កំណត់សង្ខារដែលជាខាងក្នុងហើយ កាលនឹងសម្តែងថា យើងបានសម្រេចព្រះអរហត្តហើយ ដោយការចេញចាកមគ្គក្នុងវេលាកំណត់សង្ខារទាំងនោះ ទើបពោលថា ម្នាលលោកដ៏មានអាយុ ខ្ញុំមានសតិនៅយ៉ាងនោះ ព្រោះការរួបផុតក្នុងខាងក្នុង ។ បទថា **សព្វុបាទានក្ខយា** ព្រោះឧបាទានទាំងពួងអស់ទៅ បានដល់ ព្រោះការអស់ទៅនៃឧបាទាន ៤ ។ ពាក្យថា **តថាសតោ វិហរាមិ** យើងមានសតិនៅយ៉ាងនោះ បានដល់ យើងប្រកបដោយសតិនៅដោយអាការនោះ ។ ពាក្យថា **យថាសតំ វិហរន្តំ** អ្នកមានសតិនៅយ៉ាងណា ។ បានដល់ យើងអ្នកប្រកបដោយសតិនៅដោយអាការណា ។ បទថា **អាសវា នានុស្សវន្តិ** អាសវៈទាំងឡាយ រមែងមិនគ្របសង្កត់ អធិប្បាយថា អាសវៈទាំងឡាយមានកាមាសវៈជាដើម ដែលមានការហូរទៅក្នុងអារម្មណ៍ ៦ ជាធម្មតាក្នុងទ្វារ ៦ យ៉ាងនេះ គឺ ហូរទៅ ជន់ទៅ ហូរហៀរទៅ ប្រព្រឹត្តទៅតាមរូបផ្លូវក្អែក រមែងមិនគ្របសង្កត់ គឺ មិនតាមចងយើង បានដល់ មិនកើតឡើងដល់យើង យ៉ាងណា ។ បទថា **អត្តានញ្ច នាវជានាមិ** មិនមើលងាយខ្លួនឯង សេចក្តីថា មិនមើលស្រាលខ្លួនឯង ។ ការលះបង់ការមើលងាយ ទើបព្រះសារីបុត្តត្រូវពោលហើយដោយ

ពាក្យនេះ ។ ដូច្នេះ សេចក្តីដឹងទូទៅរមែងថ្វាផូរផង់ ។

[១១៤] បទថា **សមណេន** បានដល់ សមណៈ គឺ ព្រះពុទ្ធ ។ បទថា **តេស្វាហំ ន កង្ខាមិ** ខ្ញុំមិនសង្ស័យក្នុងអាសវៈទាំងនោះ អធិប្បាយថា ខ្ញុំមិនសង្ស័យក្នុងអាសវៈទាំងនោះ សូម្បីដោយសរុបប្រភេទថា កាមាសវៈ គឺ អ្វី ភវាសវៈ គឺអ្វី ទិដ្ឋាសវៈ គឺអ្វី និងអវិជ្ជាសវៈ គឺអ្វីក្តី ដោយការកំណត់ចំនួនយ៉ាងនេះថា អាសវៈ មាន ៤ ដូច្នេះក្តី ។ បទថា **តេ មេ បហីនាតិ ន វិចិកិច្ឆាមិ** អធិប្បាយថា ខ្ញុំមិនឆ្ងល់ថា អាសវៈទាំងនោះ ខ្ញុំលះបានហើយ ។ ព្រះមានព្រះភាគកាលទ្រង់សម្តែងសេចក្តីនេះ ទើបត្រាស់ថា កាលអ្នកព្យាករណ៍ហើយយ៉ាងនេះ ជាការព្យាករណ៍ល្អហើយ តែកាលអ្នកពោលថា ម្នាលលោកដ៏មានអាយុ ខ្ញុំជាអ្នកមានសតិនៅយ៉ាងនោះ ព្រោះការរួចផុតក្នុងខាងក្នុង ដូច្នេះ ទើបធ្វើឲ្យយឺតយូរក្រៃលែង ។ ពាក្យថា **ឧដ្ឋាយាសនា វិហារំ បាវិសិ** ស្តេចក្រោកចាកអាសនៈហើយស្តេចចូលកាន់ព្រះវិហារ អធិប្បាយថា ព្រះមានព្រះភាគស្តេចក្រោកអំពីព្រះពុទ្ធាសនៈដ៏ប្រសើរដែលបានក្រាលទុកហើយ ស្តេចចូលកាន់ខាងក្នុងមហាគន្ធកុដិដែលជាទីប្រថាប់ ក្នុងកាលបរិស័ទមិនទាន់បានបែកគ្នាឡើយ ។

ព្រោះហេតុអ្វី? ព្រោះថា ព្រះពុទ្ធទាំងឡាយកាលទេសនាមិនទាន់ចប់ (និង) បរិស័ទនៅមិនបានបែកគ្នា ទើបស្តេចក្រោកចាកអាសនៈ កាលនឹងស្តេចចូលកាន់ព្រះគន្ធកុដិ ស្តេចរមែងចូលទៅដើម្បីសរសើរបុគ្គល ឬដើម្បីសរសើរធម៌ ។ ក្នុងការសរសើរនោះ ព្រះសាស្តាកាលស្តេចចូលទៅដើម្បីសរសើរបុគ្គល ទ្រង់បានព្រះតម្រិះយ៉ាងនេះថា បទនេះ តថាគតលើកឡើងកាន់ឧទ្ទេសសម្តែងដោយសង្ខេប មិនបានចែកដោយពិស្តារ ពួកភិក្ខុដែលព្រមទទួលបដិបត្តិធម៌ រៀនសូត្រហើយ នឹងចូលទៅសួរព្រះអានន្ទខ្លះ ព្រះមហាកច្ចាយនៈខ្លះ ភិក្ខុទាំងនោះសន្ទនាប្រៀបធៀបជាមួយនឹងញាណរបស់តថាគត បន្ទាប់ពីនោះ ពួកភិក្ខុដែលព្រមទទួលបដិបត្តិធម៌ ក៏នឹងសួរតថាគតទៀត តថាគតនឹងសរសើរបុគ្គលទាំងនោះយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ប្រការដែលអានន្ទក្តី មហាកច្ចាយនៈក្តី ពោលដល់ភិក្ខុទាំងនោះ ឈ្មោះថាជាការពោលល្អហើយ បើពួកអ្នកសួរសេចក្តីនេះចំពោះតថាគត តថាគតក៏នឹងគប្បីព្យាករណ៍យ៉ាងនោះឯង តពីនោះ ពួកភិក្ខុនឹងចូលទៅសម្តែងគារវៈចំពោះព្រះថេរៈទាំងពីរនោះ សូម្បីពួកភិក្ខុទាំងនោះក៏នឹងបបួលអ្នកដទៃឲ្យតាំងនៅក្នុងអត្ថ ក្នុងធម៌ អ្នកដែលត្រូវភិក្ខុទាំងនោះបបួលហើយ នឹង

បំពេញត្រៃសិក្ខាឲ្យបរិបូណ៌ ហើយធ្វើទីបំផុតទុក្ខបាន ។ ម្យ៉ាងវិញទៀត ព្រះមានព្រះភាគនោះ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា កាលតថាគតចៀសចេញទៅហើយ ព្រះសារីបុត្រនេះ នឹងបានធ្វើឲ្យច្បាស់នូវអានុភាពរបស់ខ្លួន គ្រានោះឯង តថាគតក៏នឹងសរសើរគេយ៉ាងនោះ ពួកភិក្ខុដែលស្តាប់ពាក្យសរសើរគេរបស់តថាគតហើយ កើតសេចក្តីគារវៈក្នុងព្រះសារីបុត្តនឹងសម្គាល់គេថា គួរចូលទៅរក គួរជឿ ស្តាប់ពាក្យរបស់គេ និងគួរជឿកាន់យកសេចក្តីសម្គាល់ដូច្នោះនឹងមាន ដើម្បីប្រយោជន៍ និងសេចក្តីសុខដល់ពួកគេអស់កាលយូរ ។

ព្រះសាស្តា កាលស្តេចទ្រង់ចូលទៅ ដើម្បីទ្រង់សរសើរធម៌ ទ្រង់មានព្រះតម្រិះដូចគ្នានឹងទ្រង់ព្រះតម្រិះក្នុងធម្មទាយាទសូត្រ ។ ក៏ក្នុងធម្មទាយាទសូត្រនោះ ព្រះអង្គទ្រង់ព្រះតម្រិះយ៉ាងនេះថា កាលតថាគតចូលទៅកាន់វិហារហើយ ព្រះសារីបុត្រកាលនឹងតិះដៀលអាមិសទាយាទ និងសរសើរធម្មទាយាទ នឹងអង្គុយក្នុងបរិស័ទនេះឯង សម្តែងធម្មទេសនានេះដែលតថាគត និងសារីបុត្តសម្តែងតាមការឈ្វេងយល់ ដែលមានសេចក្តីប្រាថ្នាតែម្យ៉ាងដូចគ្នា ជាការសម្តែងដ៏កំពូល និងធ្ងន់ដូចជាឆត្រថ្ម ។

តែក្នុងព្រះសូត្រនេះ ព្រះសាស្តាមានព្រះបំណងនឹងស្ថាបនាព្រះ-សារីបុត្រ ប្រកាសលើកគុណធម៌ដ៏ក្រៃលែង (របស់លោក) ទើបស្តេចក្រោកចាកអាសនៈដើម្បីទ្រង់សរសើរបុគ្គល ហើយទើបស្តេចចូលទៅកាន់ព្រះវិហារ ។ ព្រះមានព្រះភាគ ទ្រង់បាត់ទៅក្នុងអាសនៈ ប្រថាប់គង់ហើយ ក្នុងទីនោះឯង គប្បីជ្រាបថា ស្តេចចូលកាន់ព្រះវិហារដោយគតិនៃចិត្ត (ដោយអំណាចចិត្ត) ប្រសិនបើស្តេចយាងទៅដោយគតិនៃកាយ បរិស័ទទាំងពួងក៏គប្បីហែហមព្រះមានព្រះភាគទៅ ។ បរិស័ទនោះ បានបែកគ្នាចេញទៅជាលើកទីមួយ (ទំនងសម្រាកការប្រជុំ) ហើយនឹងត្រឡប់មកប្រជុំជាថ្មីទៀត តែនៅមិនទាន់រៀបរយ ដូច្នោះ ព្រះមានព្រះភាគ ទើបស្តេចចូលកាន់ព្រះវិហារទៅដោយគតិនៃចិត្ត (ដោយអំណាចចិត្ត) នោះឯង ដោយមិនប្រាកដព្រះអង្គ ។ គ្រាព្រះមានព្រះភាគ ស្តេចចូលទៅហើយយ៉ាងនេះ ព្រះសារីបុត្រប្រាថ្នានឹងបន្លឺសីហនាទដែលអនុរូបតាមព្រះបំណងនៃព្រះមានព្រះភាគ កាលព្រះមានព្រះភាគស្តេចចៀសចេញទៅហើយមិនយូរ ទើបបានហៅពួកភិក្ខុក្នុងទីប្រជុំនោះមក ។

[១១៥] ពាក្យថា **បុព្វេ អប្បដិសំវិទិតំ** មិនធ្លាប់ដឹងមកអំពីមុន

បានដល់ បញ្ហាដែលខ្ញុំមិនជ្រាប គឺ មិនបានដឹងមកអំពីមុនថា ព្រះមាន-ព្រះភាគនឹងត្រាស់សួរបញ្ហាឈ្មោះនេះ ។ ពាក្យថា **បឋមំ បញ្ហំ** បញ្ហាដំបូង បានដល់ បញ្ហាដំបូងនេះ គឺ ម្នាលសារីបុត្រ បើគេសួរអ្នកយ៉ាងនេះថា លោកម្ចាស់សារីបុត្រ លោកដឹងឃើញយ៉ាងណា ទើបព្យាករណ៍ព្រះអរហត្ត-ផលថា ខ្ញុំដឹងច្បាស់ថា ជាតិ គឺ ការកើតអស់ហើយ ។ បទថា **ទន្ធាយិតត្តំ** សេចក្ដីយឺតយូរក្នុងការដោះស្រាយ បានដល់ សេចក្ដីយឺតយូរ គឺ ភាព មិនរហ័សក្នុងការដឹងព្រះបំណងរបស់ព្រះសាស្ដា ។ បទថា **បឋមំ បញ្ហំ អនុមោទិ** ព្រះមានព្រះភាគទ្រង់អនុមោទនាបញ្ហាទី ១ ហើយ អធិប្បាយថា ព្រះមានព្រះភាគកាលនឹងទ្រង់សួរបញ្ហាប្រការទី ២ នេះថា ម្នាលសារីបុត្រ ក៏ជាតិមានអ្វីជាហេតុ បានទ្រង់អនុមោទនាបញ្ហាទី ១ ដែលព្រះសារីបុត្តត្រេរ ដោះស្រាយហើយ យ៉ាងនេះថា ជាតិមានបច្ច័យជាដើមហេតុ ។

បទថា **ឯតទហោសិ** មានសេចក្ដីគិត អធិប្បាយថា សេចក្ដីគិតនេះ បានមានហើយ ព្រោះបញ្ហាបានប្រាកដដោយន័យជាពួកដូចគ្នា ដោយន័យ ទាំងរយទាំងពាន់ ដែលព្រះមានព្រះភាគអនុមោទនាហើយ ។ ពាក្យថា **ទិវសបហំ ភគវតោ ឯតមត្ថំ ព្យាករេយ្យំ** សូម្បីខ្ញុំព្រះអង្គ ក៏គប្បីទូលឆ្លើយ សេចក្ដីនេះ ថ្វាយព្រះមានព្រះភាគរហូតអស់មួយថ្ងៃ អធិប្បាយថា ខ្ញុំព្រះអង្គ

ត្រូវព្រះមានព្រះភាគត្រាស់សួរដល់ន័យក្នុងបដិច្ចសមុប្បាទ សូម្បីរហូតអស់មួយថ្ងៃ ។

[១១៦] *យេន ភគវា តេនុបសង្កមិ* ចូលទៅ គាល់ព្រះមានព្រះភាគដល់ទីប្រថាប់ អធិប្បាយថា បានឮមកថា ព្រះកឡារខត្តិយភិក្ខុនោះ មានសេចក្ដីគិតយ៉ាងនេះថា ព្រះសារីបុត្តត្ថេរ រមែងបន្លឺសីហនាទយ៉ាងក្រៃលែង យើងនឹងក្រាបទូលហេតុដ៏ល្អនេះចំពោះព្រះទសពល ព្រោះដូច្នោះ ព្រះកឡារ-ខត្តិយៈ ទើបបានចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។

[១១៧] សាវកបារមីញាណ ដែលអាចឃើញការរលត់នៃបច្ចយាការ ( ***វិវដ្ដការទស្សនសមត្ថំ*** ) ឈ្មោះថា ធម្មធាតុ ក្នុងពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ ក៏ធម្មធាតុនោះ ។ ក៏សាវកបារមីញាណរបស់ព្រះសាវកទាំង-ឡាយ ប្រព្រឹត្តទៅក្នុងគតិនៃព្រះសព្វញ្ញុតញ្ញាណនោះឯង ។ ធម៌ទាំងឡាយដែលជាអតីត អនាគត និងបច្ចុប្បន្ន រមែងប្រាកដដល់ព្រះសព្វញ្ញុតញ្ញាណយ៉ាងណា សាវកបារមីញាណរបស់ព្រះសារីបុត្តត្ថេរ រមែងដឹងគោចរធម៌ទាំងពួងរបស់សាវកញ្ញាណ ក៏ដូច្នោះ ។

ចប់អដ្ឋកថា កឡារខត្តិយសូត្រទី ២

# អ ដ្ឋ ក ថា

## បឋមញាណវត្ថុសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង ញាណវត្ថុសូត្រទី ៣ តទៅ ៖*

[១១៨] *បទថា* **តំ សុណាថ** *ពួកលោកចូរស្តាប់ញាណវត្ថុនោះ បានដល់ ពួកលោកចូរស្តាប់ការសម្តែងញាណវត្ថុនោះ ។*

[១១៩] *ញាណនោះឯង គប្បីជ្រាបថា ញាណវត្ថុ ក្នុងពាក្យនេះថា* **ញាណវត្ថូនិ** *នេះ ។ ក្នុងញាណ ៤ មានជរាមរណញ្ញាណជាដើម ញាណទី ១ មាន ៤ យ៉ាង គឺ សវនមយញ្ញាណ (ញាណដែលសម្រេចពីការស្តាប់) ១ សម្មសនញ្ញាណ (ញាណដែលកើតពីការពិចារណា) ១ បដិវេធញ្ញាណ (ញាណដែលកើតពីការចាក់ធ្លុះ) ១ បច្ចវេក្ខណញ្ញាណ (ញាណដែលកើតពីការពិចារណា) ១ ។ ញាណទី ២ ក៏ដូចគ្នា ។ ចំណែកញាណទី ៣ វៀរសម្មសនញ្ញាណចេញ ទើបមានត្រឹមតែ ៣ យ៉ាងប៉ុណ្ណោះ ។ ញាណទី ៤ ក៏ដូចគ្នា ព្រោះថា ក្នុងលោកុត្តរធម៌ រមែងមិនមានសម្មសនញ្ញាណ ។ សូម្បីក្នុងពាក្យថា* **ជាតិយា ញាណំ** *(ញាណក្នុងជាតិ) ជាដើម ក៏មានន័យនេះ*

ឯង ។

[១២១] ពាក្យថា **ឥមិនា ធម្មេន** (ដោយធម៌នេះ) គឺ ដោយសច្ច-ធម៌ ៤ នេះ ឬដោយមគ្គញាណធម៌ ។

ក្នុងបទថា **ទិដ្ឋេន** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **ទិដ្ឋេន** បានដល់ ដែលខ្លួនឃើញហើយដោយញាណចក្ខុ (ភ្នែក គឺ បញ្ញា) ។ បទថា **វិទិតេន** បានដល់ ដឹងហើយដោយបញ្ញា ។ បទថា **អកាលិកេន** ឲ្យផលមិនមានកំណត់កាល បានដល់ ឲ្យផលក្នុងលំដាប់នៃការចាក់ធ្លុះ មិនលះបង់កាលណាៗឡើយ ។ បទថា **បត្តេន** (ដល់ហើយ) ប្រែថា ចាក់ធ្លុះហើយ ។ បទថា **បរិយោគាឡ្ហេន** ជ្រួតជ្រាបហើយ គឺ ដែលខ្លួនជ្រួតជ្រាបហើយ បានដល់ ចូលដល់ដោយបញ្ញា ។ បទថា **អតីតានាគតេ នយំ នេតិ** (នាំន័យក្នុងអតីត និងអនាគតទៅ) បានដល់ នាំន័យក្នុងអតីត និងអនាគតទៅ ដោយន័យមានជាដើមថា **សមណៈ ឬព្រាហ្មណ៍ពួកណាមួយ** ។ ក៏ក្នុងពាក្យនេះ ព្រះសារីបុត្តត្ថេរអាចនាំន័យក្នុងអតីត និងអនាគតទៅដោយសច្ចធម៌ ៤ ខ្លះ ដោយមគ្គញាណធម៌ខ្លះ ។ ក៏កាលអរិយសច្ច ៤ ក្តី មគ្គញាណក្តី ដែលខ្លួនចាក់ធ្លុះហើយ បន្ទាប់អំពីនោះ

បច្ចវេក្ខណញ្ញាណរមែងមាន ។ គប្បីជ្រាបអធិប្បាយថា នាំន័យទៅដោយបច្ចវេក្ខណញ្ញាណនោះ ។ បទថា **អញ្ញាសិ** ប្រែថា បានដឹងហើយ គឺជ្រាបហើយ ។ ពាក្យថា **សេយ្យថាបិហំ ឯតរហិ** ដូចយើងដឹងក្នុងឥឡូវនេះ គឺ ដូចយើងដឹងដោយអំណាចអរិយសច្ច ៤ ក្នុងឥឡូវនេះ ។

[១២២] បទថា **អន្វយេ ញាណំ** បានដល់ ញាណក្នុងធម៌ដ៏សមគួរ គឺ ញាណដែលជាប់តាមញាណក្នុងធម៌ ។ ពាក្យថា **អន្វយញ្ញាណ** នេះ ជាឈ្មោះរបស់បច្ចវេក្ខណញ្ញាណ ។

[១២៤] បទថា **ធម្មេ ញាណំ** បានដល់ មគ្គញ្ញាណ ។ សេក្ខភូមិរបស់ព្រះទីណាស្រេព ព្រះមានព្រះភាគត្រាស់ហើយក្នុងព្រះសូត្រនេះ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា បឋមញាណវត្ថុសូត្រទី ៣

# អ ដ្ឋ ក ថា

## ទុតិយញាណវត្ថុសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង *ទុតិយញាណវត្ថុសូត្រទី ៤* តទៅ ។

[១២៦] បទថា **សត្តសត្តតិ** ប្រែថា ៧ និង ៧០ គឺ ៧៧ ។ បាន ឮមកថា ភិក្ខុទាំងនោះជាអ្នកពោលព្យញ្ជនៈ កាលមានអ្នកពោលបន្ថែមព្យញ្ជនៈច្រើនឡើង ក៏អាចចាក់ដោតបាន ។ ព្រោះដូច្នោះ ព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់តាមអធ្យាស្រ័យរបស់ភិក្ខុទាំងនោះ ។

[១២៧] បទថា **ធម្មដ្ឋិតិញ្ញាណំ** (ធម្មដ្ឋិតិញ្ញាណ គឺ ញាណក្នុងបច្ចយការ ក៏បច្ចយាការ លោកហៅថា ធម្មដ្ឋិតិ ព្រោះជាហេតុនៃបវត្តិដ្ឋិតិនៃធម៌ទាំងឡាយ ។ ញាណក្នុងធម្មដ្ឋិតិនេះ ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** ។

ពាក្យថា ធម្មដ្ឋិតិញ្ញាណនេះ ជាឈ្មោះរបស់ញាណ ៦ តែម៉្យាងប៉ុណ្ណោះ ។ បទថា **ខយធម្មំ** គឺ ដល់ការអស់ទៅជាសភាវៈ ។ បទថា **វយធម្មំ** គឺ ដល់សេចក្តីសាបសូន្យទៅជាសភាវៈ ។ បទថា **វិរាគធម្មំ** គឺ ដល់សេចក្តីប្រាសចាកតម្រេកជាសភាវៈ ។

*បទថា* **និរោធធម្មំ** *គឺ ដល់សេចក្តីរលត់ជាសភាវៈ ។ ពាក្យថា* **សត្តសត្តតិ** *អធិប្បាយថា ក្នុង ១១ បទ បែងចែកជាមួយបទ ៗ ៧ ទើបរួមជា ៧៧ ។ ការសម្រេចវិបស្សនា* **ព្រះមានព្រះភាគត្រាស់ថា** *ឈ្មោះវិបស្សនាក្នុងព្រះសូត្រនេះ ។*

ចប់អដ្ឋកថា ទុតិយញាណវត្ថុសូត្រទី ៤

# អ ដ្ឋ ក ថា

## បឋមអវិជ្ជាបច្ចយសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង **អវិជ្ជាបច្ចយសូត្រទី ៥** តទៅ*

[១២៨] *ព្រះសាស្តាទ្រង់ឲ្យទេសនាចប់ស្រេចក្នុងពាក្យថា **សមុទយោ ហោតិ** នេះឯង ។ ព្រោះហេតុអ្វី? ព្រោះដើម្បីឲ្យឱកាសដល់អ្នកមានទិដ្ឋិ ។ ព្រោះថា ក្នុងបរិស័ទនោះ អ្នកមានទិដ្ឋិមានចិត្តជំទាស់ ។ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា បុគ្គលនោះនឹងសួរបញ្ហា លុះសួរហើយ តថាគតនឹងដោះស្រាយដល់គេ ដូច្នោះ ទើបទ្រង់ផ្អាកទេសនាសិន ដើម្បីឲ្យបុគ្គលនោះបានឱកាស ។*

[១២៩] *បទថា **នោ កល្លោ បញ្ហោ** (តាំងបញ្ហាមិនទាន់ត្រឹមត្រូវ) អធិប្បាយថា បញ្ហានេះ ជាបញ្ហាដែលមិនគួរ គឺ ជាបញ្ហាដែលមិនល្អ ។ ក៏ពាក្យដែលសួរថា **បពិត្រព្រះអង្គដ៏ចម្រើន ជរាមរណៈដូចម្តេច** នេះ ជាការសួរល្អហើយមិនមែនឬ ។ ឆ្លើយថា ជាការសួរដែលល្អហើយក៏ពិត ប៉ុន្តែថា កាលបុគ្គលយកដុំលាមកប្រមាណប៉ុនផ្លែកន្ទួតព្រៃដាក់ទុកខាងលើភោជន*

ល្អ ដែលគេជួសជាក់ថាសមាសមានតម្លៃទាំងសែន កោជនទាំងអស់ក៏ក្លាយជាកោជនមិនល្អ គួរចោល យ៉ាងណា សូម្បីបញ្ហានេះ ក៏ជាបញ្ហាមិនល្អ ព្រោះពោលអំពីការចូលទៅប្រកាន់សត្វនេះថា ក៏ជរាមរណៈនេះ ជារបស់បុគ្គលណា ។ ដូចកោជននោះ ដែលក្លាយជាកោជនមិនល្អ ព្រោះជុំលាមក ដូច្នោះឯង ។

បទថា **ព្រហ្មចរិយវាសោ** ការនៅប្រព្រឹត្តព្រហ្មចរិយ គឺ នៅដោយអរិយមគ្គ ។ ពាក្យថា **តំ ជីវំ តំ សរីរំ** ជីវិតនោះ ក៏គឺសរីរៈនោះ អធិប្បាយថា ក៏បុគ្គលណាមានការឃើញដូច្នេះ បុគ្គលនោះ រមែងប្រកាន់ថា **កាលជីវិតដាច់សូន្យ សរីរៈក៏ដាច់សូន្យ កាលសរីរៈដាច់សូន្យ ជីវិតក៏ដាច់សូន្យ** កាលប្រកាន់យ៉ាងនេះ សេចក្តីឃើញនោះ ទើបឈ្មោះថា **ឧច្ឆេទទិដ្ឋិ** ព្រោះបានប្រកាន់ថា **សត្វរមែងដាច់សូន្យ** ។ ប៉ុន្តែបើនឹងគប្បីកាន់យកថា សង្ខារទាំងឡាយនោះឯង រមែងកើតឡើង និងរលត់ទៅទាំងអស់នោះឯង ។ សេចក្តីឃើញដែលឈានចុះក្នុងព្រះសាសនា គប្បីជាសម្មាទិដ្ឋិ ក៏ឈ្មោះថា អរិយមគ្គនេះ រមែងរំលត់វដ្តៈ កាត់ផ្តាច់វដ្តៈកើតឡើង ។ កាលសភាវៈនៃអាការដែលប្រកាន់ដោយឧច្ឆេទទិដ្ឋិនៅមាន (បើ) វៀរមគ្គភាវនាចេញ វដ្តៈ

នោះឯងរមែងរលត់បាន ព្រោះហេតុនោះ មគ្គភាវនា (ការចម្រើនមគ្គ) រមែងមិនមានប្រយោជន៍ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ការប្រព្រឹត្តព្រហ្មចរិយ រមែងមិនមាន ។**

គប្បីជ្រាបវិនិច្ឆ័យក្នុងន័យទីពីរ ។ បុគ្គលណាមានការឃើញយ៉ាងនេះថា ជីវិតដទៃ សរីរៈក៏ដទៃ បុគ្គលនោះ រមែងប្រកាន់ថា សរីរៈរមែងដាច់សូន្យក្នុងលោកនេះឯង តែជីវិតរមែងទៅតាមសប្បាយ ដូចសត្វដែលចេញចាកទ្រុងបាន ក៏ទៅតាមសប្បាយរបស់ខ្លួនដូច្នោះ ។ កាលប្រកាន់យ៉ាងនេះ ការឃើញនោះ ទើបឈ្មោះថា **សស្សតទិដ្ឋិ** ព្រោះបានប្រកាន់ថា **ជីវិតចាកលោកនេះ ទៅកាន់លោកដទៃ** ក៏អរិយមគ្គនេះ កាលវៀរនូវវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ រមែងកើតឡើង ។ កាលប្រកាន់ថា ទៀងថាមានពិត ថាមាំមួន សូម្បីក្នុងសង្ខារតែម្យ៉ាងនៅមាន អរិយមគ្គនោះ សូម្បីកើតឡើងហើយ ក៏មិនអាចធ្វើឲ្យវដ្តៈឈប់វិលបាន ព្រោះដូច្នោះ មគ្គភាវនាទើបមិនមានប្រយោជន៍ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុ កាលមានការឃើញថា ជីវិតដទៃ សរីរៈក៏ដទៃ **ការប្រព្រឹត្តព្រហ្មចរិយ រមែងមិនមាន ។**

[១៣៣] បទថា **វិសូកាយិតានិ** ប្រែថា ចម្រូងចម្រាសជាដើមសុទ្ធតែជាវេវចនៈរបស់មិច្ឆាទិដ្ឋិនោះ ។ ក៏មិច្ឆាទិដ្ឋិនោះ ព្រះមានព្រះភាគត្រាស់ថា (ជាធម៌) ចម្រូងចម្រាស ព្រោះយល់ឃើញថាត្រូវនោះ ព្រោះអត្ថថា កម្ចាត់សម្មាទិដ្ឋិ ត្រាស់ហៅថា ដែលបុគ្គលសេពខុស ព្រោះមិនប្រព្រឹត្តទៅតាមសម្មាទិដ្ឋិ តែប្រព្រឹត្តទៅដោយការជំទាស់នឹងសម្មាទិដ្ឋិនោះ ត្រាស់ហៅថា ក្តៅក្រហាយខុសប្រក្រតី ព្រោះពេលខ្លះក៏ជាឧច្ឆេទទិដ្ឋិ (ប្រកាន់ថាដាច់សូន្យ) ពេលខ្លះក៏ជាសស្សតទិដ្ឋិ (ប្រកាន់ថាទៀង) ។

[១៣៤] បទថា **តាលាវត្ថុកតានិ** គឺ ធ្វើឲ្យដូចត្នោតកំបុតក អធិប្បាយថា ដូចត្នោតកំបុតក ព្រោះអត្ថថា មិនដុះឡើងតទៅទៀត និងធ្វើឲ្យដូចជាការរំលើងដើមត្នោតទាំងឫស ។ បទថា **អនភាវំ គតានិ** បានដល់មិនមានក្នុងខាងក្រោយ ។

ចប់អដ្ឋកថា បឋមអវិជ្ជាបច្ចយសូត្រទី ៩

# អ ដ្ឋ ក ថា

## ទុតិយអវិជ្ជាបច្ចយសូត្រទី ៦

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអវិជ្ជាបច្ចយសូត្រទី ៦ តទៅ ។*

[១៣៨] *ពាក្យថា ឥតិ វា ភិក្ខវេ យោ វទេយ្យ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាគប្បីពោលយ៉ាងនេះ អធិប្បាយថា ក្នុងបរិស័ទនោះ មានបុគ្គលប្រកាន់ទិដ្ឋិប្រាថ្នានឹងសួរបញ្ហា ។ តែបុគ្គលនោះមានធាតុមិនក្លាហាន ទើបមិនអាចនឹងក្រោកឡើងសួរព្រះទសពលបាន ។ ព្រោះដូច្នោះ ព្រះសាស្តាទើបត្រាស់សួរដោយព្រះអង្គឯងតាមសេចក្តីបំណងរបស់គេ កាលទ្រង់នឹងដោះស្រាយ ទើបត្រាស់យ៉ាងនេះ ។*

ចប់អដ្ឋកថា ទុតិយអវិជ្ជាបច្ចយសូត្រទី ៦

# អ ដ្ឋ ក ថា

## នត្តុម្ហសូត្រទី ៧

*គប្បីជ្រាបវិនិច្ឆ័យក្នុង* ***នត្តុម្ហសូត្រទី ៧*** *តទៅ ។*

*[១៤៣] បទថា* ***នាយំ តុម្ហាកំ*** *កាយនេះមិនមែនរបស់អ្នកទាំងឡាយ អធិប្បាយថា កាលអត្តាមាន ដែលឈ្មោះថា វត្ថុជារបស់អត្តាក៏រមែងមាន ។ ប៉ុន្តែអត្តានោះឯងរមែងមិនមាន ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា កាយនេះមិនមែនជារបស់ពួកអ្នក ។ បទថា* ***នាបិ អញ្ញេសំ*** *ទាំងមិនមែនរបស់អ្នកដទៃ គឺ អត្តារបស់បុគ្គលដទៃ ឈ្មោះថា ដទៃ ។ កាលអត្តានោះមាន ដែលឈ្មោះថា អត្តាដទៃក៏គប្បីមាន សូម្បីអត្តាដទៃនោះក៏មិនមាន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា ទាំងមិនមែនជារបស់បុគ្គលដទៃ ។ បទថា* ***បុរាណមិទំ ភិក្ខវេ កម្មំ*** *ម្នាលភិក្ខុទាំងឡាយ កម្មចាស់នេះ អធិប្បាយថា កម្មនេះមិនមែនកម្មចាស់ឡើយ តែកាយនេះ កើតព្រោះកម្មចាស់ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ទុកយ៉ាងនេះ ដោយបច្ចយវោហារ ។ បទថា* ***អភិសង្ខតំ*** *ជាដើម ព្រះមានព្រះភាគត្រាស់ដោយ*

សត្តជាការៈបុំសកលិង្គ ដោយអំណាចនៃកម្មវោហារនោះឯង ។ ក៏ក្នុងពាក្យថា **អភិសង្ខតំ** ជាដើមនេះ មានអធិប្បាយដូច្នេះ ។ បទថា **អភិសង្ខតំ** បានដល់ កាយនេះ គប្បីឃើញថា ដែលបច្ច័យតាក់តែងហើយ ។ បទថា **អភិសញ្ចេតយិតំ** បានដល់ គប្បីជ្រាបថា មានចេតនាជាទីតាំង គឺ មានការតាំងចិត្តជាមូល ។ បទថា **វេទនីយំ** បានដល់ គប្បីជ្រាបថា ជាទីតាំងនៃវេទនា ។

ចប់អដ្ឋកថា ឆត្ថុម្ភសូត្រទី ៧

# អ ដ្ឋ ក ថា

## បឋមចេតនាសូត្រទី ៨

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បឋមចេតនាសូត្រទី ៨** តទៅ ។*

*[១៨៥] បទថា **យញ្ច ភិក្ខវេ ចេតេតិ** ម្នាលភិក្ខុទាំងឡាយ ភិក្ខុ រមែងតាំងចិត្តដោយចេតនាណា អធិប្បាយថា រមែងតាំងចិត្ត គឺ ញ៉ាំង ការតាំងចិត្តណាឲ្យប្រព្រឹត្តទៅ ។ បទថា **យញ្ច បកប្បេតិ** រមែងត្រិះរិះ វត្ថុណា អធិប្បាយថា រមែងត្រិះរិះ គឺ ញ៉ាំងការត្រិះរិះណាឲ្យប្រព្រឹត្តទៅ ។ បទថា **យញ្ច អនុសេតិ** រមែងសញ្ជឹងគិតដល់វត្ថុណា អធិប្បាយថា រមែង សញ្ជឹងគិត គឺ ញ៉ាំងការសញ្ជឹងគិតណាឲ្យប្រព្រឹត្តទៅ ។ ក៏ក្នុងសេចក្តីនេះ ការ តាំងចិត្តដែលជាកុសល និងអកុសល ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ព្រះមាន-ព្រះភាគទ្រង់កាន់យកថា រមែងតាំងចិត្ត ។ ការត្រិះរិះ (កប្បៈ) ដោយតណ្ហា និងទិដ្ឋិក្នុងចិត្តដែលកើតព្រមដោយលោភៈ ៨ ដួង ទ្រង់កាន់យកថា រមែង ត្រិះរិះ ។ ការសញ្ជឹងគិត ទ្រង់កាន់យកដោយទីបំផុតនៃចេតនា ១២ ដែល កើតព្រមគ្នា និងដោយទីបំផុតនៃឧបនិស្ស័យថា រមែងសញ្ជឹងគិត ។ ប្រការថា*

**អារម្មណមេតំ ហោតិ** វត្ថុនោះជាអារម្មណប្បច្ច័យ បានដល់ ធម្មជាតិមាន ចេតនាជាដើមនេះ ជាបច្ច័យ ។ បច្ច័យ ទ្រង់ប្រាថ្នាយកថា អារម្មណ៍ក្នុង ទីនេះ ។ បទថា **វិញ្ញាណស្ស ឋិតិយា** ដើម្បីការតាំងនៅនៃវិញ្ញាណ គឺ ដើម្បីការតាំងនៅនៃកម្មវិញ្ញាណ ។ បទថា **អារម្មណេ សតិ** កាលមាន អារម្មណប្បច្ច័យ បានដល់ កាលបច្ច័យនោះមានហើយ ។ បទថា **បតិដ្ឋា វិញ្ញាណស្ស ហោតិ** សេចក្តីថា រមែងជាទីតាំងអាស្រ័យនៃកម្មវិញ្ញាណ នោះ ។ បទថា **តស្មិំ បតិដ្ឋិតេ វិញ្ញាណេ** បានដល់ កាលបើកម្មវិញ្ញាណ នោះតាំងមាំហើយ ។ បទថា **វិរុឡ្ហេ** ចម្រើនឡើងហើយ បានដល់ កាល កើតមូលហេតុនៃការកើត ព្រោះអាចឲ្យកម្មទ្រុឌទ្រោមទៅ ហើយនាំបដិសន្ធិ មក ។ បទថា **បុនព្ភវាភិនិព្វត្តិ** ប្រែថា ការកើត ពោលគឺ ភពថ្មី ។ ខណៈ ដែលការតាំងចិត្តប្រព្រឹត្តទៅក្នុងភូមិ ៣ មិនឲ្យប្រព្រឹត្តទៅ ព្រះមានព្រះភាគ ត្រាស់ដោយពាក្យនេះថា "ម្នាលភិក្ខុទាំងឡាយ ក៏ភិក្ខុមិនតាំងចិត្ត" ខណៈ ដែលការត្រិះរិះរឿងតណ្ហា និងទិដ្ឋិមិនប្រព្រឹត្តទៅ ព្រះមានព្រះភាគត្រាស់ ដោយពាក្យថា **នោ ច ភិក្ខវេ ចេតេតិ** ក៏ភិក្ខុមិនត្រិះរិះ , ដោយបទថា **នោ ច បកប្បេតិ** លោកពោលដល់ខណៈនៃការត្រិះរិះដោយអំណាចតណ្ហា

និងទិដ្ឋិមិនប្រព្រឹត្តទៅ ។ កិរិយាដែលជាកាមាវចរ គឺ ការសញ្ជឹងគិត ក្នុងវិបាកដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទ្រង់កាន់យកដោយពាក្យថា **អនុសេតិ** រមែងសញ្ជឹងគិត ។ ក្នុងពាក្យថា **អនុសេតិ** នេះ ទ្រង់កាន់យកបុគ្គលដែលនៅលះការសញ្ជឹងគិត (អនុស័យ) មិនបាន ។ ប្រការថា **អារម្មណមេតំ ហោតិ** អារម្មណប្បច្ច័យនោះរមែងមាន មានន័យថា កាលបើការសញ្ជឹងគិតមានហើយ ការសញ្ជឹងគិតនោះ ទើបជាបច្ច័យ (នៃកម្មវិញ្ញាណ) ដោយពិត ព្រោះការកើតឡើងនៃកម្មវិញ្ញាណ ជាវត្ថុដែលនរណាហាមមិនបាន ។

[១៤៦] ក្នុងបទថា **នោ ច ចេតេតិ** ក៏ភិក្ខុមិនតាំងចិត្តជាដើម កុសលចេតនា និងអកុសលចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ព្រះមានព្រះភាគត្រាស់ទុកក្នុងបទទី ១ ។ តណ្ហា និងទិដ្ឋិក្នុងចិត្ត ៨ ដួង ត្រាស់ទុកក្នុងបទទី ២ ។ ការសញ្ជឹងគិត ដែលបុគ្គលសញ្ជឹងគិត ដោយទីបំផុតដែលលះមិនទាន់បានក្នុងធម៌មានប្រការដូចពោលហើយ ត្រាស់ទុកក្នុងបទទី ៣ ។

ម្យ៉ាងទៀត ដើម្បីកុំឲ្យសង្ស័យក្នុងព្រះសូត្រនេះ គួរជ្រាបពួក ៤ ដូច្នេះ គឺ ៖

-រមែងតាំងចិត្ត រមែងត្រិះរិះ រមែងសញ្ជឹងគិត ពួក ១ ។

-មិនតាំងចិត្ត តែត្រិះរិះ និងសញ្ជឹងគិត ពួក ១ ។

-មិនតាំងចិត្ត មិនត្រិះរិះ តែសញ្ជឹងគិត ពួក ១ ។

-មិនតាំងចិត្ត មិនត្រិះរិះ មិនសញ្ជឹងគិត ពួក ១ ។

ក្នុង ៤ ពួកនោះ ការកំណត់ធម៌ ព្រះមានព្រះភាគទ្រង់សម្តែងទុកក្នុងន័យទី ១ ។ កុសលចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៣ និងអកុសល-ចេតនា ៤ ទ្រង់កាន់យកថា "តាំងចិត្ត" ក្នុងន័យទី ២ ។ តណ្ហា និងទិដ្ឋិក្នុងចិត្ត ៨ ដួង ទ្រង់ត្រាស់ថា "មិនត្រិះរិះ" ការសញ្ជឹងគិត ដោយទីបំផុតនៃឧបនិស្ស័យក្នុងកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ក្តី ដោយទីបំផុតនៃបច្ច័យដែលកើតព្រមគ្នាក្នុងអកុសលចេតនា ៤ ក្តី ដោយទីបំផុតនៃឧបនិស្ស័យក្តី ទ្រង់កាន់យកថា **អនុសយោ** "សញ្ជឹងគិត" ។ កុសល និងអកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទ្រង់ត្រាស់ថា "មិនតាំងចិត្ត" ក្នុងន័យទី ៣ ។ តណ្ហា និងទិដ្ឋិក្នុងចិត្ត ៨ ដួង ទ្រង់ត្រាស់ថា "មិនត្រិះរិះ" ព្រះមានព្រះ-ភាគ ទ្រង់ហាមចិត្តដែលមកក្នុងព្រះសូត្រ ហើយទ្រង់កាន់យកឧបនិស្ស័យ ដោយទីបំផុតដែលលះមិនទាន់បាន ក្នុងកុសលចិត្ត អកុសលចិត្ត វិបាកចិត្ត កិរិ-

យាចិត្ត ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ និងរូប ដោយពាក្យថា “រមែងសញ្ចឹងគិត” ។ ន័យទី ៤ ដូចគ្នានឹងន័យមុននោះឯង ។

បទថា **តទប្បតិដ្ឋិតេ** ប្រែថា កាលវិញ្ញាណនោះមិនតាំងមាំហើយ ។ បទថា **អវិរុឡ្ហេ** មិនចម្រើនឡើងហើយ បានដល់ កាលកើតមូលនៃការមិនកើត ព្រោះកម្មទ្រុឌទ្រោម ហើយនាំបដិសន្ធិមក ។ សួរថា ក៏ក្នុងវារៈទី ៣ នេះ លោកពោលដល់អ្វី ។ ឆ្លើយថា ពោលដល់កិច្ចរបស់អរហត្តមគ្គ ។ នឹងពោលថា ការធ្វើកិច្ចរបស់ព្រះខីណាស្រពខ្លះ នវលោកុត្តរធម៌ខ្លះ ក៏គួរ ។ តែក្នុងវារៈនេះ មានអធិប្បាយថា រវាងវិញ្ញាណ និងភពថ្មីក្នុងអនាគត ជាសន្ធិមួយ , រវាងវេទនា និងតណ្ហា ជាសន្ធិមួយ , រវាងភព និងជាតិ ជាសន្ធិមួយ ។

ចប់អដ្ឋកថា បឋមចេតនាសូត្រទី ៨

# អ ដ្ឋ ក ថា

## ទុតិយចេតនាសូត្រទី ៩

[១៤៧] ក្នុង ទុតិយចេតនាសូត្រទី ៩ មានអធិប្បាយថា ៖

*វាងវិញ្ញាណ និងនាមរូប ជាសន្ធិមួយ , វាងវេទនា និងតណ្ហា ជាសន្ធិមួយ , វាងភព និងជាតិ ជាសន្ធិមួយ ដូច្នេះឯង ៗ*

ចប់អដ្ឋកថា ទុតិយចេតនាសូត្រទី៩

# អ ដ្ឋ ក ថា

## តតិយចេតនាសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង **តតិយចេតនាសូត្រទី ១០** តទៅ ។*

[១៤៩] *បទថា **នតិ** បានដល់ តណ្ហា ។ ក៏តណ្ហានោះ ហៅថា **នតិ** ព្រោះអត្ថថា បង្អោនទៅក្នុងអារម្មណ៍ មានរូបជាដើម ដែលជាបិយរូប រូបដែលគួរស្រឡាញ់ ។ បទថា **អាគតិគតិ ហោតិ** ប្រែថា គតិក្នុងការវិលមកទើបមាន ។ កាលកម្ម កម្មនិមិត្ត ឬគតិនិមិត្តមកប្រាកដ គតិនៃវិញ្ញាណរមែងមានដោយអំណាចបដិសន្ធិ ។ បទថា **ចុតូបបាតោ** ចុតិ និងឧប្បត្តិទើបមាន មានន័យថា កាលគតិដែលជាអារម្មណ៍នៃបដិសន្ធិមកប្រាកដដល់វិញ្ញាណមានហើយ **ចុតិ** ពោលគឺ ការឃ្លាតចាកភពនេះទើបមាន ។ **ឧប្បត្តិ** ពោលគឺ ការកើតឡើងក្នុងភពនោះទើបមាន ។ ឈ្មោះថា ចុតិ និងឧប្បត្តិ (ការស្លាប់ និងការកើត) នេះ ទើបមាន ។ រវាងតណ្ហា និងគតិក្នុងការវិលមក ទើបព្រះមានព្រះភាគត្រាស់ថា ជាសន្ធិមួយក្នុងព្រះសូត្រនេះ ដោយប្រការដូច្នេះឯង ។*

ចប់អដ្ឋកថា តតិយចេតនាសូត្រទី ១០

# ចប់អដ្ឋកថាកឡារខត្តិយវគ្គ ទី ៤

## រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា


១-អដ្ឋកថាភូតមិទសូត្រ
២- អដ្ឋកថាកឡារខត្តិយសូត្រ
៣-អដ្ឋកថាបឋមញាណវត្ថុសូត្រ
៤-អដ្ឋកថាទុតិយញាណវត្ថុសូត្រ
៥-អដ្ឋកថាបឋមអវិជ្ជាបច្ចយសូត្រ
៦-អដ្ឋកថាទុតិយអវិជ្ជាបច្ចយសូត្រ
៧-អដ្ឋកថានតុម្ហសូត្រ
៨-អដ្ឋកថាបឋមចេតនាសូត្រ
៩-អដ្ឋកថាទុតិយចេតនាសូត្រ
១០-អដ្ឋកថាតតិយចេតនាសូត្រ

# គហបតិវគ្គទី ៥

## អ ដ្ឋ ក ថា

### បឋមបញ្ចវេរភយសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង បញ្ចវេរភយសូត្រទី ១ នៃគហបតិវគ្គតទៅ

[១៥១] បទថា យតោ ប្រែថា ក្នុងកាលណា ។ បទថា ភយានិ វេរានិ បានដល់ ចេតនាជាហេតុញាំងភ័យ និងពៀរ ។ បទថា សោតាបត្តិយង្គេហិ អធិប្បាយថា អង្គនៃសោតាបត្តិ មាន ២ យ៉ាង គឺ អង្គដែលប្រព្រឹត្តទៅក្នុងចំណែកខាងដើម ដើម្បីបានចំពោះនូវសោតាបត្តិមគ្គ ដែលមកយ៉ាងនេះគឺ

សប្បុរិសសំសេវៈ ការសេពគប់សប្បុរស ១

សទ្ធម្មសវនៈ ការស្តាប់ធម៌របស់សប្បុរស ១

យោនិសោមនសិការៈ ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ១

ធម្មានុធម្មប្បដិបត្តិ ការបដិបត្តិធម៌សមគួរដល់ធម៌ ១

ដែលហៅថា អង្គនៃសោតាបត្តិមគ្គ ១ អង្គនៃបុគ្គលអ្នកមានគុណ-

ធម៌ដែលបានហើយ សម្រេចសោតាបត្តិមគ្គហើយតាំងនៅ ដែលហៅថា អង្គនៃសោតាបន្ន ១ ។ ពាក្យថា **សោតាបន្នស្ស** នេះ ជាឈ្មោះរបស់អ្នកមានសេចក្តីជ្រះថ្លាមិនញាប់ញ័រជាដើមក្នុងព្រះពុទ្ធ ពាក្យនេះឯង ព្រះមាន-ព្រះភាគទ្រង់បំណងយកក្នុងទីនេះ ។

បទថា **អរិយោ** បានដល់ អ្នកមិនមានទោស គឺ អ្នកមិនមានការតិះដៀល ។ បទថា **ញាយោ** បានដល់ ញាណដែលដឹងបដិច្ចសមុប្បាទខ្លះ បដិច្ចសមុប្បាទធម៌ខ្លះ ។ ដូចដែលលោកពោលថា បដិច្ចសមុប្បាទ ហៅថា **ញាយធម៌** ។ សូម្បីអរិយមគ្គមានអង្គ ៨ លោកក៏ហៅថា **ញាយធម៌** ។ បទថា **បញ្ញាយ** ដោយបញ្ញា បានដល់ ដោយវិបស្សនាបញ្ញាដែលកើតឡើងរឿយៗ ។ បទថា **សុទិដ្ឋោ ហោតិ** (ដែលអរិយសាវកឃើញល្អហើយ) បានដល់ ដែលអរិយសាវកឃើញហើយដោយល្អ ដោយអំណាចឃើញការកើតឡើងបន្តគ្នា ។

បទថា **ខីណនិរយោ** (នរកអស់ហើយជាដើម) អធិប្បាយថា នរករបស់យើងអស់ហើយ ព្រោះមិនកើតឡើងក្នុងនរកនោះតទៅទៀត ព្រោះដូច្នោះ យើងទើបឈ្មោះថា ជាអ្នកមាននរកអស់ហើយ ។ ក្នុងបទទាំងពួង

ក៏មានន័យនេះ ។ បទថា **សោតាបន្នោ** ប្រែថា ដល់ក្រសែនៃមគ្គ ។ បទថា **អវិនិបាតធម្មោ** (មានការមិនធ្លាក់ចុះជាធម្មតា) បានដល់ មានការមិនធ្លាក់ចុះជាសភាវៈ ។ បទថា **និយតោ** ទៀង បានដល់ ទៀងដោយកំណត់ភាពត្រឹមត្រូវ ពោលគឺ មគ្គទី ១ (សោតាបត្តិមគ្គ) ។ បទថា **សម្ពោធិបរាយនោ** (នឹងត្រាស់ដឹងក្នុងខាងមុខ) បានដល់ បញ្ញាជាគ្រឿងត្រាស់ដឹង ពោលគឺ មគ្គ ៣ ខាងលើជាខាងមុខ គឺ ជាផ្លូវរបស់យើង ព្រោះហេតុនោះ យើងទើបឈ្មោះថា នឹងមានការត្រាស់ដឹងក្នុងខាងមុខ ។ អធិប្បាយថា នឹងត្រាស់ដឹងព្រះសម្ពោធិញ្ញាណនោះដោយពិត ។

[១៥២] បទថា **បាណាតិបាតប្បច្ចយា** (ព្រោះបាណាតិបាតជាបច្ច័យ) បានដល់ ព្រោះកម្ម គឺ បាណាតិបាតជាហេតុ ។ ពីរបទថា **ភយំ វេរំ** ភ័យនិងពៀរ ដោយអត្ថតែមួយ ។ ដែលឈ្មោះថា ពៀរនេះ មាន ២ យ៉ាង គឺ ពៀរខាងក្រៅ ១ ពៀរខាងក្នុង ១ ។ កាលបិតារបស់បុគ្គលម្នាក់ ត្រូវបុគ្គលដទៃសម្លាប់ គេទើបគិតថា ឮថា បិតារបស់យើងត្រូវបុគ្គលនេះសម្លាប់ឲ្យស្លាប់ហើយ សូម្បីយើងក៏នឹងសម្លាប់វាឲ្យស្លាប់ដូចគ្នា ដូច្នេះ ទើបយកសស្ត្រាជាប់ខ្លួនទៅ ។ ចេតនាដែលជាហេតុបង្ករពៀរ ដែលកើតឡើងហើយ

ក្នុងខាងក្នុងរបស់បុគ្គលនោះ នេះឈ្មោះថា **ពៀរខាងក្រៅ** ។ ចំណែកបុគ្គលក្រៅពីនេះកើតសេចក្ដីគិតថា ឮថា បុគ្គលនេះត្រាច់មកដើម្បីនឹងសម្លាប់យើង យើងនឹងសម្លាប់គេមុន នេះឈ្មោះថា **ពៀរខាងក្នុង** ។ សូម្បីពៀរទាំង ២ យ៉ាងនេះ ក៏ចាត់ជាពៀរក្នុងបច្ចុប្បន្ននោះឯង ។ ចំណែកចេតនាដែលកើតឡើងដល់នាយនិរយបាល ដែលឃើញគេកើតក្នុងនរក ក៏កាន់ដំបងដែកដែលឆេះសន្ធោសន្ធៅ ដោយគិតថា យើងនឹងសម្លាប់វា នេះជាពៀរខាងក្រៅដែលនឹងមានក្នុងអនាគត ។ បុគ្គលដែលមានការគិតមកថា អ្នកនោះកើតការតាំងចិត្តឡើងថា បុគ្គលនេះមកដើម្បីនឹងប្រហារយើង ដែលជាអ្នកមិនមានកំហុស យើងនឹងសម្លាប់វាមុន នេះឈ្មោះថា ពៀរខាងក្នុងដែលនឹងមានក្នុងអនាគត ។ មួយទៀត ពៀរវេរាដែលជាខាងក្រៅនេះ ក្នុងអដ្ឋកថា លោកហៅថា **ពៀរចំណែកបុគ្គល** ។ ពីរ បទថា **ទុក្ខំ ទោមនស្សំ** ដោយអត្ថក៏ដូចគ្នានោះឯង ។ ក៏ក្នុងសេចក្ដីនេះ មានអធិប្បាយយ៉ាងណា ។ សូម្បីក្នុងបទដ៏សេសក៏មានអធិប្បាយយ៉ាងនោះ ។ គប្បីជ្រាបការកើតឡើងនូវពៀរដោយន័យមានជាដើមថា បុគ្គលនេះបានបំផ្លាញវត្ថុរបស់យើងហើយ បុគ្គលនេះបានប្រព្រឹត្ត (ខុស) ក្នុងកិរិយារបស់យើងហើយ ប្រយោជន៍ត្រូវ

បុគ្គលនេះបំផ្លាញហើយ ព្រោះពោលកុហក កម្មឈ្មោះនេះ ដែលបុគ្គលនេះ (ធ្វើ) ហើយ ដោយហេតុត្រឹមតែស្រវឹងស្រា ដូច្នេះ ។ បទថា **អវេច្ចប្បសាទេន** បានដល់ ដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ព្រោះខ្លួនសម្រេចហើយ ។ បទថា **អរិយកន្តេហិ** បានដល់ សីល ៥ ។ ព្រោះថា សីល ៥ ទាំងនោះ ជាទីប្រាថ្នា គឺ ជាទីស្រឡាញ់របស់ព្រះអរិយៈទាំងឡាយ ។ ព្រះអរិយៈទាំងឡាយសូម្បីទៅកាន់កពជាតិទៃ ក៏មិនបានលះបង់សីល ៥ ទាំងនោះ ព្រោះដូច្នោះ សីល ៥ ទាំងនោះ ទើបហៅថា ជាទីប្រាថ្នារបស់ព្រះអរិយៈ ។ ប្រការដ៏សេសដែលគប្បីពោលក្នុងទីនេះទាំងអស់នោះ បានពោលហើយក្នុងអនុស្សតិនិទ្ទេស ក្នុងវិសុទ្ធិមគ្គនោះឯង ។

ចប់អដ្ឋកថា បឋមបញ្ចវេរភយសូត្រទី ១

# អ ដ្ឋ ក ថា

## ទុតិយបញ្ចវេរភយសូត្រទី ២

[១៥៦] ក្នុងសូត្រទី ២ សេចក្ដីផ្សេងគ្នាត្រឹមតែការៈដែលពួកភិក្ខុពោលប៉ុណ្ណោះ ។

ចប់អដ្ឋកថា ទុតិយបញ្ចវេរភយសូត្រទី ២

# អ ដ្ឋ ក ថា

## ទុក្ខនិរោធសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុក្ខនិរោធសូត្រទី ៣ តទៅ ។*

*[១៦១] បទថា ទុក្ខស្ស បានដល់ វដ្ដទុក្ខ ទុក្ខ គឺ ការវិលវល់កើតស្លាប់ ។ ហេតុកើត ក្នុងបទថា* ***សមុទយំ*** *មាន ២ យ៉ាង គឺ ហេតុកើតដែលប្រព្រឹត្តទៅជាខណៈៗ (**ខណិកសមុទយៈ**) ១ , ហេតុកើត គឺ បច្ច័យ (**បច្ចយសមុទយៈ**) ១ ។ ភិក្ខុសូម្បីឃើញហេតុកើត គឺ បច្ច័យ ក៏ឈ្មោះថា ឃើញហេតុកើតដែលប្រព្រឹត្តទៅជាខណៈៗ សូម្បីឃើញហេតុកើតដែលប្រព្រឹត្តទៅជាខណៈៗ ក៏ឈ្មោះថា ឃើញហេតុកើត គឺ បច្ច័យ ។ ការរលត់ ក្នុងបទថា* ***អត្ថង្គមោ*** *មាន ២ យ៉ាង គឺ ការរលត់ស្និទ្ធ (**អច្ចន្តអត្ថង្គម**) ១ , ការរលត់ គឺ ការបែកធ្លាយ (**ភេទត្ថង្គម**) ១ ។ ភិក្ខុសូម្បីឃើញសេចក្ដីរលត់ស្និទ្ធ ក៏ឈ្មោះថា ឃើញការរលត់ គឺ ការបែកធ្លាយ , សូម្បីឃើញការរលត់ គឺ ការបែកធ្លាយ ក៏ឈ្មោះថា ឃើញការរលត់ស្និទ្ធ ។*

បទថា **ទេសេស្សាមិ** បានដល់ តថាគតនឹងសម្តែងការកើត និង ការរលត់ ដែលឈ្មោះថា ការកើត និងការបែកធ្លាយនៃវដ្តទុក្ខនេះ ។ អធិប្បាយថា ពួកអ្នកទាំងឡាយចូរស្តាប់ហេតុនៃការកើត និងការរលត់នោះ ។

[១៦២] បទថា **បដិច្ច** បានដល់ ព្រោះការប្រជុំនៃធម៌ ៣ ប្រការ ទើបកើតផស្សៈ ព្រោះធ្វើឲ្យជាបច្ច័យ ដោយអំណាចនិស្សយប្បច្ច័យ និង អារម្មណប្បច្ច័យ ។ បទថា **អយំ ខោ ភិក្ខវេ ទុក្ខស្ស សមុទយោ** បាន ដល់ នេះជាឈ្មោះនៃការកើតនូវវដ្តទុក្ខ ។

[១៦៣] បទថា **អត្ថង្គមោ** ប្រែថា ការបែកធ្លាយ ។ វដ្តទុក្ខដែល ត្រូវទម្លាយហើយ មិនមានបដិសន្ធិ ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា ទុក្ខនិរោធសូត្រទី ៣

# អ ដ្ឋ ក ថា

## លោកនិរោធសូត្រទី ៤

[១៦៤] ក្នុង *លោកនិរោធសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*បទថា លោកស្ស បានដល់ សង្ខារលោក ។ សេចក្តីផ្សេងគ្នាក្នុងសូត្រទី ៤ នេះមានត្រឹមតែប៉ុណ្ណេះ ។*

ចប់អដ្ឋកថា លោកនិរោធសូត្រទី ៤

# អ ដ្ឋ ក ថា

## ញាតិកសូត្រទី ៥

*ក្នុង ញាតិកសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៦៦] បទថា* ***ញាតិកេ*** *បានដល់ ជិតស្រុកនៃពួកព្រះញាតិទាំង ២ ចំណែក ។ បទថា* ***គិញ្ជកាវសថេ*** *បានដល់ ក្នុងមហាប្រាសាទដែលកសាងដោយឥដ្ឋ ។ បទថា* ***ធម្មបរិយាយំ*** *បានដល់ ហេតុនៃធម៌ ។*

*[១៦៨] បទថា* ***ឧបស្សុតិ*** *បានដល់ ចូលទៅឈរអែបចាំស្តាប់ ។ អធិប្បាយថា ឈរក្នុងទីដែលខ្លួនចូលទៅហើយ អាចបានឮព្រះសូរសេងរបស់ព្រះមានព្រះភាគបាន ។ បានឮមកថា ភិក្ខុនោះមកដើម្បីនឹងបោសសម្អាតបរិវេណព្រះគន្ធកុដិ បានទុកការងាររបស់ខ្លួន ហើយទៅឈរស្តាប់សំឡេងប្រកាសធម៌របស់ព្រះមានព្រះភាគ ។ បទថា* ***អទ្ទសា*** *សេចក្តីថា បានឮមកថា ក្នុងគ្រានោះ កាលព្រះមានព្រះភាគទ្រង់មនសិការបច្ចយាការតាំងពីខាងដើម ទ្រង់រំពឹងថា* ***វត្ថុនេះ រមែងមានព្រោះបច្ច័យនេះ វត្ថុនេះរមែងមានព្រោះបច្ច័យនេះ*** *សន្ធារបានប្រាកដជាក្រុមតែមួយ រហូតដល់ភវគ្គព្រហ្ម ។*

ព្រះសាស្តាទ្រង់លះបង់មនសិការហើយ កាលទ្រង់ធ្វើការស្វាធ្យាយដោយព្រះវាចា ទ្រង់បានបញ្ចប់ព្រះធម្មទេសនាតាមអនុសន្ធិ កាលទ្រង់ព្រះរំពឹងថា មាននរណាបានស្តាប់ធម្មបរិយាយនេះខ្លះទេហ្ន៎ ទើបបានទតឃើញភិក្ខុនោះ ។ ដោយហេតុនោះ លោកទើបពោលថា **ព្រះមានព្រះភាគបានទតឃើញហើយនោះឯង** ។ បទថា **អស្សោសិ នោ** បានដល់ បានស្តាប់ហើយឬទេ ។ ម្យ៉ាងទៀត បទថា **អស្សោសិ នោ** សេចក្តីថា បានស្តាប់ហើយ ឬមិនបានស្តាប់តថាគតដែលកំពុងពោល ។ ក្នុងបទថា **ឧគ្គណ្ហាហិ** ជាដើម មានអធិប្បាយថា ភិក្ខុស្តាប់ដោយគោរពហើយធ្វើឲ្យជំនាញ ឈ្មោះថា រមែងសិក្សា ។ កាលបទ និងបទធ្វើឲ្យជំនាញដោយវាចា ឈ្មោះថា ទន្ទេញ ។ កាលធ្វើនូវភាពជំនាញដោយប្រការទាំងពីរ ឲ្យសម្រេចជាការទ្រទ្រង់ចាំបាន ឈ្មោះថា ទ្រទ្រង់ទុក ។ បទថា **អត្ថសញ្ហិតោ** បានដល់ អាស្រ័យហេតុ ។ បទថា **អាទិព្រហ្មចរិយកោ** បានដល់ ជាការប្រតិស្ឋានខាងដើមនៃមគ្គព្រហ្មចរិយៈ ។ វដ្តៈ (ការវិលវល់ស្លាប់កើត) និងវិវដ្តៈ (ព្រះនិព្វាន) ដែលព្រះមានព្រះភាគត្រាស់ហើយក្នុងព្រះសូត្រទាំង ៣ នេះ ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា ញាតិកសូត្រទី ៥

# អ ដ្ឋ ក ថា

## អញ្ញតរសូត្រទី ៦

ក្នុង *អញ្ញតរសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[១៦៩] *ពាក្យថា* ***អញ្ញតរោ*** *គឺ ព្រាហ្មណ៍ម្នាក់មិនប្រាកដឈ្មោះ ។*

ចប់អដ្ឋកថា អញ្ញត្រសូត្រទី ៦

# អ ដ្ឋ ក ថា

## ជាណុស្សោណិសូត្រទី ៧

*ក្នុង ជាណុស្សោណិសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៧២] ពាក្យថា ជាណុស្សោណិ បានដល់ មហាបុរោហិតអ្នកមានសម្បត្តិ ៨០ កោដិ ដែលបានឈ្មោះយ៉ាងនោះ ដោយអំណាចឋានន្តរៈ ។*

ចប់អដ្ឋកថា ជាណុស្សោណិសូត្រទី ៧

# អ ដ្ឋ ក ថា

## លោកាយតិកសូត្រទី ៨

*ក្នុង លោកាយតិកសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[១៧៥] *បទថា* ***លោកាយតិកោ*** *បានដល់ អ្នកធ្វើសេចក្ដីស្និទស្នាលក្នុងទិដ្ឋិ ពោលដោយការបន្ដនៃលោក ដែលពួកជនអ្នកស្និទស្នាលគ្នាដជែកគ្នាលេងសប្បាយ ។ បទថា* ***ជេដ្ឋមេតំ លោកាយតំ*** *បានដល់ ទិដ្ឋិពោលដោយការបន្ដនៃលោកប្រការទី ១ ។ បទថា* ***លោកាយតំ*** *បានដល់ ការបន្ដនៃលោកនោះឯង គឺ ការបន្ដនៃលោករបស់ពាលបុថុជ្ជន បានដល់ ទិដ្ឋិថាមានតិចតួច ដែលបុគ្គលចូលទៅសម្គាល់ថាធំ ថាជ្រៅ ។ ដោយបទថា* ***ឯកត្តំ*** *នេះ ព្រាហ្មណ៍ឈ្មោះ ជាណុស្សោណិ សួរដល់វត្ថុដែលមានសភាវៈដូចគ្នាថា ជាវត្ថុដែលទៀងនុ៎ះឯង ។ ដោយបទថា* ***បុថុត្តំ*** *ជាណុស្សោណិព្រាហ្មណ៍ សួរដល់សភាវៈដែលផ្សេងអំពីសភាវៈមុន សំដៅយកការដាច់សូន្យថា វត្ថុទាំងពួង មានដោយភាពជាទេវតា និងមនុស្សជាដើមមុន តែចំណែកខាងក្រោយរមែងមិនមានទៀត ។ ក្នុងព្រះសូត្រនេះ គប្បីជ្រាបសស្ស-*

តទិដ្ឋិ ២ គឺ វត្ថុទាំងពួងមាន ១ , វត្ថុទាំងពួងមានសភាពតែមួយដូចគ្នា ១ ។ គប្បីជ្រាបឧច្ឆេទទិដ្ឋិ ២ គឺ វត្ថុទាំងពួងមិនមាន ១ , វត្ថុទាំងពួងមានសភាពផ្សេងគ្នា ១ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា លោកាយតិកសូត្រ ទី ៨

# អ ដ្ឋ ក ថា

## បឋមអរិយសាវកសូត្រទី ៩

ក្នុង *បឋមអរិយសាវកសូត្រទី ៩* មានវិនិច្ឆ័យដូចតទៅនេះ ៖

[១៧៨] *បទថា កឹ នុខោ ជាការសម្តែងអាការកើតឡើងនៃសេចក្តីសង្ស័យ ។ បទថា សមុទយតិ ប្រែថា កើតឡើង ។*

ចប់អដ្ឋកថា បឋមអរិយសាវកសូត្រ ទី៩

# អ ដ្ឋ ក ថា

## ទុតិយអរិយសាវកសូត្រទី ១០

[១៨៣] ក្នុង *អរិយសាវកសូត្រទី ១០ ន័យសូម្បីទាំងពីរ ព្រះមានព្រះភាគត្រាស់ដោយសេចក្តីតែមួយ ។ សេចក្តីដែលផ្សេងគ្នាអំពីសូត្រមុន មានត្រឹមតែប៉ុណ្ណេះ ។ ចំណែកសេចក្តីដ៏សេស មានន័យដូចមុននោះឯង ។*

ចប់អដ្ឋកថា ទុតិយអរិយសាវកសូត្រទី ១០

## ចប់គហបតិវគ្គទី ៥

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថាបឋមបញ្ចវេរភយសូត្រ
២-អដ្ឋកថាទុតិយបញ្ចវេរភយសូត្រ
៣-អដ្ឋកថាទុក្ខនិរោធសូត្រ
៤-អដ្ឋកថាលោកនិរោធសូត្រ
៥-អដ្ឋកថាញាតិកសូត្រ
៦-អដ្ឋកថាអញ្ញតរសូត្រ
៧-អដ្ឋកថាជាណុស្សោណិសូត្រ
៨-អដ្ឋកថាលោកាយតិកសូត្រ
៩-អដ្ឋកថាបឋមអរិយសាវកសូត្រ
១០-អដ្ឋកថាទុតិយអរិយសាវកសូត្រ

# ទុក្ខវគ្គទី ៦

## អ ដ្ឋ ក ថា

### បរិវីមំសនសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង **បរិវីមំសនសូត្រទី ១** នៃទុក្ខវគ្គតទៅ ៖*

[១៨៨] *បទថា **បរិវីមំសមានោ** ប្រែថា កាលពិចារណា ។*

[១៨៩] *បទថា **ជរាមរណំ** ជរា និងមរណៈ សេចក្តីថា **បើសួរថា** ព្រោះហេតុអ្វី ជរា និងមរណៈតែមួយប៉ុណ្ណោះ ទើបមានប្រការផ្សេងៗ ច្រើនយ៉ាង ។ **ឆ្លើយថា** ព្រោះកាលចាប់ជរាមរណៈនោះបានហើយ ក៏ជាការចាប់ទុក្ខទាំងពួងបាន ដូចជា កាលបុរសត្រូវចាប់ត្រង់ផ្នួងសក់ បុរសនោះឈ្មោះថា ចាប់បានដោយពិត យ៉ាងណា កាលចាប់ជរា និងមរណៈបានហើយ ធម៌ដ៏សេសរមែងឈ្មោះថា ជាការចាប់បានដោយពិត ដូច្នោះ ។ កាលកំណត់ជរា និងមរណៈបានហើយដូច្នេះ ទុក្ខទាំងពួង រមែងឈ្មោះថា ជាការកំណត់បានដោយពិត ។ ព្រោះដូច្នោះ ព្រះមានព្រះភាគត្រាស់ថា ទុក្ខនេះមានប្រការផ្សេងៗ ច្រើនយ៉ាងកើតឡើងក្នុងលោក ដូច្នេះ ទ្រង់សម្តែងទុក្ខ*

ទាំងពួង ដូចបុរសអ្នកងូតទឹកហើយឈរ ឈ្មោះថា ទ្រង់កំណត់ជរា និង មរណៈ ដូចចាប់បុរសនោះត្រង់ផ្នូងសក់ ។ បទថា **ជរាមរណនិរោធសារុប្បគាមិនី** សេចក្តីថា បដិបទា ឈ្មោះថា ដូចគ្នានោះឯង ព្រោះមិនមានកិលេស គឺ បរិសុទ្ធិ ជាគ្រឿងឲ្យដល់ ដោយការៈសមគួរដល់សេចក្តីរលត់នៃជរា និងមរណៈ ។ បទថា **តថាបដិបន្នោ ច ហោតិ** សេចក្តីថា ភិក្ខុដែលព្រះមានព្រះភាគត្រាស់ថា ជាអ្នកបដិបត្តិតាមនោះ យ៉ាងណា ក៏រមែងជាអ្នកបដិបត្តិយ៉ាងនោះ ។ បទថា **អនុធម្មចារី** ជាអ្នកប្រព្រឹត្តធម៌ដ៏សមគួរ សេចក្តីថា ប្រព្រឹត្ត គឺ បំពេញធម៌ដែលជាវត្តបដិបត្តិទៅតាមធម៌ គឺ ព្រះនិព្វាន ។ បទថា **ទុក្ខក្ខយាយ បដិបន្នោ** ជាអ្នកបដិបត្តិដើម្បីអស់ទុក្ខ បានដល់ ជាអ្នកធ្វើសីលឲ្យជាខាងដើម ហើយបដិបត្តិដើម្បីរលត់នៃទុក្ខ គឺ ជរា និងមរណៈ ។

[១៩១] បទថា **សង្ខារនិរោធាយ** ដើម្បីរលត់នៃសង្ខារ បានដល់ ដើម្បីការរលត់នៃទុក្ខ គឺ សង្ខារ ។ ព្រះធម្មទេសនារហូតដល់ព្រះអរហត្ត ព្រះមានព្រះភាគត្រាស់ហើយដោយប្រការត្រឹមតែប៉ុណ្ណោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងការពិចារណាអរហត្ត-

ផល និងធម៌ជាគ្រឿងនៅជានិច្ចហើយ ទើបបន្តទេសនាទៀត ។

**សួរថា** ព្រះមានព្រះភាគទ្រង់មិនធ្វើយ៉ាងនោះ តែទ្រង់កាន់យកពាក្យ ថា **អវិជ្ជាគតោ** បុគ្គលធ្លាក់នៅក្នុងអវិជ្ជានេះ ព្រោះហេតុអ្វី ។

**ឆ្លើយថា** ទ្រង់កាន់យក ដើម្បីទ្រង់សម្តែងវដ្តទុក្ខដែលព្រះខីណាស្រពឈានកន្លងហើយ ។ ម្យ៉ាងទៀត កាលព្រះមានព្រះភាគ ទ្រង់ប្រារព្ធវដ្តៈ ត្រាស់ដល់វិវដ្តៈ (ព្រះនិព្វាន) ក៏នឹងមានសត្វអ្នកត្រាស់ដឹងនៅក្នុងរឿងនេះ ។ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់កាន់យកពាក្យនេះ ដោយអំណាចអធ្យាស្រ័យរបស់សត្វនោះ ។ ក្នុងព្រះបាលីនោះ បទថា **អវិជ្ជាគតោ** បានដល់ ចូលដល់ គឺ ប្រកបដោយអវិជ្ជា ។ បទថា **បុរិសបុគ្គលោ** បានដល់បុគ្គល គឺ បុរសនោះឯង ព្រះមានព្រះភាគត្រាស់សម្មុតិកថា ដោយពាក្យទាំងពីរនោះ ។ ក៏ព្រះពុទ្ធទាំងឡាយទ្រង់មានកថា (ការពោល) ២ យ៉ាង គឺ **សម្មុតិកថា ១ បរមត្ថកថា ១** ។ ក្នុងកថាទាំង ២ នោះ កថាដែលប្រព្រឹត្តទៅយ៉ាងនេះ គឺ សត្វ នរៈ បុរិសៈ បុគ្គលៈ តិស្សៈ នាគៈ ឈ្មោះថា **សម្មុតិកថា** ។ កថាដែលប្រព្រឹត្តទៅយ៉ាងនេះ គឺ ខន្ធទាំងឡាយ ធាតុទាំងឡាយ អាយតនៈទាំងឡាយ ឈ្មោះថា **បរមត្ថកថា** ។ ព្រះពុទ្ធទាំង-

ឡាយ កាលទ្រង់សម្តែងបរមត្ថកថា ទ្រង់សម្តែងមិនលះបង់នូវសម្មតិកថា នោះឯង ។ ព្រះពុទ្ធទាំងនោះ កាលទ្រង់សម្តែងសម្មតិក្តី កាលទ្រង់សម្តែង បរមត្ថក្តី ទ្រង់រមែងសម្តែងរឿងពិតប៉ុណ្ណោះ ។ ដោយហេតុនោះ ព្រះមាន-ព្រះភាគ ទើបត្រាស់ថា ៖

ព្រះសម្មាសម្ពុទ្ធជាបុគ្គលដ៏ប្រសើរ កាលទឹងត្រាស់ (រឿងណាៗ) បានត្រាស់សច្ចៈ (សេចក្តីពិត) ២ គឺ សម្មតិសច្ចៈ ១ បរមត្ថ-សច្ចៈ ១ ។ នរណាៗ រមែងមិនបានសច្ចៈទី ៣ (ព្រោះមិនមាន) ។ ការពោលដល់វត្ថុដែលដឹង ឈ្មោះសម្មតិសច្ចៈ ព្រោះហេតុដែលលោកសម្មតិ (វត្ថុដែលមនុស្សលោកដឹង) ។ ចំណែកការពោលដល់ប្រយោជន៍ដ៏ក្រៃលែង ដែលជាលក្ខណៈពិតរបស់ធម៌ទាំងឡាយ ឈ្មោះថា បរមត្ថសច្ចៈ ។

បទថា បុញ្ញញ្ចេ សង្ខារំ បានដល់ បុញ្ញាភិសង្ខារ ដែលផ្សេងគ្នាដោយចេតនា ១៣ ។ បទថា **អភិសង្ខរោតិ** តាក់តែង បានដល់ ធ្វើ ។ បទថា បុញ្ញូបគំ ហោតិ វិញ្ញាណំ វិញ្ញាណរមែងចូលដល់បុណ្យ បានដល់ កម្មវិញ្ញាណរមែងចូលដល់ គឺ ប្រកបព្រមដោយកុសលកម្ម ។ សូម្បីវិបាកវិញ្ញាណ ក៏

រមែងចូលដល់ គឺ ប្រកបព្រមដោយកុសលវិបាក ។ បទថា **អបុញ្ញញ្ចេ សង្ខារំ** បើសង្ខារដែលជាបាប បានដល់ អបុញ្ញាភិសង្ខារដែលផ្សេងគ្នាដោយចេតនា ១២ ។ បទថា **អានេញ្ជញ្ចេ សង្ខារំ** បើសង្ខារជាអនេញ្ជា បានដល់ អនេញ្ជាភិសង្ខារដែលផ្សេងគ្នាដោយចេតនា ៤ ។ បទថា **អានេញ្ជូបគំ ហោតិ វិញ្ញាណំ** វិញ្ញាណរមែងចូលដល់អនេញ្ជា បានដល់ កម្មវិញ្ញាណរមែងចូលដល់ គឺ ប្រកបព្រមដោយកម្មដែលជាអនេញ្ជា វិបាកវិញ្ញាណរមែងចូលដល់ ដោយវិបាកដែលជាអនេញ្ជា ។ បច្ចយាការដែលមាន ១២ បទ ដែលព្រះមានព្រះភាគទ្រង់កាន់យកហើយនោះឯង ព្រោះទ្រង់កាន់យកកម្មាភិសង្ខារ ៣ ក្នុងព្រះសូត្រនេះ ។ វដ្តៈ ទ្រង់សម្តែងហើយដោយប្រការត្រឹមប៉ុណ្ណេះ ។

[១៩២] ឥឡូវនេះ ព្រះមានព្រះភាគកាលទ្រង់សម្តែងវិវដ្តៈ គឺ ព្រះនិព្វាន ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះឯង ជាដើម ។ ក្នុងព្រះបាលីនោះ បទថា **អវិជ្ជា** ប្រែថា ការមិនដឹងក្នុងអរិយសច្ច ៤ ។ បទថា **វិជ្ជា** បានដល់ អរហត្តមគ្គញាណ ។ ក្នុងព្រះបាលីនេះ មានអធិប្បាយថា កាលលះបង់អវិជ្ជាបានមុនហើយនោះឯង វិជ្ជាទើបកើតឡើង ។ ដូចកាលសេចក្តីងងឹតដែលប្រកបដោយអគ្គ ៤ នឹងលះបង់សេចក្តីងងឹតបាន

ក៏ដោយការដុតប្រទីបឲ្យឆេះឡើង យ៉ាងណា កាលវិជ្ជាកើតឡើង ក៏គប្បីជ្រាបថា ជាការលះបង់អវិជ្ជាបាន ដូច្នោះ ។ បទថា **មិនប្រកាន់មាំអ្វីៗ ក្នុងលោក "ន កិញ្ចិ លោកេ ឧបាទិយតិ"** បានដល់ មិនប្រកាន់មាំ គឺមិនប្រកាន់មាំធម៌អ្វីៗ ក្នុងលោក ។ បទថា **កាលមិនប្រកាន់មាំ ក៏មិនតក់ស្លុត "អនុបាទិយំ ន បរិតស្សតិ** អធិប្បាយថា កាលមិនប្រកាន់មាំ កាលមិនប្រកាន់មាំ ក៏រមែងមិនតក់ស្លុតព្រោះតណ្ហា មិនតក់ស្លុតព្រោះភ័យខ្លាច សេចក្តីថា រមែងមិនប្រាថ្នា មិនភ័យខ្លាច ។ បទថា **ព្រោះតួខ្លួនប៉ុណ្ណោះ បច្ចត្តំយេវ** បានដល់ រមែងបរិនិព្វានដោយខ្លួនឯងប៉ុណ្ណោះ មិនបរិនិព្វានព្រោះអានុភាពរបស់អ្នកដទៃ ។

សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ផ្តើមពាក្យនេះថា ភិក្ខុនោះ បើសោយសុខវេទនា ។

ឆ្លើយថា ដើម្បីទ្រង់សម្តែងការពិចារណារបស់ព្រះខីណាស្រព ហើយសម្តែងធម៌ជាគ្រឿងនៅជានិច្ច ។ បទថា **ដែលខ្លួនមិនប្រកាន់ដោយតណ្ហា (អនជ្ឈោសិតា)** គឺ ដែលខ្លួនសោយ ព្រោះមិនប្រកាន់ដោយតណ្ហា ។ សួរថា បើដូច្នេះ ព្រោះហេតុអ្វី ទើបត្រាស់ដល់ទុក្ខវេទនា ។ អ្នកដែលរីករាយ

ទុក្ខវេទនានោះក៏នៅមានឬ ។ ឆ្លើយថា មែន នៅមាន ព្រោះអ្នកដែលរីក-រាយក្នុងសេចក្ដីសុខនោះឯង ឈ្មោះថា រមែងរីករាយក្នុងទុក្ខ ព្រោះអ្នកមានទុក្ខប្រាថ្នាសេចក្ដីសុខ សេចក្ដីសុខក៏ក្លាយជាទុក្ខ ព្រោះប្រែប្រួល ។ បទថា **ដែលប្រាកដផ្លូវកាយ (កាយបរិយន្តិកំ)** គឺ កំណត់បានដោយកាយ ។ អធិ-ប្បាយថា កាយ គឺ ទ្វារ ៥ នៅប្រព្រឹត្តទៅដរាបណា បុគ្គលរមែងសោយវេទនាតាមទ្វារ ៥ ដែលប្រព្រឹត្តទៅដរាបនោះ ។ បទថា **ដែលប្រាកដផ្លូវជីវិត (ជីវិតបរិយន្តិកំ)** បានដល់ កំណត់បានដោយជីវិត ។ អធិប្បាយថា ជីវិតនៅប្រព្រឹត្តទៅដរាបណា បុគ្គលរមែងសោយវេទនាតាមមនោទ្វារ ដែលប្រព្រឹត្តទៅដរាបនោះ ។

បណ្ដាវេទនាទាំងពីរនោះ វេទនាដែលប្រព្រឹត្តទៅតាមទ្វារ ៥ កើតឡើងក្រោយ តែរលត់មុន ។ វេទនាដែលប្រព្រឹត្តទៅតាមមនោទ្វារ កើតឡើងមុន តែរលត់ក្រោយ ។ ក៏ក្នុងខណៈបដិសន្ធិ វេទនាដែលប្រព្រឹត្តទៅតាមមនោទ្វារនោះ រមែងតាំងនៅក្នុងវត្ថុរូបប៉ុណ្ណោះ ។ ក្នុងបវត្តិកាល វេទនាដែលប្រព្រឹត្តទៅតាមទ្វារ ៥ ប្រព្រឹត្តទៅហើយដោយអំណាចទ្វារ ៥ ក្នុងវេលាដែលមនុស្សមានអាយុ ២០ ឆ្នាំជាដើម ក្នុងបឋមវ័យ រមែងមាន

កម្លាំងខ្លាំងក្លា ដោយអំណាចសេចក្ដីស្រឡាញ់ សេចក្ដីក្រោធ និងសេចក្ដីវង្វេង , ក្នុងវេលាដែលមនុស្សមានអាយុ ៥០ ឆ្នាំ រមែងជាបុគ្គលមាំទាំ , ចាប់តាំងពីវេលាដែលមនុស្សមានអាយុ ៦០ ឆ្នាំ ក៏នឹងទ្រុឌទោមចុះ , លុះដល់វេលាដែលមនុស្សមានអាយុបាន ៨០-៩០ ឆ្នាំ ក៏នឹងទន់ខ្សោយចុះ (ក្នុងទីបំផុត) ក្នុងគ្រានោះ (គឺក្នុងវេលាដែលមានអាយុ ៨០-៩០ ឆ្នាំ) កាលពួកគេពោលថា ពួកយើងអង្គុយ ដេករួមគ្នាអស់វេលាយូរ សត្វទាំងឡាយពោលថា ពួកយើងមិនដឹង គឺ រមែងពោលដល់អារម្មណ៍ មានរូបជាដើម សូម្បីមានប្រមាណក្រៃលែងថា យើងមិនឃើញ មិនបានឮ គឺ មិនដឹងថា ក្លិនក្រអូប ឬក្លិនស្អុយ ល្អ ឬមិនល្អ រឹង ឬទន់ ។ វេទនាដែលប្រព្រឹត្តទៅតាមទ្វារ ៥ របស់ជនទាំងនោះ រមែងទន់ខ្សោយហើយយ៉ាងនេះ ។ ចំណែកវេទនាដែលប្រព្រឹត្តទៅតាមមនោទ្វារ ក៏នៅប្រព្រឹត្តទៅ ។ សូម្បីវេទនានោះកាលទន់ខ្សោយទៅដោយលំដាប់ រមែងអាស្រ័យទីបំផុតនៃហទយៈនុ៎ះឯង ដែលប្រព្រឹត្តទៅក្នុងវេលាមរណៈ ។ មួយ៉ាងទៀត វេទនានោះនៅប្រព្រឹត្តទៅដរាបណា ក៏និយាយបានថា សត្វនៅមានជីវិតដរាបនោះ ។ កាលណា វេទនានោះមិនប្រព្រឹត្តទៅ កាលនោះហៅថា សត្វស្លាប់ គឺ រលត់ ។ សេចក្ដីនេះ

សេចក្តីនេះ គប្បីសម្តែង (ប្រៀបធៀប) ដោយស្រះ ។ ដូចបុរសសាងស្រះឲ្យដល់ព្រមដោយផ្លូវទឹក ៥ ខ្សែ ។ កាលភ្លៀងធ្លាក់ចុះមកគ្រាដំបូង ទឹកគប្បីហូរទៅតាមផ្លូវទឹកទាំង ៥ ខ្សែ ដរាបពេញស្រះ កាលភ្លៀងធ្លាក់រឿយៗ ទឹកក៏តាំងនៅពេញផ្លូវទឹក ហូរចុះកាន់ផ្លូវប្រមាណមួយគាវុតខ្លះ កន្លះយោជន៍ខ្លះ ទឹកដែលជន់មកពីទីនោះៗ កាលគេបើកទ្វារសម្រាប់បង្ហូរទឹក ធ្វើការងារក្នុងស្រែ ទឹកក៏ហូរចេញទៅ ។ ក្នុងវេលាដែលស្រូវទុំ ទឹកក៏ហូរចេញ ។ ទឹករីងដល់ការដែលគួរពោលថា យើងនឹងចាប់ត្រី ។ បន្ទាប់ពីនោះទៀត ២-៣ ថ្ងៃ ទឹកក៏តាំងនៅក្នុងអណ្តូងនុ៎ះឯង ។ ក៏បើក្នុងអណ្តូងមានទឹកតាំងនៅដរាបណា ក៏នឹងរាប់បានថា ក្នុងស្រះធំនៅមានទឹកដរាបនោះ ។ តែបើទឹកក្នុងអណ្តូងនោះរីងស្ងួតកាលណា កាលនោះ ក៏និយាយបានថា ក្នុងស្រះមិនមានទឹក យ៉ាងណា គប្បីជ្រាបការប្រៀបធៀប ដូច្នោះ ។ វេលាដែលវេទនាប្រព្រឹត្តទៅផ្លូវមនោទ្វារ ក្នុងខណៈបដិសន្ធិដំបូងនុ៎ះឯង វេទនាដែលប្រព្រឹត្តទៅតាមមនោទ្វារ តាំងនៅក្នុងវត្ថុរូប ក្នុងខណៈបដិសន្ធិគ្រាដំបូងនោះឯង ដូចវេលាភ្លៀងធ្លាក់គ្រាដំបូង ទឹកហូរចូលទៅតាមផ្លូវ ៥ ខ្សែ អណ្តូងក៏ពេញ ។ កាលចេតនាក្នុងមនោទ្វារប្រព្រឹត្តទៅហើយ ការប្រព្រឹត្ត

ទៅនៃវេទនាតាមទ្វារ ៥ ដូចវេលាភ្លៀងធ្លាក់រឿយៗ ផ្លូវ ៥ ខ្សែ ក៏ពេញ ។ ការៈនៃវេទនាដែលប្រព្រឹត្តទៅផ្លូវទ្វារ ៥ នោះ មានកម្លាំងក្រៃលែង ដោយអំណាចសេចក្តីស្រឡាញ់ជាដើម ក្នុងវេលាដែលបុគ្គលមានអាយុ ២០ ឆ្នាំ ក្នុងបឋមវ័យ ដូចទឹកដែលជោរជន់ក្នុងផ្លូវសូម្បីមួយគាវុត ឬកន្ទុះយោជន៍ ទឹកមិនទាន់ហូរចេញពីស្រះដរាបណា វេលាដែលវេទនានោះតាំងនៅក្នុងវេលាដែលបុគ្គលមានអាយុ ៥០ ឆ្នាំ ដូចវេលាដែលទឹកឋិតនៅក្នុងស្រះចាស់ដរាបនោះ ។ ភាពទ្រុឌទ្រោមនៃវេទនានោះ ចាប់ផ្តើមតាំងពីវេលាដែលបុគ្គលមានអាយុ ៦០ ឆ្នាំ ដូចវេលាដែលគេបើកទ្វារបង្ហូរទឹកធ្វើការងារ ទឹកក៏ហូរចេញ ។ វេលាដែលវេទនាប្រព្រឹត្តទៅតាមទ្វារ ៥ ខ្សោយចុះ ក្នុងវេលាដែលបុគ្គលមានអាយុ ៨០-៩០ ឆ្នាំ ដូចវេលាភ្លៀងធ្លាក់ហើយ ទឹកតាំងនៅដោយជុំវិញក្នុងផ្លូវទឹក ។ វេលាដែលវេទនាប្រព្រឹត្តទៅតាមមនោទ្វារ អាស្រ័យហទយវត្ថុប្រព្រឹត្តទៅ ដូចវេលាដែលទឹកតាំងនៅក្នុងអណ្តូងន៍ុះឯង ។ ការប្រព្រឹត្តទៅនោះ ដូចវេលាក្នុងស្រះមានទឹកសូម្បីត្រឹមតែបន្តិចបន្តួច ក៏គួរពោលថា ក្នុងស្រះមានទឹកដរាបណា កាលវេទនាដែលប្រព្រឹត្តទៅតាមមនោ-ទ្វារ នៅប្រព្រឹត្តទៅ រមែងពោលបានថា សត្វនៅមានជីវិតដរាបនោះ ។ ម្យ៉ាង

ទៀត កាលទឹកក្នុងអណ្តូងរីងស្ងួតអស់ទៅ រមែងពោលបានថា មិនមានទឹកក្នុងស្រះ យ៉ាងណា កាលវេទនាដែលប្រព្រឹត្តទៅតាមមនោទ្វារ មិនប្រព្រឹត្តទៅ សត្វក៏ហៅថា ស្លាប់ហើយដូច្នោះ ។ ព្រះមានព្រះភាគទ្រង់សំដៅយកវេទនានេះ (វេទនាដែលប្រព្រឹត្តទៅតាមមនោទ្វារ) ទើបត្រាស់ថា ភិក្ខុសោយវេទនាដែលមានជីវិតជាទីបំផុត ។ ពាក្យថា **កាយស្ស ភេទា** បានដល់ ព្រោះការបែកធ្លាយនៃកាយ ។ បទថា **ជីវិតបរិយាទានា ឧទ្ធំ** បានដល់ ក្រោយពីការអស់ជីវិត ។ បទថា **ឥធេវ** គឺ ក្នុងលោកនេះឯង ព្រោះមកកពខាងមុខដោយអំណាចបដិសន្ធិ ។ បទថា **សីតីភវិស្សន្តិ** នឹងជាវត្ថុដែលត្រជាក់ សេចក្តីថា ជាវត្ថុដែលវៀរចាកសេចក្តីក្តៅក្រហាយ និងសេចក្តីខ្វល់ខ្វាយ ទើបឈ្មោះថា ជាវត្ថុដែលត្រជាក់ គឺ មានការមិនប្រព្រឹត្តទៅជាធម្មតា ។ បទថា **សរីរានិ** បានដល់ សរីរធាតុ ។ បទថា **អវសិស្សន្តិ** នឹងសល់នៅ បានដល់ នឹងជាវត្ថុដែលសល់នៅ ។

[១៩៣] បទថា **កុម្ភការបាកា** (ឡដុតឆ្នាំង) បានដល់ ចាកអំពីឡដែលដុតភាជនៈរបស់ជាងឆ្នាំង ។ បទថា **បតិដ្ឋបេយ្យ** ដាក់ទុក បានដល់ តម្កល់ទុក ។

បទថា **កបល្លានិ** (អំបែងឆ្នាំង) បានដល់ អំបែងឆ្នាំងដែលជាប់ជាមួយគ្នា ព្រមទាំងកណ្តាប់មាត់ ។ បទថា **អវសិស្សេយ្យុំ** (គប្បីសល់នៅ) បានដល់ គប្បីតាំងនៅ ។ ក្នុងពាក្យថា **ឯវមេវ ខោ** នេះ មានសេចក្តីប្រៀបធៀបដោយឧបមាដូច្នេះ គត ៣ គប្បីឃើញដូចឡដុតឆ្នាំងដែលភ្លើងឆេះជាប់ ។ ព្រះយោគាវចរដូចជាងឆ្នាំង ។ អរហត្តមគ្គញាណដូចឈើដែលសម្រាប់ប្រើនាំកាជនៈចេញ របស់ជាងឆ្នាំងអំពីឡដុតឆ្នាំង ។ ព្រះនិព្វានដែលមិនមានបច្ច័យតាក់តែង ដូចផ្ទៃដីដែលរាបស្មើ ។ វេលាដែលព្រះយោគាវចរអ្នកប្រារព្ធវិបស្សនា ឃើញច្បាស់ពួក ៧ នៃរូប និងពួក ៧ នៃអរូប កាលកម្មដ្ឋានប្រាកដច្បាស់ បានឧត្តុសប្បាយជាដើមបែបនោះ អង្គុយនៅលើអាសនៈតែមួយ ចម្រើនវិបស្សនា សម្រេចព្រះអរហត្តដែលជាផលដ៏ប្រសើរ លើកខ្លួនឡើងអំពីអបាយ ៤ ហើយតាំងនៅក្នុងព្រះនិព្វានដែលជាអមតៈ ដែលមិនមានបច្ច័យតាក់តែងដោយអំណាចផលសមាបត្តិ គប្បីឃើញដូចវេលាដែលជាងឆ្នាំង យកឈើទាញឆ្នាំងដែលក្តៅមកហើយដាក់ឆ្នាំងទុកលើផ្ទៃដីរាបស្មើ ។ ចំណែកព្រះខីណាស្រព មិនបរិនិព្វានក្នុងថ្ងៃសម្រេចព្រះអរហត្ត ដូចឆ្នាំងដែលនៅក្តៅដូច្នោះ តែកាលនឹងបន្តប្រពៃណី

នៃសាសនា ក៏ប្រព្រឹត្តទៅដល់ ៥០-៦០ ឆ្នាំ រមែងបរិនិព្វានដោយអនុបា-ទិសេសនិព្វានធាតុ ព្រោះការបែកធ្លាយនៃឧបាទិន្នកខន្ធ ព្រោះដល់ចិត្តជួងចុងក្រោយ កាលនោះ សរីរៈដែលមិនមានចិត្តគ្រប់គ្រងរបស់ព្រះខីណាស្រពនោះ នឹងសល់នៅដូចជាអំបែងឆ្នាំងទុំះឯង ។ ក៏ពាក្យថា **សរីរានិ អវសិ-ស្សន្តីតិ បជានាតិ** ព្រះមានព្រះភាគត្រាស់ដើម្បីលើកសេចក្ដីព្យាយាមរបស់ព្រះខីណាស្រព ។

[១៩៤] បទថា **វិញ្ញាណំ បញ្ញាយេថ** (វិញ្ញាណគប្បីប្រាកដ) បានដល់ បដិសន្ធិវិញ្ញាណគប្បីប្រាកដ ។

[១៩៥] បទថា **សាធុ សាធុ** បានដល់ ព្រះមានព្រះភាគទ្រង់លើកសរសើរការព្យាករណ៍របស់ព្រះថេរៈ ។ បទថា **ឯវមេតំ** សេចក្ដីថា ពាក្យថា កាលអភិសង្ខារ ៣ យ៉ាងមិនមាន បដិសន្ធិវិញ្ញាណក៏មិនប្រាកដ ។ ពាក្យនោះក៏ជាយ៉ាងនោះដូចគ្នា ។ បទថា **អធិមុច្ចថ** បានដល់ ចូរបង្អោនចិត្តជឿ ពោលគឺ ការយល់ព្រម ។ ពាក្យថា **ឯសេវន្តោ ទុក្ខស្ស** (នោះជាទីបំផុតទុក្ខ) បានដល់ នេះឯងជាទីបំផុតនៃទុក្ខក្នុងវដ្ដៈ គឺ នេះជាការកំណត់បានដល់ ព្រះនិព្វាន ។

ចប់អដ្ឋកថា បរិវីមំសនសូត្រទី ១

# អ ដ្ឋ ក ថា

## ឧបាទានសូត្រទី ២

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ឧបាទានសូត្រទី ២** តទៅ ។*

*[១៩៦] បទថា **ឧបាទានីយេសុ** ដែលជាបច្ច័យនៃឧបាទាន បានដល់ក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាបច្ច័យនៃឧបាទាន ៤ ។ បទថា **អស្សាទានុបស្សិនោ** ឃើញសេចក្តីពេញចិត្តរឿយៗ គឺ ឃើញរឿយៗ ដោយសេចក្តីពេញចិត្ត ។*

*[១៩៧] បទថា **តត្រ** គឺ ក្នុងគំនរភ្លើងនោះ ។ បទថា **តទាហារោ** មានអាហារយ៉ាងនោះ ។ គឺ មានបច្ច័យយ៉ាងនោះ ។ ពាក្យថា មានស្នៀស្ងួតនោះ (**តទុបាទានោ**) ជាវេវចនៈរបស់បច្ច័យនោះឯង ។ ក្នុងពាក្យថា **ឯវមេវ ខោ** នេះ កត ៣ ឬដែលហៅថា វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ខ្លះ គប្បីឃើញថា ដូចជាគំនរភ្លើង ។ បុថុជ្ជនអ្នកល្ងង់ខ្លៅ ដែលអាស្រ័យវដ្តៈ គឺការវិលវល់ស្លាប់កើត ដូចបុរសបម្រើភ្លើង ។ ការធ្វើកម្មដែលជាកុសលនិងអកុសល តាមទ្វារ ៦ ដោយអំណាចតណ្ហាជាដើម របស់បុថុជ្ជនអ្នកឃើញ*

សេចក្ដីពេញចិត្តរឿយ ៗ ដូចការដាក់អាចម៍គោស្ងួតជាដើម ។ ការកើតនៃវដ្ដទុក្ខក្នុងកពតទៅ ព្រោះបុថុជ្ជនអ្នកល្ងង់ខ្លៅក្រោកឡើងហើយ ក្រោកឡើងទៀត ព្យាយាមធ្វើកម្មតាមដែលពោលហើយ ដូចកាលស្មៅ និងអាចម៍គោជាដើមអស់ហើយ គំនរភ្លើងក៏នៅឆេះសន្ធោសន្ធៅរឿយៗ ព្រោះដាក់ស្មៅ និងអាចម៍គោទាំងនោះចូលទៅរឿយៗ ។

[១៩៩] ពាក្យថា *ន កាលេន កាលំ សុក្ខានិ ចេវ តិណានិ បក្ខិបេយ្យ* (មិនដាក់ស្មៅស្ងួតគ្រប់ៗ កាល) អធិប្បាយថា ក៏នរណាៗ ដែលប្រាថ្នាប្រយោជន៍ គប្បីពោលចំពោះបុរសនោះយ៉ាងនេះថា អ្នកដ៏ចម្រើន ហេតុអ្វីលោកទើបក្រោកឡើងហើយ ក្រោកឡើងទៀតជាន់ក្បៀង យកស្មៅ និងឈើស្ងួតដាក់ក្នុងកញ្ជើដរាបពេញ ដាក់អាចម៍គោស្ងួតចូលទៅ ធ្វើឲ្យគំនរភ្លើងនេះឆេះសន្ធោសន្ធៅ ព្រោះការធ្វើនេះជាហេតុ សេចក្ដីចម្រើនណាៗ រមែងមានដល់លោកខ្លះឬហ្ន៎ ។ បុរសនោះពោលថា លោកដ៏ចម្រើន ការធ្វើដូច្នេះមានមកតាមវង្ស (ជាប្រពៃណី) របស់ពួកយើង តែការធ្វើដូច្នេះ ក៏មិនមានសេចក្ដីចម្រើនដល់យើងឡើយ សេចក្ដីចម្រើននឹងមានពីទីណា ។ ព្រោះយើងរវល់តែបម្រើភ្លើងនេះ ទើបមិនបានងូតទឹក ទាំងមិនបានបរិភោគ មិន

បានដេកឡើយ ។ អ្នកប្រាថ្នាប្រយោជន៍ពោលថា អ្នកដ៏ចម្រើន បើដូច្នោះ នឹងមានប្រយោជន៍អ្វីដល់លោក ដោយការដុតភ្លើងឲ្យឆេះដែលគ្មានប្រយោជន៍ នេះ លោកចូរមក ស្មៅជាដើមដែលលោកនាំមកហើយទាំងនេះ ដែលដាក់ចូល ទៅក្នុងគំនរភ្លើងនេះ នឹងឆេះឡើងនោះឯង ប៉ុន្តែថា លោកចូរទៅងូតទឹកឯ ស្រះបោក្ខរណី ដែលមានទឹកត្រជាក់នៅក្នុងទីឯណោះ តុបតែងខ្លួនដោយ គ្រឿងលាប គ្រឿងក្រអូប និងផ្កាកម្រង ស្លៀកដណ្តប់យ៉ាងល្អ ចូលទៅកាន់ ក្រុងដោយទ្រនាប់ជើងដ៏ល្អ ឡើងកាន់ប្រាសាទដ៏ប្រសើរ បើកបង្អួច ហើយ អង្គុយរីករាយជាមួយសេចក្តីសុខ មានអារម្មណ៍តែមួយ រុងរឿងនៅលើមហា វីថិ ។ កាលលោកអង្គុយក្នុងប្រាសាទនោះហើយ គំនរភ្លើងនោះ នឹងដល់ នូវភាវៈដែលតាំងនៅមិនបាននុ៎ះឯងដោយពិត ព្រោះអស់គ្រឿងឆេះ មាន ស្មៅជាដើម ។ បុរសនោះគប្បីធ្វើយ៉ាងនោះ ។ម្យ៉ាងទៀត កាលគេអង្គុយ លើប្រាសាទនោះហើយ គំនរភ្លើងនោះគប្បីដល់នូវភាវៈ គឺ ការតាំងនៅមិន បាន ព្រោះអស់គ្រឿងឆេះ ។ ពាក្យថា **ន កាលេន កាលំ** ជាដើមនេះ ព្រះមានព្រះភាគត្រាស់សំដៅយកសេចក្តីនេះ ។

តែក្នុងពាក្យថា **ឯវមេវ ខោ** នេះ មានការប្រៀបធៀបដោយសេចក្តី

ឧបមាដូច្នេះ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ គប្បីឃើញដូចគំនរភ្លើងធំ ដែលឆេះដោយឈើ (ឧស) ៤០ រទេះ ។ ព្រះយោគាវចរដែលអាស្រ័យវដ្តៈ ដូចបុរសអ្នកបម្រើភ្លើង ។ ព្រះសម្មាសម្ពុទ្ធ ដូចជាបុរសអ្នកប្រាថ្នាប្រយោជន៍ ។ វេលាដែលព្រះតថាគតត្រាស់ត្រាស់កម្មដ្ឋានក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដល់ភិក្ខុនោះថា ម្នាលភិក្ខុ អ្នកចូរនឿយណាយក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ចុះ អ្នកនឹងរួចផុតចាកវដ្តទុក្ខ យ៉ាងនេះ ។ ដូចឱវាទដែលបុរសអ្នកប្រាថ្នាប្រយោជន៍ ឲ្យដល់បុរសអ្នកបម្រើភ្លើងនោះ ។ វេលាដែលព្រះយោគីទទួលឱវាទរបស់ព្រះសុគតហើយ ចូលទៅកាន់សុញ្ញាគារ ផ្តើមតាំងវិបស្សនាក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ បានអាហារសប្បាយជាដើម ក្នុងសភាពបែបនោះដោយលំដាប់ អង្គុយលើអាសនៈមួយ ហើយតាំងនៅក្នុងផលដ៏ប្រសើរ (អរហត្តផល) ដូចវេលាដែលបុរស (អ្នកបម្រើភ្លើង) នោះ បដិបត្តិតាមដែលអ្នកទូន្មានហើយ អង្គុយក្នុងប្រាសាទ ។ វេលាដែលព្រះយោគីជម្រះមន្ទិល គឺ កិលេស ដោយទឹក គឺ មគ្គញាណ ត្រង់ស្រះបោក្ខរណី គឺ អរិយមគ្គ ស្លៀកសំពត់ គឺ ហិរិឱត្តប្បៈ ចូលទៅលាបដោយគ្រឿងលាប គឺ សីល តុបតែងអត្តភាពដោយគ្រឿងតាក់តែង គឺ

ព្រះអរហត្ត ប្រដាប់កម្រងផ្កាឈើ គឺ វិមុត្តិ ពាក់ទ្រនាប់ជើង គឺ ឥទ្ធិបាទ ចូលទៅកាន់នគរ គឺ ព្រះនិព្វាន ឡើងកាន់ប្រាសាទ គឺ ព្រះធម៌ រុងរឿងនៅលើមហាវីថិ គឺ សតិប្បដ្ឋាន នៃបនិតក្នុងផលសមាបត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ដូចវេលាដែលបុរសនោះអង្គុយលើប្រាសាទនោះ មានអារម្មណ៍តែមួយ រីករាយដោយសេចក្តីសុខ ព្រោះមានកាយដែលជម្រះ និងតុបតែងហើយដោយការងូតទឹក និងគ្រឿងលាបជាដើម ។ ចំណែកសេចក្តីស្ងប់ដ៏ជាំក្រៃលែងនៃវដ្តៈរបស់ព្រះខីណាស្រព អ្នកតាំងនៅដរាបអស់អាយុ ហើយបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ព្រោះការបែកធ្លាយនៃខន្ធដែលមានចិត្តគ្រប់គ្រង គប្បីឃើញដូចវេលាដែលបុរសនោះ អង្គុយលើប្រាសាទនោះ គំនរភ្លើងក៏ដល់នូវការមិនមានបញ្ញត្តិ ព្រោះអស់គ្រឿងឆេះ មានស្មៅជាដើម ។

ចប់អដ្ឋកថា ឧបាទានសូត្រទី ២

# អ ដ្ឋ ក ថា

## បឋមសញ្ញោជនសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសញ្ញោជនសូត្រទី ៣ តទៅ ។*

*[២០០] បទថា សញ្ញោជនីយេសុ (ដែលជាបច្ច័យនៃសញ្ញោជនៈ) គឺ ជាបច្ច័យនៃសញ្ញោជនៈ ១០ ។*

*[២០១] បទថា ឈាយេយ្យ (គប្បីឆេះ) ប្រែថា គប្បីឆេះសន្ធោសន្ធៅ ។ ពាក្យថា តេលំ អាសិញ្ចេយ្យ វដ្ដឹ ឧបសំហរេយ្យ បានដល់ ដើម្បីឲ្យប្រទីបឆេះរហូតទៅ ទើបកាន់កាជនៈប្រេង និងប្រឆេះដ៏ធំទៅតាំងទុកក្នុងទីជិតជានិច្ច កាលប្រេងអស់ក៏ថែមប្រេង កាលប្រឆេះអស់ក៏ដាក់ប្រឆេះចូលទៅ ។ ពាក្យដ៏សេសក្នុងសូត្រនេះ គប្បីជ្រាបដោយន័យមុននោះឯង ព្រមទាំងការប្រៀបធៀបដោយសេចក្ដីឧបមា ។*

ចប់អដ្ឋកថា បឋមសញ្ញោជនសូត្រទី ៣

# អ ដ្ឋ ក ថា

## ទុតិយសញ្ញោជនសូត្រទី ៤

[២០២] *ក្នុង ទុតិយសញ្ញោជនសូត្រទី ៤ ព្រះមានព្រះភាគត្រាស់ប្រៀបធៀបមុន ទើបត្រាស់ខ្ទឹមសារក្នុងខាងក្រោយ ។ ពាក្យដ៏សេសក៏មានន័យដូចគ្នានោះឯង ។*

ចប់អដ្ឋកថា ទុតិយសញ្ញោជនសូត្រទី ៤

# អ ដ្ឋ ក ថា

## បឋមមហារុក្ខសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមមហារុក្ខសូត្រទី ៥ តទៅ ។*

[២០៧] *ពាក្យថា ឧទ្ធំ ឱជំ អភិហរន្តិ (នាំឱជាឡើងខាងលើ) បានដល់ នាំរសដី និងរសទឹកឡើងទៅខាងលើ ។ ព្រោះឱជាត្រូវបានស្រូបឡើងទៅខាងលើដើមឈើកម្ពស់ ១០០ ហត្ថ ក៏មានជ័រស្អិត ទើបតាំងនៅបាន ដូចតំណក់ទឹកត្រង់ត្រួយ ។ ក្នុងសេចក្តីនេះ មានការប្រៀបធៀបដោយសេចក្តីឧបមាដូច្នេះ វដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដូចដើមឈើធំ ។ អាយតនៈទាំងឡាយ ដូចឫសឈើ ។ ការធ្វើកម្មតាមទ្វារ ៦ ដូចការស្រូបឱជាឡើងតាមឫស ។ ការតាំងនៅបានអស់វេលាយូររបស់បុថុជ្ជនល្ងង់ខ្លៅ ដែលអាស្រ័យនៅក្នុងវដ្ដៈ ព្យាយាមធ្វើកម្មតាមទ្វារ ៦ ដោយអំណាចវដ្ដៈក្នុងកពតៗ ទៅ មានសេចក្តីចម្រើនដូចដើមឈើធំ តាំងនៅបានរហូតដល់កប្ប ព្រោះឱជាចម្រើនលូតលាស់ ។*

[២០៩] *បទថា កុទ្ទាលបិដកំ ប្រែថា ចប និងកញ្ជើ ។ ពាក្យថា*

ខណ្ឌាខណ្ឌិកំ ឆិន្ទេយ្យ សេចក្តីថា កាត់ឲ្យតូចឲ្យធំ គឺ ឲ្យជាកំណាត់តូចកំណាត់ធំ ៗ ក្នុងសេចក្តីនេះ មានការប្រៀបធៀបដោយឧបមាដូច្នេះ ក៏ក្នុងព្រះសូត្រនេះ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដូចដើមឈើធំ ៗ ព្រះយោគាវចរ ដូចបុរសអ្នកត្រូវការគល់ដើមឈើ ៗ ញាណ គឺ សេចក្តីដឹងដូចចប សមាធិ ដូចកញ្ជើរ ញាណ ដូចពូថៅសម្រាប់កាត់ដើមឈើ បញ្ញារបស់ព្រះយោគីអ្នករៀនកម្មដ្ឋានក្នុងសម្នាក់អាចារ្យ ហើយមនសិការ ដូចវេលាដែលដើមឈើត្រូវកាត់ត្រង់ឫស ៗ វេលាមនសិការមហាភូតរូប ៤ ដោយសង្ខេប ដូចវេលាកំពុងកាត់ជាកំណាត់តូចធំ ៗ វេលាមនសិការដោយពិស្តារក្នុងកោដ្ឋាស ៤២ ដូចការពុះ ៗ ការកំណត់នាមរូបដោយអំណាចនៃធម៌ទាំងនេះ គឺ ឧបាទាយរូប និងវិញ្ញាណ ដែលមានរូបក្ខន្ធជាអារម្មណ៍ដូចវេលាធ្វើឲ្យជាជម្រៀកតូចៗ ៗ ការស្វែងរកបច្ច័យរបស់នាមរូបនោះឯងដូចការដកឫសឈើ ៗ ការសម្រេចផលដ៏ប្រសើរ (អរហត្តផល) របស់ព្រះយោគីអ្នកចម្រើនវិបស្សនាដោយលំដាប់ បានសប្បាយណាមួយហើយកាលកម្មដ្ឋានប្រាកដច្បាស់ អង្គុយលើអាសនៈតែមួយធ្វើសមណធម៌ ដូចវេលាដែលហាលខ្យល់ និងកំដៅថ្ងៃ ហើយយកភ្លើងដុត ៗ វេលាដែលព្រះ

យោគីមិនបរិនិព្វានក្នុងថ្ងៃដែលខ្លួនសម្រេចព្រះអរហត្តនោះឯង តែតាំងនៅ ដរាបអស់អាយុ ប្រៀបដូចមនសិការៈ ។ សេចក្ដីស្ងប់នៃវដ្ដៈរបស់ព្រះ-ខីណាស្រពអ្នកបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ព្រោះការបែកធ្លាយនៃខន្ធដែលមានចិត្តគ្រប់គ្រង គប្បីជ្រាបដូចការបាចកម្ទេចធ្យូងទៅតាមខ្យល់ធំ និងបណ្ដែតទៅក្នុងទន្លេ ។

ចប់អដ្ឋកថា បឋមមហារុក្ខសូត្រទី ៥

# អ ដ្ឋ ក ថា

## ទុតិយមហារុក្ខសូត្រទី ៦

[២១០] *ក្នុង ទុតិយមហារុក្ខសូត្រទី ៦ ព្រះមានព្រះភាគប្រៀបធៀបមុន ហើយត្រាស់ខ្ទឹមសារក្នុងខាងក្រោយ សេចក្ដីផ្សេងគ្នាមានត្រឹមតែប៉ុណ្ណេះ ។*

ចប់អដ្ឋកថា ទុតិយមហារុក្ខសូត្រទី ៦

# អ ដ្ឋ ក ថា

## តរុណរុក្ខសូត្រទី ៧

ក្នុង តរុណារុក្ខសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២១៣] បទថា តរុណោ បានដល់ មិនទាន់បញ្ចេញផល ។ បទថា បលិសជ្ជេយ្យ ប្រែថា គប្បីជម្រះ ។ ពាក្យថា បំសុំ ទទេយ្យ ដាក់ដីបានដល់ យកដីដែលរឹង និងដុំៗ ចេញ ដាក់ដីដែលមានជីជាតិលាយដោយអាចម៍គោស្រស់ និងធូលីល្អិតចូលទៅ ។ បទថា វុឌ្ឍឹ បានដល់ សូម្បីសេចក្តីចម្រើនលូតលាស់ គួរនឹងរក្សាផ្កាក៏បានផ្កា គួរនឹងរក្សាផ្លែក៏បានផ្លែ ។ ក៏ក្នុងសេចក្តីនេះ មានការប្រៀបធៀបដោយឧបមាដូច្នេះ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដូចដើមឈើជំទង់ បុថុជ្ជនអាស្រ័យវដ្តៈ ដូចបុរសរក្សាដើមឈើ ការប្រមូលមកនូវកម្មដែលជាកុសល និងអកុសលតាមទ្វារ ៣ ដូចការបន្តនៃឫស និងផ្លែឈើជាដើម ការប្រព្រឹត្តទៅនៃវដ្តៈក្នុងកពតៗ ទៅរបស់បុថុជ្ជនអ្នកប្រមូលមកនូវកម្មតាមទ្វារ ៣ ដូចដើមឈើដែលដល់នូវសេចក្តីចម្រើន ។ វិវដ្តៈ (ព្រះនិព្វាន) គប្បីជ្រាបដោយន័យដែលពោលហើយនុ៎ះឯង ។

ចប់អដ្ឋកថា តរុណារុក្ខសូត្រទី ៧

# អ ដ្ឋ ក ថា

## នាមរូបសូត្រទី ៨

[២១៦] *សូត្រទី ៨ មានសេចក្តីងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា នាមរូបសូត្រទី ៨

# អ ដ្ឋ ក ថា

## វិញ្ញាណសូត្រទី ៩

[២២០] *សូត្រទី ៩ មានសេចក្តីងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា វិញ្ញាណសូត្រទី ៩

# អ ដ្ឋ ក ថា

## និទានសូត្រទី ១០

ក្នុងនិទានសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២២៤] ពីរបទថា *កុរូសុ វិហរតិ* បានដល់ ទ្រង់ប្រថាប់នៅក្នុងជនបទដែលបានឈ្មោះយ៉ាងនេះ ដោយអំណាចការហៅគ្នាច្រើនយ៉ាងនេះថា កុរុ ។ និគមរបស់អ្នកកុរុ ឈ្មោះថា **កម្មាសធម្មៈ** ព្រោះដូច្នោះ និគមរបស់អ្នកកុរុ ទើបមានឈ្មោះយ៉ាងនេះ ។ អធិប្បាយថា ទ្រង់ធ្វើនិគមនោះឲ្យជាគោចរគ្រាម ។ ពាក្យថា **អ្នកមានអាយុ** (អាយស្មា) នេះ ជាពាក្យហៅដោយសេចក្តីស្រឡាញ់ ជាពាក្យហៅដោយសេចក្តីគោរព ។ ពាក្យថា **អានន្ទ** ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ពាក្យថា **ឯកមន្តំ និសីទិ** (អង្គុយក្នុងទីដ៏សមគួរ) មានអធិប្បាយថា ព្រះអានន្ទ ជាព្រះធម្មភណ្ឌាគារិក កាលវៀរទោសនៃការអង្គុយ ៦ ប្រការ បានចូលទៅខាងក្នុងព្រះរស្មីដែលមានវណ្ណៈ ៦ របស់ព្រះពុទ្ធអង្គ ក្នុងទីខាងមុខមណ្ឌលព្រះជានុខាងស្តាំ អង្គុយដូចកំពុងងូតទឹកថ្វា ដូចកំពុងដណ្តប់ផ្ទាំងមាស ដូចកំពុងចូលទៅកាន់សួនផ្កា

ឈូកក្រហម ព្រោះដូច្នោះ លោកទើបពោលថា អង្គុយនៅក្នុងទីដ៏សមគួរ ។

សួរថា ក៏លោកមានអាយុនេះ ចូលទៅគាល់ព្រះមានព្រះភាគវេលាណា ព្រោះហេតុអ្វី ។ ឆ្លើយថា ចូលទៅគាល់ក្នុងវេលាល្ងាច ព្រោះហេតុដើម្បីទូលសួរបញ្ហាបច្ចយាការ ។

បានឮមកថា ក្នុងថ្ងៃនោះ លោកដ៏មានអាយុនេះ (ព្រះអានន្ទ) បានត្រាច់ទៅប្រោសសត្វ ញុំាងនិគមកម្មាសធម្មៈដូចដាក់វត្ថុរាប់ពាន់យ៉ាងចុះគ្រប់ទ្វារផ្ទះ ត្រឡប់ពីបិណ្ឌបាតហើយ បានសម្តែងវត្តថ្វាយព្រះសាស្តា កាលព្រះសាស្តាស្តេចចូលទៅកាន់ព្រះគន្ធកុដិហើយ ក៏ថ្វាយបង្គំព្រះសាស្តា ហើយទៅកាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន កាលពួកអន្តេវាសិកសម្តែងវត្តហើយត្រឡប់ទៅ ទើបបោសសម្អាតត្រង់ទីសម្រាកពេលថ្ងៃ ក្រាលផ្ទាំងស្បែក យកទឹកពីឆ្នាំងទឹកលាងដៃ និងជើងជរាបត្រជាក់ ហើយអង្គុយពែនភ្នែន ចូលសោតាបត្តិផលសមាបត្តិ ពេលចេញចាកសមាបត្តិ ដោយអំណាចកំណត់វេលា ទើបបានញុំាងញាណចុះក្នុងបច្ចយាការ ។ លោកពិចារណាបច្ចយាការ ១២ បទ ចាប់ផ្តើមតាំងពីដើមថា **ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ** រហូតដល់ខាងចុង , តាំងពីខាងចុង រហូតដល់ខាងដើម , តាំងពីខាងចុង

ទាំងពីរហូតដល់កណ្តាល តាំងពីកណ្តាលរហូតដល់ខាងចុងទាំងពីរ ៣ ដង ។ កាលលោកពិចារណាហើយយ៉ាងនេះ បច្ចយាការ បានប្រាកដច្បាស់ដូចជាងាយ បន្ទាប់ពីនោះក៏គិតថា **បច្ចយាការនេះ ព្រះពុទ្ធទាំងឡាយត្រាស់ថាជ្រាលជ្រៅ និងមានក្រសែជ្រាលជ្រៅ តែប្រាកដថាងាយ ជាក់ច្បាស់ដល់យើងដែលជាសាវកអ្នកតាំងនៅក្នុងបទេសញាណ បច្ចយាការនេះ រមែងប្រាកដដូចជាងាយដល់យើងប៉ុណ្ណោះឬហ្ន៎** ឬថា ប្រាកដដល់ភិក្ខុពួកដទៃផង ព្រះអានន្ទគិតថា យើងនឹងក្រាបទូលហេតុដែលប្រាកដដល់ខ្លួនចំពោះព្រះសាស្តាទើបក្រោកចាកទីអង្គុយ គោះផ្ទាំងស្បែកហើយកាន់ចូលទៅគាល់ព្រះមានព្រះភាគក្នុងវេលាល្ងាច ។ ព្រោះដូច្នោះ លោកទើបពោលថា ព្រះអានន្ទចូលទៅគាល់ក្នុងវេលាល្ងាច ដោយហេតុដើម្បីទូលសួរបញ្ហារឿងបច្ចយាការ ។

**យាវ** សព្ទ ក្នុងពាក្យថា **យាវគម្ភីរោ** នេះ ប្រព្រឹត្តទៅក្នុងការឈានកន្លងហួសប្រមាណ គឺ ជ្រាលជ្រៅហួសប្រមាណ ។ អធិប្បាយថា ជ្រាលជ្រៅយ៉ាងក្រៃលែង ។ បទថា **គម្ភីរាវភាសោ** មានខ្លឹមសារជ្រាលជ្រៅ អធិប្បាយថា ពន្លឺ គឺ ប្រាកដជ្រាលជ្រៅដោយពិត ។ ពិតណាស់ ទឹកមួយ

កន្ទែង រាក់ៗ តែដូចជាជ្រៅ ដូចទឹកល្អក់ដែលមានពណ៌ខ្មៅ ដោយអំណាចរសស្លឹកឈើស្អុយ ។ ព្រោះថា ទឹកនោះសូម្បីជ្រៅត្រឹមជង្គង់ ក៏ប្រាកដដូចជ្រៅទាំងរយជួរបុរស ។ ទឹកកន្ទែងខ្លះជ្រៅ តែដូចជារាក់ ដូចទឹកដែលថ្លាច្បាស់នៃមណីគង្គា ព្រោះទឹកនោះ សូម្បីជ្រៅទាំងរយជួរបុរស ក៏ប្រាកដដូចជ្រៅត្រឹមជង្គង់ ។ ទឹកកន្ទែងខ្លះរាក់ និងមានសភាពរាក់ ដូចទឹកក្នុងភាជន៍ជាដើម ។ ទឹកកន្ទែងខ្លះជ្រៅផង និងមានសភាពជ្រៅផង ដូចទឹកក្នុងមហាសមុទ្រទាជើងភ្នំសិនេរុ ។ ទឹក រមែងបានឈ្មោះ ៤ យ៉ាង ដោយប្រការដូច្នេះឯង ។ តែសេចក្តីរាក់ជ្រៅ រមែងមិនមានក្នុងបដិច្ចសមុប្បាទ ។ ព្រោះថា បដិច្ចសមុប្បាទនេះ បានឈ្មោះត្រឹមតែម្យ៉ាងប៉ុណ្ណោះថា "ជ្រាលជ្រៅនិងមានសភាពជ្រាលជ្រៅ" ។ ព្រះអានន្ទ កាលនឹងប្រកាសសេចក្តីអស្ចារ្យនៃចិត្តរបស់ខ្លួនយ៉ាងនេះថា បដិច្ចសមុប្បាទយ៉ាងនេះ ក៏ប៉ុន្តែប្រាកដដូចជាធម៌ងាយៗ សម្រាប់ខ្ញុំព្រះអង្គ ។ សេចក្តីនេះ គួរអស្ចារ្យណាស់ព្រះអង្គបពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនេះមិនធ្លាប់មានដល់ខ្ញុំព្រះអង្គ ទើបទូលសួរបញ្ហា ហើយបានអង្គុយស្ងៀម ។

[២២៥] ព្រះមានព្រះភាគ ទ្រង់បានស្តាប់ពាក្យរបស់ព្រះអានន្ទហើយ

ទ្រង់ព្រះតម្រិះថា ភិក្ខុឈ្មោះអានន្ទ ដូចជាលូកដៃចេញដើម្បីចាប់កវគ្គព្រហ្ម ដូចជាព្យាយាមទម្លាយភ្នំសិនេរុ នាំបំណែកថ្មចេញ ដូចប្រាថ្នានឹងឆ្លងមហាសមុទ្រដោយមិនចាំបាច់ប្រើទូក និងដូចព្យាយាមត្រឡប់ផែនដីកាន់យកឱជៈនៃដី ទើបពោលដល់បញ្ហាដែលជាពុទ្ធវិស័យថា រាក់ៗ សម្រាប់ខ្លួន ណ្ហើយចុះ តថាគតនឹងសម្តែងសេចក្តីជ្រាលជ្រៅដល់គេ ដូច្នេះ ទើបត្រាស់ថា **មាហេវំ** ដូច្នេះ ជាដើម ។ ក្នុងព្រះបាលីនោះ **ហ** អក្សរ ក្នុងពាក្យថា **មា-ហេវំ** ត្រឹមតែជានិបាត ។ អធិប្បាយថា អ្នកកុំពោលយ៉ាងនេះ ។ ព្រះ-មានព្រះភាគ សូម្បីទ្រង់ធ្វើឲ្យព្រះអានន្ទត្រេកអរ ឬមិនត្រេកអរក៏ដោយ ទើបបានត្រាស់ពាក្យថា **មាហេវំ** នេះ ។ ក្នុងព្រះបាលីនោះ បទថា **ឧស្សា-ទេន្តោ** ធ្វើឲ្យត្រេកអរ មានអធិប្បាយថា ម្នាលអានន្ទ អ្នកមានបញ្ញាច្រើន មានញាណចាស់ក្លា ដោយហេតុនោះ អ្នកមិនគួរកំណត់ថា បដិច្ចសមុប្បាទ សូម្បីជ្រាលជ្រៅ តែក៏ប្រាកដជារាក់ៗ សម្រាប់អ្នក ឬថា រាក់សម្រាប់ភិក្ខុពួកដទៃក៏ទេ ។ ព្រោះថា បដិច្ចសមុប្បាទនេះ ទាំងជ្រាលជ្រៅផង និងជាធម៌មានសភាពជ្រាលជ្រៅផង ។

នៅក្នុងសេចក្តីនោះ ព្រះអដ្ឋកថាចារ្យពោលឧបមាទុក ៤ ប្រការថា

ដំណាលមកថា ជនទាំងឡាយបានសម្តែងដុំថ្មដែលអ្នកចំបាប់គប្បីលើក ក្នុងរោងអ្នកចំបាប់ដ៏ធំ ដែលហ្វឹកហាត់ជំនាញហើយ បានទទួលការចិញ្ចឹមរក្សាដោយសេរកោជនដ៏ល្អអស់ ៦ ខែ ទៅកាន់យុទ្ធភូមិ ចំបាប់ក្នុងសម័យជំនុំនៃអ្នកចំបាប់ខ្លាំងៗ ។ អ្នកចំបាប់នោះនិយាយថា វត្ថុមួយនេះ គឺអ្វី ។ ជនទាំងឡាយពោលថា ដុំថ្មដែលអ្នកចំបាប់នឹងត្រូវលើក ។ គេពោលថា ពួកលោកចូរនាំដុំថ្មនោះមកចុះ ។ លុះជនទាំងឡាយពោលថា ពួកខ្ញុំលើកមិនរួចទេ ទើបលើកឡើងដោយខ្លួនឯង ហើយពោលថា ដែលធ្ងន់ជាងថ្មនេះនៅទីណា ហើយលើកដុំថ្ម ២ ដុំឡើងដោយដៃទាំងពីរ ហើយដាក់ចុះ ដូចលើកដុំស្ករអំពៅលេង ។ ក្នុងសេចក្តីនោះ គេត្រូវជនទាំងឡាយពោលថា ដុំថ្មដែលអ្នកចំបាប់លើក ជារបស់ស្រាលសម្រាប់អ្នកចំបាប់ តែមិនគួរនឹងពោលថា ជារបស់ស្រាលសម្រាប់បុគ្គលពួកដទៃទេ ។ ព្រះអានន្ទអ្នកដល់ព្រមដោយអភិនិហារមួយសែនកប្ប ក៏ដូចអ្នកចំបាប់ដែលត្រូវបានចិញ្ចឹមរក្សាដោយសេរកោជនដ៏ល្អអស់ ៦ ខែ ។ ដុំថ្មដែលអ្នកចំបាប់នឹងត្រូវលើក ជារបស់ស្រាលសម្រាប់អ្នកចំបាប់ ព្រោះអ្នកចំបាប់មានកម្លាំងខ្លាំង យ៉ាងណា ។ បដិច្ចសមុប្បាទ គប្បីពោលថា ជាធម៌ដែលងាយសម្រាប់ព្រះអានន្ទ ព្រោះព្រះ

ថេរៈ មានបញ្ញាច្រើន តែមិនមែនជាធម៌ដែលរាក់សម្រាប់ភិក្ខុពួកដទៃ ដូច្នោះ ។

ក៏ក្នុងមហាសមុទ្រ ត្រីធំឈ្មោះ តិមិ ប្រវែង ២០០ យោជន៍ ត្រីតិមិង្គលៈ ប្រវែង ៣០០ យោជន៍ ត្រីតិមេរបិង្គលៈ ប្រវែង ៥០០ យោជន៍ ។ ត្រី ៤ យ៉ាងទាំងនេះ គឺ ត្រីអានន្ទ ត្រីបនន្ទៈ ត្រីអជ្ឈោហារៈ ត្រីមហាតិមិ មានប្រវែងមួយពាន់យោជន៍ ។ ក្នុងត្រីទាំង ៤ យ៉ាងនោះ លោកសម្តែងដោយត្រីតិមេរបិង្គលៈនុ៎ះឯង ។ កាលវាកម្រើកព្រុយស្តាំ ផ្ទៃទឹកប្រមាណ ៥០០ យោជន៍ ក៏នឹងញាប់ញ័រ ព្រុយឆ្វេង កន្ទុយ ក្បាល ក៏ដូចគ្នា ។ តែកាលវាកម្រើកព្រុយទាំង ២ វាត់កន្ទុយ ផ្ទៀងក្បាលទៅមក ដើម្បីនឹងលេងទឹក កាលនោះ ដូចមនុស្សយកទឹកដាក់កាជនៈ ផ្ទៃទឹកក្នុងទី ៧-៨ រយយោជន៍ក៏រញ្ជួយ ដូចទឹកនៅលើចង្ក្រាន ផ្ទៃទឹកក្នុងទីប្រមាណ ៣០០ យោជន៍ក៏មិនអាចលិចខ្នង (របស់វា) ។ វាគប្បីពោលយ៉ាងនេះថា ជនទាំងឡាយពោលថា មហាសមុទ្រនេះជ្រៅ ការជ្រៅរបស់មហាសមុទ្រនោះ នៅទីណា ។ ពួកយើងមិនបានទឹកសូម្បីត្រឹមតែនឹងលិចខ្នងរបស់ពួកយើងផង ក្នុងសេចក្តីនោះ គប្បីពោលថា មហាសមុទ្ររាក់ តែសម្រាប់ត្រីតូចៗពួកដទៃមិនរាក់ឡើយ បដិច្ចសមុប្បាទក៏យ៉ាងនោះដូចគ្នា គប្បីពោលថា ងាយសម្រាប់ព្រះ

អានន្ទអ្នកចូលដល់ញាណ (អ្នកមានបញ្ញាច្រើន) តែមិនគប្បីពោលថា ងាយសម្រាប់ភិក្ខុពួកដទៃ ។ មួយទៀត ស្តេចគ្រុឌកម្ពស់ ១៥០ យោជន៍ ស្លាបស្តាំរបស់ស្តេចគ្រុឌនោះប្រវែង ១៥០ យោជន៍ ស្លាបឆ្វេងក៏ដូចគ្នា កន្ទុយប្រវែង ៦០ យោជន៍ មាត់ ៩ យោជន៍ ជើង ១២ យោជន៍ ។ កាលវាផ្តើមទទះស្លាបបក់ខ្យល់ ស្ថានទីប្រមាណ ៧-៨ រយយោជន៍ ក៏មិនល្មម ។ វាគប្បីពោលយ៉ាងនេះថា ជនទាំងឡាយពោលថា អាកាសនេះមិនមានទីបំផុត ការមិនមានទីបំផុតនៃអាកាសនោះ ដូចម្តេច ។ យើងមិនបានសូម្បីឱកាសសម្រាប់ទទះស្លាបផង ។ ក្នុងសេចក្តីនោះ គប្បីពោលថា អាកាសមានត្រឹមតែតិចតួចសម្រាប់ស្តេចគ្រុឌ អ្នកចូលដល់កាយ (ជាសត្វគ្រុឌធំ) ។ តែមិនគប្បីពោលថា មានត្រឹមបន្តិចបន្តួចសម្រាប់សត្វតូចៗ ពួកដទៃ ។ បដិច្ចសមុប្បាទក៏យ៉ាងនោះដូចគ្នា គប្បីពោលថា ងាយសម្រាប់ព្រះអានន្ទអ្នកចូលដល់ញាណ (មានបញ្ញាច្រើន) តែមិនគប្បីពោលថា ងាយសម្រាប់ភិក្ខុពួកដទៃ ។

ចំណែកអសុរិន្ទរាហូ តាំងពីចុងជើងដល់ចុងសក់ មានកម្ពស់ ៤.៨០០ យោជន៍ ដៃទាំង ២ របស់អសុរិន្ទរាហូនោះប្រវែង ១.២០០ យោជន៍ ទទឹង

ខ្លួនប្រវែង ៦០០ យោជន៍ បាតដៃបាតជើង ៣០០ យោជន៍ មាត់ក៏ដូចគ្នា ថ្នាំងម្រាមមួយៗ ៥០ យោជន៍ ចន្លោះចិញ្ចើមក៏ដូចគ្នា ទំហំថ្ងាស់ ៣០០ យោជន៍ សីសៈ ៩០០ យោជន៍ កាលអសុរិន្ទរាហូចុះក្នុងមហាសមុទ្រ ទឹកមានជម្រៅប្រមាណត្រឹមតែជង្គង់ ។ គេគប្បីពោលថា ជនទាំងឡាយពោលថា មហាសមុទ្រនេះជ្រៅ ការជ្រៅរបស់មហាសមុទ្រនោះ មានអំពីណា ។ យើងមិនបានទឹកសូម្បីត្រឹមតែលិចដល់ជង្គង់ ។ ក្នុងសេចក្តីនោះគប្បីពោលថា មហាសមុទ្ររាក់សម្រាប់អសុរិន្ទរាហូ ដែលមានកាយធំ តែមិនគប្បីពោលថា រាក់សម្រាប់អ្នកដទៃ ។ បដិច្ចសមុប្បាទ ក៏ដូចគ្នាយ៉ាងនោះឯង គប្បីពោលថា ងាយសម្រាប់ព្រះអានន្ទអ្នកចូលដល់ញាណ (មានបញ្ញាច្រើន) តែមិនគប្បីពោលថា ងាយសម្រាប់ភិក្ខុពួកដទៃ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ដូច្នេះ ទ្រង់សំដៅយកសេចក្តីនេះឯង ។

ពិតណាស់ បដិច្ចសមុប្បាទ សូម្បីជាធម៌ដ៏ជ្រាលជ្រៅ តែក៏ប្រាកដថាជាធម៌ងាយដល់ព្រះអានន្ទត្ថេរ ដោយហេតុ ៤ ប្រការ ។ ហេតុ ៤ ប្រការ គឺអ្វីខ្លះ ។ គឺ ៖

១-**បុព្វូបនិស្សយសម្បត្តិយា** ការដល់ព្រមដោយឧបនិស្ស័យក្នុងកាលមុន ។

២-**តត្ថវាសេន** ដោយការនៅជិតព្រះសាស្តា ។

៣-**សោតាបន្នតាយ** ភាពជាអ្នកសម្រេចសោតបន្ន ។

៤-**ពហុស្សុតភាវេន** ភាពជាអ្នកបានស្តាប់ច្រើន ។

បានឮមកថា ក្នុងសែនកប្ប រាប់ពីកប្បនេះទៅ មានព្រះសាស្តាទ្រង់ព្រះនាមថា **បទុមុត្តរៈ** ទ្រង់ឧប្បត្តិឡើងហើយក្នុងលោក ព្រះអង្គទ្រង់មាននគរដែលប្រថាប់នាមថា **ហង្សវតី** ទ្រង់មានព្រះបិតាជាព្រះរាជា ទ្រង់ព្រះនាមថា **អានន្ទៈ** ទ្រង់មានព្រះមាតាជាព្រះទេវី ទ្រង់ព្រះនាមថា **សុមេធា** ព្រះពោធិសត្វទ្រង់ព្រះនាមថា **ឧត្តរកុមារ** ។ ព្រះអង្គស្តេចបានចេញមហាភិនេស្ក្រម៍ក្នុងថ្ងៃដែលព្រះឱរសប្រសូតិ ទ្រង់ព្រះផ្នួសហើយប្រកបសេចក្តីព្យាយាមរឿយៗ ទ្រង់សម្រេចសព្វញ្ញុតញ្ញាណតាមលំដាប់ ទ្រង់បន្លឺឧទានថា **អនេកជាតិសំសារំ** ជាដើម ទ្រង់ញុំាងវេលាឲ្យកន្លងទៅត្រង់ពោធិបល្ល័ង្កអស់ ៧ ថ្ងៃ ហើយទ្រង់លើកព្រះបាទចេញ ដោយទ្រង់ព្រះតម្រិះថា យើងនឹងយកជើងជាន់លើផែនដី ។ ខណៈនោះ ផ្កាឈូកធំក៏ផុសពីផែនដី

ប្រាកដឡើង ត្របកផ្កាឈូកនោះ ប្រវែង ៩០ ហត្ថ , កេសរ ៣០ ហត្ថ កណ្ណិកា ១២ ហត្ថ , មានលម្អងកេសរប្រមាណ ៩ ថ្នាំង ។

ចំណែកព្រះសាស្តា ដោយកម្ពស់ ទ្រង់មានកម្ពស់ ៥៨ ហត្ថ ចន្លោះព្រះពាហាទាំង ២ របស់ព្រះអង្គ ប្រវែង ១៨ ហត្ថ ព្រះនលាដ៍ ៥ ហត្ថ ព្រះហស្ថ និងព្រះបាទ ១១ ហត្ថ លុះព្រះអង្គទ្រង់ប្រើព្រះបាទ ១១ ហត្ថ ប្រថាប់លើផ្កាឈូកប្រមាណ ១២ ហត្ថ លម្អងកេសរដែលមានប្រមាណ ៩ ថ្នាំង ក៏ហុយឡើងពាសពេញទៅរហូតដល់កម្ពស់ ៥៨ ហត្ថ ដូចលម្អិតនៃមនោសិលា ដូច្នោះ អាស្រ័យហេតុនោះ ព្រះមានព្រះភាគ ទើបប្រាកដព្រះនាមថា **បទុមុត្តរៈ** ។ ព្រះអង្គមានអគ្គសាវក ២ រូប គឺ **ព្រះទេវិលៈ** និង **ព្រះសុជាតៈ** ។ អគ្គសាវិកា ២ រូប គឺ **ព្រះនាងអមិតា** និង **ព្រះនាងអសមា** ។ ឧបដ្ឋាកឈ្មោះ **សុមនៈ** ។ **ព្រះមានព្រះភាគបទុមុត្តរៈ** កាលទ្រង់ធ្វើការសង្គ្រោះព្រះបិតា ទ្រង់ប្រថាប់នៅហង្សវតីរាជធានី មានភិក្ខុ ១ សែនរូបជាបរិវារ ។ មួយទៀត ព្រះកនិដ្ឋភាតារបស់ព្រះអង្គ ទ្រង់ព្រះនាមថា **សុមនកុមារ** ។ ព្រះរាជាបានព្រះរាជទានភោគៈក្នុងទី ១២០ យោជន៍ អំពីហង្សវតី ដល់សុមនកុមារនោះ ។ ពេលខ្លះ ព្រះសុមនកុមារក៏មកគាល់

ព្រះបិតា និងព្រះសាស្តា ។

ក្នុងថ្ងៃមួយ ជាយដែនកើតមានចលាចល (កើតសេចក្តីមិនស្ងប់) **សុមនកុមារ** ទ្រង់បានបញ្ជូនសាសន៍ទៅថ្វាយព្រះរាជា ព្រះរាជាទ្រង់បញ្ជូនសាសន៍តបទៅថា កូនអើយ បិតាតាំងឯងទុកដើម្បីអ្វី ។ **សុមនកុមារ** ទ្រង់បង្ក្រាបចោរឲ្យស្ងប់ ហើយទ្រង់បញ្ជូនសាសន៍ទៅថ្វាយព្រះរាជាវិញថា បពិត្រសម្មតិទេព ជនបទស្ងប់ហើយ ។ ព្រះរាជាទ្រង់ត្រេកអរ ត្រាស់បង្គាប់ថា សូមឲ្យកូនរបស់យើងចូរមករហ័ស ។ សុមនកុមារនោះ ទ្រង់មានអាមាត្យប្រមាណ ១,០០០ នាក់ ព្រះអង្គទ្រង់ប្រឹក្សានឹងអាមាត្យទាំងនោះក្នុងចន្លោះផ្លូវថា ព្រះរាជបិតារបស់យើងទ្រង់ត្រេកអរ បើទ្រង់ប្រទានពរដល់យើង យើងនឹងទទួលអ្វីល្អ ។ គ្រានោះ អាមាត្យមួយពួក បានក្រាបទូលព្រះកុមារថា ព្រះអង្គចូរយកដំរី យកសេះ យកជនបទ យកកែវ ៧ ប្រការ ។ អាមាត្យមួយពួកទៀតក្រាបទូលថា ព្រះអង្គជាព្រះរាជឱរសរបស់ព្រះរាជា ដែលជាធំក្នុងផែនដី ទ្រព្យមិនមែនជារបស់រកបានលំបាកសម្រាប់ព្រះអង្គ ព្រះអង្គគួរលះបង់ទ្រព្យដែលបានហើយទាំងអស់នេះទៅ បុណ្យតែម្យ៉ាងប៉ុណ្ណោះដែលគួរនាំទៅ ព្រោះដូច្នោះ កាលព្រះរាជាព្រះរាជទានពរ

សូមព្រះអង្គទ្រង់ទទួលពរ ដើម្បីឧបដ្ឋាកចំពោះព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ រហូតដល់អស់ត្រៃមាសចុះ ។ ព្រះកុមារត្រាស់ថា ពួកលោកជាកល្យាណមិត្តរបស់យើង ដែលពិត យើងមានការគិតដូច្នោះ តែពួកលោកឲ្យកើតឡើងមុន យើងនឹងធ្វើយ៉ាងនោះ ហើយស្តេចទៅថ្វាយបង្គំព្រះបិតា កាលព្រះបិតាទ្រង់ក្រសោប ទ្រង់ថើបត្រង់ព្រះសីសៈហើយ ត្រាស់ថា បុត្តបិតាសូមឲ្យពរដល់បុត្ត ទើបក្រាបទូលថា បពិត្រព្រះមហារាជ ខ្ញុំព្រះអង្គប្រាថ្នានឹងឧបដ្ឋាកព្រះមានព្រះភាគដោយបច្ច័យ ៤ រហូតដល់អស់ត្រៃមាសធ្វើជីវិតមិនឲ្យមានទោស សូមព្រះអង្គទ្រង់ព្រះរាជទានពរនេះ ដល់ខ្ញុំព្រះអង្គចុះ ។

ព្រះរាជា. ត្រាស់ថា កូន បិតាមិនអាចនឹងឲ្យបាន ចូរកូនសូមវត្ថុដទៃចុះ ។

ព្រះកុមារ. ក្រាបទូលថា បពិត្រសម្មតិទេពដែលឈ្មោះថា ក្សត្រិយ៍ទាំងឡាយ រមែងមិនត្រាស់ពាក្យពីរ សូមព្រះអង្គមេត្តាព្រះរាជទានពរនេះឯង ខ្ញុំព្រះអង្គមិនមានសេចក្តីត្រូវការដោយវត្ថុដទៃ ។

ព្រះរាជា. ត្រាស់ថា កូន ព្រះទ័យរបស់ព្រះពុទ្ធទាំងឡាយដឹងបាន

លំបាក បើព្រះមានព្រះភាគទ្រង់នឹងមិនប្រាថ្នា សូម្បីកាលបិតាឲ្យពរទៅហើយ នឹងមានប្រយោជន៍អ្វី ។

ព្រះកុមារក្រាបទូលថា បពិត្រសម្មតិទេព ខ្ញុំព្រះអង្គនឹងដឹងព្រះទ័យរបស់ព្រះមានព្រះភាគ ដូច្នេះ ហើយស្ដេចទៅកាន់ព្រះវិហារ ។ វេលានោះព្រះមានព្រះភាគទ្រង់សម្រេចភត្តកិច្ចហើយ ស្ដេចចូលទៅកាន់ព្រះគន្ធកុដិ ។ ព្រះសុមនកុមារនោះ ស្ដេចបានទៅដល់សម្នាក់ពួកភិក្ខុដែលអង្គុយប្រជុំគ្នាក្នុងមណ្ឌប ។ ភិក្ខុទាំងនោះ ថ្វាយព្រះពរព្រះរាជកុមារនោះថា សូមថ្វាយព្រះពរ ព្រោះហេតុអ្វី ព្រះអង្គទើបស្ដេចមក (ទីនេះ) ។

ព្រះកុមារ. មកគាល់ព្រះមានព្រះភាគ សូមឲ្យលោកម្ចាស់មេត្តាសម្ដែងព្រះមានព្រះភាគដល់ខ្ញុំព្រះករុណាផង ។

ពួកភិក្ខុ. សូមថ្វាយព្រះពរ ពួកអាត្មាឲ្យព្រះអង្គគាល់ព្រះសាស្ដាក្នុងខណៈដែលព្រះអង្គទ្រង់មិនបំណាំងបានទេ ។

ព្រះកុមារ. លោកម្ចាស់ដ៏ចម្រើន អ្នកណាហ្ន៎ ឲ្យគាល់បាន ។

ពួកភិក្ខុ. សូមថ្វាយព្រះពរ ព្រះថេរៈឈ្មោះ សុមនៈ ។

ព្រះកុមារត្រាស់សួរដល់ទីកន្លែងរបស់ព្រះថេរៈថា លោកម្ចាស់ដ៏-

ចម្រើន ព្រះថេរៈនោះនៅទីណា ស្ដេចទៅសំពះព្រះថេរៈហើយ ត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំប្រាថ្នានឹងគាល់ព្រះមានព្រះភាគ សូមលោក-ម្ចាស់សម្ដែងព្រះមានព្រះភាគដល់ខ្ញុំផងចុះ ។ ព្រះថេរៈថ្វាយព្រះពរថា សូមថ្វាយព្រះពរ សូមព្រះអង្គចូរស្ដេចមកចុះ ហើយនាំព្រះកុមារទៅសម្រាកត្រង់បរិវេណព្រះគន្ធកុដិ ហើយឡើងទៅកាន់ព្រះគន្ធកុដិ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់សួរព្រះថេរៈនោះថា ម្នាលសុមនៈ ព្រោះហេតុអ្វី អ្នកទើបមក (ទីនេះ) ។

ព្រះថេរៈ. ព្រះរាជឱរស ស្ដេចមកគាល់ព្រះមានព្រះភាគ ព្រះអង្គ ។

ព្រះមានព្រះភាគ. ម្នាលភិក្ខុ បើដូច្នោះ អ្នកចូរក្រាលអាសនៈចុះ ។

ព្រះថេរៈក្រាលអាសនៈហើយ ព្រះមានព្រះភាគ ស្ដេចប្រថាប់លើអាសនៈដែលក្រាលហើយ ព្រះរាជឱរសថ្វាយបង្គំព្រះមានព្រះភាគ ហើយធ្វើបដិសណ្ឋារៈ ។

ព្រះមានព្រះភាគត្រាស់សួរថា សូមថ្វាយព្រះពរ ព្រះអង្គស្ដេចមកពីកាល ។

ព្រះរាជឱរស. មកកាលព្រះអង្គស្ដេចយាងចូលទៅកាន់ព្រះគន្ធកុដិ

ព្រះអង្គ ។ តែពួកភិក្ខុពោលថា ពួកអាត្មាឲ្យព្រះអង្គគាល់ព្រះមានព្រះភាគ ក្នុងខណៈដែលព្រះអង្គទ្រង់មិនបំណងបានទេ ហើយបង្គាប់ខ្ញុំព្រះអង្គទៅកាន់សម្នាក់ព្រះថេរៈ ព្រះថេរៈក៏បានសម្តែង (ឲ្យបានគាល់) ដោយពាក្យត្រឹមតែម្តងប៉ុណ្ណោះ ព្រះថេរៈឃើញទីងជាទីប្រោសប្រាណក្នុងព្រះសាសនារបស់ព្រះអង្គច្រើន ព្រះអង្គ ។

ព្រះមានព្រះភាគ. សូមថ្វាយព្រះពរ ត្រូវហើយ ភិក្ខុនេះជាទីប្រោស-ប្រាណក្នុងសាសនារបស់តថាគត ។

ព្រះរាជកុមារ. ធ្វើដូចម្តេច ទើបជាទីប្រោសប្រាណក្នុងព្រះសាសនារបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ព្រះអង្គ ។

ព្រះមានព្រះភាគ. សូមថ្វាយព្រះពរ ត្រូវឲ្យទាន សមាទានសីល រក្សាឧបោសថ ទើបទីងជាទីប្រោសប្រាណ ។

ព្រះរាជកុមារ. បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គប្រាថ្នាទីងជាទីប្រោសប្រាណក្នុងព្រះពុទ្ធសាសនា ដូចព្រះថេរៈដែរ សូមព្រះអង្គទ្រង់ទទួលនិមន្តអំពីខ្ញុំព្រះអង្គ នៅចាំវស្សារហូតអស់ត្រៃមាសផងចុះ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រួតមើលថា និងមានប្រយោជន៍ដោយការ

ទៅទេហ្ន៎ ទ្រង់ឃើញថា មាន ទើបត្រាស់ថា សូមថ្វាយព្រះពរ ព្រះតថាគត ទាំងឡាយ រមែងទ្រង់ត្រេកអរក្នុងផ្ទះស្ងាត់នោះឯង ។

ព្រះរាជកុមារ. ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គបាន ជ្រាបហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គបានជ្រាបហើយ ។ ទ្រង់កាន់យក ពាក្យប្តេជ្ញាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅមុន ហើយឲ្យសាង វិហារ កាលខ្ញុំព្រះអង្គបញ្ជូនដំណឹងមក សូមព្រះមានព្រះភាគចូរស្តេចមក ព្រមនឹងភិក្ខុ ១ សែនរូប ហើយស្តេចទៅកាន់សម្នាក់ព្រះបិតា ក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះមានព្រះភាគទ្រង់អនុគ្រោះដល់ខ្ញុំព្រះអង្គហើយ កាលខ្ញុំព្រះអង្គបញ្ជូនដំណឹងមក សូមមហារាជមេត្តាបញ្ជូនដំណឹងដល់ព្រះ-មានព្រះភាគផង ។ ថ្វាយបង្គំព្រះបិតាហើយ ស្តេចចេញទៅសាងវិហារក្នុង ទី ១ យោជន៍ ស្តេចទៅផ្លូវឆ្ងាយ ២,០០០ យោជន៍ លុះស្តេចដល់ហើយ ទ្រង់ជ្រើសរើសទីតាំងវិហារក្នុងព្រះនគររបស់ព្រះអង្គ ទ្រង់បានឃើញឧទ្យាន របស់កុដុម្ពីឈ្មោះសោភណៈ ទ្រង់ទិញដោយទ្រព្យ ១ សែន និងទ្រង់លះបង់ ទ្រព្យ ១ សែនឲ្យសាងវិហារ ។

ក្នុងឧទ្យាននោះ ព្រះរាជកុមារត្រាស់បង្គាប់ឲ្យសាងព្រះគន្ធកុដិសម្រាប់

ព្រះមានព្រះភាគ កុដិ និងមណ្ឌប ដើម្បីជាទីសម្រាកពេលយប់ និងពេលថ្ងៃសម្រាប់ពួកភិក្ខុ ទ្រង់សាងកំពែង និងខ្លោងទ្វារស្រេចហើយ ក៏បញ្ជូនដំណឹងទៅកាន់សម្នាក់ព្រះបិតាថា ការងាររបស់ខ្ញុំព្រះអង្គសម្រេចហើយ សូមឲ្យព្រះអង្គមេត្តាបញ្ជូនដំណឹងដល់ព្រះសាស្តាផង ។

ព្រះរាជាថ្វាយភត្តាហារព្រះមានព្រះភាគហើយ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ការងាររបស់សុមនកុមារសម្រេចហើយ សុមនកុមារប្រាថ្នាការស្តេចយាងទៅរបស់ព្រះមានព្រះភាគ ។

ព្រះមានព្រះភាគ ព្រមដោយភិក្ខុ ១ សែនរូបជាបរិវារ ស្តេចបានទៅប្រថាប់សម្រាកក្នុងវិហារក្នុងរយៈផ្លូវមួយយោជន៍ៗ ។

ព្រះរាជកុមារ ទ្រង់បានស្តាប់ដំណឹងថា ព្រះសាស្តាស្តេចកំពុងមកទ្រង់ក៏ទៅទទួលក្នុងរវាងផ្លូវ ១ យោជន៍ៗ ទ្រង់បូជាដោយរបស់ក្រអូប និងផ្កាឈើជាដើម អារាធនាឲ្យស្តេចចូលទៅកាន់វិហារ ហើយបានថ្វាយវិហារថា ៖

បពិត្រព្រះមហាមុនី សូមព្រះអង្គទ្រង់ទទួលឧទ្យានឈ្មោះ **សោភណៈ** ដែលខ្ញុំព្រះអង្គទិញដោយប្រាក់ ១ សែន សាងដោយប្រាក់ ១ សែន ។

ក្នុងថ្ងៃចូលវស្សា ព្រះរាជាថ្វាយទាន ទ្រង់ត្រាស់បង្គាប់ឲ្យព្រះឱរស និងព្រះមហេសីរបស់ព្រះអង្គ និងពួកអាមាត្រចូលគាល់ ហើយត្រាស់ថា ព្រះសាស្តាស្តេចមកពីទីឆ្ងាយ មកកាន់សម្នាក់របស់ពួកយើង ដែលឈ្មោះថា ព្រះពុទ្ធទាំងឡាយទ្រង់ជាអ្នកគោរពធម៌ ទ្រង់មិនឃើញដល់អាមិស ព្រោះដូច្នោះ ខ្ញុំនឹងស្លៀកសំពត់សាដក ២ ផ្ទាំង សមាទានសីល ១០ នៅត្រង់ទីនេះឯង រហូតដល់អស់ត្រៃមាសនេះ សូមឲ្យពួកអ្នកទាំងឡាយថ្វាយទានចំពោះព្រះខីណាស្រព ១ សែនរូប រហូតដល់អស់ត្រៃមាស ដោយទំនងនេះ ។

ព្រះរាជាប្រថាប់នៅក្នុងទីដែលមានចំណែកស្មើនឹងទីនៅ របស់ព្រះសុមនត្ថេរ បានទតឃើញវត្តគ្រប់យ៉ាងដែលព្រះថេរៈធ្វើថ្វាយដល់ព្រះមានព្រះភាគ ទើបទ្រង់ព្រះតម្រិះថា ព្រះថេរៈរូបនេះ នៅក្នុងឋានៈជាទីប្រោសប្រាណដោយចំណែកមួយ យើងគួរនឹងប្រាថ្នាឋានន្តរៈដូចព្រះថេរៈនេះឯង ។ កាលជិតបវារណា ស្តេចបានចូលកាន់ស្រុក ព្រះរាជទានមហាទានអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទ្រង់ដាក់ត្រៃចីវរចុះត្រង់ជិតជើងរបស់ភិក្ខុ ១ សែនរូប ថ្វាយបង្គំព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានធ្វើបុណ្យហើយ តាំងពីឲ្យសាងវិហារក្នុងរយៈផ្លូវមួយយោជន៍ៗ ។

ខ្ញុំព្រះអង្គមិនបានធ្វើបុណ្យនោះ ព្រោះប្រាថ្នាសម្បត្តិ គឺ ភាពជាស្តេចសក្ក-ទេវរាជ ទាំងមិនបានធ្វើព្រោះប្រាថ្នាមារសម្បត្តិ និងព្រហ្មសម្បត្តិឡើយ តែធ្វើព្រោះប្រាថ្នាភាពជាពុទ្ធុបដ្ឋាក បពិត្រព្រះមានព្រះភាគ ព្រោះដូច្នោះ សូមឲ្យខ្ញុំព្រះអង្គបានជាពុទ្ធុបដ្ឋាកដូចព្រះសុមនត្ថេរក្នុងអនាគតផងចុះ ដូច្នេះ ទ្រង់ក្រាបចុះ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។

ព្រះមានព្រះភាគទ្រង់ពិចារណាមើលថា ការគិតដ៏ធំក្រៃលែងរបស់កុលបុត្រនឹងសម្រេចឬទេហ្ន៎ ។ ទ្រង់ជ្រាបថា ក្នុងកប្បទីមួយសែន រាប់ពីកទ្រកប្បនេះទៅក្នុងអនាគត ព្រះពុទ្ធទ្រង់ព្រះនាមថា **គោតម** នឹងឧប្បត្តិឡើង ព្រះរាជកុមារនេះ នឹងបានជាឧបដ្ឋាកនៃព្រះគោតមនោះឯង ទើបត្រាស់ (ឲ្យពរ) ថា ៖

ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ សព្វេ

បូរេន្តុ សង្កប្បា ចន្ទោ បណ្ណរសោ យថា ។

សូមឲ្យវត្ថុដែលព្រះអង្គទ្រង់ប្រាថ្នាហើយ តាំងចិត្តហើយ

ចូរសម្រេចឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមឲ្យព្រះតម្រិះត្រូវ

ទាំងពួងចូរពេញ ដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី ដូច្នោះ ។

ព្រះកុមារទ្រង់បានស្តាប់ហើយ ទើបទ្រង់ត្រិះរិះថា ដែលឈ្មោះថា ព្រះពុទ្ធទាំងឡាយ រមែងមិនមានព្រះវាចាជាពីរ ក្នុងថ្ងៃទី ២ នុ៎ះឯង ទ្រង់ទទួលបាត្រ និងចីវររបស់ព្រះមានព្រះភាគហើយ បាន (តាម) ស្តេចមកពីខាងក្រោយៗ ។ ព្រះរាជាទ្រង់ឲ្យទានរហូតអស់សែនឆ្នាំក្នុងពុទ្ធប្បាទនោះ ទ្រង់កើតក្នុងស្ថានសួគ៌ សូម្បីក្នុងសម័យព្រះកស្សបសម្ពុទ្ធជាម្ចាស់ ក៏បានថ្វាយសំពត់ដណ្តប់ដើម្បីជាប្រយោជន៍ទ្របាត្រ ដែលព្រះថេរៈត្រាច់ប្រោសសត្វ ធ្វើការបូជាហើយ ទ្រង់កើតក្នុងស្ថានសួគ៌ទៀត ចុតិចាកស្ថានសួគ៌នោះ បានជាព្រះបាទក្រុងពារាណសី ទ្រង់ឲ្យសាងបណ្ណសាលាថ្វាយព្រះ-បច្ចេកពុទ្ធ ៨ អង្គ ទ្រង់តាំងជើងទ្របាត្រដោយកែវមណី ទ្រង់ធ្វើការទំនុកបម្រុងដោយបច្ច័យ ៤ រហូតអស់វេលា ១ ម៉ឺនឆ្នាំ ។ នេះជាឋានៈដែលប្រាកដ ។

ម្យ៉ាងទៀត កាលទ្រង់ឲ្យទានរហូតអស់សែនកប្ប ទ្រង់បានកើតក្នុងតុសិតបុរីជាមួយនឹងព្រះពោធិសត្វរបស់យើង ចុតិចាកតុសិតបុរីនោះហើយ ទ្រង់បដិសន្ធិក្នុងព្រះរាជនិវេសន៍របស់សក្យរាជ ទ្រង់ព្រះនាមថា **អមិតោទនៈ** កាលព្រះមានព្រះភាគទ្រង់ធ្វើមហាភិនេស្ក្រម៍ សម្រេចព្រះសម្មាសម្ពោធិ-

ញ្ញាណតាមលំដាប់ នឹងកាលស្តេចមកកាន់ក្រុងកបិលភស្តុគ្រាដំបូង ហើយស្តេចចេញចាកពីក្រុងកបិលភស្តុនោះ កាលព្រះរាជកុមារទាំងឡាយទ្រង់បព្វជ្ជា ដើម្បីជាបរិវាររបស់ព្រះមានព្រះភាគ ស្តេចបានចេញបួសជាមួយនឹងសក្យរាជព្រះនាមថា ភទ្ទិយៈជាដើម ក្នុងសម្នាក់ព្រះមានព្រះភាគ បានស្តាប់ធម្មកថាក្នុងសម្នាក់របស់ព្រះបុណ្ណមន្តានីបុត្រ បានតាំងនៅក្នុងសោតាបត្តិផលក្នុងកាលមិនយូរឡើយ ។ ព្រះអានន្ទនេះ ដល់ព្រមដោយឧបនិស្ស័យក្នុងកាលមុនយ៉ាងនេះ ។ បដិច្ចសមុប្បាទ សូម្បីជាធម៌ដ៏ជ្រាលជ្រៅ ក៏ប្រាកដដូចជាធម៌ងាយដល់លោក ព្រោះគុណសម្បត្តិ ដោយប្រការដូច្នេះ ។

ចំណែកការរៀន ការស្តាប់ ការសាកសួរ និងការទ្រទ្រង់ចាំក្នុងសម្នាក់របស់គ្រូទាំងឡាយ លោកហៅថា នៅជិតសាស្តា ។ ព្រះអានន្ទមានការរស់នៅដ៏បរិសុទ្ធិយ៉ាងក្រៃលែង ។ ដោយហេតុនោះ បដិច្ចសមុប្បាទសូម្បីជ្រាលជ្រៅ ក៏ប្រាកដដូចជាធម៌ងាយដល់លោក ។ ឯព្រះសោតាបន្នទាំងឡាយ បច្ចយាការប្រាកដជាធម៌ងាយ ។ ព្រះអានន្ទនេះ ក៏ជាព្រះសោតាបន្ន ការកំណត់នាមរូប រមែងប្រាកដដល់អ្នកបានឮ បានស្តាប់ច្រើន ដូចប្រទីបឆេះបំភ្លឺក្នុងបន្ទប់ ៤ ហត្ថ គ្រែ និងតាំងក៏ប្រាកដ ដូច្នោះ ព្រះអានន្ទ

ក៏ជាកំពូលនៃបុគ្គលជាពហុស្សុតទាំងឡាយ ព្រោះហេតុនោះ បច្ចយាការសូម្បីជាធម៌ជ្រាលជ្រៅ ក៏ប្រាកដដូចជាធម៌ងាយសម្រាប់លោក ព្រោះភាពជាពហុស្សុត ។

បដិច្ចសមុប្បាទ ជាធម៌ជ្រាលជ្រៅ ព្រោះសេចក្តីជ្រាលជ្រៅ ៤ ប្រការ និងសេចក្តីជ្រាលជ្រៅនៃបដិច្ចសមុប្បាទនោះ លោកពោលទុកពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។ សេចក្តីជ្រាលជ្រៅសូម្បីទាំងអស់នោះប្រាកដដូចជាធម៌ងាយសម្រាប់ព្រះអានន្ទត្ថេរ ដោយហេតុនោះ ព្រះមានព្រះ-ភាគ កាលនឹងធ្វើឲ្យព្រះអានន្ទត្ថេរកអរ ទើបត្រាស់ថា **មាហេវំ** ជាដើម ។ ក៏ក្នុងព្រះបាលីនោះ មានអធិប្បាយដូច្នេះ ម្នាលអានន្ទ អ្នកមានបញ្ញាច្រើនមានញាណជាក់ច្បាស់ ដោយហេតុនោះ បដិច្ចសមុប្បាទសូម្បីជាធម៌ជ្រាលជ្រៅ ក៏រមែងប្រាកដដូចជាធម៌ងាយសម្រាប់អ្នក ព្រោះដូច្នោះ អ្នកកុំពោលយ៉ាងនេះថា បដិច្ចសមុប្បាទនេះ ប្រាកដជាធម៌ងាយសម្រាប់យើងឬហ្ន៎ ឬថាងាយសម្រាប់អ្នកដទៃផង ។ តែព្រះអានន្ទត្ថេរនៅមិនត្រេកអរដោយពាក្យដែលព្រះមានព្រះភាគត្រាស់ហើយ យ៉ាងណា ក្នុងសេចក្តីនោះ មានអធិ-ប្បាយដូច្នេះថា ម្នាលអានន្ទ អ្នកកុំគប្បីពោលយ៉ាងនេះថា បដិច្ចសមុប្បាទ

ប្រាកដដូចជាធម៌ងាយៗ សម្រាប់យើង ក៏បើបដិច្ចសមុប្បាទនេះ ប្រាកដដូចជាធម៌ងាយៗ សម្រាប់អ្នកសោត ព្រោះហេតុអ្វី អ្នកទើបមិនបានជាព្រះសោតាបន្នតាមធម្មតារបស់ខ្លួនឯង តែអ្នកបានតាំងនៅក្នុងន័យដែលតថាគតឲ្យហើយ ទើបចាក់ធ្លុះសោតាបត្តិមគ្គ ម្នាលអានន្ទ ព្រះនិព្វាននេះប៉ុណ្ណោះ ជ្រាលជ្រៅ ។ ចំណែកបច្ចយាការជាធម៌ងាយ លុះកើតហើយព្រោះហេតុអ្វី អ្នកទើបមិនដកឡើងនូវកិលេស ៤ ទាំងនេះ គឺ កាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដែលគ្រោតគ្រាត កាមរាគានុស័យ បដិឃានុស័យដែលគ្រោតគ្រាត ហើយធ្វើឲ្យច្បាស់នូវសកទាគាមិផល មិនដកឡើងនូវកិលេស ៤ ដែលអាស្រ័យសញ្ញោជនៈ និងអនុស័យទាំងនោះហើយធ្វើអនាគាមិផលឲ្យជាក់ច្បាស់ មិនដកឡើងនូវកិលេស ៨ ទាំងនេះ គឺ សញ្ញោជនៈ ៥ មានរូបរាគៈជាដើម មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ហើយធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត ឬថា ព្រោះហេតុអ្វីទើបមិនចាក់ធ្លុះសាវកបារមីញាណ ដូចព្រះសារីបុត្រ និងព្រះមហាមោគ្គល្លាន ដែលបានបំពេញបារមីអស់ ១ អសង្ខេយ្យក្រៃលែងដោយសែនកប្បមិនចាក់ធ្លុះបច្ចេកពោធិញ្ញាណ ដូចព្រះបច្ចេកពុទ្ធទាំងឡាយ ដែលបានបំពេញ

បារមីអស់ ២ អសង្ខេយ្យក្រៃលែងដោយសែនកប្ប ។ ម្យ៉ាងទៀត បើបដិច្ចសមុប្បាទនេះ ប្រាកដជាធម៌ងាយដោយប្រការទាំងពួង ចំពោះអ្នកសោត បើដូច្នេះ ព្រោះហេតុអ្វី អ្នកទើបមិនធ្វើឲ្យច្បាស់នូវព្រះសព្វញ្ញុតញ្ញាណ ដូចព្រះពុទ្ធទាំងឡាយ ដែលបានទ្រង់បំពេញអស់ព្រះបារមី ៤ អសង្ខេយ្យ ក្រៃលែងដោយសែនកប្បខ្លះ ៨ អសង្ខេយ្យខ្លះ ១៦ អសង្ខេយ្យខ្លះ អ្នកមិនមានសេចក្តីត្រូវការដោយធម៌ ជាគ្រឿងសម្រេចគុណពិសេសទាំងនេះ ឬ ។ អ្នកចូរឃើញថា ត្រឹមតែជាការគិតខុសរបស់អ្នក អ្នកឈ្មោះថា ជាអ្នកតាំងនៅក្នុងសាវកបទេសញ្ញាណ បានពោលដល់បច្ចយាការដ៏ជ្រាលជ្រៅក្រៃលែងថា ប្រាកដជាងាយសម្រាប់យើង ពាក្យនិយាយដូច្នេះរបស់អ្នកនោះ ជាសត្រូវចំពោះព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ ប្រការដែលភិក្ខុនោះគប្បីពោលពាក្យដែលជាសត្រូវចំពោះព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ ជាការមិនសមគួរ ។ ម្នាលអានន្ទ កាលតថាគតព្យាយាមដើម្បីចាក់ធ្លុះបច្ចយាការនេះ ឈ្មោះថា ការឲ្យទានដែលមិនធ្លាប់ឲ្យ ដើម្បីប្រយោជន៍ដល់ការចាក់ធ្លុះបច្ចយាការ រមែងមិនមានដល់តថាគត រហូតអស់ ៤ អសង្ខេយ្យមួយសែនកប្ប ។ ដែលឈ្មោះថា អ្នកមិនបានបំពេញបារមី រមែងមិនមាន ។ នឹង

កាលតថាគតកម្ចាត់ពលរបស់មារ ដូចជាថាឲ្យអស់សេចក្តីព្យាយាមដោយគិតថា យើងនឹងចាក់ធ្លុះបច្ចយាការក្នុងថ្ងៃនេះ មហាប្រថពីនេះ ក៏មិនបានញាប់ញ័រសូម្បីត្រឹមតែ ២ អង្គុលី ។ ម្យ៉ាងទៀត កាលតថាគតញុំាងបុព្វេនិវាសានុស្សតិញ្ញាណឲ្យដល់ព្រមក្នុងបឋមយាម និងញុំាងទិព្វចក្ខុញ្ញាណឲ្យដល់ព្រមក្នុងមជ្ឈិមយាម ចំណែកក្នុងបច្ឆិមយាម ដោយត្រឹមតែឃើញថា អវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ដោយអាការ ៩ យ៉ាង ដូច្នេះ ក្នុងវេលាព្រឹកព្រលឹម លោកធាតុនេះ បន្លឺសំឡេងទាំងរយទាំងពាន់ ដូចរគាំងត្រូវគោះដោយកំណាត់ឈើ បានញាប់ញ័រហើយ ដូចតំណក់ទឹកលើស្លឹកឈូកដែលត្រូវខ្យល់បក់ ដូច្នោះ ម្នាលអានន្ទ បដិច្ចសមុប្បាទនេះ ទាំងជ្រាលជ្រៅ ទាំងមានក្រសែជ្រាលជ្រៅ ដោយប្រការដូច្នេះ ម្នាលអានន្ទ ព្រោះមិនដឹងធម៌នេះ ។ល។ សត្វទាំងឡាយ រមែងមិនកន្លងផុតអបាយ ទុគ្គតិ វិនិបាត សង្សារ ។

បទថា **ឯតស្ស ធម្មស្ស** ធម៌នេះ បានដល់ ធម៌ដែលជាបច្ច័យនៃធម៌នេះ ។ បទថា **អននុពោធា** ព្រោះមិនដឹង បានដល់ ព្រោះមិនត្រាស់ដឹងដោយអំណាចញាតបរិញ្ញា ( ការកំណត់ដឹងវត្ថុដែលខ្លួនដឹងហើយ ) ។

បទថា **អប្បដិវេធា** ព្រោះមិនចាក់ធ្លុះ បានដល់ ព្រោះមិនចាក់ធ្លុះដោយអំណាចតីរណបរិញ្ញា (ការកំណត់ដឹងដោយការពិចារណា) និងបហានបរិញ្ញា (ការកំណត់ដឹងដោយការលះបង់) ។ បទថា **តន្តាកុលជាតា** ប្រែថា ដូចជាសរសៃអំបោះដែលជំពាក់ ។ ព្រោះថា អំបោះរបស់ជាងតម្បាញដែលរក្សាទុកមិនល្អ ត្រូវកណ្ដុរខាំដាច់ ទើបជំពាក់ក្នុងទីនោះៗ ការដែលចាត់ចែងឲ្យចុងស្មើចុង ឲ្យគល់ស្មើគល់ថា នេះគល់ នេះចុង រមែងធ្វើបានលំបាក យ៉ាងណា សត្វទាំងឡាយដែលសោប់សល់ ខ្វល់ខ្វាយ ច្របូកច្របល់ក្នុងបច្ច័យការនេះ ក៏យ៉ាងនោះដូចគ្នា មិនអាចនឹងធ្វើបច្ចយាការឲ្យប្រាកដបាន ។ អ្នកដែលតាំងនៅក្នុងសេចក្ដីគោរពរាប់អាននៃបុរសចំពោះខ្លួន គប្បីជាអ្នកអាចធ្វើឧទាហរណ៍ក្នុងបច្ចយាការនោះឲ្យប្រាកដបាន ។ ក្រៅអំពីព្រះពោធិសត្វទាំងពីរ សត្វដទៃឈ្មោះថា ជាអ្នកអាចធ្វើបច្ចយាការឲ្យប្រាកដតាមធម្មតារបស់ខ្លួន រមែងមិនមាន ព្រោះថា សរសៃអំបោះដែលជំពាក់ ដែលគេឲ្យបាយហើយ យកតាំង (កៅអី) សង្កត់ រមែងនឹងកើតជាដុំជាប់គ្នាជាវមូរក្នុងទីបំផុត យ៉ាងណា សត្វទាំងនេះក៏ដូច្នោះ វង្វេងក្នុងបច្ច័យហើយ មិនអាចធ្វើបច្ច័យឲ្យប្រាកដ ទើបកើតជាក្រុមជាប់គ្នាជាចំណង

ដោយអំណាចនៃទិដ្ឋិ ៦២ ។ ក៏ជនពួកណាមួយអាស្រ័យទិដ្ឋិ ពួកជនទាំងអស់នោះ មិនអាចធ្វើបច្ច័យឲ្យប្រាកដបានឡើយ ។ អំបោះដែលជាប់ជំពាក់របស់ជាងតម្បាញ ហៅថា ដុំសរសៃអំបោះចំពាក់ ក្នុងពាក្យថា **គុឡីគុណ្ឋិកជាតា** ។

សំបុកសត្វ ឈ្មោះថា **គុឡា** ។ អាចារ្យពួកខ្លះពោលថា សំបុករបស់ជន្លេនទាង ដូច្នេះក៏មាន ។ អំបោះដែលជំពាក់ និងសំបុកជន្លេនទាងទាំងពីរនោះ ក៏រាប់ថា ជាប់ជំពាក់ ។ ការនឹងធ្វើឲ្យចុងស្មើចុង ឲ្យគល់ស្មើគល់ ជាការធ្វើបានលំបាក ។ ព្រោះដូច្នោះ សេចក្តីនោះ គប្បីប្រកបបចូលដោយន័យមុនទុំះឯង ។

បទថា **មុញ្ជបព្វជភូតា** បានដល់ ដូចជាស្មៅជំណោកទន្សាយ ស្មៅយ៉ាប្លង គឺ កើតដូច្នោះ ។ ការកាន់យកវត្ថុដែលធ្លាក់ទៅក្នុងទីណាមួយក្នុងវេលាខ្សែដែលគេវិញដោយស្មៅទាំងនោះ ធ្វើដាច់ ហើយចាត់ឲ្យចុងស្មើចុង ឲ្យគល់ស្មើគល់ថា នេះគឺ ចុង នេះគឺ គល់ របស់ស្មៅទាំងនោះជាវត្ថុធ្វើបានលំបាក បុគ្គលតាំងនៅក្នុងសេចក្តីគោរពសក្ការៈនៃបុរសចំពោះខ្លួន គប្បីជាអ្នកអាចធ្វើ (បច្ចយាការ) ឲ្យប្រាកដបាន ក្រៅអំពីព្រះពោធិសត្វ

ទាំងពីរ សត្វដទៃឈ្មោះថា ជាអ្នកអាចធ្វើបច្ចយាការឲ្យប្រាកដ រមែងមិនមាន យ៉ាងណា ពួកសត្វនេះ ក៏ដូច្នោះ មិនអាចធ្វើបច្ច័យឲ្យប្រាកដបាន ដូចជាដុំសរសៃអំបោះដែលជំពាក់ ទើបមិនកន្លងផុតអបាយ ទុគតិ វិនិបាត សង្សារ ដោយអំណាចទិដ្ឋិ ។

ក្នុងសេចក្ដីនោះ នរក កំណើតតិរច្ឆាន បេតវិស័យ និងអសុរកាយ ឈ្មោះថា **អបាយ** ។ ព្រោះដូច្នោះ អបាយសូម្បីទាំងអស់នោះ ហៅថា **អបាយ** ព្រោះមិនមានការប្រព្រឹត្តទៅ ពោលគឺ សេចក្ដីចម្រើន ។ មួយទៀត ដែលហៅថា **ទុគ្គតិ** ព្រោះមានការប្រព្រឹត្តទៅនៃទុក្ខ ដែលហៅថា **វិនិបាត** ព្រោះការកើតឡើងនៃសុខបានធ្លាក់ចុះទៅហើយ ចំណែកក្រៅពីនេះ ហៅថា **សង្សារ** ព្រោះខន្ធ ធាតុ និងអាយតនៈ នៅប្រព្រឹត្តទៅតាមលំដាប់មិនដាច់ខ្សែ ពួកសត្វ រមែងមិនកន្លងផុត គឺ មិនឈានកន្លងទុក្ខសូម្បីទាំងអស់នោះ សេចក្ដីពិត ពួកសត្វកាន់យកចុតិ និងបដិសន្ធិរឿយៗ យ៉ាងនេះ គឺ អំពីចុតិ ក៏បដិសន្ធិ អំពីបដិសន្ធិ ក៏ចុតិ ទើបត្រូវវិលវល់ក្នុងភព ៣ ក្នុងកំណើត ៤ ក្នុងគតិ ៥ ក្នុងវិញ្ញាណឋិតិ ៧ ក្នុងសត្តាវាស ៩ ដូចទូកដែលត្រូវខ្យល់បក់ទៅក្នុងមហាសមុទ្រ និងដូចគោទឹមដោយគ្រឿង

យន្ត ដូច្នោះ ។

ព្រះមានព្រះភាគ ទ្រង់មិនបៀតបៀនព្រះអានន្ទ ទើបត្រាស់សេចក្តីនេះទាំងអស់ ដោយប្រការដូច្នេះ ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ មានន័យដូចពោលហើយនោះឯង ។

ចប់អដ្ឋកថា និទានសូត្រទី ១០

## ចប់ទុក្ខវគ្គទី ៦

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថាបរិវីមង្សនសូត្រ ២-អដ្ឋកថាឧបាទានសូត្រ
៣-អដ្ឋកថាបឋមសំយោជនសូត្រ ៤-អដ្ឋកថាទុតិយសំយោជនសូត្រ
៥-អដ្ឋកថាបឋមមហារុក្ខសូត្រ ៦-អដ្ឋកថាទុតិយមហារុក្ខសូត្រ
៧-អដ្ឋកថាតរុណរុក្ខសូត្រ ៨-អដ្ឋកថានាមរូបសូត្រ
៩-អដ្ឋកថាវិញ្ញាណសូត្រ ១០-អដ្ឋកថានិទានសូត្រ

# មហាវគ្គទី ៧

## អ ដ្ឋ ក ថា

### អស្សុតវតាសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុងអស្សុតវតាសូត្រទី ១ នៃមហាវគ្គតទៅ ។

[២៣០] បទថា **អស្សុតវា** អ្នកមិនបានស្តាប់ បានដល់ អ្នកវៀរចាកការរៀន ការសាកសួរ និងការវិនិច្ឆ័យ ក្នុងខន្ធ ធាតុ អាយតនៈ បច្ចយាការ និងសតិប្បដ្ឋានជាដើម ។ បទថា **បុថុជ្ជនោ** បុថុជ្ជន បានដល់ ឈ្មោះថា បុថុជ្ជន ព្រោះហេតុដែលញ៉ាំងកិលេសដ៏ច្រើនជាដើមឲ្យកើត ។ ពិតណាស់ លោកពោលពាក្យនេះទុកថា ឈ្មោះថា បុថុជ្ជន ព្រោះញ៉ាំងកិលេសដ៏ក្រាស់ឲ្យកើត ។ សេចក្តីទាំងពួងនោះ គប្បីធ្វើឲ្យពិស្តារ ។ម្យ៉ាងទៀត ឈ្មោះថា **បុថុជ្ជន** ព្រោះធ្លាក់ចុះខាងក្នុងរបស់ពួកជនចំនួនច្រើន គឺរាប់មិនបាន បែរខ្នងឲ្យអរិយធម៌ ប្រព្រឹត្តធម៌អាក្រក់ ម្យ៉ាងទៀត បុគ្គលនេះឈ្មោះថា បុថុ ព្រោះដល់ការរាប់ទុកមួយផ្នែក ឈ្មោះថា ជន ព្រោះបែកពីព្រះអរិយៈអ្នកប្រកបដោយគុណ មានសីល និងសុតៈជាដើម ដូច្នោះ ទើប

ឈ្មោះថា **បុថុជ្ជន** ។ ដោយបទទាំងពីរ គឺ **អស្សុតវា បុថុជ្ជនោ** ដូចពោល ហើយនេះ លោកកាន់យកអន្ធបុថុជ្ជន ក្នុងចំនួនបុថុជ្ជន ២ ពួក ដែលព្រះ-មានព្រះភាគអ្នកមានផៅពង្សព្រះអាទិត្យត្រាស់ទុកថា បុថុជ្ជនមាន ២ ពួក គឺ អន្ធបុថុជ្ជន ១ កល្យាណបុថុជ្ជន ១ ។ ដោយបទថា **ឥមស្មឹ** ព្រះមាន-ព្រះភាគទ្រង់សម្តែងកាយដែលឃើញប្រចក្សក្នុងបច្ចុប្បន្ន ។ បទថា **ចាតុ-ម្មហាភូតិកស្មឹ** ប្រែថា ក្នុងកាយដែលជាទីប្រជុំនៃមហាភូតរូប ៤ ។ អធិ-ប្បាយថា កើតពីមហាភូតរូប ៤ ឈ្មោះថា សម្រេចពីមហាភូតរូប ៤ បទថា **និព្វិន្ទេយ្យ** ប្រែថា គប្បីនឿយនាយ ។ បទថា **វិរជ្ជេយ្យ** ប្រែថា មិនគប្បីត្រេកអរ ។ បទថា **វិមុច្ចេយ្យ** ប្រែថា គប្បីជាអ្នកប្រាថ្នានឹងរួចផុត ។

បទថា **អាចយោ** ប្រែថា សេចក្តីចម្រើន ។ បទថា **អបចយោ** ប្រែថា សេចក្តីសាបសូន្យ ។ បទថា **អាទានំ** ប្រែថា ការកើត ។ បទថា **និក្ខេបនំ** ប្រែថា ការបែកធ្លាយ ។ បទថា **តស្មា** បានដល់ ព្រោះហេតុដែលមហាភូតរូប ៤ ទាំងនេះ រមែងប្រាកដ ព្រោះមានសេចក្តីចម្រើន សេចក្តីសាបសូន្យ ការកើត និងការបែកធ្លាយ ។ អធិប្បាយថា ព្រោះហេតុនោះព្រះមានព្រះភាគទ្រង់ធ្វើរូបដែលមិនបានប្រកប (ក្នុងការ) ដើម្បីកំណត់រូបក្នុង

កាយដែលជាទីប្រជុំនៃមហាភូតរូប ៤ ហើយទ្រង់ធ្វើរូបដែលប្រកបក្នុងកាយ ដើម្បីកំណត់ថា មិនមានរូប ។ ព្រោះហេតុអ្វី ។ ព្រោះថា ការប្រកាន់មាំក្នុងរូបរបស់ភិក្ខុទាំងនោះ មានកម្លាំងហួសប្រមាណ ។ ដោយហេតុនោះ ព្រះមានព្រះភាគទ្រង់សម្តែងការប្រកាន់មាំក្នុងរូបរបស់ភិក្ខុទាំងនោះថា ជារូបដែលមិនគួរកំណត់កាល នឹងទ្រង់នាំចេញ ទើបត្រាស់យ៉ាងនោះ ដើម្បីទ្រង់តាំងទុកក្នុងការមិនមានរូប ។ ពាក្យទាំងពួងមាន **ចិត្តំ** ជាដើម ជាឈ្មោះរបស់មនាយតនៈនុ៎ះឯង ។ ក៏មនាយតនៈនោះ ហៅថា **ចិត្ត** ព្រោះជាទីតាំងនៃចិត្ត ព្រោះជាគោចរនៃចិត្ត ព្រោះមានចិត្តជាសម្បយុត្តធម៌ ហៅថា **មនៈ** ព្រោះអត្ថថា បង្អោនទៅ និងហៅថា **វិញ្ញាណ** ព្រោះអត្ថថា ដឹងច្បាស់ ។ បទថា **នាលំ** ប្រែថា មិនអាច ។ បទថា **អជ្ឈោសិតំ** ប្រែថា ត្រូវតណ្ហាលេប គឺ រួបរឹតទុក ។ បទថា **មមាយិតំ** បានដល់ ប្រកាន់ថា នេះរបស់យើង ដោយការប្រកាន់ថា ជារបស់យើងដោយអំណាចតណ្ហា ។ បទថា **បរាមដ្ឋំ** បានដល់ ត្រូវទិដ្ឋិប្រកាន់ ដោយប្រការដទៃ (ក្រៅព្រះពុទ្ធសាសនា) ។ ពាក្យថា **ឯតំ មម** នុ៎ះរបស់យើង ជាការប្រកាន់ដោយអំណាចតណ្ហា ។ សេចក្តីវិបរិតនៃតណ្ហា ១០៨ ជាការកាន់យកដោយពាក្យនោះ ។ បទថា

**ឯសោហមស្មិ** ជាការប្រកាន់ដោយអំណាចមានះ ។ មានះ ៩ ក៏កាន់យកផងដោយពាក្យនោះ ។ បទថា **ឯសោ មេ អត្តា** នោះ គឺ ខ្លួនរបស់យើង ជាការប្រកាន់ដោយអំណាចទិដ្ឋិ ។ ទិដ្ឋិ ៦២ ជាការកាន់យកដោយពាក្យនោះ ។ បទថា **តស្មា** បានដល់ ព្រោះប្រកាន់រូបនេះទុករហូតអស់កាលយូរ ដូច្នោះ ទើបមិនអាចនឹងនឿយណាយបាន ។

[២៣១] សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបត្រាស់ពាក្យថា **វរំ ភិក្ខវេ** នេះ ។

ឆ្លើយថា ព្រោះរូបទី ១ ភិក្ខុនោះធ្វើឲ្យជារូបដែលមិនសមគួរនឹងកំណត់ ធ្វើអរូបឲ្យជារូបដែលសមគួរ កាលដូច្នេះ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ភិក្ខុទាំងនោះចេញចាកការប្រកាន់រូប ប្រកាន់អរូប ដូច្នេះ ទើបទ្រង់ប្រារព្ធព្រះទេសនានេះ ដើម្បីទ្រង់ទាញចេញពីការប្រកាន់នោះ ។

បណ្តាបទទាំងនោះ បទថា **អត្តតោ ឧបគច្ឆេយ្យ** សេចក្តីថា គប្បីប្រកាន់ថា ជាអត្តា ។ បទថា **ភិយ្យោបិ** សេចក្តីថា សូម្បីនឹងលើសពី ១០០ ឆ្នាំឡើងទៅ ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបត្រាស់យ៉ាងនោះ ដែលឈ្មោះថា រូបតាំងនៅលើសពី ១០០ ឆ្នាំ មានឬ ។ រូបដែល

ប្រព្រឹត្តទៅក្នុងបឋមវ័យ នៅមិនដល់មជ្ឈិមវ័យ , រូបដែលប្រព្រឹត្តទៅក្នុងមជ្ឈិមវ័យ នៅមិនដល់បច្ឆិមវ័យ , រូបដែលប្រព្រឹត្តទៅមុនអាហារ នៅមិនដល់ក្រោយអាហារ , រូបដែលប្រព្រឹត្តទៅក្រោយអាហារ នៅមិនដល់បឋមយាម , រូបដែលប្រព្រឹត្តទៅក្នុងបឋមយាម នៅមិនដល់មជ្ឈិមយាម , រូបដែលប្រព្រឹត្តទៅក្នុងមជ្ឈិមយាម នៅមិនដល់បច្ឆិមយាម , មានមែនឬ ម្យ៉ាងទៀត រូបដែលប្រព្រឹត្តទៅក្នុងវេលាដើរ នៅមិនដល់វេលាឈរ , រូបដែលប្រព្រឹត្តទៅក្នុងវេលាឈរ នៅមិនដល់វេលាអង្គុយ , រូបដែលប្រព្រឹត្តទៅក្នុងវេលាអង្គុយ នៅមិនដល់វេលាដេក ។ សូម្បីក្នុងឥរិយាបថមួយ រូបដែលប្រព្រឹត្តទៅក្នុងវេលាលើកជើង នៅមិនដល់ដាក់ជើង , រូបដែលប្រព្រឹត្តទៅក្នុងវេលាដាក់ជើង នៅមិនដល់វេលាឈាន , រូបដែលប្រព្រឹត្តទៅក្នុងវេលាឈាន នៅមិនដល់វេលាទម្លាក់ជើងចុះ , រូបដែលប្រព្រឹត្តទៅក្នុងវេលាទម្លាក់ជើងចុះ នៅមិនដល់វេលាជាន់ផែនដី , រូបប្រព្រឹត្តទៅក្នុងវេលាជាន់ផែនដី នៅមិនទាន់ដល់វេលាផ្តល់ផែនដី ។ សង្ខារទាំងឡាយធ្វើសំឡេង តដៈ តដៈ លាន់ឮដោយផ្នែកៗ ក្នុងទីនោះៗ ដូចល្ងដែលគេដាក់ចុះក្នុងភាជនៈក្តៅ ដូច្នោះឬ? ។ ឆ្លើយថា ប្រការនោះ រមែងពិតយ៉ាងនោះ ។

ដូចកាលប្រទីបកំពុងឆេះ អណ្តាតភ្លើង មិនឆេះកន្លងចំណែកនៃប្រឆេះនោះៗ រមែងបែកក្នុងទីនោះៗ ឯង កាលប្រទីបកំពុងឆេះអស់មួយយប់ដល់ព្រឹក ដោយអំណាចការបន្ត លោកក៏ហៅថា ប្រទីប យ៉ាងណា សូម្បីក្នុងទីនេះ កាយនេះ លោកសម្តែងឲ្យដូចជាការតាំងនៅអស់កាលយូរ យ៉ាងនោះ ដោយអំណាចការបន្ត ក៏ដូច្នោះ ។

ក៏បទថា **រត្តិយា ច ទិវសស្ស ច** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ បទថា **អញ្ញទេវ ឧប្បជ្ជតិ អញ្ញំ និរុជ្ឈតិ** សេចក្តីថា ចិត្តកើតឡើង និងរលត់ទៅក្នុងវេលាយប់ ចិត្តដួងដទៃក្រៅអំពីចិត្តដួងនោះឯង រមែងកើតឡើង និងរលត់ទៅក្នុងពេលថ្ងៃ ។ តែមិនគួរកាន់យកអត្ថយ៉ាងនេះថា ចិត្តដួងដទៃកើតឡើង ចិត្តដួងដទៃដែលមិនទាន់កើតឡើងនុ៎ះឯង រមែងរលត់ទៅ ។ បទថា **រត្តិយា ច ទិវសស្ស ច** នេះ លោកកាន់យកការបន្តដែលតិចជាងការបន្តពីដើម ហើយពោលអំពីអំណាចការបន្តនុ៎ះឯង ។ ក៏ចិត្តដួងតែមួយប៉ុណ្ណោះឈ្មោះថា អាចតាំងនៅអស់យប់មួយ ឬថ្ងៃមួយរមែងមិនមាន ។ ពិតណាស់ ក្នុងខណៈផ្ទាត់ម្រាមដៃមួយ ចិត្តកើតឡើងច្រើនសែនកោដិដួង សមដូចពាក្យដែលលោកពោលទុកក្នុងមិលិន្ទប្បញ្ហាថា មហា

បពិត្រ ស្រូវ ១០០ វាហៈ ១ និក្ខៈ[១] ៧ សត្ត[២] និង ២ នាឡិ ក៏មិនដល់ការរាប់ គឺ មិនដល់ចំរៀក មិនដល់ចំណែកនៃចំរៀកនៃចិត្តដែលប្រព្រឹត្តទៅក្នុងខណៈមួយផ្ទាត់ម្រាមដៃម្តង ។

[២៣២] បទថា **ព្រហាវនេ** ប្រែថា ព្រៃធំ ។ ដោយពាក្យថា **តំ មុញ្ចិត្វា អញ្ញំ គណ្ហាតិ តំ មុញ្ចិត្វា គណ្ហាតិ** ទ្រង់សម្តែងសេចក្តីទុកដូច្នេះថា ស្វានោះមិនបានមែកឈើដែលនឹងគប្បីចាប់ ក៏មិនចុះកាន់ផែនដី ដោយពិត ត្រាច់នៅក្នុងព្រៃធំនោះចាប់យកតែមែកឈើនោះៗ ត្រាច់ទៅប៉ុណ្ណោះ ។ ក្នុងបទថា **ឯវមេវ ខោ** នេះ មានឧបមាជាគ្រឿងប្រៀបធៀបដូចតទៅនេះ ពិតណាស់ ព្រៃដែលកាន់យកជាអារម្មណ៍ គប្បីជ្រាបដូចព្រៃធំក្នុងព្រៃ ចិត្តដែលកើតឡើងក្នុងព្រៃ គឺ អារម្មណ៍ គប្បីជ្រាបដូចស្វាដែលត្រាច់ទៅក្នុងព្រៃនោះ ការបានអារម្មណ៍ ដូចការចាប់មែកឈើ ។ ស្វានោះត្រាច់ទៅក្នុងព្រៃព្រលែងមែកឈើនោះៗ ហើយចាប់មែកឈើនោះៗ យ៉ាងណា សូម្បីចិត្តនេះក៏ដូច្នោះ ត្រាច់ទៅក្នុងព្រៃ គឺ អារម្មណ៍ ពេលខ្លះកាប់យករូបារម្មណ៍កើតឡើង ពេលខ្លះកាន់យកអារម្មណ៍ មានសទ្ទារម្មណ៍ជាដើមណាមួយ ពេល

១-២ ជាមាត្រារង្វាល់សម័យដើម ។

ខ្លះកាន់យកអតីតារម្មណ៍ ឬអនាគតារម្មណ៍ ពេលខ្លះកាន់យកបច្ចុប្បន្នារម្មណ៍ ពេលខ្លះកាន់យកអារម្មណ៍ខាងក្នុង ឬអារម្មណ៍ខាងក្រៅ ។ ដូចស្វានោះត្រាច់ទៅក្នុងព្រៃមិនបានមែកឈើ មិនគប្បីពោលថា នឹងចុះលើភាគផែនដី ។ តែចាប់យកមែកឈើណាមួយហើយអន្ទុយ យ៉ាងណា សូម្បីចិត្តក៏ដូច្នោះ ត្រាច់ទៅក្នុងព្រៃ គឺ អារម្មណ៍ មិនគប្បីពោលថា មិនបានអារម្មណ៍ដែលប្រកាន់ស្អិតណាមួយកើតឡើង តែគប្បីជ្រាបថា ក្នុងការកើតឡើងមួយគ្រាចិត្តកាន់យកអារម្មណ៍ហើយ ទើបកើតឡើង ។ ក៏ដោយលំដាប់ពាក្យត្រឹមប៉ុណ្ណេះ គឺ ព្រះមានព្រះភាគទ្រង់នាំចេញចាករូបហើយ ឲ្យតាំងការកាន់យកក្នុងអរូប នាំចេញចាកអរូបឲ្យតាំងក្នុងរូប ។

[២៣៣] ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ព្រះបំណងនឹងចែករូបនោះចេញជា ២ ចំណែក ទើបផ្តើមសម្តែងថា **តត្រ ភិក្ខវេ សុតវា អរិយសាវកោ** គប្បីជ្រាបសេចក្តីឧបមាគ្រាបុរសអ្នកត្រូវពស់ពិសខាំដូចតទៅនេះ ៖

បានឮថា បុរសម្នាក់ត្រូវពស់ពិសខាំ ។ លំដាប់នោះគ្រូដ៏ឆ្លាតម្នាក់មកដោយបំណងថា នឹងដកពិសពស់នោះចេញ ហើយបន្សាបពិស រាយមន្តថា ខាងក្រោមជាគ្រុឌ ខាងលើជានាគ ហើយដេញពិសទុកខាងលើ ។

គ្រូនោះដឹងថា ពិសត្រូវឡើងដរាបដល់ចំណែករន្ធដ៏ក្អែកហើយ គិតថា តពីនេះទៅយើងមិនឲ្យឡើងទៅទៀត យើងនឹងតាំងទុកក្នុងទីដែលត្រូវខាំនុ៎ះឯង ទើបរាយមន្តថា ខាងលើជាគ្រុឌ ខាងក្រោមជានាគ ទើបពេលផ្សែងភ្លើងត្រង់ជំពៅ យកឈើគោះ ដកពិសចុះ តាំងទុកក្នុងទីដែលត្រូវខាំនុ៎ះឯង ។ គេដឹងថា ពិសតាំងនៅក្នុងទីនោះ ទើបទម្លាយពិសដោយការលាបថ្នាំពីរប្រភេទដ៏យ៉ាងពិសេសឲ្យផ្លូតទឹក ពោលថា សូមលោកមានសេចក្តីសុខចុះ ហើយចៀសចេញទៅតាមប្រាថ្នា ។

ក្នុងសេចក្តីនោះ កាលដែលភិក្ខុទាំងនេះកាន់យកប្រមាណក្រៃលែងក្នុងរូប គប្បីជ្រាបដូចការតាំងនៅរបស់ពិសក្នុងកាយរបស់បុរសដែលត្រូវអាសេរ្ពិសខាំ ។ ព្រះតថាគតដូចគ្រូពេទ្យដ៏ឆ្លាត ។ កាលភិក្ខុទាំងនោះ ត្រូវព្រះតថាគតឲ្យធ្វើការកាន់យកដោយរូបហើយ ឲ្យតាំងនៅក្នុងអរូប ដូចវេលាដែលគ្រូពេទ្យរាយមន្តហើយដាក់ថ្នាំដេញពិសទុកខាងលើ កាលភិក្ខុទាំងនោះត្រូវព្រះតថាគតឲ្យនាំការប្រកាន់ចាកអរូប ហើយឲ្យតាំងនៅក្នុងរូប ប្រៀបដូចវេលាដែលគ្រូពេទ្យ មិនឲ្យពិសដែលស្ទុះឡើងខាងលើ ដរាបដល់រន្ធក្អែក ហើយដេញចុះដោយកម្លាំងមន្តទៀត ឲ្យតាំងនៅក្នុងទីដែលត្រូវអា-

សេដ្ឋិសខាំ គប្បីជ្រាបកាលដែលព្រះសាស្តាទ្រង់ផ្តើមទេសនានេះ ដើម្បីនាំការប្រកាន់ចេញចាកអារម្មណ៍ទាំង ២ ចំណែក ប្រៀបដូចទម្លាយពិសដោយថ្នាំដែលបញ្ឈប់ទុកត្រង់ទីដែលត្រូវអាសេដ្ឋិសខាំ ដោយការលាបថ្នាំពីរប្រភេទដ៏យ៉ាងពិសេស ។

[២៣៤] បណ្តាបទទាំងនោះ ដោយបទថា **និព្វិន្ទំ វិរជ្ជតិ** ព្រះអង្គត្រាស់ដូចមគ្គ ។ ដោយបទថា **វិរាគា វិមុច្ចតិ** ត្រាស់ផល ។ ដោយបទថា **វិមុត្តស្មឹ** ជាដើម ត្រាស់បច្ចវេក្ខណញ្ញាណ ។

ចប់ អដ្ឋកថាអស្សុតវតាសូត្រទី ១

# អ ដ្ឋ ក ថា

## អស្សុតវតាសូត្រទី ២

ក្នុង *អស្សុតវតាសូត្រទី ២* មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៣៧] បទថា ***សុខវេទនីយំ*** បានដល់ ជាបច្ច័យនៃសុខវេទនា ។ បទថា ***ផស្សំ*** បានដល់ ចក្ខុសម្ផស្សជាដើម ។ សួរថា ក៏ចក្ខុសម្ផស្សមិនជាបច្ច័យដល់សុខវេទនាមិនមែនឬ ។ ឆ្លើយថា មិនជាបច្ច័យដោយសហ-ជាតប្បច្ច័យ តែជាបច្ច័យដល់ជវនៈវេទនាដោយឧបនិស្សយប្បច្ច័យ ដែលព្រះអង្គត្រាស់សំដៅយកពាក្យនោះ ។ សូម្បីក្នុងសោតសម្ផស្សជាដើម ក៏ន័យនេះ ។ បទថា ***តជ្ជំ*** បានដល់ កើតពីវេទនានោះ គឺ សមគួរដល់ផស្សៈនោះ ។ អធិប្បាយថា សមគួរដល់ផស្សៈនោះ ។ បទថា ***ទុក្ខវេទនីយំ*** ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយនុ៎ះឯង ។

[២៣៨] បទថា ***សង្ឃដ្ដសមោធានា*** បានដល់ ដោយការកកិតគ្នានិងការរួមគ្នា អធិប្បាយថា ដោយការត្រេដុសគ្នា ។ បទថា ***ឧស្មា*** បានដល់ អាការក្តៅ ។ បទថា ***តេជោ អភិនិព្វត្តតិ*** សេចក្តីថា មិនគួរកាន់ប្រកាន់ថា

កំទេចភ្លើងរមែងចេញទៅ ។ ក៏បទថា **ឧស្មា** នេះ ជាវេវចនៈនៃអាការក្តៅ នុ៎ះឯង ។ បណ្តាបទទាំងនោះ បទថា **ទ្វិន្នំ កដ្ឋានំ** បានដល់ ឈើពួតភ្លើងទាំងពីរ ។ ក្នុងពីរយ៉ាងនោះ **វត្ថុ** ដូចឈើពួតភ្លើងខាងក្រោម **អារម្មណ៍** ដូចឈើពួតភ្លើងដែលលើ **ផស្សៈ** ដូចការកកិតគ្នា **វេទនា** ដូចធាតុក្តៅ ។

ចប់អដ្ឋកថា អស្សុតវតាសូត្រទី ២

# អ ដ្ឋ ក ថា

## បុត្តមំសសូត្រទី ៣

*ក្នុង បុត្តមំសសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៤០] *ក្នុងពាក្យថា ចត្តារោមេ ភិក្ខវេ អាហារា ជាដើម មានន័យដូចពោលហើយនុ៎ះឯង ។ ក៏ព្រះសូត្រនោះតាំងឡើងដោយអត្ថុប្បត្តិ ដូច្នោះកាលខ្ញុំសម្តែងរឿងនោះហើយ ក្នុងទីនេះនឹងសម្តែងការពណ៌នាតាមលំដាប់បទ ។ សួរថា ព្រះសូត្រនេះតាំងឡើងដោយអត្ថុប្បត្តិអ្វី ។ ឆ្លើយថា ដោយរឿងលាភ និងសក្ការៈ ។*

*បានឮថា លាភ និងសក្ការៈជាច្រើនកើតឡើងដល់ព្រះមានព្រះភាគ ។ ដូចសម័យទ្រង់សន្សំព្រះបារមីដែលទ្រង់បំពេញរហូតអស់ ៤ អសង្ខេយ្យ ។ ពិតណាស់ បារមីទាំងអស់របស់ព្រះដ៏មានព្រះភាគនោះ ដូចជាប្រមូលមកថា យើងនឹងឲ្យវិបាកក្នុងអត្តភាពមួយ ទើបញុំាងអន្លង់ទឹកដ៏ធំ គឺ លាភ និងសក្ការៈឲ្យកើត ដូចផ្ទៃមេឃធំតាំងឡើង ហើយញុំាងអន្លង់ទឹកដ៏ធំឲ្យកើតដូច្នោះ ។ ជនទាំងឡាយមានក្សត្រិយ៍ និងព្រាហ្មណ៍ជាដើម កាន់បាយ ទឹក*

យាន សំពត់ កម្រងផ្កាឈើ គ្រឿងក្រអូប និងគ្រឿងលាបជាដើម មកពីទីនោះៗ នាំគ្នាគិតថា ព្រះពុទ្ធទ្រង់ប្រថាប់ទីណា ព្រះមានព្រះភាគប្រថាប់នៅទីណា ព្រះអង្គជាទេពក្រៃលែងជាងទេព ទ្រង់អង់អាចជាងនរៈ ទ្រង់ជាបុរស-រាជសីហ៍ទ្រង់ប្រថាប់នៅទីណា ដូច្នេះ ទើបស្វែងរកព្រះមានព្រះភាគ ។ ជនទាំងនោះនាំបច្ច័យទាំងឡាយរយរទេះ កាលមិនបានឱកាស ទើបឈប់យកទូករទេះតគ្នានិងទូករទេះ ដំកង់ដោយជុំវិញប្រមាណមួយគាវុត ដូចរឿងអន្ធកវិន្ទព្រាហ្មណ៍ដូច្នោះ ។ រឿងទាំងអស់គប្បីជ្រាបដោយន័យដែលពោលហើយក្នុងខន្ធកៈ និងក្នុងព្រះសូត្រនោះៗ លាភសក្ការៈកើតឡើងដល់ព្រះមានព្រះភាគយ៉ាងណា សូម្បីដល់ព្រះភិក្ខុសង្ឃក៏ដូច្នោះ ។ សមពិតតាមពាក្យដែលលោកពោលទុកថា ក៏ដោយសម័យនោះឯង ព្រះដ៏មានព្រះភាគជាអ្នកដែលបរិស័ទសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ជាអ្នកបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ សូម្បីព្រះសង្ឃក៏ជាអ្នកដែលជនសក្ការៈ ។ល។ ជាអ្នកបាន ។ល។ បរិក្ខារ ។ ដូចដែលព្រះមានព្រះភាគត្រាស់ថា ចុន្ទៈ ឥឡូវនេះ សង្ឃ ឬគណៈ មានប្រមាណប៉ុនណាកើតឡើងក្នុងលោក ចុន្ទៈ តថាគតពិចារណាមិនឃើញសង្ឃពួកដទៃ

អ្នកដល់កាលប្រសើរលើស ដោយលាភ និងប្រសើរលើសដោយយស ដូចជាភិក្ខុសង្ឃនេះឡើយ ។

លាភ និងសក្ការៈដែលកើតឡើងដល់ព្រះមានព្រះភាគ និងដល់សង្ឃនេះ រួមហើយ ប្រមាណមិនបាន ដូចទឹកនៃមហានទីទាំងពីរ ។ លំដាប់នោះ ព្រះសាស្តាប្រថាប់នៅក្នុងទីកំបាំង ទ្រង់ព្រះតម្រិះថា លាភ និងសក្ការៈធំ បានជារបស់សមគួរសូម្បីដល់ព្រះពុទ្ធក្នុងអតីត ទាំងនឹងសមគួរដល់ព្រះពុទ្ធក្នុងអនាគត ភិក្ខុទាំងឡាយប្រកបដោយសតិ និងសម្បជញ្ញៈដែលកំណត់យកអាហារជាអារម្មណ៍ ជាអ្នកដាក់ខ្លួនជាកណ្តាល ប្រាសចាកឆន្ទរាគៈ មិនមានសេចក្តីពេញចិត្ត និងសេចក្តីត្រេកអរ អាចបរិភោគបុហ្ន៎ ឬនឹងមិនអាចបរិភោគ ។ ព្រះអង្គទ្រង់បានឃើញកុលបុត្រពួកខ្លះបួសថ្មី មិនពិចារណាហើយបរិភោគអាហារ គ្រាព្រះអង្គទ្រង់ឃើញហើយ ទ្រង់មានព្រះតម្រិះថា តថាគតបំពេញបារមីអស់ ៤ អសង្ខេយ្យកម្រៃសែនកប្ប នឹងបានបំពេញព្រោះហេតុនៃបច្ច័យ មានចីវរជាដើមក៏ទេ ដែលពិតបំពេញដើម្បីប្រយោជន៍ដល់ព្រះអរហត្តដែលជាផលដ៏ខ្ពស់បំផុត ។ ភិក្ខុសូម្បីទាំងនេះ បួសក្នុងសម្នាក់តថាគត មិនបានបួសព្រោះហេតុនៃបច្ច័យ មានចីវរជាដើម តែបួស

ដើម្បីប្រយោជន៍ដល់ព្រះអរហត្តនុ៎ះឯង ។ ឥឡូវនេះ ភិក្ខុទាំងនោះធ្វើវត្ថុ ដែលមិនជាសារៈនោះថា ជាសារៈ និងវត្ថុដែលមិនជាប្រយោជន៍នុ៎ះឯងថា ជាប្រយោជន៍ ។ ធម្មសង្វេគកើតឡើងដល់ព្រះអង្គដោយប្រការដូច្នេះ ។ លំដាប់នោះ ព្រះអង្គទ្រង់ព្រះតម្រិះថា បើនឹងអាចបញ្ញត្តិបញ្ចមបារាជិកបាន ដែរ តថាគតក៏នឹងគប្បីបញ្ញត្តិការបរិភោគអាហារដោយមិនពិចារណាឲ្យជា បញ្ចមបារាជិក តែទ្រង់មិនអាចធ្វើយ៉ាងនេះបាន ព្រោះថា អាហារនោះជា ទីសេពសោយប្រចាំរបស់សត្វទាំងឡាយ តែកាលតថាគតត្រាស់ទុក ភិក្ខុ ទាំងនោះក៏នឹងឃើញប្រការនោះដូចបញ្ចមបារាជិក បើដូច្នោះ តថាគតក៏នឹង តាំងការបរិភោគអាហារដែលមិនពិចារណានោះថា ជាកញ្ចក់ធម៌ ជាសំវរៈ ជាព្រំដែន ដល់ពួកភិក្ខុក្នុងអនាគត រំលឹកហើយ នឹងពិចារណាបច្ច័យ ៤ ជាមុន ទើបបរិភោគ ។

ក្នុងអត្ថុប្បត្តិហេតុនេះ បានបន្ថែមបុត្តមំសូបមសុត្តន្តៈដូចតទៅនេះ ។ បណ្ដាបទទាំងនោះ បទថា **ចត្តារោមេ ភិក្ខវេ អាហារា** ជាដើម មានអត្ថ ដូចពោលហើយក្នុងកាលមុននុ៎ះឯង ។ ក៏ត្រាឲ្យអាហារ ៤ ពិស្ដារហើយ ឥឡូវនេះ ដើម្បីនឹងសម្ដែងទោសក្នុងអាហារ ៤ ទាំងនោះ ទើបត្រាស់ថា

កថញ្ច ភិក្ខវេ កវឡិង្ការោ អាហារោ ទដ្ឋព្វោ ជាដើម ។

[២៤១] បណ្ដាបទទាំងនោះ បទថា **ជាយបតិកា** បានដល់ ភរិយា និងស្វាមី បទថា **បរិត្តំ សម្ពលំ** បានដល់ ស្បៀង មានអន្សម បាយសត្ថុ និងនំជាដើមណាមួយតិចតួច ។ បទថា **កន្តារមគ្គំ** បានដល់ ផ្លូវកន្តារ ។ បទថា **កន្តារំ** បានដល់ កន្តារ ៥ យ៉ាង គឺ ចោរកន្តារ ពាឡកន្តារ អមនុស្សកន្តារ និរុទកកន្តារ អប្បភក្ខកន្តារ ។

បណ្ដាកន្តារ ៥ យ៉ាងនោះ ទីដែលមានចោរភ័យ ឈ្មោះថា **ចោរ-កន្តារ** ។ ទីដែលមានសត្វកាច មានរាជសីហ៍ និងខ្លាធំជាដើម ឈ្មោះថា **ពាឡកន្តារ** ។ ទីដែលមានភ័យដោយអមនុស្ស មានយក្ខិណី ឈ្មោះថា ពលវាមុខជាដើម ឈ្មោះថា **អមនុស្សកន្តារ** ។ ទីដែលមិនមានទឹកផឹក ឬ ងូត ឈ្មោះថា **និរុទកកន្តារ** ។ ទីដែលមិនមានវត្ថុទំពារ ឬស៊ី ដោយហោច ទៅសូម្បីត្រឹមតែមើមត្រាវជាដើម ឈ្មោះថា **អប្បភក្ខកន្តារ** ។ មួយទៀត ក្នុងទីណាមានភ័យទាំង ៥ យ៉ាងនេះហើយ ទីនោះឈ្មោះថា កន្តារដោយពិត ។ កន្តារទាំង ៥ នេះ គប្បីកន្លងទៅដោយ ១-២-៣ ថ្ងៃក៏មាន ។ ផ្លូវនោះ លោកមិនបំណងយកក្នុងទីនេះ តែក្នុងទីនេះលោកបំណងយកផ្លូវកន្តារ

ប្រមាណ ១០០ យោជន៍ ដែលមិនមានទឹក និងមានអាហារតិច ផ្លូវក្នុងគ្រាកន្តារបែបនេះ ឈ្មោះថា **ផ្លូវកន្តារ** ។ បទថា **បដិបជ្ជេយ្យុំ** សេចក្តីថា ពីរនាក់ស្វាមីភរិយាត្រូវធាតុកភ័យ រោគភ័យ និងរាជភ័យបៀតបៀន នាំគ្នាដើរទៅ សម្គាល់ថា យើងនឹងឆ្លងកន្តារ ហើយនៅជាសុខក្នុងវេជ្ជសម័យដែលប្រាសចាកអន្តរាយរបស់ព្រះរាជាអ្នកទ្រទ្រង់ធម៌ ។

បទថា **ឯកបុត្តកោ** បានដល់ បុត្រតូចមួយនាក់ មានរាងកាយស្គមដែលគួរអាណិតពេកទៅ ។ បទថា **វល្លូរញ្ច សោណ្ឌិកញ្ច** សេចក្តីថា យកពីទីមានសាច់ជាដុំៗ ធ្វើជាឆៀត យកពីទីជាប់ឆ្អឹង និងជាប់ក្បាល ធ្វើជាផ្អក ។ បទថា **បដិបីសេយ្យុំ** បានដល់ គប្បីប្រហារ ។ ស័ព្ទថា **កហំ ឯកបុត្តក** នេះ ជាអាការសម្តែងភាពសោយសោករបស់ស្វាមីភរិយាទាំងពីរនោះ ។

ក៏ក្នុងសេចក្តីនេះ មានការពណ៌នាសេចក្តីដោយសង្ខេប ផ្តើមតាំងពីធ្វើខ្លឹមសារឲ្យជាក់ច្បាស់ ដូចតទៅនេះ ៖

បានឮថា ពីរនាក់ស្វាមីភរិយាពកូនដើរផ្លូវកន្តារប្រមាណ ១០០ យោជន៍ ដោយស្បៀងបន្តិចបន្តួច ។ គេធ្វើដំណើរទៅបាន ៥០ យោជន៍ ស្បៀងក៏អស់ ភាពសោប់សល់ព្រោះសេចក្តីឃ្លាន អង្គុយត្រង់ម្លប់ឈើដែលដុះល្អ ។

លំដាប់នោះ ស្វាមីបានពោលចំពោះភរិយាថា ប្រពន្ធសំឡាញ់ អំពីនេះទៅ ដោយជុំវិញ ៥០ យោជន៍ មិនមានស្រុក ឬនិគមឡើយ ដូច្នោះ ឥឡូវនេះ យើងមិនអាចនឹងធ្វើកសិកម្ម និងគោរក្ខកម្មជាដើម ដែលជាការងាររបស់ បុរសធ្វើបាន មកចុះ នាងចូរសម្លាប់យើងហើយស៊ីសាច់ពាក់កណ្តាល ធ្វើ ស្បៀងពាក់កណ្តាល ហើយចូរឆ្លងផ្លូវកន្តារទៅព្រមនឹងកូនចុះ ។ ចំណែក ភរិយាពោលថា បងឥឡូវនេះ ខ្ញុំមិនអាចនឹងធ្វើកម្ម មានការខារអំបោះជា ដើម សូម្បីស្ត្រីដទៃពីងឲ្យធ្វើ មកចុះ បងចូរសម្លាប់ខ្ញុំស៊ីសាច់ចំណែកខ្លះ ធ្វើស្បៀងចំណែកខ្លះ ហើយចូរឆ្លងផ្លូវកន្តារទៅជាមួយនឹងកូនចុះ ។ ស្វាមី ពោលនឹងភរិយាទៀតថា នាងជាទីស្រឡាញ់ សេចក្តីស្លាប់រមែងប្រាកដដល់ មនុស្សពីរនាក់ ព្រោះម្តាយស្លាប់ ព្រោះទារក វៀរម្តាយចេញហើយ ក៏មិន អាចនឹងមានជីវិតរស់នៅបាន តែបើយើងទាំងពីរនៅមានជីវិត យើងក៏នឹង គប្បីបានកូនទៀត ណ្ហើយចុះ យើងនឹងសម្លាប់កូនតូចក្នុងកាលឥឡូវនេះ កាន់យកសាច់ស៊ី ឆ្លងកន្លងផ្លូវកន្តារ ។ លំដាប់នោះ ម្តាយពោលនឹងកូនថា កូនសម្លាញ់ ឯងចូរទៅរកឪពុក ។ កូនក៏ទៅរកឪពុក ។ គ្រានោះឪពុករបស់ ក្មេងតូចពោលថា យើងបានទទួលសេចក្តីទុក្ខមិនមែនតិច ព្រោះកសិកម្ម និង

គោរក្ខកម្មជាដើម ក៏ដើម្បីនឹងចិញ្ចឹមកូនតូច យើងមិនអាចសម្លាប់កូនបាន នាងនុ៎ះឯង ចូរសម្លាប់កូនរបស់នាង ហើយពោលនឹងកូនតូចថា កូនសម្លាញ់ ឯងចូរទៅរកម្តាយ ។ កូនក៏ទៅរកម្តាយ ។ គ្រានោះ ម្តាយរបស់ក្មេងតូច ពោលថា កាលយើងចង់បានកូន យើងបានទទួលសេចក្តីទុក្ខដ៏ច្រើន ដោយការបួងសួងទេវតាដោយគោវត្ត និងកុក្កុរវត្តជាដើមមុន មិនចាំបាច់ពោលដល់ការរក្សាគភ៌ ខ្ញុំមិនអាចសម្លាប់កូនបាន ហើយពោលនឹងកូនតូចថា កូនសម្លាញ់ អ្នកចូរទៅរកឪពុកចុះ ។ កូនតូចនោះកាលដើរទៅក្នុងរវាងឪពុកម្តាយនុ៎ះឯង ក៏ស្លាប់ទៅដោយប្រការដូច្នេះ ។ ពីរនាក់ស្វាមីភរិយាឃើញដូច្នោះ យំសោក កាន់យកសាច់កូនទំពារស៊ី ធ្វើដំណើរទៅ ដោយន័យដូចពោលហើយ ។

អាហារ គឺ សាច់កូននៃជនទាំងពីរនាក់ស្វាមីភរិយានោះ មិនមែនស៊ីដើម្បីលេង មិនមែនស៊ីដើម្បីស្រវឹង មិនមែនស៊ីដើម្បីប្រដាប់ មិនមែនស៊ីដើម្បីតុបតែងខ្លួន ព្រោះបដិកូលដោយហេតុ ៩ ប្រការ ជាអាហារដើម្បីឆ្លងផ្លូវកន្តារតែម្យ៉ាងប៉ុណ្ណោះ ។ បើនឹងសួរថា ព្រោះបដិកូលដោយហេតុ ៩ ប្រការ អ្វីខ្លះ ។

គប្បីឆ្លើយថា ៖

១-ព្រោះជាសាច់របស់អ្នករួមជាតិ ១

២-ព្រោះជាសាច់របស់ញាតិ ១

៣-ព្រោះជាសាច់របស់បុត្រ ១

៤-ព្រោះជាសាច់របស់បុត្រជាទីស្រឡាញ់ ១

៥-ព្រោះជាសាច់ក្មេងតូច ១

៦-ព្រោះជាសាច់ឆៅ ១

៧-ព្រោះមិនជាគោរស (ទឹកដោះគោ) ១

៨-ព្រោះមិនប្រៃ ១

៩-ព្រោះមិនបានចំអិន ១

ពិតណាស់ ពីរនាក់ស្វាមីភរិយានោះ ទំពារស៊ីសាច់បុត្រនោះព្រោះភាពបដិកូលដោយហេតុទាំង ៩ ប្រការនោះ ដោយប្រការដូច្នេះ ទើបមិនបានទំពារស៊ីដោយសេចក្តីត្រេកអរ ពេញចិត្ត តែតាំងនៅក្នុងភាវៈកណ្តាលៗ ទុំះឯង គឺ ក្នុងការបរិភោគ ដោយមិនមានសេចក្តីពេញចិត្ត និងត្រេកអរ ទំពារស៊ីហើយ គេមិនបានយកសាច់ដែលជាប់ឆ្អឹងសរសៃ និងស្បែកចេញ

ហើយទំពារស៊ីតែសាច់ដុំៗ គឺ សាច់ដែលល្អៗ ប៉ុណ្ណោះទេ ទំពារស៊ីចំពោះសាច់ដែលនៅចំពោះមុខ មិនបានទំពារស៊ីតាមត្រូវការរហូតពេញមាត់ តែទំពារស៊ីម្តងបន្តិចៗ ល្មមញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅមួយថ្ងៃៗ ប៉ុណ្ណោះ មិនបានហួងហែងគ្នានិងគ្នាទំពារស៊ី ទំពារស៊ីដោយចិត្តដែលបរិសុទ្ធិពិតៗ ប្រាសចាកមន្ទិល គឺ សេចក្តីកំណាញ់ មិនបានទំពារស៊ីដោយវង្វេងថា ពួកយើងទំពារស៊ីសាច់ណាមួយ នឹងជាសាច់ម្រឹគ ឬសាច់សត្វក្ងោកជាដើមណាមួយក៏ដោយ តែទំពារស៊ីទាំងដែលដឹងថា ជាសាច់របស់កូនសម្លាញ់ មិនបានទំពារស៊ីដោយប្រាថ្នាថា ដូចម្តេចហ្ន៎ យើងគប្បីទំពារស៊ីសាច់កូនបែបនេះទៀត តែទំពារស៊ីដោយមិនប្រាថ្នា មិនបានសន្សំ ដោយតាំងចិត្តថា យើងទំពារស៊ីត្រឹមតែប៉ុណ្ណោះក្នុងផ្លូវកន្តារ កាលផុតផ្លូវកន្តារហើយ នឹងយកសាច់ដែលសល់ទៅផ្សំដោយសប្រែ រសជូរជាដើម ទំពារស៊ី តែកាលឆ្លងផ្លូវកន្តារហើយ គិតថា ពពួកជនក្នុងក្រុងនឹងឃើញ ទើបកប់ទុកក្នុងដី ឬយកភ្លើងដុត មិនបានប្រកាន់ ឬអួតអាងថា អ្នកណាដទៃនឹងបានទំពារស៊ីសាច់បុត្របែបនេះដូចយើង តែទំពារស៊ីដោយកម្ចាត់សេចក្តីប្រកាន់ខ្លួន និងអួតអាងចេញ មិនបានទំពារស៊ីដោយមើលងាយថា ប្រយោជន៍អ្វីដោយសាច់បែប

នេះ ដែលមិនប្រែ មិនជូរ មិនទាន់បានចំអិន មានក្លិនស្អុយ តែទំពារស៊ី ដោយប្រាសចាកការមើលងាយ មិនមើលងាយគ្នានិងគ្នាថា ចំណែករបស់នាង ចំណែករបស់យើង បុត្ររបស់នាង បុត្ររបស់យើង តែមានសេចក្តីព្រមព្រៀងក្នុងការទំពារស៊ី ។

ព្រះសាស្តាទ្រង់ពិចារណាឃើញ ជនពីរនាក់ស្វាមីភរិយាបរិភោគដោយប្រាសចាកឆន្ទរាគៈបែបនោះ កាលនឹងទ្រង់ឲ្យភិក្ខុសង្ឃជ្រាបហេតុនោះ ទើបត្រាស់ពាក្យជាដើមថា **តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ តេ ទវាយ វា អាហារំ អាហរេយ្យុំ** ដូច្នេះ ។ ក្នុងព្រះបាលីនោះ ពាក្យជាដើមថា **ទវាយ វា** ពោលទុកពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គនុ៎ះឯង ។

បទថា **កន្តារស្ស** បានដល់ កន្តារក្រៅពីដែលពីរនាក់ស្វាមីភរិយាឆ្លងមក ។ បទថា **ឯវមេវ ខោ** សេចក្តីថា គប្បីឃើញអាហារដូចសាច់កូនសម្លាញ់ ដោយអំណាចជារបស់បដិកូល ៩ យ៉ាង ។ សួរថា ភាពជារបស់បដិកូល ៩ យ៉ាងអ្វីខ្លះ ឆ្លើយថា ជារបស់បដិកូលក្នុងការទៅជាដើម ។ ពិតណាស់ កាលពិចារណាភាពបដិកូលដោយការទៅក្តី កាលពិចារណាភាពបដិកូលដោយការស្វែងរកក្តី កាលពិចារណាភាពបដិកូលដោយការបរិ-

ភោគ ដោយទីគ្រប់ទុក ដោយទីអាស្រ័យ ដោយជារបស់ឆ្អិន ដោយជារបស់មិនឆ្អិន ដោយជារបស់ប្រឡាក់ និងដោយជារបស់ហូរចេញក្តី ឈ្មោះថារមែងកំណត់កវឡិង្ការាហារ ។ ក៏ភាពបដិកូលដោយការទៅជាដើមទាំងនេះ ពោលទុកពិស្តារហើយ ក្នុងអាហារេបដិកូលនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ គប្បីបរិភោគអាហារប្រៀបដោយសាច់កូនឯង ដោយភាពបដិកូលទាំង ៩ យ៉ាងនេះ ដោយប្រការដូច្នេះ ។

ពីរនាក់ស្វាមីភរិយានោះ កាលទំពារស៊ីសាច់កូនសម្លាញ់ ដែលជារបស់បដិកូល មិនបានទំពារស៊ីដោយសេចក្តីត្រេកអរជាប់ចិត្ត តែតាំងនៅក្នុងភាវៈកណ្តាល ៗ នុ៎ះឯង គឺ ក្នុងការបរិភោគដោយមិនមានសេចក្តីពេញ-ចិត្ត និងសេចក្តីត្រេកអរ យ៉ាងណា គប្បីបរិភោគអាហារដោយមិនមានសេចក្តីពេញចិត្ត និងត្រេកអរ ដូច្នោះ ។

ដូចពីរនាក់ស្វាមីភរិយានោះ នឹងបានយកសាច់ដែលជាប់ឆ្អឹង សរសៃ និងស្បែកចេញ ទំពារស៊ីតែសាច់ដុំៗ គឺ សាច់ដែលល្អៗ ប៉ុណ្ណោះក៏ទេ តែទំពារស៊ីសាច់ត្រង់ចាប់បានប៉ុណ្ណោះ យ៉ាងណា ភិក្ខុមិនគប្បីប្រើខ្នងដៃកៀរបាយក្រៀម និងនឹងបាយក្តាំងជាដើមចេញ មិនសម្តែងភាពចំពោះ ដូចសត្វចាប

និងដូចមាន់ មិនបានជ្រើសរើសចំពោះភោជនដែលល្អ ដែលផ្សំទឹកដោះថ្លា និងសាច់ជាដើមអំពីទីនោះៗ បរិភោគគប្បី បរិភោគតាមលំដាប់ដូចរាជសីហ៍ ដូច្នោះ ។ ដូចពីរនាក់ស្វាមីភរិយានោះ មិនបានទំពារស៊ីតាមដែលត្រូវការ ដរាបពេញមាត់ តែទំពារស៊ីម្តងបន្តិចៗ ល្មមញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅក្នុង មួយថ្ងៃៗ ប៉ុណ្ណោះ យ៉ាងណា ភិក្ខុក៏យ៉ាងនោះ មិនបរិភោគតាមត្រូវការ ដរាបដល់កើ ដូចពួកព្រាហ្មណ៍ដែលមានអាហារនៅក្នុងដៃជាដើម អ្នកខ្លះ វៀរឱកាសសម្រាប់បាយ ៤-៥ ពំនូតទុកហើយបរិភោគ ដូចព្រះធម្មសេ-នាបតី ។

បានឮមកថា ព្រះធម្មសេនាបតីថេរៈនោះតាំងនៅ (ភាពជាភិក្ខុ) ៤៥ វស្សា ពោលថា សូម្បីមួយថ្ងៃ យើងក៏មិនបានឆាន់អាហារដរាបដល់កើចេញ មកជារសដូវខាងក្រោយឆាន់អាហារ ដូច្នេះ កាលបន្លឺសីហនាទ បានពោល គាថានេះថា ៖

ភិក្ខុវៀរការឆាន់បាយ ៤-៥ ពំនូត គប្បីផឹកទឹក ល្មមដែល

និងនៅយ៉ាងសប្បាយសម្រាប់ភិក្ខុដែលមានចិត្តអង់អាច ។

ដូចស្វាមីភរិយាទាំងពីរនាក់នោះ ទឹងបានហួងហែងគ្នានិងគ្នាទំពារ ស៊ីក៏ទេ

តែទំពារស៊ីដោយចិត្តដ៏បរិសុទ្ធិពិតៗ ប្រាសចាកមន្ទិល គឺ សេចក្តីកំណាញ់ យ៉ាងណា ភិក្ខុក៏យ៉ាងនោះដែរ បានបិណ្ឌបាតហើយមិនកំណាញ់ គិតថា កាលភិក្ខុទទួលបិណ្ឌបាតនេះបានទាំងអស់ យើងក៏នឹងឲ្យទាំងអស់ កាលទទួលបានពាក់ យើងនឹងឲ្យពាក់កណ្តាល ប្រសិនបើនឹងមានបិណ្ឌបាតនៅសល់ពីភិក្ខុទទួល យើងនឹងបរិភោគខ្លួនឯង ដូច្នេះ តាំងនៅក្នុងសាភណីយធម៌ដ៏មុតមាំហើយបរិភោគ ។ ដូចជាពីរស្វាមីភរិយានោះ មិនបានទំពារស៊ីដោយវង្វេងថា ពួកយើងទំពារស៊ីសាច់យ៉ាងណាមួយ នឹងជាសាច់ម្រឹគ ឬសាច់សត្វក្ងោកជាដើមណាមួយក៏ដោយ តែទំពារស៊ីទាំងដែលដឹងថា ជាសាច់របស់កូនសម្លាញ់ យ៉ាងណា ភិក្ខុក៏ដូច្នោះ បានបិណ្ឌបាតហើយ មិនគប្បីកើតសេចក្តីវង្វេងព្រោះឃើញដល់ខ្លួន យើងនឹងទំពារស៊ី នឹងបរិភោគ គប្បីគិតថា កវឡិង្ការាហារ រមែងមិនដឹងថា យើងធ្វើកាយដែលអាស្រ័យមហាភូតរូប ៤ ឲ្យចម្រើន សូម្បីកាយ ក៏មិនដឹងថា កវឡិង្ការាហារធ្វើយើងឲ្យចម្រើន ដូច្នេះ គប្បីលះសេចក្តីវង្វេងហើយបរិភោគ ដោយអាការយ៉ាងនេះ ។ ពិតណាស់ កវឡិង្ការាហារនេះ ភិក្ខុគប្បីជាអ្នកមិនវង្វេង បរិភោគដោយសតិសម្បជញ្ញៈ ។

ដូចជាពីរស្វាមីភរិយានោះ មិនទំពារស៊ីដោយតាំងសេចក្ដីប្រាថ្នាថា ដូចម្ដេចហ្ន៎ យើងគប្បីទំពារស៊ីសាច់កូនបែបនេះទៀត តែលះបង់ផុតសេចក្ដីប្រាថ្នាទៅហើយ ក៏ទំពារស៊ី យ៉ាងណា ភិក្ខុក៏ដូច្នោះដែរ បានភោជនដែលប្រណីតហើយ គិតថា ដូចម្ដេចហ្ន៎ យើងគប្បីបានភោជនបែបនេះ ក្នុងថ្ងៃស្អែកនេះក្ដី ក្នុងថ្ងៃតទៅក្ដី ក៏កាលបានភោជនដែលសៅហ្មងក៏គិតថា ថ្ងៃនេះយើងមិនបានភោជនដែលប្រណីតដូចថ្ងៃម្សិលមិញ មិនបានធ្វើសេចក្ដីប្រាថ្នា ឬក្ដៅក្រហាយចិត្ត ជាអ្នកប្រាសចាកសេចក្ដីប្រាថ្នា រឭកដល់ឱវាទនេះថា ៖

ជនទាំងឡាយ រមែងមិនសោកសៅដល់អាហារដែល

ជាអតីត រមែងមិនកន្លល់ដល់អាហារដែលជាអនាគត

ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយអាហារដែលជាបច្ចុប្បន្ន

ដូច្នោះ ពណ៌សម្បុរទើបថ្លាផូរផង់ ។

គប្បីបរិភោគដោយគិតថា នឹងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយអាហារដែលជាបច្ចុប្បន្នប៉ុណ្ណោះ ។

មួយទៀត ពីរស្វាមីភរិយានោះ មិនបានសន្សំដោយគិតថា យើង

នឹងទំពារស៊ីសាច់កូនប៉ុណ្ណោះក្នុងផ្លូវកន្តារ ធ្លងផ្លូវកន្តារហើយ នឹងយកសាច់កូនចំណែកដែលសល់ទៅផ្សំដោយរសជូរជាដើមទំពារស៊ី តែកាលធ្លងផ្លូវកន្តារហើយគិតថា ពួកជនក្នុងក្រុងនោះនឹងឃើញ ទើបកប់ទុកក្នុងដី ឬយកភ្លើងដុតចោល យ៉ាងណា ភិក្ខុក៏ដូច្នោះដែរ រំឮកដល់ឱវាទនេះថា បានបាយឬទឹកក៏ដោយ របស់ទំពារ ឬសំពត់ក៏ដោយ មិនគប្បីសន្សំ កាលមិនបានវត្ថុទាំងនោះ ក៏មិនគប្បីភ័យខ្លាច កាន់យកល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅពីបច្ច័យ ៤ តាមដែលបាននោះៗ ចំណែកដែលសល់ ចែកចាយដល់សព្រហ្មចារី វៀរការសន្សំបរិភោគ ។ មួយទៀត ពីរស្វាមីភរិយានោះ មិនបានប្រកាន់ខ្លួន ឬអួតអាងថា អ្នកដទៃណានឹងបានទំពារស៊ីសាច់កូនបែបនេះដូចយើង តែទំពារស៊ីដោយកម្ចាត់សេចក្តីប្រកាន់ខ្លួន និងការអួតអាងចេញ យ៉ាងណា ភិក្ខុក៏ដូច្នោះ បានភោជនដែលប្រណីតហើយ មិនគប្បីប្រកាន់ខ្លួន ឬអួតអាងថា យើងបានចីវរ និងបិណ្ឌបាតជាដើម គប្បីពិចារណាថា ការបួសនេះមិនមែនហេតុនៃចីវរជាដើម តែការបួសនេះជាការបួសព្រោះហេតុនៃព្រះអរហត្ត ហើយគប្បីបរិភោគដោយប្រាសចាកសេចក្តីប្រកាន់ខ្លួន និងការអួតអាងតែម្យ៉ាង ។

មួយទៀត ពីរស្វាមីភរិយានោះមិនបានទំពារស៊ីដោយមើលងាយថា ប្រយោជន៍អ្វីដោយសាច់ដែលមិនប្រៃ មិនជូរ មិនទាន់បានចម្អិន មានក្លិនស្អុយ តែទំពារស៊ីដោយប្រាសចាកការមើលងាយ យ៉ាងណា ភិក្ខុក៏ដូច្នោះ បានបិណ្ឌបាតហើយ មិនគប្បីមើលងាយបិណ្ឌបាតថា ប្រយោជន៍អ្វីដោយភត្តដែលអាក្រក់ មិនមានរសជាតិដូចជាអាហារសេះ អាហារគោ ចូរយកវាទៅដាក់ក្នុងស្នូកសុនខ ឬមិនមើលងាយទាយកយ៉ាងនេះថា អ្នកណានឹងបរិភោគភត្តនេះបាន ចូរឲ្យដល់ក្អែក និងសុនខជាដើមចុះ រព្លកដល់ឱវាទនេះថា ៖

គេបីបាត្រត្រាច់ទៅ មិនគួតក៏ធ្វើជាគួត មិនគប្បីមើល
ងាយទានដែលតិចតួច មិនគប្បីមើលងាយអ្នកឲ្យ ដូច្នេះ ។

គប្បីបរិភោគ ។ មួយទៀត ពីរនាក់ស្វាមីភរិយានោះ មិនបានមើលងាយគ្នានិងគ្នាថា ចំណែករបស់នាង ចំណែករបស់យើង បុត្ររបស់នាង បុត្ររបស់យើង តែមានសេចក្តីព្រមព្រៀងរីករាយទំពារស៊ីយ៉ាងណា ភិក្ខុក៏ដូច្នោះ បានបិណ្ឌបាតហើយ មិនគប្បីមើលងាយអ្នកណាៗ ដូចភិក្ខុពួកខ្លះមើលងាយសព្រហ្មចារីអ្នកមានសីលថា នរណានឹងឲ្យដល់មនុស្សដូចពួក

លោក ពួកលោកជាអ្នកមិនមានហេតុ ដើរជួលត្រង់ធរណីទ្វារ សូម្បីមាតាបង្កើតរបស់ខ្លួនក៏មិនសម្គាល់របស់ដែលនឹងឲ្យ តែពួកយើងរមែងបានចីវរជាដើមដែលប្រណីតក្នុងទីដែលទៅហើយ ដូចព្រះអង្គត្រាស់ទុកថា ភិក្ខុនោះមើលងាយភិក្ខុពួកដទៃអ្នកមានសីលជាទីស្រឡាញ់ ដោយលាភសក្ការៈ និងសរសើរនោះ ភិក្ខុទាំងឡាយ សេចក្ដីនោះរមែងមានដល់មោឃបុរសនោះ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលយូរ ដូច្នេះ គប្បីជាអ្នកព្រមព្រៀងរីករាយបរិភោគជាមួយសព្រហ្មចារីទាំងពួង ។

បទថា **បរិញ្ញាតេ** បានដល់ កំណត់ដឹងដោយបរិញ្ញា ៣ ទាំងនេះ គឺ ញាតបរិញ្ញា តីរណបរិញ្ញា បហានបរិញ្ញា ។ កំណត់យ៉ាងណា ។ គឺភិក្ខុក្នុងធម្មវិន័យនេះ រមែងដឹងច្បាស់ថា ឈ្មោះថា កវឡីការាហារនេះជារូបមានឱជាជាទី ៨ (ឱជដ្ឋមករូប) ដោយអំណាចរូបដែលមានវត្ថុ ។ ឱជដ្ឋមករូបត្រូវប៉ះខ្ទប់ក្នុងទីណា ។ ប៉ះខ្ទប់ត្រង់ជិវ្ហាបសាទ ។ ជិវ្ហាបសាទអាស្រ័យអ្វី ។ អាស្រ័យមហាភូតរូប ៤ ។ រូបមានឱជាជាទី ៨ ជិវ្ហា-បសាទ មហាភូតរូប ដែលជាបច្ច័យនៃជិវ្ហាបសាទនោះ ធម៌ទាំងនេះ ដូចពោលមកនេះ ឈ្មោះថា **រូបខន្ធ** កាលភិក្ខុកំណត់រូបខន្ធ ធម៌ដែលមានផស្សៈ

ជាគម្រប់ ៥ ដែលកើតឡើង ឈ្មោះថា **អរូបក្ខន្ធ ៤** ។ ធម៌សូម្បីទាំងអស់នេះ ឈ្មោះថា **ខន្ធ ៥** ដោយសង្ខេបត្រឹមតែជានាមរូប ។ ភិក្ខុនោះ លុះកំណត់ធម៌ទាំងនោះដោយលក្ខណៈព្រមដោយកិច្ចហើយ ស្វែងរកបច្ច័យនៃធម៌ទាំងនោះ រមែងឃើញបដិច្ចសមុប្បាទដែលជាអនុលោម ។ ដោយលំដាប់ពាក្យត្រឹមតែប៉ុណ្ណេះ ជាការដែលភិក្ខុនោះកំណត់ដឹងកពឡីង្ការាហារដោយ **ញាតបរិញ្ញា** ព្រោះឃើញនាមរូបព្រមដោយបច្ច័យ ដោយប្រមុខ គឺ កពឡីង្ការាហារតាមសេចក្ដីពិត ភិក្ខុលើកនាមរូបព្រមដោយបច្ច័យនោះឯងឡើងកាន់លក្ខណៈ ៣ ថា មិនទៀង ជាទុក្ខ ជាអនត្តា ហើយពិចារណាឃើញដោយអនុបស្សនា ៧ ។ ដោយលំដាប់ពាក្យត្រឹមប៉ុណ្ណេះ ជាការដែលភិក្ខុកំណត់ដឹងកពឡីង្ការាហារនោះ ពោលគឺ ញាណជាគ្រឿងបាក់ធ្លុះ និងពិចារណាឃើញត្រៃលក្ខណ៍ដោយ **តីរណបរិញ្ញា** ។ ក៏កពឡីង្ការាហារនោះ ជាការដែលភិក្ខុកំណត់ដឹងដោយ **បហានបរិញ្ញា** ព្រោះកំណត់ដឹងដោយអនាគាមិមគ្គ ដែលដកនូវឆន្ទរាគៈក្នុងនាមរូបនោះឯង ។

បទថា **បញ្ចកាមគុណិកោ** ដែលភិក្ខុកំណត់ដឹងការកើតនៃកាមគុណ ៥ ។ តែក្នុងទីនេះ បរិញ្ញា ៣ បានដល់ ឯកបរិញ្ញា សព្វបរិញ្ញា មូលបរិញ្ញា

សួរថា **ឯកបរិញ្ញា** តើដូចម្ដេច ។

ឆ្លើយថា ភិក្ខុណាកំណត់ដឹងតណ្ហាមានរសតែម្យ៉ាងក្នុងជិវ្ហាទ្វារ ភិក្ខុនោះ ឈ្មោះថា ជាការកំណត់រាគៈដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ។ ព្រោះហេតុអ្វី ។ ព្រោះតណ្ហានោះឯងកើតឡើងក្នុងទីនោះ ពិតណាស់ តណ្ហានោះឯង កើតឡើងក្នុងចក្ខុទ្វារ ឈ្មោះថា ជារូបរាគៈ ក្នុងសោតទ្វារជាដើម ក៏កើតសទ្ទរាគៈជាដើម ដូច្នោះ រាគៈដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ដែលភិក្ខុនោះកំណត់ដឹងហើយ ដោយការកំណត់ដឹងរសតណ្ហាក្នុងជិវ្ហាទ្វារ ដូចកាលរាជបុរសចាប់ចោរម្នាក់ ដែលជាអ្នកសម្លាប់មនុស្សក្នុងផ្លូវទាំង ៥ ចាប់បានក្នុងផ្លូវណាមួយហើយកាត់សីសៈចោល ដូច្នេះ ផ្លូវទាំង ៥ រមែងជាផ្លូវរួចផុតភ័យ ដូច្នោះ នេះឈ្មោះថា **ឯកបរិញ្ញា** ។

សួរថា **សព្វបរិញ្ញា** តើដូចម្ដេច ។

ឆ្លើយថា សេចក្ដីពិត កាលបិណ្ឌបាតដែលគេដាក់ចុះក្នុងបាត្រ តែម្យ៉ាងប៉ុណ្ណោះ រមែងបានសេចក្ដីត្រេកអរដែលប្រកបដោយកាមគុណ ៥ ។

យ៉ាងណា ។ គឺ ជាដំបូង កាលភិក្ខុនោះក្រឡេកមើលពណ៌ដែលបរិសុទ្ធិ សេចក្ដីត្រេកអរក្នុងរូបរមែងមាន កាលចាក់ទឹកដោះថ្លាដែលក្ដៅ

ចូលក្នុងទីនោះ សំឡេងរមែងលាន់ឮបង:បង: កាលទំពាររបស់ដែលគួរទំពារបែបនោះ សំឡេងឮ មុរុ មុរុ រមែងកើតឡើង កាលត្រេកអរក្នុងសំឡេងនោះ សេចក្តីត្រេកអរក្នុងសំឡេងរមែងកើតឡើង កាលត្រេកអរក្លិនដែលជាគ្រឿងផ្សំ មានខ្ទឹមជាដើម សេចក្តីត្រេកអរក្នុងក្លិនរមែងកើតឡើង សេចក្តីត្រេកអរក្នុងរស ដោយអំណាចរសដែលល្អរមែងកើតឡើង កាលត្រេកអរថា ភោជនទន់ល្មមគួរដល់សម្ផស្ស សេចក្តីត្រេកអរក្នុងផោដ្ឋព្វៈ រមែងកើតឡើង ។ ដូច្នោះ កាលភិក្ខុកំណត់អាហារដោយសតិ និងសម្បជញ្ញៈហើយបរិភោគ ដោយការបរិភោគដែលប្រាសចាករាគៈ ការបរិភោគទាំងអស់ ក៏ឈ្មោះថា ភិក្ខុកំណត់ដឹងហើយ ការកំណត់ដឹង ដូចពោលមកនេះ ឈ្មោះថា **សព្វបរិញ្ញា** ។

សួរថា **មូលបរិញ្ញា** តើដូចម្តេច ។

ពិតណាស់ កពឡីង្ការាហារជាមូលនៃសេចក្តីត្រេកអរដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ។ ព្រោះហេតុអ្វី ។ ព្រោះកាលកពឡីង្ការាហារនៅមានសេចក្តីត្រេកអរក្នុងអាហារនោះដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ក៏កើតឡើង ។ បានឮថា ពីរនាក់ស្វាមីភរិយាមិនមានចិត្តគិតសម្លឹងរំពៃរហូតអស់ ១២ ឆ្នាំ

ព្រោះភ័យកើតពីតិស្សៈព្រាហ្មណ៍ ។ ព្រោះហេតុអ្វី ។ ព្រោះមានអាហារតិច តែកាលភ័យស្ងប់រំងាប់ កោះតម្ពបណ្ណិទ្វីបប្រមាណ ១០០ យោជន៍ ក៏មានមន្តលតែមយ៉ាងដូចគ្នា ដោយមន្តលដែលកើតឡើងដល់អ្នកធ្វើ ដូច្នោះ កាលកំណត់ដឹងអាហារដែលជាមូលបានហើយ ក៏បានឈ្មោះថា ភិក្ខុកំណត់ដឹងរាគៈ គឺ សេចក្តីត្រេកអរដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ផង ដូចពោលមកនេះ ឈ្មោះថា **មូលបរិញ្ញា** ។

បទថា **នត្ថិ តំ សំយោជនំ** សេចក្តីថា សញ្ញោជនៈនោះមិនមាន ព្រោះអរិយសាវកលះធម៌ដែលមានទីតាំងតែមួយ ជាមួយធម៌ដែលគួរលះព្រមទាំងរាគៈនោះបាន ។ ទេសនានេះ ព្រះមានព្រះភាគត្រាស់ទុកជរាបដល់អនាគាមិមគ្គ ដោយប្រការដូច្នេះ ។ តែគួរចម្រើនវិបស្សនាក្នុងខន្ធ ៥ ដោយអំណាចនៃរូបជាដើមទាំងនោះឯង ហើយត្រាស់ជរាបដល់ព្រះអរហត្ត ដោយទ្រង់ព្រះតម្រិះថា ក៏ដោយហេតុត្រឹមប៉ុណ្ណេះ ភិក្ខុទាំងឡាយកុំបានដល់ទីបំផុតឡើយ ។

-ចប់អាហារទី ១ (កពឡីការាហារ)-

[២៤២] ក្នុងអាហារទី ២ (ផស្សាហារ) មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **និច្ចម្មា** បានដល់ ស្បែកដែលត្រូវបកចេញពីសរីរៈទាំងអស់ តាំងអំពីកដល់កជើង មានពណ៌ដូចគំនរផ្កាចារ សួរថា ក៏ព្រោះហេតុអ្វីឧបមានេះទើបទ្រង់មិនកាន់យកឧបមាដោយដំរី សេះ និងគោជាដើម តែទ្រង់កាន់យកឧបមាដោយមេគោដែលមិនមានស្បែក ។ ឆ្លើយថា ដើម្បីទ្រង់សម្តែងការៈដែលមិនអាចនឹងអត់ទ្រាំបាន ពិតណាស់ មាតុគ្រាមមិនអាចអត់ទ្រាំចំពោះទុក្ខវេទនាដែលកើតឡើងបាន ។ ដើម្បីទ្រង់សម្តែងថា **ផស្សាហារ** មិនមានកម្លាំង មានកម្លាំងខ្សោយ ដូច្នោះ ទើបទ្រង់នាំឧបមាមកប្រៀបធៀបប៉ុណ្ណោះ ។ បទថា **កុណ្ឌំ** បានដល់ ជញ្ជាំង មានជញ្ជាំងសិលាជាដើមណាមួយ ។ ឈ្មោះថា ពួកសត្វដែលតោងជញ្ជាំង បានដល់ សត្វ មានពីងពាង តុកកែ និងកណ្តុរជាដើម ។ បទថា **រុក្ខនិស្សិតា** បានដល់ សត្វតូចៗ មានខ្មូនល្អិតៗ ជាដើម ។ បទថា **ឧទកនិស្សិតា** បានដល់ សត្វក្នុងទឹក មានត្រី និងក្រពើជាដើម ។ បទថា **អាកាសនិស្សិតា** បានដល់ របោម មូស ក្អែក និងត្មាតជាដើម ។ បទថា **ខាទេយ្យុំ** បានដល់ ខាំចឹកស៊ី ។ មេគោនោះពិចារណាឃើញទីនោះៗ ថា ជាភ័យពីការខាំស៊ីរបស់បាណកសត្វ

ដែលមានទីប្រជុំអាស្រ័យកាយជាមូល មិនបានប្រាថ្នាសក្ការៈ និងសេចក្តីរាប់អានសម្រាប់ខ្លួន ទាំងមិនប្រាថ្នាការគក់ប្របាច់ខ្នង ការគក់ប្របាច់រាង-កាយ និងទឹកក្តៅ ។ ភិក្ខុក៏ដូច្នោះ ពិចារណាឃើញភ័យ គឺ ការទំពារស៊ីរបស់បាណកសត្វ គឺ កិលេសដែលមានផស្សាហារជាមូល រមែងមិនមានសេចក្តីត្រូវការដោយផស្សៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

បទថា **ផស្សេ ភិក្ខវេ អាហារេ បរិញ្ញាតេ** បានដល់ កាលកំណត់ដឹងដោយបរិញ្ញា ៣ ។ សួម្បីក្នុងទីនេះ លោកក៏កំណត់យកបរិញ្ញា ៣ ។ ក្នុងបរិញ្ញា ៣ ទាំងនោះ ការឃើញនូវកិច្ចរបស់នាមរូបព្រមទាំងបច្ច័យតាមសេចក្តីពិតយ៉ាងនេះថា ផស្សៈចាត់ជាសង្ខារក្ខន្ធ វេទនាដែលសម្បយុត្តដោយផស្សៈនោះ ចាត់ជាវេទនាខន្ធ សញ្ញាចាត់ជាសញ្ញាខន្ធ ចិត្តជាវិញ្ញាណក្ខន្ធ អារម្មណ៍ដែលជាវត្ថុនៃខន្ធទាំងនោះ ចាត់ជារូបខន្ធ ឈ្មោះថា **ញាតបរិញ្ញា** ។ ក្នុងបរិញ្ញាទាំង ៣ នោះឯង កាលភិក្ខុលើកនាមរូបឡើងកាន់ត្រៃលក្ខណ៍ ហើយពិចារណាឃើញថាជារបស់មិនទៀងជាដើម ដោយអំណាចនៃអនុ-បស្សនា ៧ ឈ្មោះថា **តីរណបរិញ្ញា** ។ ក៏ព្រះអរហត្តមគ្គ ដែលដកឆន្ទរាគៈក្នុងនាមរូបនោះឯងចេញ ឈ្មោះថា **បហានបរិញ្ញា** ។

បទថា **តិស្សោ វេទនា** សេចក្ដីថា កាលកំណត់ដឹងផស្សាហារដោយបរិញ្ញា ៣ យ៉ាងនេះហើយ វេទនា ៣ រមែងជាការកំណត់ដឹងហើយដូចគ្នា ព្រោះមានផស្សាហារនោះជាមូល និងព្រោះសម្បយុត្តដោយផស្សាហារនោះ ។ ដោយប្រការដូច្នេះ ជាការត្រាស់ទេសនាដរាបដល់ព្រះអរហត្ត ដោយអំណាចផស្សាហារ ។

ចប់អាហារទី ២ (ផស្សាហារ)

ក្នុងអាហារទី ៣ (មនោសញ្ចេតនាហារ) មានវិនិច្ឆ័យដូចតទៅនេះ

[២៤៣] បទថា **អង្គារកាសុ** បានដល់ រណ្ដៅរងើកភ្លើង ។ បទថា **កាសុ** លោកពោលសំដៅសេចក្ដីថា គំនរខ្លះ ថារណ្ដៅខ្លះ ក្នុងពាក្យនេះថា

**អង្គារកាសុំ អបរេ ផុណន្តិ នរា រុទន្តា**
**បរិទឌ្ឍគត្តា កយំ ហិ មំ វិន្ទតិ សុត**
**ទិស្វា បុច្ឆាមិ តំ មាតលិ ទេវសារថី ។**

ជនមួយពួកទៀតកម្ចាយគំនររងើកភ្លើង នរៈអ្នក
មានរាងកាយក្ដៅផ្សាស្រែកយំហើយ ភ័យមក

ដល់យើង ព្រោះឃើញសារថី នៃទេវសារថីមាតលី
យើងសូមសួរលោក ។

បទថា **កាសុ** លោកពោលសំដៅសេចក្តីថា **គំនរ** ក្នុងពាក្យនេះថា **កឹនុ សន្តរមានោវ កាសុំ ខណសិ សារថិ** នៃនាយសារថី ខ្ញុំនលោកញ៉ាប់រន្ធត់ជីករណ្តៅព្រោះហេតុអ្វីហ្ន៎ ។ លោកពោលសំដៅសេចក្តីថា **រណ្តៅ** សូម្បីក្នុងទីនេះក៏បំណងសេចក្តីថា **រណ្តៅ** នេះឯង ។ បទថា **សាធិកបោ-រិសា** បានដល់ លើសមួយជួរបុរស គឺ ប្រមាណ ៥ ហត្ថ ។ ដោយបទថា **វីតច្ចិកានំ វីតធូមានំ** នេះ លោកសម្តែងថា រណ្តៅរងើកភ្លើងនោះ មានការក្តៅខ្លាំង ។ ព្រោះថា កាលមានអណ្តាតភ្លើង ឬផ្សែង សភាពក្តៅក៏ខ្លាំងខ្យល់តាំងឡើង សភាពក្តៅរមែងថយចុះ កាលមានអណ្តាតភ្លើង ឬផ្សែងនោះ តែមិនមានខ្យល់ សភាពក្តៅរមែងខ្លាំង ។ បទថា **អារកាវស្ស** ប្រែថា គប្បីមានក្នុងទីឆ្ងាយតែម្យ៉ាង ។

ក្នុងពាក្យថា **ឯវមេវ ខោ** នេះ មានការប្រៀបធៀបដោយឧបមាដូចតទៅនេះ គប្បីឃើញវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដូចរណ្តៅរងើកភ្លើង បុថុជ្ជនល្ងង់ខ្លៅអាស្រ័យវដ្តៈ ដូចបុរសអ្នកចង់រស់ កុសលកម្ម និង

អកុសលកម្ម ដូចបុរស ២ នាក់ដែលមានកម្លាំង វេលាដែលបុថុជ្ជនធ្វើកម្ម ដូចវេលាដែលបុរស ២ នាក់ ចាប់បុរសនោះត្រង់ដៃម្ខាងម្នាក់ ទាញទម្លាក់ក្នុងរណ្តៅរងើកភ្លើង ពិតណាស់ កម្មដែលបុថុជ្ជនល្ងង់ខ្លៅធ្វើហើយ រមែងនាំទៅរកបដិសន្ធិ វដ្តទុក្ខដែលមានកម្មជាហេតុ គប្បីជ្រាប ដូចទុក្ខដែលមានរណ្តៅរងើកភ្លើងជាហេតុ ។

បទថា **បរិញ្ញាតេ** បានដល់ កំណត់ដឹងដោយបរិញ្ញា ៣ ក៏ការប្រកបរឿងបរិញ្ញាក្នុងទីនេះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងផស្សៈនុ៎ះឯង ។

បទថា **តិស្សោ តណ្ហា** បានដល់ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ តណ្ហាទាំងនេះ រមែងជាការកំណត់ដឹងហើយដូចគ្នា ។ ព្រោះហេតុអ្វី ។ ព្រោះមនោសញ្ចេតនា មានតណ្ហាជាមូល ព្រោះថា កាលលះហេតុមិនទាន់បាន ក៏លះផស្សៈមិនបាន ។ ដោយប្រការដូច្នេះ ជាការត្រាស់ទេសនាដរាបដល់ព្រះអរហត្ត ដោយអំណាចមនោសញ្ចេតនាហារ ។

ចប់អាហារទី ៣ (**មនោសញ្ចេតនាហារ**)

[២៤៤] ក្នុងអាហារទី ៤ (វិញ្ញាណាហារ) មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **អាគុចារី** បានដល់ អ្នកប្រព្រឹត្តអាក្រក់ គឺ អ្នកធ្វើខុស ។ ដោយបទថា **កថំ សោ បុរិសោ** ព្រះរាជាត្រាស់សួរថា បុរសនោះយ៉ាងណា គឺ ចិញ្ចឹមជីវិតដូចម្តេច ។ បទថា **តថេវ ទេវ ជីវតិ** សេចក្តីថា សូម្បីក្នុងកាលឥឡូវនេះ គេក៏ចិញ្ចឹមជីវិតដូចកាលមុនទុំះឯង ។

សូម្បីក្នុងពាក្យថា **ឯវមេវ ខោ** នេះ មានការប្រៀបធៀបដោយឧបមាដូចតទៅនេះ ។ ពិតណាស់ កម្ម គប្បីឃើញដូចព្រះរាជា បុថុជ្ជនល្ងង់ខ្លៅអាស្រ័យវដ្ដៈ ដូចបុរសអ្នកប្រព្រឹត្តអាក្រក់ បដិសន្ធិវិញ្ញាណដូចជាលំពែង ៣០០ ដើម វេលាដែលព្រះរាជា គឺ កម្ម ចាប់បុថុជ្ជនអ្នកអាស្រ័យវដ្ដៈបោះទៅក្នុងបដិសន្ធិ ដូចវេលាដែលព្រះរាជាចាប់បុរសអ្នកប្រព្រឹត្តអាក្រក់ ត្រាស់បង្គាប់ថា ចូរប្រហារដោយលំពែង ៣០០ ដើម ។ ក្នុងឧបមាទាំងនោះ បដិសន្ធិវិញ្ញាណ ប្រៀបដូចលំពែង ៣០០ ក៏ពិត តែទុក្ខ រមែងមិនមានក្នុងលំពែង ទុក្ខ មានត្រង់មុខរបួសដែលត្រូវលំពែងចាក់ជាមូល ទុក្ខក៏ដូចគ្នា រមែងមិនមានសូម្បីក្នុងបដិសន្ធិ តែកាលវិបាកឲ្យបដិសន្ធិ វិបាកទុក្ខក្នុងបច្ចុ-ប្បន្ន រមែងដូចជាទុក្ខ មានមុខរបួសដែលត្រូវលំពែងចាក់ជាមូល ។

បទថា **បរិញ្ញាតេ** បានដល់ កំណត់ដឹងដោយបរិញ្ញា ៣ ។ សូម្បីក្នុងទីនេះ ការប្រកបរឿងបរិញ្ញា គប្បីជ្រាបតាមន័យដែលពោលហើយក្នុងផស្សាហារនុ៎ះឯង ។ បទថា **នាមរូបំ** បានដល់ ព្រោះមានវិញ្ញាណជាបច្ច័យទើបកើតមាននាមរូប ព្រោះកាលកំណត់ដឹងវិញ្ញាណ រមែងជាការកំណត់ដឹងនាមរូបនោះដូចគ្នា ព្រោះមានវិញ្ញាណនោះជាបច្ច័យ និងព្រោះកើតព្រមគ្នា ។ ដោយប្រការដូច្នេះ ជាការត្រាស់ទេសនាដរាបដល់ព្រះអរហត្ត សូម្បីដោយអំណាចវិញ្ញាណាហារនុ៎ះឯង ។

ចប់អដ្ឋកថា បុត្តមំសសូត្រទី ៣

# អដ្ឋកថា

## អត្ថិរាគសូត្រទី ៤

ក្នុង *អត្ថិរាគសូត្រទី ៤* មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៤៦] ពាក្យថា **រាគោ** ជាដើម ជាឈ្មោះរបស់លោភៈនុ៎ះឯង ។ ពិតណាស់ លោភៈនោះ ហៅថា **រាគៈ** ដោយអំណាចសេចក្តីត្រេកអរ , ហៅថា **នន្ទិ** ដោយអំណាចសេចក្តីក្រេតក្រេន , ហៅថា **តណ្ហា** ដោយអំណាចសេចក្តីប្រាថ្នា ។ បទថា **បតិដ្ឋិតំ តត្ថ វិញ្ញាណំ វិរូឡ្ហំ** សេចក្តីថា តាំងនៅនិងលូតលាស់ ព្រោះអាចធ្វើកម្មឲ្យប្រព្រឹត្តទៅ ហើយនាំបដិសន្ធិមក ។ បទថា **យត្ថ** ជាសត្តមីវិភត្តិប្រើក្នុងអត្ថនៃវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ម្យ៉ាងទៀត បទថា **យត្ថ** នេះ ជាសត្តមីវិភត្តិប្រើក្នុងបទដើមៗ ក្នុងទីគ្រប់កន្លែង ។ បទថា **អត្ថិ តត្ថសង្ខារានំ វុឌ្ឍិ** នេះ លោកពោលសំដៅយកសង្ខារដែលមានវដ្តៈជាហេតុតទៅ ។ របស់នាមរូបដែលតាំងនៅក្នុងវិបាក-វដ្តនេះ ។ បទថា **យត្ថ អត្ថិ អាយតឹ បុនព្ភវាភិនិព្វត្តិ** សេចក្តីថា ការកើតក្នុងភពថ្មីតទៅ មាននៅក្នុងទីណា ។

[២៤៧] ក្នុងពាក្យថា *ឯវមេវ ខោ* នេះ មានការប្រៀបធៀបដោយឧបមា ដូចតទៅនេះ ៖

ក៏កម្មដែលកើតព្រម និងកម្មដែលឧបត្ថម្ភ (សហកម្ម និងសម្ភារកម្ម) ដូចជាងជ្រលក់ និងជាងគំនូរ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដូចផ្ទាំងក្តារជញ្ជាំង និងផ្ទាំងសំពត់ កម្មដែលជាតួតាក់តែង រមែងសាងរូបក្នុងភពទាំងឡាយ ដូចជាងជ្រលក់ និងជាងគំនូរ រមែងសាងរូបត្រង់ផ្ទាំងក្តារជាដើមដែលបរិសុទ្ធិ ក្នុងឧបមាទាំងនោះ បុគ្គលខ្លះកាលធ្វើកម្ម រមែងធ្វើដោយចិត្តដែលជាញាណវិប្បយុត្ត កម្មនោះ (របស់គេ) កាលនឹងសាងរូប រមែងមិនឲ្យសេចក្តីសម្បូរណ៍នៃរូបសម្រាប់ចក្ខុជាដើម សាងតែរូបដែលមានវណ្ណៈមិនល្អ ទ្រង់ទ្រាយមិនល្អ មិនគួរពេញចិត្ត សូម្បីរបស់បិតាមាតា ប្រៀបដូចរូបដែលជាងគំនូរមិនឆ្លាតសាងឡើង ជារូបវិកល ខ្វះខាត មិនគួរពេញចិត្ត ដូច្នោះ ។ មួយទៀត បុគ្គលខ្លះកាលធ្វើកម្ម រមែងធ្វើដោយចិត្តដែលជាញាណសម្បយុត្ត កម្មនោះ (របស់គេ) កាលសាងរូប រមែងឲ្យសេចក្តីសម្បូរណ៍នៃរូបសម្រាប់ចក្ខុជាដើម សាងតែរូបដែលមានវណ្ណៈល្អ ទ្រង់ទ្រាយល្អ ប្រដាប់តាក់តែងខ្លួនហើយ ប្រៀបដូចរូបដែលជាងគំនូរដ៏ឆ្លាតសាងឡើង

ជារូបល្អ ទ្រង់ទ្រាយល្អ ជាគួរជាទីពេញចិត្ត ដូច្នោះ ។

ក៏ក្នុងឧបមានេះ គប្បីជ្រាបថា លោកសង្គ្រោះអាហារចូលជាមួយវិញ្ញាណ គឺ រវាងអាហារ និងនាមរូប ជាសន្ធិមួយ ឈ្មោះថា **វិបាកវិថី** , សង្គ្រោះចូលជាមួយរូប រវាងនាមរូប និងសង្ខារ ជាសន្ធិមួយ , រវាងសង្ខារ និងភពតទៅ ជាសន្ធិមួយ ។

[២៤៩] បទថា **កូដាគារំ** (ផ្ទះកំពូល) បានដល់ ផ្ទះកំពូលមួយដែលគេសាងទុក ។ បទថា **កូដាគារសាលា** បានដល់ សាលាមានកំពូល ២ ដែលគេសាងទុក ។ ក្នុងពាក្យថា **ឯវមេវ ខោ** នេះ គប្បីជ្រាបថា កម្មរបស់ព្រះខីណាស្រព ក៏ស្មើនឹងរស្មីនៃព្រះអាទិត្យ ក៏រស្មីនៃព្រះអាទិត្យ មានតែរស្មីនោះតាំងនៅតែម្យ៉ាង ព្រោះមិនមាន ទើបឈ្មោះថា មិនតាំងនៅ ។ ព្រោះមិនមានទីតាំងនោះឯង កម្មរបស់ព្រះខីណាស្រព ទើបមិនតាំងនៅ ។

ពិតណាស់ កាយជាដើមរបស់ព្រះខីណាស្រពនោះមាននៅ តែកម្មដែលព្រះខីណាស្រពទាំងនោះធ្វើ មិនចាត់ជាកុសល និងអកុសល តាំងនៅត្រឹមតែជាកិរិយា មិនមានវិបាក កម្មរបស់លោកឈ្មោះថា មិនតាំងនៅ ព្រោះមិនមានទីតាំងនោះឯង ។

ចប់អដ្ឋកថា អត្ថិរាគសូត្រទី ៤

# អ ដ្ឋ ក ថា

## នគរសូត្រទី ៥

ក្នុង នគរសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៥១] ក្នុងពាក្យថា នាមរូបេ ខោ សតិ វិញ្ញាណំ នេះ គួរនឹងពោលថា សង្ខារេសុ សតិ វិញ្ញាណំ និងថា វិជ្ជាយ សតិ សង្ខារា សូម្បីពាក្យទាំងពីរនោះ លោកក៏មិនពោល ។ ព្រោះហេតុអ្វី ។ ព្រោះអវិជ្ជា និងសង្ខារជាភពទី ៣ វិបស្សនានេះ មិនភ្ជាប់អវិជ្ជា និងសង្ខារនោះ ។ ពិតណាស់ ព្រះមហាបុរសទ្រង់ចាប់យកយ៉ាងក្រៃលែងនូវបច្ចុប្បន្នភព ដោយអំណាចបញ្ចវោការភព (ភពដែលមានខន្ធ ៥) ដូច្នេះឯង ។

សួរថា កាលមិនឃើញអវិជ្ជា និងសង្ខារ ក៏មិនអាចជាព្រះពុទ្ធបានមិនមែនឬ ។

ឆ្លើយថា ពិតមែន មិនអាចកើតបាន តែព្រះពុទ្ធនេះទ្រង់ឃើញអវិជ្ជា និងសង្ខារនោះ ដោយអំណាចភព ឧបាទាន និងតណ្ហានោះឯង ព្រោះដូច្នោះទើបប្រៀបដូចបុរសដេញតាមសត្វទន្សង ឃើញសត្វទន្សងនោះចូលរន្ធ ក៏ទៅជីកត្រង់រន្ធដែលសត្វទន្សងចូល ចាប់សត្វទន្សងបាន ក៏ចៀសចេញទៅ

មិនជីកត្រង់ទីដទៃ ។ ព្រោះអ្វី ។ ព្រោះមិនមានអ្វី យ៉ាងណា សូម្បីព្រះ-មហាបុរសក៏ដូច្នោះ ប្រថាប់អង្គុយត្រង់ពោធិបល្ល័ង្ក ស្វែងរកតាំងពីជរា និងមរណៈថា នេះជាបច្ច័យនៃវត្ថុនេះ នេះជាបច្ច័យនៃវត្ថុនេះ ដូចបុរសដេញតាមសត្វទន្សង ទ្រង់ឃើញបច្ច័យរហូតដល់នាមធម៌ និងរូបធម៌ សូម្បីកាលស្វែងរកបច្ច័យរបស់នាមរូបនោះ ក៏បានឃើញចំពោះវិញ្ញាណប៉ុណ្ណោះ ។ បន្ទាប់ពីនោះ ទើបទ្រង់ត្រឡប់ចម្រើនវិបស្សនាថា ធម៌ប្រមាណប៉ុណ្ណោះជាដំណើរការពិចារណាដោយអំណាចបញ្ចវោការភព ។ បច្ច័យ គឺ អវិជ្ជា និងសង្ខារមាន ដូចត្រង់ទ្វេទទេខាងមុខដែលមិនទាន់ត្រូវទម្លាយ ទ្រង់មិនកាន់យកបច្ច័យ គឺ អវិជ្ជា និងសង្ខារនោះថា មិនគួរពិចារណាចែកជាចំណែកៗ ព្រោះវិបស្សនា លោកកាន់យកក្នុងកាលខាងក្រោយហើយ ។

បទថា **បច្ចុទាវត្តតិ** បានដល់ វិលត្រឡប់ ។

សួរថា ក៏ក្នុងទីនេះវិញ្ញាណប្រភេទណាវិលត្រឡប់ ។

ឆ្លើយថា បដិសន្ធិវិញ្ញាណក៏មាន វិបស្សនាវិញ្ញាណក៏មាន ។

ក្នុង ២ យ៉ាងនោះ បដិសន្ធិវិញ្ញាណ រមែងវិលត្រឡប់ព្រោះបច្ច័យ វិបស្សនាវិញ្ញាណ រមែងវិលត្រឡប់ព្រោះអារម្មណ៍ សូម្បីវិញ្ញាណទាំងពីរក៏មិនកន្លងនាមរូបទៅបាន គឺ មិនទៅកាន់ទីដទៃអំពីនាមរូប ។

ក្នុងពាក្យថា **ឯត្តាវតា ជាយេថ វា** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ថា វិញ្ញាណជាបច្ច័យដល់នាមរូប នាមរូបជាបច្ច័យដល់វិញ្ញាណ សូម្បីទាំងពីរផ្សេងគ្នា ក៏ជាបច្ច័យដល់គ្នានិងគ្នា , នាមរូបគប្បីកើត ឬគប្បីបដិសន្ធិដោយហេតុត្រឹមតែប៉ុណ្ណេះ ។ ខាងមុខអំពីនេះ បាននាមរូបដទៃណាមួយនឹងកើត ឬបដិសន្ធិ ។ នាមរូបនោះឯង រមែងកើត និងរមែងបដិសន្ធិមិនមែនឬ ។ លុះទ្រង់សម្តែងបទទាំងប្រាំ ព្រមដោយចុតិ និងបដិសន្ធិយ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងសេចក្តីដដែលនោះថា **ឯត្តាវតា** ទៀត ទើបត្រាស់ថា គឺ វិញ្ញាណមានព្រោះនាមរូបជាបច្ច័យ នាមរូបមានព្រោះវិញ្ញាណជាបច្ច័យនោះ ដើម្បីនឹង សម្តែងជាតិជរា និងមរណៈក្នុងអនាគត ដែលមាននាមរូបជាមូល ព្រោះវិញ្ញាណជាបច្ច័យដោយអំណាចបច្ចយាការដោយអនុ-លោម ទើបត្រាស់ពាក្យមានជាដើមថា **នាមរូបបច្ចយា សឡាយតនំ** ដូច្នេះ ។

[២៥៣] បទថា **អញ្ចសំ** (ផ្លូវ) ជាវេវចនៈនៃមគ្គនុ៎ះឯង ។ បទថា **ឧទ្ទាបវន្តំ** បានដល់ ប្រកបដោយវត្ថុ គឺ កំពែង ដែលបានហៅហារថា **ឧទាបនំ** ព្រោះលើកឡើងពីអណ្តូងទឹក ។ បទថា **រមណីយំ** បានដល់ ជាទីរីករាយ ដល់ព្រមដោយមូលនៃទ្វារទាំង ៤ ដោយជុំវិញ និងវត្ថុផ្សេងៗក្នុងខាងក្នុង ។ បទថា **មាបេហិ** (ចូរសាង) សេចក្តីថា ចូរបញ្ចូនមហាជន

ទៅឲ្យសាងទីនៅ ។ បទថា **មាបេយ្យ** សេចក្ដីថា គប្បីឲ្យធ្វើទីនៅ ។ ពិតណាស់ កាលសាងក្រុង គប្បីបញ្ជូនមនុស្ស ១៨ កោដិ ទៅមុន ហើយត្រាស់សួរថា ពេញល្អហើយឬ កាលគេទូលថា មិនទាន់ពេញ ទើបបញ្ជូនត្រកូល ៥ ត្រកូលដទៃទៀតទៅ លុះត្រាស់សួរទៀត កាលគេទូលថា មិនទាន់ពេញ ទើបបញ្ជូនត្រកូល ៥៥ ត្រកូលដទៃទៀតទៅ លុះសួរទៀត កាលគេទូលថា មិនទាន់ពេញ ទើបបញ្ជូនត្រកូល ៣០ ត្រកូលដទៃទៀតទៅ លុះត្រាស់សួរទៀត កាលគេទូលថា មិនទាន់ពេញ ទើបបញ្ជូនត្រកូល ១,០០០ ត្រកូលដទៃទៀតទៅ លុះត្រាស់សួរទៀត កាលគេទូលថា មិនទាន់ពេញ ទើបបញ្ជូនត្រកូល ១១ នហុត[១]ត្រកូលដទៃទៀតទៅ លុះត្រាស់សួរទៀត កាលគេទូលថា មិនទាន់ពេញ ទើបបញ្ជូនត្រកូល ៨៤,០០០ ត្រកូលដទៃទៀតទៅ កាលត្រាស់សួរទៀតថា ពេញហើយឬ ទើបទូលថា បពិត្រមហារាជ ត្រាស់អ្វីនគរដ៏ធំ មិនចង្អៀត ទ្រង់មិនអាចនឹងបញ្ជូន ត្រកូលទៅឲ្យពេញដោយន័យនេះបាន គប្បីត្រាស់បង្គាប់ឲ្យវាយស្គរ ស្រែកប្រកាសថា នគររបស់យើងសម្បូរណ៍ដោយសម្បត្តិនេះនិងនេះ អ្នកដែលប្រាថ្នានឹងនៅក្នុងទីនោះ ចូរទៅតាមសប្បាយចុះ នឹងបានទទួលការរក្សាយ៉ាងនេះ និងយ៉ាងនេះ គប្បី

---

១ នហុត= ១០,០០០ ។

ត្រាស់បង្គាប់ថា ពួកលោកចូរឲ្យស្រែកប្រកាស សរសើរគុណនៃនគរ និង ការបានទទួលការបរិហារលោកដល់អ្នកស្រុក ។ គេគប្បីធ្វើយ៉ាងនោះ ។ លំដាប់នោះ មនុស្សទាំងឡាយបានឮគុណតម្លៃរបស់នគរ និងការបានទទួល ការបរិហារលោក ប្រជុំគ្នាគ្រប់ទិសទាំងពួង ធ្វើនគរឲ្យពេញ ។ លុះសម័យ តមក នគរនោះក៏ស្តុកស្តម្ភសម្បូរ លោកពោលសំដៅយកសេចក្តីនោះ ទើប ពោលថា នគររបស់ព្រះអង្គនោះ លុះសម័យតមក ស្តុកស្តម្ភទូលំទូលាយ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឥទ្ធំ** បានដល់ ស្តុកស្តម្ភ បាយត្រីរក បានងាយ ។ បទថា **ផីតំ** បានដល់ សម្បូរដោយសម្បត្តិគ្រប់យ៉ាង ។ បទថា **ពហុជញ្ញំ** ប្រែថា ដែលបុគ្គលពួកច្រើនគប្បីដឹង ឬជាប្រយោជន៍ដល់ជន ពួកច្រើន ។ បទថា **អាកិណ្ណមនុស្សំ** (កុះករដោយមនុស្ស) បានដល់ មាន មនុស្សកុះករ គឺ នៅចង្អៀត ។ បទថា **វុឌ្ឍិវេបុល្លប្បត្តំ** បានដល់ សេចក្តី ចម្រើន និងសេចក្តីបរិបូណ៌ គឺ ដល់ភាពជានគរយ៉ាងប្រសើរ និងបរិបូណ៌ អធិប្បាយថា ជានគរដ៏ប្រសើរក្នុងម៉ឺនចក្រវាឡ ។

ក្នុងបទថា **ឯវមេវ ខោ** នេះ មានការប្រៀបធៀបដោយឧបមា ដូច តទៅនេះ ៖

ក៏ព្រះមហាបុរសអ្នកបំពេញព្រះបារមី ចាប់ផ្ដើមតាំងពីបាទមូលនៃព្រះពុទ្ធទីបង្ករ គប្បីឃើញដូចបុរសអ្នកត្រាច់ទៅក្នុងព្រៃធំ ការឃើញមគ្គប្រកបដោយអង្គ ៨ ព្រមដោយវិបស្សនា ក្នុងចំណែកខាងដើមនៃព្រះមហាសត្វដែលប្រថាប់អង្គុយក្នុងពោធិបល្ល័ង្កដោយលំដាប់ គប្បីឃើញដូចបុរសឃើញផ្លូវ ដែលពួកមនុស្សពីមុននាំគ្នាដើរមក ការដែលព្រះមហាសត្វឃើញលោកុត្តរមគ្គ ទីបំផុតនៃវិបស្សនាជាន់ខ្ពស់ ដែលព្រះអង្គធ្លាប់ប្រព្រឹត្តមកគប្បីឃើញដូចបុរសកំពុងដើរផ្លូវ ដែលដើរទៅបានម្នាក់ឯងនោះ ឃើញផ្លូវធំខាងក្រោយ ការដែលព្រះតថាគតទ្រង់ឃើញនគរ គឺ ព្រះនិព្វាន គប្បីឃើញដូចបុរសដើរផ្លូវនោះ ទៅឃើញផ្លូវនគរខាងមុខ តែក្នុងឧបមាទាំងនេះ នគរខាងក្រៅ អ្នកដទៃឃើញ អ្នកដទៃសាងឲ្យជាទីនៅរបស់មនុស្ស ។ ព្រះនគរ គឺ ព្រះនិព្វាន ព្រះសាស្ដាទ្រង់ឃើញដោយព្រះអង្គឯង ទ្រង់ធ្វើឲ្យជាទីនៅដោយព្រះអង្គឯង វេលាដែលព្រះតថាគតទ្រង់ឃើញមគ្គ ៤ ដូចវេលាដែលបុរសនោះឃើញទ្វារទាំង ៤ , វេលាដែលព្រះតថាគតស្ដេចកាន់ព្រះនិព្វានដោយមគ្គ ៤ ដូចវេលាបុរសនោះចូលទៅកាន់ព្រះនគរតាមទ្វារទាំង ៤ , វេលាដែលព្រះតថាគតទ្រង់កំណត់កុសលធម៌ជាង ៥០ ដោយបច្ចវេក្ខណញ្ញាណ ដូចវេលាដែលបុរសនោះកំណត់វត្ថុខាងក្នុងព្រះនគរ , វេលាដែល

ព្រះសាស្តាស្តេចចេញចាកផលសមាបត្តិហើយត្រួតមើលវេនេយ្យសត្វ ដូចវេលាដែលបុរសនោះស្វែងរកត្រកូល ដើម្បីធ្វើឲ្យជាទីអាស្រ័យរបស់នគរ , វេលាដែលព្រះមានព្រះភាគ ដែលមហាព្រហ្មទូលអារាធនា ទ្រង់ឃើញព្រះ-អញ្ញាកោណ្ឌញ្ញត្ថេរ ដូចវេលាព្រះរាជាដែលបុរសនោះទូលឲ្យទ្រង់ជ្រាបបានទ្រង់ឃើញកុដុម្ពីធំម្នាក់ , វេលាដែលព្រះមានព្រះភាគស្តេចទៅកាន់ផ្លូវ ១៨ យោជន៍ ក្នុងបច្ឆាភត្តថ្ងៃមួយ ហើយស្តេចទៅកាន់ព្រៃឥសិបតនមិគទាយ-វ័ន ក្រុងពារាណសី ហើយទ្រង់សម្តែងធម៌ ធ្វើព្រះថេរៈឲ្យជាកាយសក្ខីក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ដូចវេលាដែលព្រះរាជាត្រាស់បង្គាប់ឲ្យហៅកុដុម្ពីធំម្នាក់មក ហើយបញ្ជូនទៅដោយព្រះតម្រាស់ថា ចូរសាងព្រះនគរឲ្យបរិបូណ៌ វេលាកាលព្រះតថាគតទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ឲ្យព្រះថេរៈតាំងនៅក្នុងសោតាបត្តិផល ព្រមជាមួយនឹងព្រហ្ម ១៨ កោដិ ដូចវេលាដែលកុដុម្ពីធំម្នាក់ នាំមនុស្ស ១៨ កោដិ ចូលទៅនៅអាស្រ័យព្រះនគរ ព្រះអង្គត្រាស់នគរនោះឲ្យជានគរ គឺ ព្រះនិព្វានយ៉ាងនេះមុន បន្ទាប់ពីនោះបានត្រាស់សួរថា នគរបរិបូណ៌ឬ កាលបុរសនោះក្រាបទូលថា នៅមិនទាន់បរិបូណ៌ទេ វេលាដែលព្រះតថាគតទ្រង់សម្តែងអនត្តលក្ខណសូត្រជាដើម តាំងពីថ្ងៃទី ៥ ( ៥ កេច ខែអាសាឡ្ហ ឆ្នាំជំបូងដែលត្រាស់ដឹង) ទ្រង់ធ្វើជនប្រមាណប៉ុណ្ណោះ

គឺ ចាប់តាំងពីព្រះបញ្ចវគ្គិយ , កុលបុត្រ ៥៥ នាក់ មានយសកុលបុត្រជាប្រមុខ , ភទ្ទវគ្គីយ៍ ៣០ , ជដិល ១,០០០ , អ្នកក្រុង រាជគ្រឹះ ១១ នហុត មានព្រះបាទពិម្ពិសារជាប្រមុខ , សត្វ ៨៤,០០០ អនុមោទនាដោយតិរោកុឌ្ឍសូត្រ ឲ្យធ្លាក់ចុះកាន់អរិយមគ្គ ហើយទ្រង់បញ្ចូនចូលនគរ គឺ ព្រះនិព្វាន ដូចបញ្ចូនត្រកូល ៥ ត្រកូលជាដើម រហូតដល់ ៨៤,០០០ ត្រកូល កាលដូច្នោះ ដោយន័យនោះ ការដែលព្រះធម្មកថិកអង្គុយប្រកាសគុណនៃព្រះនិព្វាន និងអានិសង្សនៃការលះបង់ជាតិកន្ទារជាដើម របស់អ្នកសម្រេចព្រះនិព្វាន ក្នុងទីនោះៗ ៨ ថ្ងៃ ក្នុងមួយខែ ដូចកាលនគរមិនទាន់ពេញ ក៏វាយស្គរប្រកាសគុណរបស់នគរ និងដូចការប្រកាសបរិហារលោករបស់ត្រកូលទាំងឡាយ តអំពីនោះ គប្បីឃើញកុលបុត្រទាំងឡាយរកប្រមាណមិនបាន ស្តាប់ធម្មកថាក្នុងទីនោះៗ ហើយចេញចាកត្រកូលនោះ ចាប់ផ្តើមបព្វជ្ជា បដិបត្តិអនុលោមបដិបទាប្រជុំចុះក្នុងព្រះនិព្វាន ដូចមនុស្សទាំងឡាយមកពីគ្រប់ទិសទាំងពួង ប្រជុំចុះក្នុងព្រះនគរ ។

បទថា **បុរាណមគ្គំ** (ផ្លូវចាស់) បានដល់ អរិយមគ្គមានអង្គ ៨ ។ ពិតណាស់ អរិយមគ្គនេះ ក្នុង**បវារណាសូត្រ** លោកពោលថា **អនុប្បន្នមគ្គោ** ដោយអត្ថថា មិនប្រព្រឹត្តទៅ ក្នុងសូត្រនេះ លោកពោលថា **បុរាណមគ្គោ**

ដោយអត្ថថា មិនប្រើប្រាស់ ។ បទថា **ព្រហ្មចរិយំ** បានដល់ ពាក្យទូន្មាន ទាំងអស់ដែលសង្គ្រោះដោយសិក្ខា ៣ ។ បទថា **ឥទ្ធំ** បានដល់ ចម្រើន គឺ មានកិច្ចាហារផាយ ដោយសេចក្ដីត្រេកអរក្នុងឈាន ។ បទថា **ផីតំ** បាន ដល់ សម្បូរដោយហេតុ គឺ អភិញ្ញា ។ បទថា **វិត្ថារិកំ** បានដល់ ទូលាយ ។

បទថា **ពាហុជញ្ញំ** បានដល់ ជនច្រើនគ្នាចេះដឹង ។ បទថា **យាវ-ទេវមនុស្សេហិ សុប្បកាសិតំ** សេចក្ដីថា ព្រះតថាគតទ្រង់ប្រកាសល្អហើយ គឺ ទ្រង់សម្ដែងល្អហើយក្នុងរវាងនេះ រហូតដល់ពួកទេវតា និងមនុស្សទាំង ឡាយ ដែលមានកំណត់ក្នុងម៉ឺនចក្រវាឡនុ៎ះឯង ។

ចប់អដ្ឋកថា ឆគរសូត្រទី ៥

# អ ដ្ឋ ក ថា

## សម្មសសូត្រទី ៦

ក្នុង *សម្មសសូត្រទី ៦* មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៥៤] បទថា *អាមន្តេសិ* សេចក្តីថា សួរថា ព្រោះហេតុអ្វី ទើបត្រាស់ហៅ ។

ឆ្លើយថា ព្រោះព្រះធម្មទេសនាសុខុម នាំត្រៃលក្ខណ៍មកប្រាកដ ។

បានឮមកថា ក្នុងជនបទនោះ ពួកមនុស្សជាអ្នកមានហេតុផល មានបញ្ញា បានឮថា ភោជនាហារទាំងឡាយក្នុងជនបទនោះទន់ល្អិត ។ កាលប្រជាជនបរិភោគភោជនាហារទាំងនោះ បញ្ញាក៏ចម្រើន ពួកគេអាចចាក់ធ្លុះធម្មកថាដ៏ជ្រាលជ្រៅដែលនាំត្រៃលក្ខណ៍មកបាន ព្រោះហេតុនោះឯង ព្រះមានព្រះភាគទើបបានត្រាស់ព្រះសូត្រដ៏ជ្រាលជ្រៅសូម្បីដទៃៗ មានជាដើមយ៉ាងនេះ គឺ មហាសតិប្បដ្ឋានសូត្រ មហានិទានសូត្រ អានេញ្ជសប្បាយសូត្រ ក្នុងទីឃនិកាយ និងមជ្ឈិមនិកាយ ចូឡនិទានសូត្រជាដើមក្នុងសំយុត្តនិកាយ ក្នុងជនបទនោះឯង ។

បទថា *សម្មសថ នោ* (បានពិចារណាខ្លះឬទេ) បានដល់ បានពិចារណា

ឬ ។ បទថា **អន្តរំ សម្ផស្សំ** បានដល់ ពិចារណាបច្ច័យខាងក្នុង ។ បទថា **ន សោ ភិក្ខុ ភគវតោ ចិត្តំ អារាធេសិ** សេចក្តីថា ភិក្ខុនោះមិនព្យាករណ៍យ៉ាងនោះ កាលព្យាករណ៍ដោយអំណាចអាការ ៣២ ទើបមិនអាចញុំាងព្រះអធ្យាស្រ័យរបស់ព្រះមានព្រះភាគ ព្រះអង្គមានព្រះបំណងនឹងឲ្យព្យាករណ៍ដោយអំណាចបច្ចយាការ ។

[២៥៥] បទថា **ឯតទវោច** សេចក្តីថា ទេសនាមិនទៅតាមអនុសន្ធិបានត្រាស់ពាក្យនេះ ដើម្បីទេសនាពាក្យនោះទៅតាមអនុសន្ធិ ។ បទថា **តេនហានន្ទ សុណាថ** នេះ ជាបទមិនផ្សេងគ្នាក្នុងពុទ្ធវចនៈ គឺ ព្រះត្រៃបិដកពិតណាស់ ក្នុងទីដទៃ ឈ្មោះថា ពាក្យដែលពោលយ៉ាងនេះមិនមាន ។

[២៥៦] បទថា **ឧបធិនិទានំ** បានដល់ មានឧបធិ គឺ ខន្ធជាហេតុពិតហើយ ខន្ធ ៥ ក្នុងទីនេះ លោកហៅថា ឧបធិ ។

[២៥៨] **ឧប្បជ្ជតិ** ប្រែថា រមែងកើត ។

បទថា **និវិសតិ** (រមែងតាំងនៅ) សេចក្តីថា រមែងតាំងនៅដោយអំណាចការប្រព្រឹត្តរឿយៗ ។

បទថា **យំ លោកេ បិយរូបំ សាតរូបំ** សេចក្តីថា រូបណាមានសភាពជាទីស្រឡាញ់ និងជាទីត្រេកអរក្នុងលោក ។ គប្បីជ្រាបវិនិច្ឆ័យក្នុង

ក្នុងពាក្យថា ចក្ខុំ លោកេ ជាដើមដូចតទៅនេះ

ពិតណាស់ សត្វទាំងឡាយក្នុងលោកប្រកាន់មាំ ដោយប្រកាន់ថាជារបស់យើងក្នុងចក្ខុជាដើម តាំងនៅក្នុងសម្បត្តិ (សម្បត្តិគឺកព) សម្គាល់បសាទរូបទាំង ៥ ដែលថាផូរផង់ដោយទំនងនៃការប្រកាន់ចក្ខុរបស់ខ្លួនថាជានិមិត្តក្នុងរង្វង់កញ្ចក់ជាដើម ដូចសីហបញ្ជរកែវមណី ដែលលើកឡើងក្នុងវិមានមាស រមែងសម្គាល់ចក្ខុបសាទនោះដូចទងប្រាក់ និងខ្សែសង្វារសម្គាល់ឃានបសាទ ដែលបានវោហារថា តុង្គនាសា (ច្រមុះខ្ពស់) ដូចបង្ហិនថ្មហរិតាលដែលគេដាក់ទុក សម្គាល់ជិវ្ហាបសាទទន់ល្មើយ ជាទីទទួលរសឆ្ងាញ់ ដូចសំពត់កម្ពលទន់ សម្គាល់កាយបសាទដូចគ្រាប់សាលៈ និងខ្លោងទ្វារមាស សម្គាល់ចិត្តថា ធំក្រៃលែង មិនដូចគ្នានឹងចិត្តរបស់ជនពួកដទៃ ។

[២៥៩] បទថា និច្ចតោ អទ្ទក្ខុំ សេចក្តីថា បានឃើញថាទៀង ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះ ។

បទថា ន បរិមុច្ចិសុ ទុក្ខស្មា សេចក្តីថា មិនរួចផុតពីវដ្តទុក្ខសូម្បីទាំងអស់ ។

បទថា ទក្ខិស្សន្តិ ប្រែថា នឹងឃើញ ។

[២៦០] បទថា **អាបានីយកំសោ** ជាឈ្មោះរបស់ផ្តិល ក៏ព្រោះហេតុដែលជនទាំងឡាយផឹកទឹកក្នុងផ្តិលនេះ ដូច្នោះ ទើបហៅថា **អាបានីយ** ។ **អាបានីយ** នោះផង **កំស** ផង ឈ្មោះថា **អាបានីយកំសោ** ពាក្យថា **អាបា-នីយកំសោ** នេះ ជាឈ្មោះរបស់ផ្តិលសម្រាប់ដាក់សុរា ។ តែដែលវាតាំងនៅក្នុងផ្តិលសំរឹទ្ធនុ៎ះឯង លោកពោលទុកយ៉ាងនោះ ព្រោះព្រះបាលីថា **វណ្ណសម្បន្នោ** ដល់ព្រមដោយពណ៌ ។ បទថា **ឃម្មាភិតត្តោ** ប្រែថា ត្រូវសេចក្តីក្តៅដុតកោល ។ បទថា **ឃម្មបរេតោ** ប្រែថា ត្រូវសេចក្តីក្តៅប៉ះពាល់ហើយត្រាច់ទៅតាម ។ បទថា **បិវតោ ហិ ខោ តំ ឆាទេស្សតិ** សេចក្តីថា ទឹកផឹកនោះ នឹងជាទីពេញចិត្តរបស់អ្នកផឹក ឬនឹងធ្វើឲ្យកើតសេចក្តីត្រេកអរផ្សាយទៅទូទាំងសរីរៈ ហើយតាំងនៅ ។ បទថា **អប្បដិសង្ខា** ប្រែថា មិនបានពិចារណា ។

ក្នុងបទថា **ឯវមេវ ខោ** នេះ មានពាក្យប្រៀបធៀប និងឧបមាដូចតទៅនេះ ៖

ពិតណាស់ អារម្មណ៍ដែលជាបិយរូបសាតរូបក្នុងលោក គប្បីឃើញដូចផ្តិលសំរឹទ្ធសម្រាប់ដាក់ទឹកផឹក ។ បុថុជ្ជនអ្នកអាស្រ័យវដ្តៈ ដូចបុរសអ្នកត្រូវសេចក្តីក្តៅដុតកោល ជនអ្នកត្រូវអារម្មណ៍ដែលជាបិយរូបសាតរូប

គោរពអញ្ជើញក្នុងលោក ដូចបុរសអ្នកត្រូវអញ្ជើញដោយផ្តិលសំរិទ្ធសម្រាប់ដាក់ទឹកផឹក កល្យាណមិត្ត មានអាចារ្យ និងឧបជ្ឈាយ៍ជាដើម ដូចមនុស្សអ្នកអញ្ជើញឲ្យផឹកទឹក ប្រាប់គុណសម្បត្តិ និងទោសក្នុងផ្តិលសំរិទ្ធសម្រាប់ដាក់ទឹកផឹក , អាចារ្យ ឬព្រះឧបជ្ឈាយ៍ រមែងប្រាប់គុណ និងទោសក្នុងកាមគុណ ៥ ដល់ភិក្ខុ ដូចមនុស្សអ្នកឈរក្នុងទីផ្សារប្រាប់គុណ និងទោសក្នុងផ្តិលសំរិទ្ធសម្រាប់ដាក់ទឹកផឹកដល់បុរសនោះ ក្នុងឧបមានោះ ប្រៀបដូចកាលគេប្រាប់ដល់គុណ និងទោសក្នុងផ្តិលសំរិទ្ធដាក់ទឹកផឹកហើយ បុរសនោះ ដោយគុណសម្បត្តិ មានពណ៌ជាដើមនុ៎ះឯង ក៏កើតសេចក្តីស្រេកឃ្លានមួយរំពេចថា បើនឹងស្លាប់ ក៏នឹងដឹងគ្នាពេលក្រោយ មិនពិចារណាដោយជុំវិញ ហើយផឹកទឹកក្នុងផ្តិលសំរិទ្ធនោះ ក៏ប្រសព្វសេចក្តីស្លាប់ ឬទុក្ខស្មើរតែនឹងស្លាប់ យ៉ាងណា ភិក្ខុក៏ដូច្នោះដែរ សូម្បីត្រូវអាចារ្យ និងព្រះឧបជ្ឈាយ៍សម្តែងអានិសង្ស និងទោសយ៉ាងនេះថា អស្សាទៈមានត្រឹមតែសោមនស្សដែលកើតឡើងក្នុងកាមគុណ ៥ ដោយអំណាចការឃើញជាដើម តែទោសមានប្រការផ្សេងៗ ជាច្រើនប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយភព កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ហើយឲ្យឱវាទយ៉ាងនេះថា លោកចូរបដិបត្តិ

សមណបដិបទា ចូរឃុំគ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ចូរស្គាល់ប្រមាណក្នុងភោជន ចូរប្រកបរឿយៗ នូវសេចក្ដីព្យាយាមជាគ្រឿងភ្ញាក់ ដូច្នេះ ព្រោះខ្លួនមានចិត្តត្រូវអស្សាទៈរួបរឹតហើយ ទើបអាចារ្យ និងព្រះឧបជ្ឈាយ៍ថាប្រសិនបើនឹងមានទោស មានប្រការដូចពោលហើយ ខ្ញុំនឹងដឹងក្នុងខាងក្រោយហើយលះឧទ្ទេស និងបរិបុច្ឆាជាដើម និងវត្តបដិបត្តិ និយាយតែក្នុងរឿងលោកាមិស ប្រាប់លាសិក្ខា វិលមកដើម្បីហីនភេទ ព្រោះប្រាថ្នានឹងបរិភោគកាម បន្ទាប់ពីនោះ បំពេញទុច្ចរិត ៣ ត្រូវចាប់ខ្លួនបានក្នុងខណៈកាត់ទី-តជាដើម សម្ដែងចំពោះព្រះរាជាថា អ្នកនេះជាចោរ ក៏ប្រសព្វអនិដ្ឋ-ផល មានការត្រូវកាត់ដៃកាត់ជើងជាដើម ឬត្រូវកាត់ក្បាលក្នុងលោកនេះឯង ហើយសោយទុក្ខជាច្រើនក្នុងអបាយទាំងបួនក្នុងសម្បរាយភព ។

[២៦២] បទថា **បានីយេន វា វិនេតុំ** សេចក្ដីថា នាំទៅដោយទឹកត្រជាក់ ។ បទថា **ទធិមណ្ឌកេន** បានដល់ ដោយទឹកដោះជូរដែលថ្លា ។ បទថា **មដ្ឋលោណិកាយ** បានដល់ ដោយទឹកសជូរ និងទឹកផឹកដែលប្រៃ ។ បទថា **លោណសោចិរកេន** បានដល់ ជនទាំងឡាយដាក់ស្រូវ ផ្លែឈើ និងទំពាំងជាដើម គ្រប់យ៉ាងធ្វើជាថ្នាំត្រាំ ឈ្មោះ សោណសោចិរកៈ ដោយថ្នាំត្រាំឈ្មោះ សោណសោចិរកៈនោះ ។

ក៏ក្នុងសេចក្ដីនេះ មានការប្រៀបធៀបឧបមាដូច្នេះ ព្រះយោគាវចរ ក្នុងវេលាអាស្រ័យវដ្ដៈ គប្បីឃើញដូចបុរសត្រូវសេចក្ដីក្ដៅជុតពេល ការសម្រេចអរហត្តផលរបស់ភិក្ខុ ដែលតាំងនៅក្នុងឱវាទរបស់ឧបជ្ឈាយ៍ និងអាចារ្យ កំណត់ទ្វារ ៦ ជាដើម ចម្រើនវិបស្សនាដោយលំដាប់ គប្បីឃើញដូចបុរសនោះពិចារណាហើយលះបង់ផ្ដិលសំរឹទ្ធសម្រាប់ដាក់ទឹកផឹក បន្ទោបង់សេចក្ដីស្រេកឃ្លានដោយទឹកដែលគួរផឹកជាដើម , មគ្គ ៤ គប្បីឃើញដូចឋានៈ ៤ មានទឹកផឹកជាដើម , វេលាដែលព្រះខីណាស្រពផឹកទឹក គឺមគ្គ ៤ បន្ទោបង់តណ្ហា ទៅកាន់ទិសព្រះនិព្វានដែលមិនធ្លាប់ទៅ គប្បីជ្រាបដូចជាបុរសផឹកទឹកផឹក ៤ យ៉ាង យ៉ាងណាមួយ បន្ទោបង់ស្រេកឃ្លានស្ងប់មានសេចក្ដីសុខ ទៅតាមទិសដែលប្រាថ្នា ។

ចប់អដ្ឋកថា សច្ចសូត្រទី ៦

# អ ដ្ឋ ក ថា

## នឡកលាបិយសូត្រទី ៧

ក្នុង នឡកលាបិយសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៦៤] ពាក្យថា កឹ នុ ខោ អាវុសោ មានសេចក្តីថា ព្រោះហេតុអ្វី ព្រះមហាកោដ្ឋិតៈ ទើបសួរឡើង ។ ព្រោះដើម្បីជ្រាបអធ្យាស្រ័យរបស់ព្រះថេរៈថា ត្រូវសួរយ៉ាងនេះហើយ គប្បីព្យាករណ៍យ៉ាងណា ។ មួយវិញទៀត លោកសួរថា ពួកភិក្ខុក្នុងអនាគតនឹងដឹងថា ព្រះអគ្គសាវកទាំងពីរក្នុងអតីតវិនិច្ឆ័យបញ្ហានេះហើយ ដូច្នេះ ក៏មាន ។

[២៦៥] ព្រះថេរៈពោលពាក្យនេះថា ឥទានេវ ខោ មយំ ដូច្នេះ ព្រោះលោកពោលទុកថា នាមរូបដែលពោលថា មានវិញ្ញាណជាបច្ច័យនុ៎ះឯងជាបច្ច័យនៃវិញ្ញាណ ។

[២៦៦] ក៏ក្នុងបទថា នឡកលាបិយោ នេះ លោកមិននាំយកបាច់បបុសជាដើមមកប្រៀបធៀប តែលោកប្រៀបធៀបដូច្នេះ ដើម្បីសម្តែងភាវៈនៃវិញ្ញាណ និងនាមរូបថា មិនមានកម្លាំង និងមានកម្លាំងទុព្វល ។ ពាក្យថា និរោធោ ហោតិ លោកពោលថា ទេសនា ដោយបញ្ចៀវាការភព (ភពដែល

មានខន្ធ ៥) ជាបច្ចុប្បន្ន ក្នុងឋានៈប្រមាណប៉ុណ្ណេះ ។

[២៦៧] បទថា **ឆត្តឹសាយ វត្ថូហិ** សេចក្តីថា ដោយហេតុ ៣៦ ប្រការ គឺ ក្នុង ១២ បទ ដែលលោកចែកទុកខាងក្រោយ មួយបទៗ មានហេតុ ៣ ។ ក្នុងទីនេះ គុណរបស់ព្រះធម្មកថិកទី ១ ការបដិបត្តិទី ២ ផលនៃការបដិបត្តិទី ៣ ។ ក្នុងផលនៃការបដិបត្តិនោះ លោកពោលទេសនាសម្បត្តិដោយន័យទី ១ ពោលសេក្ខភូមិដោយន័យទី ២ ពោលអសេក្ខភូមិដោយន័យទី ៣ ។

ចប់អដ្ឋកថា ឆឡកលាបិយសូត្រទី ៧

# អ ដ្ឋ ក ថា

## កោសម្ពីសូត្រទី ៨

ក្នុង *កោសម្ពីសូត្រទី ៨* មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៦៩] បទថា *អញ្ញត្រ* សេចក្តីថា ក៏បុគ្គលខ្លះជឿបុគ្គលដទៃរមែងប្រកាន់ថា សេចក្តីដែលបុគ្គលនេះពោលនោះ ជាសេចក្តីពិត រមែងពេញចិត្តហេតុដែលអ្នកដទៃអង្គុយគិត ហើយគេរមែងប្រកាន់តាមសេចក្តីពេញចិត្តថា នោះមានម្នាក់ប្រកាន់តាមដែលឮមកថា រឿងលេចឮយ៉ាងនេះមានមកយូរហើយ នោះជាសេចក្តីពិត ។ កាលបុគ្គលដទៃត្រិះរិះ រមែងប្រាកដហេតុមួយយ៉ាង គេប្រកាន់ដោយត្រិះរិះតាមអាការថា នោះមាន រមែងយល់ឃើញតាមទិដ្ឋិមួយយ៉ាង ដែលកើតឡើងដល់ម្នាក់ទៀត អ្នកគិតសម្លឹងពិនិត្យដល់ហេតុ គេរមែងប្រកាន់ដោយការយល់ឃើញ ការសម្លឹងពិនិត្យដោយទិដ្ឋិថា នោះមាន ។ តែព្រះថេរៈបដិសេធហេតុទាំង ៥ នេះ កាលសួរដល់ភាវៈដែលចាក់ធ្លុះដោយញាណដែលប្រចក្ស ទើបពោលពាក្យជាដើមថា *អញ្ញត្រ អាវុសោ មុសិល សទ្ធាយ* ដូច្នេះ ។

[២៧១] ក្នុងបទទាំងនោះ បទថា *អញ្ញត្រ* បានដល់ វៀរហេតុ

មានសទ្ធាជាដើម អធិប្បាយថា វៀរចាកហេតុទាំងនោះ ។ បទថា **ភវនិ-រោធោ និព្វានំ** បានដល់ ព្រះនិព្វាន គឺ ការរលត់នៃបញ្ចក្ខន្ធ ។

បទថា **តុណ្ហី អហោសិ** សេចក្តីថា ព្រះថេរៈជាខីណាស្រព មិនពោលថា ក៏យើងជាខីណាស្រព ឬថា មិនមែន បាននៅស្ងៀមនោះឯង ។

[២៧២] ពាក្យថា **អាយស្មា នារទោ អាយស្មន្តំ បវិដ្ឋំ ឯតទវោច** (ព្រះនារទៈបានពោលចំពោះព្រះបវិដ្ឋៈ) សេចក្តីថា ព្រោះហេតុអ្វី ព្រះថេរៈទើបពោល ។ ព្រោះពួកមកថា ព្រះថេរៈនោះគិតថា ការរលត់នៃភព ឈ្មោះថា និព្វាន បញ្ហានេះ ព្រះសេក្ខៈក្តី ព្រះអសេក្ខៈក្តី គួរដឹង តែព្រះនារទត្រូវនេះ ឲ្យព្រះបវិដ្ឋត្រូវធ្វើដោយអសេក្ខភូមិ បានពោលយ៉ាងនេះថា យើងនឹងឲ្យដឹងឋានៈនេះ ។

[២៧៤] បទថា **សម្មប្បញ្ញាយ សុទិដ្ឋំ** សេចក្តីថា ឃើញដោយល្អព្រមដោយវិបស្សនាបញ្ញា និងមគ្គបញ្ញា ។ ដោយពាក្យថា **ន ចម្ហិ អរហំ** ព្រះថេរៈសម្តែងថា យើងមិនមែនជាព្រះអរហន្ត ព្រោះតាំងនៅក្នុងអនាគា-មិមគ្គ ។ ក៏ញាណរបស់លោកក្នុងកាលឥឡូវនេះថា ការរលត់នៃភព ឈ្មោះថា និព្វាននោះ ផុតពីបច្ចវេក្ខណញ្ញាណ ១៩ ឈ្មោះថា បច្ចវេក្ខណញ្ញាណ ។ បទថា **ឧទបានោ** បានដល់ អណ្តូងទឹកជ្រៅ ២០-៣០ ហត្ថ ។ បទថា **ឧទ-**

ករកោ បានដល់ ធុងសម្រាប់ដងទឹក ។ បទថា **ឧទកន្តិ ហិ ខោ ញាណំ អស្ស** (ក៏ដឹងថាមានទឹក) សេចក្ដីថា កាលឈរពិចារណានៅត្រង់មាត់ប្រាំង គប្បីមានញាណយ៉ាងនេះ ។ បទថា **ន ច កាយេន ផុសិត្វា** (តែប៉ះពាល់ដោយកាយមិនបាន) សេចក្ដីថា តែមិនអាចប្រើកាយនាំទឹកចេញមកប៉ះពាល់បាន ។ ពិតណាស់ ការឃើញព្រះនិព្វានរបស់ព្រះអនាគាមី ដូចការឃើញទឹកក្នុងអណ្ដូងទឹក ។ ព្រះអនាគាមី ដូចបុរសដែលត្រូវសេចក្ដីក្ដៅក្រហាយគ្របសង្កត់ អរហត្តមគ្គ ដូចធុងសម្រាប់ដងទឹក ព្រះអនាគាមី រមែងដឹងថាបន្ទាប់ទៅ រមែងមានការសម្រេចព្រះអរហត្តផល ដោយបច្ចវេក្ខណញាណ ដូចបុរសដែលត្រូវសេចក្ដីក្ដៅក្រហាយគ្របសង្កត់ ឃើញទឹកក្នុងអណ្ដូង ។

ម្យ៉ាងទៀត ព្រះអនាគាមី រមែងមិនបានធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ អង្គុយចូលផលសមាបត្តិ ដែលសម្បយុត្តដោយព្រះអរហត្ត ព្រោះមិនមានអរហត្តមគ្គ ដូចបុរសនោះមិនអាចនឹងប្រើកាយនាំទឹកចេញមកស្រោចស្រពខ្លួន ព្រោះមិនមានធុងសម្រាប់ដងទឹក ដូច្នោះ ។

ចប់អដ្ឋកថា កោសម្ពីសូត្រទី ៨

# អ ដ្ឋ ក ថា

## ឧបយសូត្រទី ៩

ក្នុង ឧបយសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៧៧] បទថា **ឧបយន្តោ** (ជោរឡើង) សេចក្តីថា ជោរវេលាទឹកឡើង ។ បទថា **មហានទិយោ** បានដល់ ទន្លេធំ មានទន្លេគង្គា និងយមុនាជាដើម ។ បទថា **ឧបយាបេតិ** សេចក្តីថា ឲ្យជោរទៅ អធិប្បាយថា បន្ថែមគឺ ឲ្យពេញ ។ បទថា **អវិជ្ជា ឧបយន្តិ** (កាលអវិជ្ជាកើត) សេចក្តីថា អវិជ្ជារមែងចម្រើនទៅខាងលើ ឬអាចជាបច្ច័យដល់សង្ខារទាំងឡាយ ។ បទថា **សង្ខារេ ឧបយាបេតិ** សេចក្តីថា រមែងញ៉ាំងសង្ខារក្នុងខាងលើ ឲ្យប្រព្រឹត្តទៅ គឺ ឲ្យចម្រើន ។ គប្បីជ្រាបសេចក្តីគ្រប់ៗ បទ ដោយប្រការដូច្នេះ ។

[២៧៨] បទថា **អបយន្តោ** (កាលទឹកស្រក) បានដល់ ប្រាសទៅគឺ ស្រកចុះ ។ បទថា **អវិជ្ជា អបយន្តិ** សេចក្តីថា អវិជ្ជាប្រាសទៅ គឺ មិនកើត រមែងមិនអាចជាបច្ច័យដល់សង្ខារក្នុងខាងលើ ។ បទថា **សង្ខារេ អបយាបេតិ** បានដល់ រមែងមិនញ៉ាំងសង្ខារឲ្យប្រព្រឹត្តទៅ ។ ក្នុងបទទាំងពួង ក៏ន័យនេះ ។

ចប់អដ្ឋកថា ឧបយសូត្រទី៩

# អ ដ្ឋ ក ថា

## សុសិមសូត្រទី ១០

*ក្នុង សុសិមសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៧៩] *បទថា* ***គរុកតោ*** *(ធ្វើការគោរព) សេចក្តីថា ដែលទេវតានិងមនុស្សធ្វើធ្វើការគោរពដោយចិត្ត ដូចឆត្រថ្ម ។ បទថា* ***មានិតោ*** *(រាប់អាន) បានដល់ ដែលគេស្រឡាញ់ដោយចិត្ត ។ បទថា* ***បូជិតោ*** *បានដល់ ដែលគេបូជា ដោយការបូជាដោយបច្ច័យ ៤ ។*

*បទថា* ***អបចិតោ*** *(កោតក្រែង) បានដល់ ដែលគេកោតក្រែងដោយការប្រព្រឹត្តឱនលំទោន ។ ពិតណាស់ មនុស្សទាំងឡាយឃើញព្រះសាស្តាហើយ រមែងចុះអំពីកដំរីជាដើម ថ្វាយផ្លូវ ដាក់សំពត់ចេញពីចង្កេះស្មាក្រោកចាកអាសនៈ ថ្វាយបង្គំ ដូចពោលមកនេះ ឈ្មោះថា ដែលមនុស្សទាំងនោះកោតក្រែងហើយ ។ បទថា* ***សុសិមោ*** *បានដល់ បណ្ឌិតបរិព្វាជកអ្នកឆ្លាតក្នុងវេទ ដែលមានឈ្មោះយ៉ាងនោះ ។*

[២៨០] *បទថា* ***ឯហិ ត្វំ*** *សេចក្តីថា បរិព្វាជកទាំងនោះមានសេចក្តីគិតយ៉ាងនេះថា ព្រះសមណគោតមអាស្រ័យជាតិ និងគោត្រជាដើម សូម្បី*

ដល់ភាពជាអ្នកប្រសើរដោយលាភក៏មិនមែន ដែលពិត ទ្រង់ជាកំពូលកវី ចងក្រងគម្ពីរប្រទានដល់សាវក ព្រោះទ្រង់ជាកំពូលកវី សាវកទាំងនោះ រៀនគម្ពីរនោះបន្តិចបន្តួច ហើយពោលពាក្យជាដើមថា ឧបនិសិន្នកថាខ្លះ អនុមោទនាខ្លះ សរភញ្ញខ្លះ ដល់ឧបដ្ឋាកទាំងឡាយ ឧបដ្ឋាកទាំងនោះក៏បង្អោននាំលាភចូលទៅ បើពួកយើងគប្បីដឹងបន្តិចៗ អំពីវត្ថុដែលព្រះសមណគោតមដឹង យើងគប្បីដាក់លទ្ធិរបស់ខ្លួនក្នុងគម្ពីរនោះ ពោលដល់ឧបដ្ឋាកទាំងឡាយ តពីនោះយើងគប្បីជាអ្នកមានលាភច្រើនជាងសាវកទាំងនោះ អ្នកណាហ្ន៎ នឹងបួសក្នុងសម្នាក់ព្រះសមណគោតមហើយ អាចរៀនបានឆាប់រហ័ស ។ បរិព្វាជកទាំងនោះ គិតយ៉ាងនេះហើយ ឃើញថា សុសិមៈ ជាអ្នកឆ្លាត ទើបចូលទៅរក ហើយពោលយ៉ាងនោះ ។

បទថា **យេនាយស្មា អានន្ទោ តេនុបសង្កមិ** (ចូលទៅរកព្រះអានន្ទដល់ទីនៅ) សួរថា ព្រោះហេតុអ្វី សុសិមបរិព្វាជក ទើបចូលទៅរក ។ បានឮថា សុសិមបរិព្វាជកមានការគិតយ៉ាងនេះថា យើងទៅសម្នាក់អ្នកណាហ្ន៎ ទើបនឹងអាចបានធម៌ដោយឆាប់រហ័ស ។ បន្ទាប់ពីនោះ ទើបគិតថា ព្រះសមណគោតម ទ្រង់ចម្រើនដោយគុណសម្បត្តិ គឺ សេចក្តីគោរពអ្នកប្រកបរឿយ ៗ ដោយការនិយម អ្នកណា ៗ មិនអាចនឹងចូលទៅគាល់

ក្នុងវេលាដែលមិនសមគួរ សូម្បីជនពួកដទៃជាច្រើន មានក្សត្រិយ៍ជាដើម រមែងចូលទៅគាល់ព្រះសមណគោតម ក្នុងសម័យសូម្បីនោះ អ្នកណាក៏មិនអាចនឹងចូលទៅគាល់បាន សូម្បីបណ្ដាព្រះសាវករបស់ព្រះអង្គ ព្រះសារី-បុត្រអ្នកមានបញ្ញាច្រើន ទ្រង់តាំងទុកក្នុងឯតទគ្គៈក្នុងវិបស្សនាលក្ខណៈ ព្រះមហាមោគ្គល្លាន ទ្រង់តាំងទុកក្នុងឯតទគ្គៈក្នុងសមាធិលក្ខណៈ ព្រះមហា-កស្សបៈ ទ្រង់តាំងទុកក្នុងឯតទគ្គៈជាអ្នកទ្រទ្រង់ធុតង្គគុណ ព្រះអនុរុទ្ធ ទ្រង់តាំងទុកក្នុងឯតទគ្គៈអ្នកមានចក្ខុទិព្វ ព្រះបុណ្ណមន្តានីបុត្រ ទ្រង់តាំងទុកក្នុងឯតទគ្គៈជាព្រះធម្មកថិក ព្រះឧបាលីត្ថេរ ទ្រង់តាំងទុកក្នុងឯតទគ្គៈជាអ្នកទ្រទ្រង់នូវព្រះវិន័យ ចំណែកព្រះអានន្ទនេះ ជាពហុស្សូត ទ្រទ្រង់ព្រះត្រៃ-បិដក សូម្បីព្រះសាស្ដា ក៏ទ្រង់នាំទេសនាដែលត្រាស់ហើយក្នុងទីនោះៗ មកត្រាស់ដល់ព្រះអានន្ទនោះទៀត ទ្រង់តាំងទុកក្នុងឯតទគ្គៈ ៥ តំណែង លោកបានពរ ៨ ប្រការ ប្រកបដោយអច្ឆរិយព្ភូតធម៌ ៤ ប្រការ យើងចូលទៅរកលោក នឹងអាចបានធម៌ដោយឆាប់រហ័ស ដូច្នោះ សុសិមបរិព្វាជក ទើបចូលទៅរកព្រះអានន្ទដល់ទីនៅ ។

[២៨១] បទថា ***យេន ភគវា តេនុបសង្កមិ*** សេចក្ដីថា សួរថា ព្រោះហេតុអ្វី ទើបនាំចូលទៅរក ឆ្លើយថា បានឮថា ព្រះអានន្ទមានសេចក្ដីគិត

យ៉ាងនេះថា សុសិមបរិព្វាជកនេះ ជាម្ចាស់លទ្ធិមួយផ្អែកក្នុងលទ្ធិតិរ្ថិយ ដើរប្រេជ្ញាថា យើងជាសាស្តា លុះបួសហើយ សូម្បីកាលមិនបានពាក្យទូន្មាន ក៏នៅព្យាយាម ទាំងយើងក៏មិនដឹងអធ្យាស្រ័យរបស់លោក ព្រះសាស្តាទ្រង់នឹងជ្រាប ដូច្នោះ ទើបនាំលោកចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។

បទថា **តេនហានន្ទ សុសិមំ បព្វាជេថ** សេចក្តីថា បានឮថា ព្រះសាស្តាមានព្រះតម្រិះថា បរិព្វាជកនេះ ដើរប្រេជ្ញាក្នុងលទ្ធិរបស់តិរ្ថិយថា យើងជាសាស្តាក្នុងលទ្ធិមួយ បានឮថា អ្នកពោលថា យើងប្រាថ្នានឹងប្រព្រឹត្តមគ្គ-ព្រហ្មចរិយៈក្នុងសាសនានេះ អ្នកជ្រះថ្លាក្នុងតថាគត ឬក្នុងសាវកតថាគត ឬជ្រះថ្លាក្នុងធម្មកថារបស់តថាគត ឬសាវករបស់តថាគត លុះទ្រង់ជ្រាបថា គេមិនមានសេចក្តីជ្រះថ្លាសូម្បីក្នុងឋានៈណាមួយ ទ្រង់ត្រួតមើលថា បុគ្គលនេះបួសដោយតាំងចិត្តថា នឹងលួចធម៌ក្នុងសាសនារបស់តថាគត ដូច្នោះ ការមករបស់គេទើបមិនបរិសុទ្ធិ ផលសម្រេចដូចម្តេចហ្ន៎ ទ្រង់ជ្រាបថា សូម្បីសុសិមៈបួសដោយតាំងចិត្តថា នឹងលួចធម៌ក៏ពិត តែគេព្យាយាម ២-៣ ថ្ងៃប៉ុណ្ណោះ ក៏នឹងសម្រេចព្រះអរហត្ត ទើបត្រាស់ថា **តេនហានន្ទ សុសិមំ បព្វាជេថ** ដូច្នេះ ។

បទថា **អញ្ញា ព្យាកតា ហោតិ** សេចក្តីថា បានឮថា ភិក្ខុទាំងនោះ

រៀនព្រះកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដា នៅចាំវស្សារហូតដល់អស់ត្រៃមាស ប្រារព្ធសេចក្ដីព្យាយាម បានសម្រេចព្រះអរហត្តខាងក្នុងវស្សានោះឯង ។ ភិក្ខុទាំងនោះគិតថា យើងនឹងក្រាបទូលគុណដែលខ្លួនបានហើយចំពោះព្រះ-សាស្ដា ធ្វើបវិសុទ្ធបវារណាហើយ រក្សាទុកដាក់សេនាសនៈ ក៏មកគាល់ព្រះសាស្ដា ក្រាបទូលគុណដែលខ្លួនបាន លោកសំដៅយកពាក្យដែលពោលទុកហើយនោះឯង ។

ក៏បទថា **អញ្ញា** ជាឈ្មោះរបស់ព្រះអរហត្ត ។ បទថា **ព្យាកតា** ប្រែថា ក្រាបទូលហើយ ។ បទថា **អស្សោសិ** សេចក្ដីថា បានឮថា លោកផ្សៀងសោតៈស្ដាប់ ទៅកាន់កន្លែងដែលភិក្ខុទាំងនោះនៅ ប្រាថ្នានឹងស្ដាប់ពាក្យនោះៗ ។ ពាក្យថា **យេន តេ ភិក្ខូ តេនុបសង្កមិ** (ទើបចូលទៅរកភិក្ខុទាំងនោះដល់ទីនៅ) ។ សួរថា ចូលទៅរកធ្វើអ្វី ។ បានឮថា លោកស្ដាប់រឿងនោះហើយ ទើបគិតដូច្នេះថា ដែលឈ្មោះថា ព្រះអរហត្តផលជាវត្ថុដែលមានតម្លៃរកប្រមាណមិនបានក្នុងព្រះសាសនានេះ ប្រហែលជាថា សេចក្ដីដឹងរបស់អាចារ្យមានត្រឹមតែកណ្ដាប់ដៃជាសារៈ យើងនឹងសួរឲ្យដឹងនូវសេចក្ដីនោះ ព្រោះដូច្នោះ ទើបចូលទៅរក ។

[២៨៣] បទថា **អនេកវិហិតំ** ប្រែថា មានច្រើនយ៉ាង ។ បទថា

ឥទ្ធិវិធំ បានដល់ ចំណែកនៃឫទ្ធិ ។ ដោយបទថា **អាវីភាវំ តិរោភាវំ** លោក សួរថា ពួកលោកអាចធ្វើវត្ថុដែលប្រាកដឲ្យបាត់ទៅ (បាត់ខ្លួន) ធ្វើវត្ថុដែល បាត់ទៅឲ្យប្រាកដបានឬ (ប្រាកដខ្លួន) ។ បទថា **តិរោកុឌ្ឌំ** ប្រែថា ខាង ក្រៅជញ្ជាំង ។ សូម្បីខាងក្រៅភ្នំ ក៏ន័យនេះឯង ។ បទថា **ឧម្មុជ្ជនិម្មុជ្ជំ** ប្រែថា ផុសឡើង និងមុជចុះ ។ បទថា **បល្លង្កេន** ប្រែថា ដោយការអង្គុយ ពែនភ្នែន ។ ដោយបទថា **កមថ** (ហោះទៅ) លោកសួរថា ពួកលោកអាច អង្គុយ ឬចាប់យកបានឬ ។ បទថា **បក្ខីសកុណោ** ប្រែថា សត្វដែលមាន ស្លាប ។ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេបត្រឹមតែប៉ុណ្ណេះ ចំណែកសេចក្តី ពិស្តារ គប្បីជ្រាបន័យនៃការពណ៌នាឥទ្ធិវិធញ្ញាណនេះ និងទិព្វសោតជា ដើម ក្រៅអំពីនេះ ដោយន័យដែលពោលហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។

[២៨៨] បទថា **សន្តា វិមោក្ខា** សេចក្តីថា អរូបវិមោក្ខ ឈ្មោះថា ស្ងប់ ព្រោះស្ងប់អង្គ (ឈាន) និងព្រោះស្ងប់អារម្មណ៍ ។ បទថា **កាយេន ផុសិត្វា** បានដល់ ពាល់ត្រូវ គឺ ដោយនាមកាយ ។

[២៨៩] ដោយពាក្យថា **បញ្ញាវិមុត្តា ខោ មយំ អាវុសោ** លោក សម្តែងថា អាវុសោ ពួកយើងជាអ្នកសម្ងំឈាន ជាសុក្ខវិបស្សកៈ រួចផុត ដោយត្រឹមតែបញ្ញាប៉ុណ្ណោះ ។ សួរថា ព្រោះហេតុអ្វី ភិក្ខុទាំងនោះទើបពោល

យ៉ាងនេះថា **អាជានេយ្យាសិ វា ត្វំ អាវុសោ សុសិម ន វា ត្វំ អាជានេយ្យាសិ** ដូច្នេះ ។ ព្រោះបានឮមកថា ភិក្ខុទាំងនោះមានការគិតយ៉ាងនេះថា ពួកយើងមិនអាចនឹងចាប់យក (គឺយល់) អធ្យាស្រ័យរបស់សុសិមភិក្ខុនេះ ពោលបាន សុសិមភិក្ខុនេះសួរព្រះទសពលទៀត ទើបអស់សេចក្តីសង្ស័យ ។

[២៩០] បទថា **ធម្មដ្ឋិតិញាណំ** បានដល់ វិបស្សនាញាណ ។ វិបស្សនាញាណនោះកើតឡើងមុន ។ បទថា **និព្វានេ ញាណំ** បានដល់ មគ្គញាណដែលប្រព្រឹត្តទៅក្នុងទីបំផុតនៃវិបស្សនាដែលធ្លាប់សន្សំមក ។ មគ្គញាណនោះកើតឡើងខាងក្រោយ ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់យ៉ាងនេះ ។

សួរថា ព្រោះហេតុអ្វី លោកទើបពោលថា **អាជានេយ្យាសិ វា** ជាដើម ។

ឆ្លើយថា ដើម្បីសម្តែងការកើតឡើងនៃញាណយ៉ាងនេះ សូម្បីវៀរសមាធិ ។ ពិតណាស់ ព្រះមានព្រះភាគត្រាស់អធិប្បាយទុកដូច្នេះថា ម្នាលសុសិម: មគ្គក៏ដោយ ផលក៏ដោយ មិនមែនជាផលរបស់សមាធិ មិនមែនជាអានិសង្សរបស់សមាធិ មិនមែនជាសេចក្តីសម្រេចរបស់សមាធិ តែមគ្គឬផលនេះ ជាផលរបស់វិបស្សនា ជាអានិសង្សរបស់វិបស្សនា ជាសេចក្តីសម្រេចរបស់វិបស្សនា ដូច្នោះ លោកនឹងដឹងក៏ដោយ មិនដឹងក៏ដោយ ដែលពិតធម្មដ្ឋិតិញាណ ជាញាណក្នុងខាងដើម ញាណក្នុងព្រះនិព្វាន ជាញាណខាងក្រោយ ។

[២៩១] ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ជ្រាបថា សុសិមភិក្ខុនោះ

គួរនឹងចាក់ធ្លុះ កាលទ្រង់សម្ដែងព្រះធម៌ទេសនាអំពីត្រៃលក្ខណ៍ ទើបត្រាស់ថា **តំ កឹមញ្ញសិ សុសិម រូបំ និច្ចំ វា អនិច្ចំ វា** (ម្នាលសុសិម: អ្នកនឹងសម្គាល់សេចក្ដីនោះដូចម្ដេច រូបទៀង ឬមិនទៀង ដូច្នេះជាដើម ។ ក៏ក្នុងវេលាចប់ទេសនារឿងត្រៃលក្ខណ៍ ព្រះថេរៈសម្រេចព្រះអរហត្ត ។

[២៩៥] ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់លើកឡើងនូវសេចក្ដីព្យាយាមរបស់ព្រះថេរៈនោះ ទើបត្រាស់ថា **ជាតិបច្ចយា ជរាមរណន្តិ សុសិម បស្សសិ** (ម្នាលសុសិម: អ្នកឃើញថា ព្រោះជាតិជាបច្ច័យទើបមានជរា និងសមណៈឬ) ដូច្នេះជាដើម ។

[២៩៦] សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ប្រារព្ធពាក្យនេះថា **អបិ នុ ត្វំ សុសិម** ដូច្នេះ ។

ឆ្លើយថា ដើម្បីទ្រង់ធ្វើឲ្យប្រាកដដល់ពួកសុក្ខវិបស្សកភិក្ខុ អ្នកដែលសម្ងំឈាន ។ ក៏ក្នុងប្រការនេះ មានអធិប្បាយដូច្នេះថា មិនមែនអ្នកតែម្នាក់ប៉ុណ្ណោះដែលជាអ្នកសម្ងំឈានជាសុក្ខវិបស្សកៈ សូម្បីភិក្ខុទាំងនោះ ក៏យ៉ាងនោះដូចគ្នា ។ ពាក្យដ៏សេសក្នុងបទទាំងពួង ប្រាកដហើយទាំងនោះឯង ។

ចប់អដ្ឋកថា សុសិមសូត្រទី ១០

## ចប់មហាវគ្គ ទី ៧

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថាបឋមអស្សុតវាសូត្រ
២-អដ្ឋកថាទុតិយអស្សុតវាសូត្រ
៣-អដ្ឋកថាបុត្តមំសសូត្រ
៤-អដ្ឋកថាអដ្ឋិរាគសូត្រ
៥-អដ្ឋកថានគរសូត្រ
៦-អដ្ឋកថាសម្មសនសូត្រ
៧-អដ្ឋកថានឡកលាបិយសូត្រ
៨-អដ្ឋកថាកោសម្ពីសូត្រ
៩-អដ្ឋកថាឧបយន្តិសូត្រ
១០-អដ្ឋកថាសុសិមបរិព្វាជកសូត្រ

# សមណព្រាហ្មណវគ្គទី ៨

[៣០៥] *ក្នុង សមណព្រាហ្មណវគ្គ លោកបែងចែកបទមួយៗ ក្នុងជរា និងមរណៈជាដើម ចេញជាសូត្រមួយៗ រួមជា ១១ សូត្រ មានខ្លឹមសារងាយទាំងអស់នោះឯង ។*

## ចប់សមណព្រាហ្មណវគ្គ ទី ៨

# អន្តរបេយ្យាលវគ្គទី ៩

## អដ្ឋកថា

## សត្ថុសូត្រជាដើម

[៣០៩] ខាងមុខពីនេះ ១២ សូត្រ ដែលប្រព្រឹត្តទៅដោយន័យមានជាដើមថា **សត្ថា បរិយេសិតព្វោ** ដូច្នេះ ឈ្មោះថា **អន្តរបេយ្យាលវគ្គ** ។ ព្រះសូត្រទាំងអស់នោះ លោកពោលតាមអធ្យាស្រ័យរបស់វេនេយ្យបុគ្គលដែលត្រាស់ដឹងដោយប្រការនោះៗ ។ ក្នុងពាក្យទាំងនោះ ។ បទថា **សត្ថា** បានដល់ ជាព្រះពុទ្ធក៏ដោយ សាវកក៏ដោយ ដែលជាទីអាស្រ័យរបស់អ្នកបានមគ្គញ្ញាណ នេះឈ្មោះថា សាស្តា សាស្តានោះគប្បីស្វែងរក ។

[៣១០] បទថា **សិក្ខាករណីយា** បានដល់ គប្បីធ្វើសិក្ខាទាំង ៣ យ៉ាង ។ បណ្តាយោគៈជាដើម បទថា **យោគោ** បានដល់ ការប្រកប ។ បទថា **ឆន្ទោ** បានដល់ សេចក្តីពេញចិត្តក្នុងកុសល គឺ ភាពជាអ្នកប្រាថ្នានឹងធ្វើ ។ បទថា **ឧស្សោឡ្ហិ** បានដល់ សេចក្តីព្យាយាមដែលមានប្រមាណក្រៃលែង ដែលអត់ធន់ចំពោះវត្ថុទាំងពួង ។ បទថា **អប្បដិវានី** ប្រែថា មិន

ត្រឡប់ ។ បទថា **អាតប្បំ** បានដល់ សេចក្តីព្យាយាមដែលធ្វើកិលេសឲ្យក្តៅទូទៅ គឺ វីរិយៈនុ៎ះឯង ។ បទថា **សាតច្ចំ** បានដល់ ការធ្វើប្រព្រឹត្តជាប់តគ្នា ។

បទថា **សតិ** បានដល់ សតិដែលកំណត់សច្ចៈ ៤ ជាអារម្មណ៍ ដោយអំណាចជរា និងមរណៈជាដើម ។ បទថា **សម្បជញ្ញំ** បានដល់ ញាណនុ៎ះឯង ។

បទថា **អប្បមាទោ** បានដល់ សេចក្តីមិនប្រមាទក្នុងការចម្រើនសច្ចៈ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយទាំងនោះឯង ។

## ចប់អន្តរបេយ្យាលវគ្គ ទី ៩

# អភិសមយវគ្គទី ១០

## អ ដ្ឋ ក ថា

### នខសិខាសូត្រទី ១

[៣១១] *នខសិខាសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*បទថា* ***នខសិខាយ*** *សេចក្តីថា ត្រង់ចុងក្រចកដែលផុតពីសាច់ ពិតណាស់ ឈ្មោះថា ចុងក្រចកជារបស់ធំសម្រាប់លោកិយជន តែសម្រាប់ព្រះសាស្តាជារបស់តូច ដូចចុងផ្កាឧប្បលក្រហម ។*

*សួរថា បើដូច្នោះ ធូលីនឹងតាំងនៅត្រង់ចុងក្រចកនោះបានយ៉ាងណា ឆ្លើយថា តាំងនៅបានដោយកម្លាំងអធិដ្ឋាន ។ ព្រោះថា ព្រះមានព្រះភាគមានព្រះបំណងនឹងឲ្យគេដឹងសេចក្តី ទើបទ្រង់ឲ្យធូលីនោះតាំងនៅត្រង់ចុងក្រចកដោយកម្លាំងអធិដ្ឋាន ។ បទថា* ***សតិមំ កលំ*** *សេចក្តីថា បែងចែកធូលីក្នុងផែនដីដ៏ធំជា ១០០ ចំណែក គប្បីកាន់យកអំពី ១០០ ចំណែកនោះត្រឹមតែ ១ ចំណែក ។ សូម្បីសេចក្តីតទៅ ក៏មានន័យនេះដូចគ្នា ។*

[៣១២] *បទថា* ***អភិសមេតាវិនោ*** *(ត្រាស់ដឹងហើយ) បានដល់ អ្នកត្រាស់ដឹងអរិយសច្ចៈដោយបញ្ញា ហើយតាំងនៅ ។ បទថា* ***បុរិមំ ទុក្ខក្ខន្ធំ***

**បរិក្ខីណំ បរិយាទិន្នំ ឧបនិធាយ** សេចក្តីថា ប្រៀបធៀបកងទុក្ខដែលត្រាស់ទុកអំពីមុនយ៉ាងនេះថា ទុក្ខនេះឯង គឺ ដែលអស់ទៅហើយ មានច្រើនជាង អធិប្បាយថា ពិចារណាហើយដោយញាណ ដោយវៀរកងទុក្ខដ៏ច្រើនជាងនោះ ក្នុងសម្នាក់របស់ភិក្ខុនោះ ។ សួរថា ក៏ក្នុងទីនេះដែលឈ្មោះថា ទុក្ខមានក្នុងកាលមុនដូចម្តេច ទុក្ខដែលអស់ទៅ តើដូចម្តេច ទុក្ខដែលគប្បីកើតឡើង ព្រោះមិនអប់រំបឋមមគ្គ តើដូចម្តេច ទុក្ខដែលគប្បីកើតឡើងក្នុងអត្តភាពទាំង ៧ ទុក្ខក្នុងអបាយ និងក្នុងទីណាមួយ ចាប់តាំងពីបដិសន្ធិទី ៨ ទៅ ។ ទុក្ខទាំងអស់នោះ គប្បីជ្រាបថា **បរិក្ខីណទុក្ខ** (ទុក្ខដែលអស់ទៅ) ។ បទថា **សត្តក្ខត្តុំ** ប្រែថា ៧ ដង ។ អធិប្បាយថា ក្នុងអត្តភាពទាំង ៧ ។ ដោយបទថា **បរមតា** (យ៉ាងក្រៃលែង) លោកសម្តែងថា នេះជាប្រមាណក្រៃលែងរបស់ទុក្ខនោះ ។ បទថា **មហត្ថិយោ** បានដល់ ឲ្យសម្រេចប្រយោជន៍ដ៏ធំ ។

ចប់អដ្ឋកថា នខសិខាសូត្រទី ១

# អ ដ្ឋ ក ថា

## បោក្ខរណីសូត្រទី ២

[៣១៣] ក្នុង *បោក្ខរណីសូត្រទី ២* មានវិនិច្ឆ័យដូចតទៅនេះ ៖

*បទថា* ***បោក្ខរណី*** *បានដល់ បឹង ។ បទថា* ***ឧព្វេធេន*** *បានដល់ ព្រោះជ្រៅ ។*

*បទថា* ***សមតិត្តិកា*** *បានដល់ ស្មើកណ្តាប់មាត់ ។ បទថា* ***កាក-បេយ្យា*** *សេចក្តីថា ក្អែកនៅត្រង់ច្រាំងជំ អាចនឹងឱនចំពុះចុះទៅផឹកខ្លួនឯងតាមប្រក្រតីបាន ។*

ចប់អដ្ឋកថា បោក្ខរណីសូត្រទី ២

# អ ដ្ឋ ក ថា

## បឋមសម្ភេជឧទកសូត្រទី ៣

[៣១៥] ក្នុង *បឋមសម្ភេជឧទកសូត្រទី ៣* មានវិនិច្ឆ័យដូចតទៅនេះ ៖

*បទថា* ***យត្ថិមា*** *សេចក្តីថា ទន្លេធំទាំងនេះ ក្នុងទីប្រសព្វគ្នា ។ បទថា* ***សំសន្ទន្តិ*** *សេចក្តីថា ហូរទៅដោយប្រពៃ ។ បទថា* ***សមេន្តិ*** *បានដល់ មកជួបប្រសព្វគ្នា ។ បទថា* ***ទ្វេ វា តីណិ វា*** *ប្រែថា ២ ឬ ៣ ។ បទថា* ***ឧទកផុសិតានិ*** *បានដល់ តំណក់ទឹក ។ បទថា* ***សម្ភេជ្ជឧទកំ*** *បានដល់ ទឹកក្នុងទីប្រសព្វគ្នាជាមួយនឹងស្ទឹងដទៃ ។*

ចប់អដ្ឋកថា បឋមសម្ភេជឧទកសូត្រទី ៣

# អ ដ្ឋ ក ថា

## ទុតិយសម្ភេជឧទកសូត្រទី ៤

[៣១៧] *ទុតិយសម្ភេជឧទកសូត្រទី ៤ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា ទុតិយសម្ភេជឧទកសូត្រទី ៤

# អ ដ្ឋ ក ថា

## បឋមបឋវីសូត្រទី ៥

[៣១៩] ក្នុង *បឋមបឋវីសូត្រទី ៥* មានវិនិច្ឆ័យដូចតទៅនេះ ៖

*បទថា* **មហាបឋវិយា** *សេចក្ដីថា លើកឡើងទុកលើផែនដីដ៏ធំខាងក្នុងចក្រវាឡ ។ បទថា* **គោលដ្ឋិមត្តិយោ** *បានដល់ ប្រមាណប៉ុនផ្លែពុទ្រា ។ បទថា* **គុឡិកា** *បានដល់ ដុំដីស្អិត ។ បទថា* **ឧបនិក្ខិបេយ្យ** *សេចក្ដីថា គប្បីដាក់ទុកក្នុងកន្លែងមួយ ។*

ចប់អដ្ឋកថា បឋមបឋវីសូត្រទី ៥

# អ ដ្ឋ ក ថា

## ទុតិយបឋវីសូត្រទី ៦ ជាដើម

[៣២០] ក្នុង អដ្ឋកថាទុតិយបឋវីសូត្រទី ៦ ជាដើម គប្បីជ្រាបសេចក្តីតាមន័យដែលពោលហើយនុ៎ះឯង ។ តែក្នុងសូត្រចុងក្រោយ បទថា អញ្ញតិត្ថិយ សមណព្រាហ្មណបរិព្វាជកានំ អធិគមោ សេចក្តីថា ការសម្រេចគុណទាំងអស់របស់ពាហិរកជន មិនដល់នូវចំណែក ១០០ ខ្វះ ចំណែក ១,០០០ ខ្វះ ចំណែក ១០០,០០០ ខ្វះ របស់អ្នកដែលសម្រេចគុណទាំងឡាយ ដោយបឋមមគ្គនុ៎ះឯង ។

ចប់អដ្ឋកថា ទុតិយបឋវីសូត្រទី៦ ជាដើម

## ចប់អភិសមយវគ្គ ទី ១០

### រួមក្នុងវគ្គនេះមាន ៦ អដ្ឋកថា

១-អដ្ឋកថានខសិខាសូត្រ
២-អដ្ឋកថាបោក្ខរណីសូត្រ
៣-អដ្ឋកថាបឋមសម្ភេជឧទកសូត្រ
៤-អដ្ឋកថាទុតិយសម្ភេជឧទកសូត្រ
៥-អដ្ឋកថាបឋមបឋវីសូត្រ
៦-អដ្ឋកថាទុតិយបឋវីសូត្រជាដើម

## រាយនាមសប្បុរសជន
## ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 US |

តាមរយៈភិក្ខុធម្មបញ្ញោ ជុំ សាវឿន វត្តពន្លឺពុទ្ធចក្រ
នៅរដ្ឋម៉ាសាជូសេត សហរដ្ឋអាមេរិក

| | |
|---|---|
| -សមាគមពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | $ 300 US |
| -ភិក្ខុវិជ្ជាសម្បន្នោ ឈួម សំបូរ និងឧបាសិកាគង់ គី | $ 200 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 105 US |
| -ឧបាសិកា ជីវ យួម និងស្វាមី ព្រមទាំងបុត្ត | $ 101 US |
| -ឧបាសក សោម រតនៈ និងភរិយា " ខេត្តព្រៃវែង " | $ 100 US |
| -សីលវត្តី នួន សូនី និងបុត្ត នាងវ៉ង់ | $ 100 US |
| -លោក គ្រី សុភី និងភរិយា ផៃ សុណាំង ព្រមទាំងបុត្ត | $ 100 US |
| -លោក តឹក គ្រី និងភរិយា ព្រមទាំងបុត្ត | $ 100 US |
| -ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព | $ 100 US |
| -ឧបាសក លន ចំរើន ឧបាសិកា ម៉ុក ថានិ | $ 100 US |
| -ឧបាសក ម៉ៅ ប៊ួយ ឧបាសិកា ម៉ៅ លន់<br>-ម៉ៅ ម៉ារ៉ា និងសៀង ថៃបញ្ញារិទ្ធ ព្រមទាំងបុត្ត<br>-ម៉ៅ ម៉ារ៉ង ម៉ៅ គឹមអាន ម៉ៅ គឹមសៀង<br>-ម៉ៅ ប៊ុនសន្ថា ក្អួយស្រី ធន់ សន្ថានី | $ 700 US |
| -ឧបាសិកា ពិន សាមឿន និងបុត្ត | $ 50 US |
| -ឧបាសិកា ពិន សាម៉ុន និងបុត្ត | $ 50 US |
| -ឧបាសិកា ប៊ុន សារ៉ុម និងបុត្ត | $ 50 US |
| -ឧបាសិកា គង់ ជី និងបុត្ត | $ 50 US |

| | |
|---|---|
| -ឧបាសិកា ឡាច ម៉ាឡៃ និងបុត្ត | $ 50 US |
| -ឧបាសិកា ទូត ច័ន្ទវណ្ណី និងបុត្ត | $ 50 US |
| -ឧបាសិកា ម៉ែន សាវ៉ាត | $ 50 US |
| -ឧបាសិកា ពិន សាត | $ 50 US |
| -ឧបាសិកា អ៊ុំ សាត | $ 50 US |
| -លោក ណៃ សារិន និងឧបាសិកា ជា សូភី | $ 50 US |
| -លោក កែវ ណាត និងឧបាសិកា សឹម គឿន | $ 50 US |
| -ឧបាសក កុក ឆាយ និងកូនប្រុស ឧបាសក តាំង សុផល និងភរិយា ព្រមទាំងបុត្ត នៅខេត្តបាត់ដំបង | $ 50 US |
| -ឧបាសិកា សៀន សេង និងបុត្ត | $ 20 US |
| -ឧបាសក ឡាង ឆរី និងភរិយា ព្រមទាំងបុត្ត | $ 20 US |
| -ឧបាសក ម៉ឺន ប៊ុនហេង និងឧបាសិកា កូវ៉ាញ | $ 20 US |
| -ឧបាសក ប៉ោ ហេង និងឧបាសិកា លន់ ឈុនលី | $ 20 US |
| -ឧបាសិកា ពិន សាម៉ុន | $ 20 US |
| -ឧបាសក កែវ សារិន ឧបាសិកា សំឯម | $ 15 US |
| -ឧបាសិកា ប៊ុន សារុំ | $ 10 US |
| -ឧបាសិកា ហាក់ សៃហេង | $ 10 US |
| -ឧបាសិកា ទេព សុផល | $ 10 US |
| -ឧបាសិកា ទេព ណាម | $ 10 US |
| -ឧបាសក គីម កក់ និងភរិយា ពិសី | $ 10 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 10 US |
| -ឧបាសិកា តាំង ផល្លា ព្រមទាំងស្វាមី និងបុត្ត | $ 10 US |
| -ឧបាសក តាំង សុខឡាយ ភរិយា និងបុត្ត | $ 10 US |
| -អ្នកស្រី បុប្ផអ៊ីវ និងស្វាមី ព្រមទាំងបុត្ត | $ 10 US |
| -ឧបាសក យិន ឈួ និងភរិយា ព្រមទាំងបុត្ត | $ 6 US |
| -ឧបាសក តាំង សុខឡាយ ឧបាសិកា សន ស៊ីណែត និងបុត្ត នៅខេត្តបាត់ដំបង | $ 5 US |

## តាមរយៈភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ប្រទេសអូស្ត្រាលី

| | |
|---|---|
| -ភិក្ខុ ចៅ សៀប " អូស្ត្រាលី " | 100 AUS |
| -ពុទ្ធបរិស័ទច្រើននាក់ " មែលប៊ន " | 955 AUS |
| -បុណ្យនៅផ្ទះឧបាសិកា លឹម ស៊ូឆេង | 627 AUS |
| -បុណ្យនៅផ្ទះឧបាសិកា ស៊ុយ មន្នា ព្រមទាំងកូនចៅ | 450 AUS |
| -បុណ្យនៅផ្ទះឧបាសិកា អ៊ូច សុផល្លី ព្រមទាំងបុត្ត | 400 AUS |
| -ឧបាសក ឡៅ គឹមងួន ឧបាសិកា ដួង លី | 200 AUS |
| -បុណ្យនៅផ្ទះឧបាសិកា តែ យក់ហ៊ុន | 200 AUS |
| -ឧបសិកា គង់ សារឿម | 200 AUS |
| -លោកជំទាវ " ឯកអគ្គរដ្ឋទូតអាឡឺម៉ង់ " | 100 US |
| -ឧបាសិកា កូវ សារី | 100 AUS |
| -ឧបាសិកា ឈ គិមស៊ិន និងបុត្ត សំ ថានី | 100 AUS |
| -លោក ឥន ចាវ៉ាន់ ឧបាសិកា យ៉ុម យ៉ា | 100 AUS |
| -ឧបាសក ឌី មុយ ឧបាសិកា តែ ចាន់ណាវ៉ា | 100 AUS |
| -ឧបាសិកា ឯម ផាយ៉,ឆេង លន់,ម៉ា ឈួអៀ,អាបួយ | 70 AUS |
| -ឧបាសក ឈិត ទ្រី ឧបាសិកា បាន់ ណៃហ៊ាង | 50 AUS |
| -ឧបាសិកា សុឃឿន ប៊ូ | 50 AUS |
| -ឧបាសក ឡុង ហ៊ន ឧបាសិកា លិម យូអេង និងបុត្ត | 50 AUS |
| -ឧបាសិកា ហេង ប៉ោគី ព្រមទាំងកូនចៅ | 50 AUS |
| -ឧបាសិកា ស៊ុម គិមហេង | 50 AUS |
| -ឧបាសិកា ឃឹម វីឡាត់ | 50 AUS |
| -ឧបាសក តូ សវ៉ឺន ឧបាសិកា មាន សុវត្ថិ និងបុត្ត | 50 AUS |
| -ឧបាសក មង្គល ផន ឧបាសិកា គឹម លាភ ( មាណ) | 50 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 50 AUS |
| -ឧបាសិកា ផ្លោក វណ្ណា | 40 AUS |
| -ឧបាសិកា សំ សុមុន្នា ស្វាមី និងបុត្ត | 30 AUS |
| -ឧបាសិកា រ័ត្ន គីមសាន | 30 AUS |
| -ឧបាសិកា ខូវ ម៉េងលួង ព្រមទាំងស្វាមី និងបុត្ត | 30 AUS |
| -ឧបាសក ហៀក ប៉េងហួរ ឧបាសិកា ផ្លោក ម៉ុង | 30 AUS |
| -ឧបាសិកា ទូច សីណា និងស្វាមី | 20 AUS |

| | |
|---|---|
| -ឧបាសក ស៊ូ យឹម ឧបាសិកា ស៊ូ សៀងតិច | 20 AUS |
| -ឧបាសក ប៉េង គ្រីគួ ឧបាសិកា គីម សៀងគួ | 20 AUS |
| -ឧបាសិកា គង់ សម្បត្តិ | 20 AUS |
| -ឧបាសិកា ចំរើន វ៉ាក់ជិត | 20 AUS |
| -ឧបាសិកា តែ យក់ហ៊ុន | 20 AUS |
| -ឧបាសិកា យ៉ា យ៉ុម | 20 AUS |
| -ឧបាសិកា លឹម ស៊ូឆេង | 20 AUS |
| -ឧបាសក សន់ ប៊ុនភាវ ឧបាសិកា កាំង គីមហាន | 20 AUS |
| -ឧបាសិកា ហេង ងួនអ៊ុម | 20 AUS |
| -ឧបាសិកា យានី | 20 AUS |
| -សេង សៀងឈុន | 20 AUS |
| -ឧបាសក វ៉ាន់ យ៉ាណូរ៉េត ឧបាសិកា វ៉ាន់យ៉ាណូរី | 20 AUS |
| -ឧបាសិកា អ៊ុច សុផល្លី | 20 AUS |
| -ឧបាសិកា ឡាច សារិម | 15 AUS |
| -ចៃស៊ីម,ចៃខេង,អាមួយ | 15 AUS |
| -ឧបាសិកា កូវ សារី | 15 AUS |
| -ឧបាសិកា ទូច ស៊ីណា | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លីសាង | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លាង ហុងប៊ុន | 10 AUS |
| -ឧបាសិកា សៀ ចន្ថា និងគ្រួសារ | 10 AUS |
| -ឧបាសិកា កាំង អ៊ីវហ៊ួច | 10 AUS |
| -ឧបាសក ក្រូច សាន | 10 AUS |
| -ឧបាសិកា សា ចាន់ថា | 10 AUS |
| -ឧបាសក យឹម វ៉ាន់ ឧបាសិកា អ៊ុំ ខេង | 10 AUS |
| -ឧបាសក សុខ ជួន ឧបាសិកា សុខ ធួក | 10 AUS |
| -ឧបាសិកា អេង ងីមសុខ | 10 AUS |
| -ឧបាសក យុត សរ ឧបាសិកា សុខ សច្ចា | 10 AUS |
| -ឧបាសិកា កេសរកូល និងគ្រួសារ | 5 AUS |
| -ឧបាសិកា វាណ្ណនីសា | 5 AUS |
| -ឧបាសិកា សាន់ ឆាយ, គីម ស្រួន | 5 AUS |

| | |
|---|---|
| -ភិក្ខុ ផុំ សារឿន និងពុទ្ធបរិស័ទ វត្តពន្លឺពុទ្ធចក្ក | 620 USA |
| -ឧបាសក សោមរតនៈ ឧបាសិកា ស៊ុប វណ្ណា និងបុត្ត | 200 USA និង 1 លានរៀល |
| -ឧបាសក តាំង សុផល ឧបាសិកា ឡុង កេន និងបុត្ត | 30 USA |
| -ហាង ពិភពកុំព្យូទ័រ | 20 USA |
| -ឧបាសិកា តាំង ផល្លា និងស្វាមី ព្រមទាំងបុត្ត | 10 USA |
| -ឧបាសក ហេង វីរិន្ទ និងភរិយា ព្រមទាំងបុត្ត | 10 USA និង 2 ម៉ឺនរៀល |
| -ឧបាសក តាំង សុខឡាយ និងភរិយា ព្រមទាំងបុត្ត | 10 USA |
| -ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមឃន់ និងកូនចៅ | 5 USA និង 1 ម៉ឺនរៀល |
| -ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ធីតា និងកូនចៅ | 5 USA និង 1 ម៉ឺនរៀល |
| -ឧបាសិកា កំសត់  នៅស្រុកសំឡូត | 30000 រៀល |
| -ឧបាសក ម៉េង ប៊ិច ព្រមទាំងកូនចៅ | 20000 រៀល |
| -ឧបាសិកា ហួន ណងសីម | 20000 រៀល |
| -ឧបាសិកា គាត ស៊ីណា | 20000 រៀល |
| -ឧបាសិកា ទេព គឹមហ៊ា | 20000 រៀល |
| -ឧបាសិកា ហេង គូ | 20000 រៀល |
| -ឧបាសិកា គី ពេញ | 20000 រៀល |
| -ម៉ាឧបាសិកា ឆាយ អ៊ីសែង | 20000 រៀល |
| -ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្ត | 20000 រៀល |
| -ឧបាសក ហុង ជ្រិន ឧបាសិកា ឡេង ចំរើន និងកូនចៅ | 20000 រៀល |
| -ឧបាសិកា កែ ថន | 10000 រៀល |
| -ឧបាសិកា អ៊ុយ លឹង | 10000 រៀល |
| -យុវជន ស៊ូ តារា | 10000 រៀល |

